# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

**ដាក់ជូន:** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jul-2018, 14:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** **កោសល្យុមសាធារណៈ:**

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**កោសល្យុមសាធារណៈ:**

**ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង**

---

| **ដាក់ដោយ÷** | **ផ្ញើជូន÷** | |
|---|---|---|
| **សហមេធាវី** | **សហចៅក្រមស៊ើបអង្កេត** | **សហព្រះរាជអាជ្ញា** |
| ប៊ិត ស៊ាងលឹម | ចៅក្រម យូ ប៊ុនឡេង | ជា លាង |
| Wayne JORDASH, QC | ចៅក្រម Michael BOHLANDER | Nicholas KOUMJIAN |

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង ០០៤/១ ទាំងអស់**

មាតិកាលម្អិត

I. **សេចក្តីផ្តើម** ........................................................ ១

II. **សាវតារពាក់ព័ន្ធ** ........................................................ ៤

III. **ទស្សនករណ៍សង្ខេប** ........................................................ ៨

IV. **ការអង្គេតបឋម** ........................................................ ១១

**ក. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើដោយចំហ សុំឱ្យមានដីកាលើកលែងការចោទប្រកាន់លើបទចោទទាំងអស់នៃការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦** ... ១១

**ខ. សហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមពង្រីកវិសាលភាពនៃដីកាដំណោះស្រាយ ដោយគ្មានការអនុញ្ញាត** ........................................................ ១២

**គ. សហព្រះរាជអាជ្ញាអន្តរជាតិខកខានក្នុងការជួយតុលាការដើម្បីរកឱ្យឃើញការពិត** ... ២៧

**ឃ. សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវ លើបទដ្ឋានបង្ហាញភស្តុតាងដែលបានតម្រូវ ក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ** ........................................................ ៣៥

**ង. សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវ ពីតួនាទីជនរងគ្រោះនៅ អ.វ.ត.ក** ........................................................ ៣៩

V. **ចម្លើយតប** ........................................................ ៤៦

**ក. ការពិចារណាលើយុត្តាធិការបុគ្គល** ........................................................ ៤៦

១. ប្រវត្តិចរចាដែលនាំឱ្យឈានដល់ការកំណត់និយមន័យនៃប្រភេទ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” នៅ អ.វ.ត.ក ........................................................ ៤៧

២. ការវាយតម្លៃថាតើជនសង្ស័យស្ថិតនៅក្នុងប្រភេទជនទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណា ........................................................ ៤៩

៣. បទដ្ឋានបង្ហាញភស្តុតាងសម្រាប់វាយតម្លៃថាតើជនត្រូវចោទស្ថិតនៅក្នុងចំណោម “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” នៅ អ.វ.ត.ក ដែរ ឬយ៉ាងណា ............. ៥៥

**ខ. ការពិចារណាទូទៅពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម** ........................................................ ៥៨

១. អ្នកស្រី អ៊ឹម ចែម មិនមានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ទេ.........................៦០

២. ភាពមិនសមទំនងទាល់តែសោះដែលថា អ្នកស្រី អ៊ឹម ចែម អាចមានតួនាទីសំខាន់ទាក់ទងនឹងបញ្ហាសន្តិសុខ ក្នុងនាមជាកម្មាភិបាលនារី ........................................................៦៦

**គ. អ្នកស្រី អ៊ឹម ចែម មិនបានកាន់កាប់តួនាទីសំខាន់ណាមួយឡើយ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ.......................................................................................................៧១**

១. អ្នកស្រី អ៊ឹម ចែម ពុំមានតួនាទីសំខាន់ៗ នៅក្នុងភូមិភាគនិរតីឡើយ .......................... ៧៣

i. *អ្នកស្រី អ៊ឹម ចែម ពុំមែនជាសមាជិកស្របច្បាប់នៃគណៈតំបន់១៣ ក្នុងភូមិភាគនិរតីនោះទេ*...................................................................................................៧៤

ii. *អ្នកស្រី អ៊ឹម ចែម ពុំមានតួនាទីជាសមាជិក* ជាក់ស្តែង *នៃគណៈតំបន់១៣ ឡើយ*......៨៣

២. អ្នកស្រី អ៊ឹម ចែម គ្មានតួនាទីសំខាន់ក្នុងភូមិភាគនិរតី ..........................................៨៦

i. *អ្នកស្រី អ៊ឹម ចែម មិនមានតួនាទី* ស្របច្បាប់ *ជាសមាជិក ឬជាអនុលេខាគណៈតំបន់៥ ឡើយ*.................................................................................................... ៨៨

ii. *អ្នកស្រី អ៊ឹម ចែម គ្មានតួនាទីជាសមាជិក ឬអនុលេខា* ជាក់ស្តែង*នៃគណៈតំបន់៥*.... ១១១

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ថាជាអ្នករៀបចំកិច្ចប្រជុំនានានៅថ្នាក់តំបន់ .............................................................. ១១២

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ថា អ្នកស្រីជាគណៈអធិបតីក្នុងអង្គប្រជុំធំៗជាមួយនឹង *តា មុក*.......................................... ១១៧

៣. ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគពាយព្យត្រូវបានកំណត់យ៉ាងតឹងរ៉ឹងត្រឹមតែចំពោះតួនាទី *ស្របច្បាប់* និង *ជាក់ស្តែង* របស់អ្នកស្រីជាលេខាស្រុក..................... ១២០

i. *ក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម ផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះ តាមរយៈដោះស្រាយបញ្ហាកង្វះស្បៀង* .................................................................... ១២០

ii. *ក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម ពុំបានទទួលខុសត្រូវលើការងារសន្តិសុខនៅស្រុកព្រះនេត្រព្រះឡើយ*.....................................................................១២៧

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើ*ឃាតដា*.... ១៣០

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើ*ល្អួប*......១៣៥

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើការងារសន្តិសុខ នៅក្នុងស្រុកព្រះនេត្រព្រះ ........................................................................១៣៧

**ឃ.អ្នកស្រី អ៊ឹម ចែម មិនបានដើរតួនាទីទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តនៅនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងឡើយ............... ១៤០**

១. អ្នកស្រី អ៊ឹម ចែម មិនដើរតួនាទីសំខាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ ................ ១៤២

i. *មន្ទីរសន្តិសុខភ្នំទ្រយោងស្ថិតក្រោមការគ្រប់គ្រងជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ ទុំ សឿន កម្មាភិបាលតំបន់៥*..................................................................១៤៣

ii. *អ្នកស្រី អ៊ឹម ចែម មិនបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលមានសភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលត្រូវបានចោទថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោងទេ* ............................ ១៥៤

ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការឃុំឃាំង អ្នកទោសរាប់ពាន់នាក់ នៅមន្ទីរសន្តិសុខភ្នំទ្រយោង ...................... ១៥៥

ការទម្លាក់កំហុសលើអ្នកស្រី អ៊ឹម ចែម ពីការជាប់ពាក់ព័ន្ធនឹងការស្លាប់អ្នកទោសចំនួនរាប់ពាន់នាក់ ដោយសារភាពអត់ឃ្លាន ជំងឺ និងធ្វើការហួសកម្រិតនៅមន្ទីរសន្តិសុខភ្នំទ្រយោង ...................................................................................១៦៥

ការទម្លាក់កំហុសដាក់អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងការសម្លាប់អ្នកទោសចំនួនរាប់ពាន់នាក់នៅមន្ទីរសន្តិសុខភ្នំទ្រយោង ..........................................១៦៩

២. អ្នកស្រី អ៊ឹម ចែម មិនបានដើរតួនាទីណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងនោះទេ ........................................ ១៧៨

i. *ភាពជាក់លាក់ទាក់ទងនឹងវិសាលភាពភូមិសាស្ត្រនៃការដ្ឋានស្ពានស្រែង*...............១៨០

ii. *ការដ្ឋានស្ពានស្រែងស្ថិតក្រោមអំណាចផ្លូវការ និងដែលមានប្រសិទ្ធភាពរបស់គណៈតំបន់៥ និង តា ពាល់ ដែលជាប្រធានកងចល័តតំបន់៥* ................................ ១៨២

iii. *អ្នកស្រី អ៊ឹម ចែម មិនបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់គ្រប់គ្រាន់ដូចបានចោទ ប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងឡើយ*...............................១៩៤

ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ក្នុងការងារដោយបង្ខំលើពលកររាប់ពាន់នាក់នៅការដ្ឋានស្ពានស្រែង ....................................១៩៥

ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ីម ចែម ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការស្លាប់ដោយសារការបង្អត់អាហារ និងជំងឺ នៅការដ្ឋានស្ពានស្រែង................២០២

ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ីម ចែម ដែលត្រូវបានចោទប្រកាន់ក្នុងការចាប់ខ្លួន ការឃុំឃាំង ការសម្លាប់ និងការបាត់ខ្លួន នៅការដ្ឋានស្ពានស្រែង..................២០៤

**ខ. សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការបុគ្គល** ........................................................ ២០៩

**VI. សំណើដែលស្នើសុំ**...................................................................................... ២២០

# I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី ("ក្រុមការពារក្តី") តទៅនេះ សូមដាក់ចម្លើយតប[1] ទៅនឹង*ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម*[2] ។

២. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ភាគីទាំងអស់ត្រូវបានជូនដំណឹងថា បញ្ហាអង្គច្បាប់សំខាន់នៅក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម គឺជាបញ្ហាយុត្តាធិការបុគ្គល[3] ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថា ពួកគាត់មានទិន្នាការចង់ "លើកលែងការចោទប្រកាន់ប្រឆាំង [អ្នកស្រី អ៊ឹម] ចែម ដោយសារកង្វះយុត្តាធិការបុគ្គល"[4] ។

---

1 ចម្លើយតបនេះត្រូវបានដាក់ជាភាសាអង់គ្លេសជាមុនសិន ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយឱ្យបានឆាប់បំផុត ដូចដែលត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេត ។ *សូមមើល* ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដាក់សារណាតបទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាភាសាអង់គ្លេសជាមុនសិន ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/5/1**។ ក្រុមការពារក្តីបានព្យាយាមធ្វើការទំនាក់ទំនងជាមួយអង្គភាពបកប្រែភាសា ដើម្បីធានាបាននូវការផ្តល់អាទិភាពនៃការបកប្រែចម្លើយតបនេះ ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ *សូមមើល* អ៊ីមែលពីអ្នកនាង RY Noyel (អ្នកគ្រប់គ្រងសំណុំរឿងរបស់ក្រុមការពារក្តីរបស់ អ៊ឹម ចែម) ផ្ញើជូនលោក KORM Chanmony (ប្រធានអង្គភាពបកប្រែភាសា) ដែលមានចំណងជើងថា "ការបកប្រែនៃចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ" ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១**] ។

2 ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន៦៦ នៃផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/2** ("ដីកាសន្និដ្ឋានស្តាពរ")។

3 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286** នៅកថាខណ្ឌ ៥ ។ នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ជាថ្មីម្តងទៀតថា បញ្ហាអង្គច្បាប់សំខាន់នៅក្នុងសំណុំរឿង០០៤/១ គឺនៅលើបញ្ហាថាតើ អ.វ.ត.ក មានយុត្តាធិការបុគ្គលលើអ្នកស្រីអ៊ឹម ចែម ដែរ ឬយ៉ាងណា។ *សូមមើល* សេចក្តីជូនដំណឹងមេធាវីការពារក្តីអំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានតាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/4** នៅកថាខណ្ឌ ៦។

4 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង[អ្នកស្រី] អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286** នៅកថាខណ្ឌ ៧។

៣. នៅក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុង "ចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[5] ។ សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើភស្តុតាងទាំងមូលដែលមាននៅក្នុងសំណុំរឿង ០០៤/១ និងអះអាងថា អ្នកស្រី អ៊ឹម ចែម i) គឺជាមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា "ក្នុងឋានានុក្រមដ៏សំខាន់នៅថ្នាក់ស្រុក និងថ្នាក់តំបន់"[6] ទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយព្យ និង ii) បានដើរ "តួនាទីយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ដែលបានប៉ះពាល់ដល់មនុស្សរាប់សិបពាន់នាក់ និងបានបណ្តាលឱ្យមានមនុស្សស្លាប់រាប់ពាន់នាក់"[7] ។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនខ្លួនអ្នកស្រី អ៊ឹម ចែម ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[8] ។

៤. នៅក្នុងចម្លើយតបនេះ ក្រុមការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការធ្វើសេចក្តីសន្និដ្ឋានដែលថា អ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិមានកំហុសអង្គច្បាប់ក្នុងការដាក់ការសំអាងរបស់ខ្លួនផ្អែកលើភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង ០០៤/១ ដោយមិនពិចារណាលើការជូនដំណឹងអំពីបទចោទប្រកាន់ និងការសម្រេចជាស្ថាពរនៃបទចោទប្រកាន់ទាំងនោះ[9] ។ ទីពីរ ការវាយតម្លៃលើភស្តុតាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺផ្អែកលើវិធីសាស្ត្រភ័ន្តច្រឡំលើអង្គហេតុ ដោយសារត្រូវបានធ្វើឡើងដោយគ្មានអ្នកវិនិច្ឆ័យសមហេតុផលដែលអាចទទួលយកមកអនុវត្តបានឡើយ ។ សហព្រះរាជអាជ្ញាអន្តរជាតិបន្តនីតិវិធីលើសំណុំរឿងមួយដោយគ្មានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ ដែលជាការរំពឹងទុកថានឹងទទួលបានពីមន្ត្រីយុត្តិធម៌មួយ

---

[5] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០-៣៨។

[6] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០។

[7] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០។

[8] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩។

[9] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៥៤-៦០។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ២០-២៩។

រូប[10] និងដោយគ្មានការពិចារណាឱ្យបានត្រឹមត្រូវពីសត្យានុម័តភាពដែលបានតម្រូវ ដើម្បីរួមចំណែកដល់ការរកឱ្យឃើញការពិត[11] ។

៥. ដោយផ្អែកលើបទដ្ឋានបង្ហាញភស្តុតាង[12] ការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យរួមចំនួនពីរដែលជាលក្ខខណ្ឌតម្រូវសម្រាប់ធ្វើការវាយតម្លៃយុត្តាធិការបុគ្គល ដោយផ្អែកលើភស្តុតាងពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ (ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង)[13] បង្ហាញថា អ្នកស្រី អ៊ឹម ចែម មិនអាចត្រូវបានចាត់ទុកថាជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"[14] នោះទេ ។ សរុបសេចក្តីមក ភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម គឺជាលេខាស្រុកព្រះនេត្រព្រះ ទាំង*ស្របច្បាប់* និង*ជាក់ស្តែង* ។ អ្នកស្រីមិនមានអំណាច*ស្របច្បាប់* ឬ *ជាក់ស្តែង* ផ្សេងទៀតឡើយនៅក្នុងភូមិភាគពាយព្យ[15] ។ ក្នុងឋានៈអ្នកស្រីជាលេខាស្រុក និងក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម គឺ ត្រូវបានកម្រិតត្រឹមតែការងារផ្នែកកសិកម្ម និងការបង្កបង្កើនស្បៀងអាហារ[16] រួមទាំងការសាងសង់ប្រឡាយ និងទំនប់[17] ក្រោមសិទ្ធិអំណាចដែលថ្នាក់តំបន់បានប្រគល់ឱ្យអ្នកស្រី[18] ។

---

10 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣០-៣៦។

11 *ប្រៀបធៀបជាមួយសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **E72/3** ("សេចក្តីសម្រេច អំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋាន ឯកសារ **E72/3**") នៅកថាខណ្ឌ ២០-២១, ២៤, ៣៤។

12 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣៧-៤១, ៦១-៦២។

13 *សូមមើលជាទូទៅ* ចម្លើយតប នៅកថាខណ្ឌ ៥៤-៦០, ១៤៤-២២៦។ *សូមប្រៀបធៀបជាមួយ* ចម្លើយតប នៅកថាខណ្ឌ ២០-២៩។ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239.1** ("ការជូនដំណឹងអំពីអំពីបទចោទប្រកាន់ ឯកសារ **D239.1**") នៅកថាខណ្ឌ ២-៩។

14 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៤-២២៦, ២៣០-៣៨។

15 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៩៧-១២១។

16 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២២-២៩ និង ១៧៣-៧៤។

17 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២២-២៩ និង ២១៤-១៦។

លើសពីនេះទៀត ភស្តុតាងមិនគាំទ្រដល់ការសន្និដ្ឋានដែលថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ដែលជាទីតាំងស្ថិតក្រោមអំណាចផ្ទាល់របស់ថ្នាក់តំបន់[19] មានស្ថានភាពធ្ងន់ធ្ងរជាពិសេសឡើយ[20] ។ ទោះក្នុងស្ថានភាពណាក៏ដោយ ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះទីតាំងឧក្រិដ្ឋកម្មទាំងពីរនេះ គឺមានលក្ខណៈខុសឆ្ងាយពីរាល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ឬ គ្រប់គ្រងដោយកម្មាភិបាលថ្នាក់តំបន់[21] ។

៦. ហេតុនេះ ដោយផ្អែកលើមូលដ្ឋាននៃទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងចម្លើយតបនេះ ក្រុមការពារក្តីសូមគោរពស្នើសុំសហចៅក្រមស៊ើបអង្កេត មេត្តាអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើអ្នកស្រី អ៊ឹម ចែម និងសម្រេចច្រានចោលនូវបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី ។

## II. សាវតារពាក់ព័ន្ធ

៧. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដើម្បីបើកការស៊ើបអង្កេតប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[22] ។

៨. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទថាបានប្រព្រឹត្តឡើង ប្រហែលនៅចន្លោះពីខែ មេសា ឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ក្នុងឋានៈអ្នកស្រីជាលេខាស្រុកព្រះនេត្រព្រះ ចំពោះទីតាំងឧក្រិដ្ឋកម្មចំនួនពីរកន្លែង គឺមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋាន

---

18 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៩៩-១១០, ១១៣ និង ១២២-៤២។

19 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤ និង ១៩៣-២០៧។

20 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៥៥-៨៦ និង ២០៨-២៦។

21 *សូមមើលជាទូទៅ* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៨៦ និង ១៩៣-២២៦។

22 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D1** ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ឯកសារ **D1**")។

ស្ពានស្រែង[23] ។ អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ តែប៉ុណ្ណោះ[24] ។ ក្រុមការពារក្តីត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងប្រឆាំងអ្នកស្រី អ៊ឹម ចែម នៅកាលបរិច្ឆេទដូចគ្នា[25] ។

៩. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញាជាតិ និងក្រុមការពារក្តីបានដាក់សេចក្តីអង្កេតរៀងៗខ្លួន ស្តីពីបញ្ហាថាតើគួរត្រូវបានចាត់ទុកអ្នកស្រី អ៊ឹម ចែម ជាមេដឹកនាំជាន់ខ្ពស់ ឬ ជាបុគ្គលម្នាក់ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យឬទេ[26]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា អ្នកស្រី អ៊ឹម ចែម គួរត្រូវបានចាត់ទុកជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយផ្អែកលើមូលដ្ឋានថា "ក្នុងនាមជាកម្មាភិបាលដែលមានឋានៈសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា [អ្នកស្រី អ៊ឹម ចែម] បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលបានប៉ះពាល់ដល់មនុស្សរាប់សិបពាន់នាក់ និងបានបណ្តាលឱ្យមានមនុស្សស្លាប់រាប់ពាន់នាក់"[27] ។ សហព្រះរាជអាជ្ញាជាតិ និងក្រុមការពារក្តីបានលើកឡើងថា អ.វ.ត.ក

---

23 ដីកាសម្រេចដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239**។ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ឯកសារ **D239.1** នៅកថាខណ្ឌ ២-៩។

24 ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ឯកសារ **D239.1** នៅកថាខណ្ឌ ៤-៩។

25 ដីកាសម្រេចដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239** នៅកថាខណ្ឌ ៧៧។

26 សេចក្តីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា *'មេដឹកនាំជាន់ខ្ពស់'* ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម *'អ្នកទទួលខុសត្រូវខ្ពស់បំផុត'* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D251/4** ("សារណារបស់ក្រុមការពារក្តី ស្តីពីបញ្ហាយុត្តាធិការបុគ្គល ឯកសារ **D251/4**")។ សារណាលើបញ្ហាថាតើ[អ្នកស្រី] អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា *'មេដឹកនាំជាន់ខ្ពស់'* ឬ ក្នុងចំណោម *'អ្នកទទួលខុសត្រូវខ្ពស់បំផុត'* ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D251/5** ("សារណាលើបញ្ហាយុត្តាធិការបុគ្គលរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ **D251/5**")។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណីរបស់ អ៊ឹម ចែម យោងតាមឯកសារ **D251** ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D251/6**។

27 សារណាយុត្តាធិការបុគ្គលរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ **D251/5** នៅកថាខណ្ឌ ៤៥។

មិនមានយុត្តាធិការបុគ្គលលើអ្នកស្រី អ៊ឹម ចែម ឡើយ ។ ជាពិសេស ក្រុមការពារក្តីបានលើកឡើងថា "មានតែភស្តុតាងបន្តិចបន្តួច ឬក៏គ្មានភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលអ្នកស្រីត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ដោយទុកដោយឡែកនូវភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះ និងមានភស្តុតាងតិចណាស់ដែលថា អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងឧក្រិដ្ឋកម្មមួយចំនួនដែលអ្នកស្រីរងការចោទប្រកាន់"[28] ។

១០. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានបិទកិច្ចស៊ើបសួរប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[29] និងបានជូនដំណឹងដល់ភាគីទាំងអស់អំពីគោលបំណងរបស់ពួកគាត់ក្នុងការលើកលែងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ហើយបានបំបែកអ្នកស្រីចេញពីកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤[30] ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានបង្ហាញពីនិន្នាការរបស់ខ្លួន "ក្នុងការលើកលែងការចោទប្រកាន់ប្រឆាំងអ្នកស្រី អ៊ឹម ចែម ដោយសារកង្វះយុត្តាធិការបុគ្គល"[31] ។

១១. នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានបំបែកអ្នកស្រី អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤[32] ។ បន្ទាប់ពីរយៈពេលផុតកំណត់ គឺ១៥ ថ្ងៃ សម្រាប់ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដូច្នេះការកិច្ចស៊ើបអង្កេតនៅក្នុងរឿងក្តីពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម ត្រូវបានបិទបញ្ចប់ជាស្ថាពរ ។

១២. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿង ០០៤/១ ទៅ

---

28 សារណារបស់ក្រុមការពារក្តី ស្តីពីបញ្ហាយុត្តាធិការបុគ្គល ឯកសារ **D251/4** នៅកថាខណ្ឌ ២។

29 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D285**។

30 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286**។

31 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286** នៅកថាខណ្ឌ ៧។

32 ដីកាសម្រេចបំបែកសំណុំរឿងទាក់ទងនឹង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **D286/7**។

សហព្រះរាជអាជ្ញាដើម្បីរៀបចំធ្វើដីកាសន្និដ្ឋានស្ថាពរ[33] ហើយនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរចំនួនពីរដាច់ដោយឡែកពីគ្នា[34] ។ សហព្រះរាជអាជ្ញាជាតិបានស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងអ្នកស្រី អ៊ឹម ចែម[35] ។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យនាំខ្លួន ឃុំខ្លួន និងបញ្ជូនអ្នកស្រី អ៊ឹម ចែម ទៅជំនុំជម្រះ[36] ។

១៣. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ក្រុមការពារក្ដីបានដាក់លិខិតមួយច្បាប់ ដោយបានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបដិសេធចោលនូវសំណើនានា ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណើសុំចុះផ្សាយសំណៅកោសលុបនៃដីកាសន្និដ្ឋានស្ថាពរ មុនពេលចេញដីកាដំណោះស្រាយ[37] ។ សំណើនេះត្រូវបានធ្វើឡើងដោយសារទំហំនៃការចោទប្រកាន់ដោយភ័ន្តច្រឡំ និងគ្មានភស្តុតាងគាំទ្រជាច្រើននៅក្នុងដីកាសន្និដ្ឋានស្ថានពរនេះ ដែលធ្វើឱ្យសារធារណជនអាចមានការបំភ័ន្ត និងអាចបង្កគ្រោះថ្នាក់ផ្នែកសន្តិសុខផ្ទាល់ខ្លួនដល់អ្នកស្រី អ៊ឹម ចែម ប្រសិនជាដីកាសន្និដ្ឋានស្ថាពរនេះ ត្រូវបានផ្សព្វផ្សាយក្នុងទម្រង់នៃការកោសលុប ឬជាការកែសម្រួលក្ដី ។ នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតប ដោយបានស្នើឱ្យ

---

33 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) [នៃវិធានផ្ទៃក្នុង] ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ **D304**។

34 ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/1**។ ដីកាសន្និដ្ឋានស្ថាពរ។

35 ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/1** នៅកថាខណ្ឌ ៣៨។

36 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩-៤១។

37 លិខិតរបស់ អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្តីពីអត្ថបទកោសលុបសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/3**។

ច្រានចោលសំណើរបស់ក្រុមការពារក្ដី[38] ។

១៤. នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ក្រុមការពារក្ដីថា កាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់ចម្លើយតបរបស់ខ្លួន គឺនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៦[39] ។ នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ក្រុមការពារក្ដីបានស្នើសុំការអនុញ្ញាតដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយ[40] ។ នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតតាមសំណើរបស់ក្រុមការពារក្ដី[41] ។

## III. ទឡ្ហីករណ៍សង្ខេប

១៥. មុនពេលឆ្លើយតបនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងបញ្ហាចម្បងក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ថាតើ អ.វ.ត.ក មានយុត្តាធិការបុគ្គល ឬយ៉ាងណានោះ ជាដំបូង ក្រុមការពារក្ដីនឹងលើកឡើងនូវការអង្កេតបឋមមួយចំនួន ដែលពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរ និង វិធីសាស្ត្រផ្នែកអង្គហេតុ និង អង្គច្បាប់ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល និងការចោទប្រកាន់ដែលអាចនឹងធ្វើទៅបាន ។ ការអង្កេតបឋមទាំងនេះ ត្រូវបានសង្ខេបនៅផ្នែកខាងក្រោម និង រៀបរៀងនៅក្នុងកថាខណ្ឌ **១៩** រហូតដល់កថាខណ្ឌ **៤៧** ។ ការអង្កេតបឋមទាំងនេះ នឹងជួយដល់សហចៅក្រមស៊ើបអង្កេត ដោយធ្វើការបង្ហាញនូវបញ្ហារួមជាដំបូង ដែលពាក់ព័ន្ធនឹងការរៀបចំធ្វើដីកាដំណោះស្រាយ ។ ចំណុចជាក់លាក់ ក្រុមការពារក្ដីនឹង

---

38 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្ដីពីការដាក់ច្បាប់កោសល្យបជាសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/3/1**។

39 សេចក្ដីជូនដំណឹងក្រុមការពារក្ដីអំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានតាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/4** នៅកថាខណ្ឌ ៨។

40 លិខិតរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាភាសាអង់គ្លេសមុន និងដាក់អត្ថបទបកប្រែភាសាខ្មែរតាមក្រោយ ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/5**។

41 ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដាក់សារណាតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិជាភាសាអង់គ្លេសជាមុនសិន ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **D304/5/1** នៅកថាខណ្ឌ ៥។

បង្ហាញថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ៖

(i) ផ្អែកតាមអង្គច្បាប់ ស្នើសុំដោយប្រយោលឱ្យមានដីកាលើកលែងការចោទប្រកាន់លើបទចោទប្រកាន់ទាំងអស់ ដែលពាក់ព័ន្ធនឹងការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដោយការសម្រេចមិនលើកឡើងពីបទចោទប្រកាន់ទាំងនេះនៅក្នុងដីកាសន្និដ្ឋានស្ថាពរ ។

(ii) ផ្អែកតាមអង្គច្បាប់ ព្យាយាមឱ្យមានពង្រីកវិសាលភាពនៃដីកាដំណោះស្រាយទាំងគ្មានការអនុញ្ញាត ដោយស្នើឱ្យមានការជំនុំជម្រះលើបទចោទប្រកាន់ជាច្រើន ដែលមិនមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ដែលទង្វើនេះ ជាការរំលោភបំពានលើដំណើរការសមស្រប និងសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។

(iii) ផ្អែកតាមអង្គហេតុ និង/ឬអង្គច្បាប់ [សហព្រះរាជអាជ្ញាអន្តរជាតិ]បន្តការមិនយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់ខ្លួន ក្នុងការជួយដល់សហចៅក្រមស៊ើបអង្កេតដើម្បីរកឱ្យឃើញការពិត ដោយសារតែមិនបានអនុវត្តតាមវិធីសាស្ត្រប្រយ័ត្នប្រយែងរបស់ចៅក្រម Bohlander ក្នុងការវាយតម្លៃភស្តុតាង ហើយនិងធ្វើការបង្ហាញនូវទស្សនៈកិច្ចការណ៍នានាដោយមិនបំពេញនូវលក្ខខណ្ឌសត្យានុម័ត ។

(iv) ផ្អែកតាមអង្គច្បាប់ [សហព្រះរាជអាជ្ញាអន្តរជាតិ]ខិតខំបន្ទាបនូវបទដ្ឋានបង្ហាញភស្តុតាងជាធរមានដែលតម្រូវ ក្នុងការចោទប្រកាន់ជនត្រូវចោទ និង

(v) ផ្អែកតាមអង្គច្បាប់ [សហព្រះរាជអាជ្ញាអន្តរជាតិ]បកស្រាយខុសនូវមុខងាររបស់ជនរងគ្រោះនៅ អ.វ.ត.ក ដោយច្រឡំបញ្ចូលគ្នាតែមួយនូវស្ថានភាពរបស់*អ្នកដាក់ពាក្យសុំតាំងខ្លួនជា*ដើមបណ្តឹងរដ្ឋប្បវេណី និង*ដើមបណ្តឹងរដ្ឋប្បវេណី* ដើម្បីគាំទ្រការអះអាងដែលថា វាមានអត្ថប្រយោជន៍យ៉ាងធំធេងចំពោះការកាត់ទោសអ្នកស្រី អ៊ឹម ចែម ។

១៦. បន្ទាប់ពីផ្តល់នូវការអង្កេតបឋមទាំងនេះ ក្រុមការពារក្តីនឹងលើកឡើងដោយត្រង់ៗ នូវបញ្ហាចម្បង

ពោលថាតើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានចាត់ទុកជាបុគ្គលក្នុងចំណោមជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឬទេ[42] ។

១៧. ទីមួយ ក្រុមការពារក្តីនឹងលើកឡើងពីធាតុផ្សំផ្លូវច្បាប់នៃលក្ខណៈវិនិច្ឆ័យជាធរមាន ទាក់ទងនឹងការកំណត់យុត្តាធិការបុគ្គល ។ ទីពីរ ក្រុមការពារក្តីនឹងវាយតម្លៃលើភស្តុតាងពាក់ព័ន្ធ ដោយសំអាងលើលក្ខណៈវិនិច្ឆ័យរួមចំនួនពីរដែលកំណត់ថា តើជនត្រូវចោទ គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា ។ ជារួម បញ្ហាពាក់ព័ន្ធនឹងអង្គហេតុនានា ក្រុមការពារក្តីនឹងផ្តោតការតវ៉ាចំពោះករណីដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានវាយតម្លៃដោយភ័ន្តច្រឡំលើការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ដោយ ៖

(i) ការអនុវត្តមិនត្រឹមត្រូវនូវលក្ខណៈវិនិច្ឆ័យជាធរមាន ពាក់ព័ន្ធនឹងប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកលើការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរួមចំនួនពីរ (ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងការចោទប្រកាន់លើកម្រិតការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្ត) ដោយអនុវត្តនូវលក្ខណៈវិនិច្ឆ័យនេះទៅលើភស្តុតាងដែលស្ថិតនៅក្រៅព្រំដែនកំណត់ ដូចមានក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ និង

(ii) ប្រើវិធីសាស្ត្រមួយចំពោះភស្តុតាងពាក់ព័ន្ធ ទាក់ទងនឹងអង្គហេតុនានាពាក់ព័ន្ធនឹងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ដោយគ្មានអ្នកវិនិច្ឆ័យសមហេតុផលអាចទទួលមកអនុវត្តបានដែលទង្វើនេះ មិនអាចឈានទៅរកការរកឱ្យឃើញការពិតបាននោះទេ ។

១៨. ជារួម ក្រុមការពារក្តីនឹងស្នើឡើងថា ការវាយតម្លៃចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបង្កើតបានជាមូលដ្ឋាននៃបទចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ព្រមទាំងការចោទប្រកាន់ចំពោះការទទួលខុសត្រូវរបស់អ្នកស្រីទាក់ទងនឹងបទ

---

[42] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៤៨-២៤០។ *សូមប្រៀបធៀបជាមួយ* សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងអ្នកស្រី អ៊ឹម ចែម និងការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ **D286** កថាខណ្ឌ ៥។ សេចក្តីជូនដំណឹងមេធាវីការពារក្តីអំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានតាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ឯកសារ **D304/4** នៅកថាខណ្ឌ ៦។

ចោទប្រកាន់ទាំងនេះ បង្ហាញឱ្យឃើញថា អ្នកស្រីមិនស្ថិតក្នុងប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ឡើយ ។ ជាពិសេស ចម្លើយតបនេះនឹងបង្ហាញថា ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិផ្អែកលើគោលការណ៍មិនត្រឹមត្រូវធំៗពីរ ដែលថា៖ អ្នកស្រី អ៊ឹម ចែម បានប្រើប្រាស់អំណាចថ្នាក់តំបន់*ស្របច្បាប់* ឬ *ជាក់ស្តែង* នៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ហើយដែលឧក្រិដ្ឋកម្មរងការចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅក្នុងទីតាំងទាំងនោះ ស្ថិតក្នុងក្របខ័ណ្ឌពេលវេលាពាក់ព័ន្ធមានកម្រិតធ្ងន់ធ្ងរ ។

## IV. ការអង្កេតបឋម

### ក. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើដោយចំៗ សុំឱ្យមានដីកាលើកលែងការចោទប្រកាន់ លើបទចោទទាំងអស់នៃការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

១៩. ទោះបីជាមានការទទួលស្គាល់ថា អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[43] ក្តី ក៏សហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើដោយចំៗ សុំឱ្យមានការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មស្ថិតក្រោមច្បាប់ជាតិពាក់ព័ន្ធដែរ[44] ។ ដោយសារតែដីកាសន្និដ្ឋានស្ថាពរ គឺជាសំណើសុំឱ្យមានដីកាដំណោះស្រាយ*ជាក់លាក់*ក្នុងសំណុំរឿងមួយ[45] ជម្រើសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការមិនបន្តការចោទប្រកាន់លើឧក្រិដ្ឋកម្មនានាក្រោមច្បាប់ជាតិ គួរត្រូវបានចាត់ទុកថា ជាសំណើសុំលើកលែងការចោទប្រកាន់ទាំងអស់ចំពោះការរំលោភបំពាន

---

[43] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៦។

[44] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ និងនៅកថាខណ្ឌ ២៩៤-៣៧៨ នៅកថាខណ្ឌ៤៤២-៥០៣ (ដែលគ្រាន់តែផ្តល់ច្បាប់ពាក់ព័ន្ធ និងការស្នើឡើងពីការកំណត់បទចោទលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)។

[45] *សូមមើល* វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី ៩) ដែលអនុម័តនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (ត្រូវបានកែសម្រួលនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥) ("វិធានផ្ទៃក្នុង"), សទ្ទានុក្រម, ទំព័រ ៨៣ (និយមន័យ "ដីកាសន្និដ្ឋានស្ថាពរ") (ដែលកំណត់និយមន័យដីកាសន្និដ្ឋានស្ថាពរជា "ដីកា*ជាលាយលក្ខណ៍អក្សរ*ដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឱ្យធ្វើដីកាដំណោះស្រាយចំពោះសំណុំរឿងណាមួយ (សេចក្តីបញ្ជាក់បន្ថែម)។

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ ព្រោះហេតុដូច្នេះហើយ ចម្លើយតបរបស់ក្រុមការពារក្តីនឹងមិនលើកឡើងពីឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិនោះទេ ។

### ខ. សហព្រះរាជអាជ្ញាអន្តរជាតិ ព្យាយាមពង្រីកវិសាលភាពដីកាដំណោះស្រាយដោយគ្មានការអនុញ្ញាត

២០. សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចនឹងធ្វើការស្វះស្វែងឱ្យមានការចោទប្រកាន់ណាមួយ ក្រៅតែពីបទចោទប្រកាន់ទាំងឡាយណា ដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ឡើយ[46] ។ ទោះជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម លើបទចោទប្រកាន់ទាំងឡាយ ក្រៅពីបទចោទប្រកាន់នានាដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ហេតុដូច្នេះ អង្គហេតុពាក់ព័ន្ធនឹងបទចោទប្រកាន់ទាំងនោះ ក៏មិនបានបង្កើតបានជាមូលដ្ឋានអ្វីចំពោះបទចោទប្រកាន់បច្ចុប្បន្នដែរ[47] ។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាសំណើមានកំហុសអង្គច្បាប់ ។ ដូចមានរៀបរាប់នៅផ្នែកខាងក្រោម ក្រុមការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនត្រូវទទួលបានការអនុញ្ញាតជាដាច់ខាត ក្នុងការបន្តព្យាយាមពង្រីកដីកាដំណោះស្រាយឱ្យលើសពីវិសាលភាពនៃការជូនដំណឹងអំពីបទចោទប្រកាន់ ឬព្យាយាមធ្វើការពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ *លើហេតុបច្ច័យកើតក្រោយៗមកទៀត* ដោយគ្មានដំណើរការសមស្របដូច្នេះឡើយ ។ ជាធម្មតា ដើម្បីធ្វើការចោទប្រកាន់បានជនសង្ស័យត្រូវតែបានជូនដំណឹងជាមុនពីបទចោទប្រកាន់នានា តាមរយៈសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់[48] ។

46 *សូមប្រៀបធៀបជាមួយសំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ **D198/1** នៅកថាខណ្ឌ ១០។

47 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩។

48 *សូមប្រៀបធៀបជាមួយ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ **D198/1** នៅកថាខណ្ឌ ១០ ។ សេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** ។ *សូមមើល* ដីកា

២១. ផ្ទុយពីវិធីសាស្ត្រដែលបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ជនត្រូវចោទមិនចាំបាច់ស្វែងយល់ពីខ្លឹមសារនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣[49] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរ[50] និងការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[51] ដើម្បីពិនិត្យឱ្យបានដឹងច្បាស់នូវបទចោទប្រកាន់*សំខាន់ៗ*ដែលអាចមានក្នុងឯកសារវាប់រយទំព័រនេះឡើយ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មិនមែនជាឯកសារចោទប្រកាន់នោះទេ ប៉ុន្តែវាជា*សំណើ*សុំឱ្យសហចៅក្រមស៊ើបអង្កេតបើក ឬពង្រីកការស៊ើបសួរចំពោះ

---

សម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ឯកសារ **D239** នៅកថាខណ្ឌ ៥៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា អ៊ឹម ចែម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **D 285** នៅកថាខណ្ឌ ២ ("នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥....អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ពីបទរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (មនុស្សឃាត) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត") ។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **D239/1/8** នៅកថាខណ្ឌ ១០ (ដែលរៀបរាប់ពីការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ៖ "សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរៀបរាប់លម្អិតអំពីបទចោទប្រឆាំង អ៊ឹម ចែម ដែលរួមមានការចោទប្រកាន់អំពីការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងនឹងមនុស្សជាតិ នៅក្នុងឧបសម្ព័ន្ធដាច់ដោយឡែកមួយភ្ជាប់ជាមួយនឹងដីកាសម្រេចដែលរងការជំទាស់នេះ")។

49 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ឯកសារ **D1**។

50 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ឯកសារ **D65** ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ ឯកសារ **D65**" ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ឯកសារ **D191** (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ២ឯកសារ **D191**")។

51 ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធានផ្ទៃក្នុង ២១(១)(ឃ)] នៅក្នុងសំណុំរឿង ០០៤ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D111**។

អង្គហេតុដែលបានចោទប្រកាន់[52] ។ ហើយការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យក៏មិនមែនជាឯកសារចោទប្រកាន់ដែរ ប៉ុន្តែការជូនដំណឹងនេះ មានគោលបំណង*ផ្តល់ព័ត៌មាន*ដល់ជនសង្ស័យពី "ឧក្រិដ្ឋកម្មដែលគាត់កំពុងស្ថិតក្រោមការស៊ើបអង្កេត និងអំឡុងពេលដែលឧក្រិដ្ឋកម្មទាំងអស់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង"[53] ។

២២. ការជូនដំណឹងអំពីបទចោទប្រកាន់ ជាមធ្យោបាយដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ជនសង្ស័យអំពីបទចោទប្រកាន់លើពួកគេ ហើយលុះត្រាតែបន្ទាប់ពីបានរកឃើញថាមាន "តម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"[54] ។ ជាលទ្ធផល សេចក្តីជូនដំណឹងអំពីបទចោទប្រកាន់បានជះឥទ្ធិពលយ៉ាងខ្លាំងលើស្ថានភាពរបស់ជនសង្ស័យ ពោលគឺនៅក្រោយពេលត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់លើខ្លួន ជនសង្ស័យនឹងក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី[55] និងមានសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរតាមរយៈការចូលពិនិត្យមើលសំណុំរឿង[56] អាចធ្វើការតទល់នឹងសាក្សី[57] ការស្នើសុំឱ្យមានកិច្ចស៊ើបសួរ[58] ឬអាចសូម្បីតែធ្វើការស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យដាក់សំណើជូនទៅអង្គបុរេជំនុំជម្រះ

---

[52] សទ្ទានុក្រមក្នុងវិធានផ្ទៃក្នុង ទំព័រ ៨៤ (និយមន័យ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ទំព័រ ៨៥ (និយមន័យ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។

[53] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១) (ឃ) នៃវិធានផ្ទៃក្នុង] នៅក្នុងសំណុំរឿង ០០៤ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ឯកសារ **D111** នៅកថាខណ្ឌ ២។

[54] វិធានផ្ទៃក្នុង វិធាន ៥៥ (៤) នៃវិធានផ្ទៃក្នុង។

[55] *សូមមើល* សទ្ទានុក្រមក្នុងវិធានផ្ទៃក្នុង ទំព័រ ៨៤ (និយមន័យនៃពាក្យ "ភាគី") ("ភាគី" សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី")។

[56] *សូមមើល* ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239** នៅកថាខណ្ឌ ៧៧។

[57] *សូមមើល* វិធានផ្ទៃក្នុង វិធាន ៦០(២) នៃវិធានផ្ទៃក្នុង "ដែលចែងថា ការតទល់នឹងសាក្សីអាចត្រូវបានរៀបចំឡើងដោយមានវត្តមានរបស់ជនត្រូវចោទ)។

[58] *សូមមើល* វិធានផ្ទៃក្នុង វិធាន ៥៥(១០), វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង (ដែលចែងថា មុនពេលការបិទបញ្ចប់ និងភ្លាមៗបន្ទាប់ពីកិច្ចស៊ើបសួរ ភាគីនានាអាចស្នើឱ្យមានកិច្ចស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត)។

ដើម្បីស្នើសុំមោឃភាពកិច្ចស៊ើបសួរ[59] ។ វាជាច្បាប់ដ៏សាមញ្ញ ដែលថា ការជូនដំណឹងអំពីបទចោទប្រកាន់ *គឺជា*ឯកសារចោទប្រកាន់ ។

២៣. ខណៈដែលសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចស៊ើបអង្កេតលើអង្គហេតុទាំងអស់ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[60] ពួកគាត់មានអំណាចក្នុងការកំណត់យកអង្គហេតុណាមួយ ដែលអាចបង្កើតបានជាមូលដ្ឋាននៃបទចោទប្រកាន់[61] ។ ក្នុងសំណុំរឿងអ្នកស្រី អ៊ឹម ចែម អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចោទប្រកាន់អ្នកស្រីលើឧក្រិដ្ឋកម្មជាក់លាក់ ដែលអ្នកស្រីត្រូវបានរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង*តែប៉ុណ្ណោះ*[62] ។ ខណៈដែលចៅក្រម Harmon បើកឱ្យមានការចោទប្រកាន់បន្ថែម[63] សហចៅក្រមស៊ើបអង្កេតបានបិទកិច្ចស៊ើបសួរនៅត្រឹមថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥[64] ដោយមិនបានជូនដំណឹងដល់អ្នកស្រី អ៊ឹម ចែម អំពីការចោទ

[59] *សូមមើល* វិធានផ្ទៃក្នុង វិធាន ៧៦ (២) នៃវិធានផ្ទៃក្នុង (ដែលចែងថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេតដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព)។

[60] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ឯកសារ **D198/1** នៅកថាខណ្ឌ ១០។

[61] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ឯកសារ **D198/1** នៅកថាខណ្ឌ ១០។

[62] ការជូនដំណឹងអំពីបទចោទប្រកាន់ឯកសារ **D239.1** នៅកថាខណ្ឌ ២-៨។

[63] *សូមមើល* ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239** នៅកថាខណ្ឌ ៥("មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ដែលគាំទ្រការដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យផ្នែកខ្លះ") ។ *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ឯកសារ **D239.1** នៅកថាខណ្ឌ ១៩ ("មុនពេលបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀតដោយផ្អែកលើការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ ប្រសិនបើសហចៅក្រមស៊ើបអង្កេតជឿជាក់ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ")។

[64] *សូមមើល* សេចក្តីជូនដំណឹងអំពីការការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែមថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **D285**។

ប្រកាន់បន្ថែមណាមួយទៀតឡើយ ។ អង្គហេតុដែលថា អ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មបន្ថែម ក្រៅតែពីឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង គឺជាសេចក្តីសម្រេចបញ្ចប់បញ្ហា ពោលគឺ សហចៅក្រមស៊ើបអង្កេតជឿជាក់ថាមាន "គម្រុយច្បាស់លាស់ និងស៊ីសង្វាក់" ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង[65] និងមិនពាក់ព័ន្ធឡើយនឹងបទចោទប្រកាន់ផ្សេងៗទៀត ដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរផ្សេងទៀតនោះទេ ។ សេចក្តីអះអាងបច្ចុប្បន្នរបស់សហព្រះរាជអាជ្ញាអន្តរជាតិជាការចោទប្រកាន់គ្មានមូលដ្ឋានភស្តុតាងគាំទ្រដូចដែលតម្រូវក្នុងការចោទប្រកាន់ ពេលនេះអាចជាកម្មវត្ថុនៃការបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺធ្វើឡើងដោយមានកំហុសអង្គច្បាប់ ហើយប្រសិនបើត្រូវបានទទួលយកមែន វានឹងរំលោភបំពានចំពោះក្នុងការទាមទារឱ្យមាននូវដំណើរការសមស្របមួយ[66] ។

២៤. លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចអះអាងថា ខ្លួនមិនបានដឹងពីសារៈសំខាន់នៃការធានាផ្នែកនីតិវិធីនេះបានឡើយ ។ កាលពីឆ្នាំ២០០៩ នៅក្នុងចម្លើយតបទៅនឹងការចោទសួរជាក់លាក់របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងវិសាលភាពនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានចេញដីកាស្រាយបំភ្លឺមួយ ដោយបានបញ្ជាក់សាជាថ្មីអំពីការការពារជាមូលដ្ឋាន ពោលគឺ: ចៅក្រមអាចចោទប្រកាន់បុគ្គលណាម្នាក់បាន សម្រាប់តែឧក្រិដ្ឋកម្មណា

---

[65] *សូមប្រៀបធៀបជាមួយ* ការជូនដំណឹងអំពីបទចោទប្រកាន់ឯកសារ **D239.1** នៅកថាខណ្ឌ ២-៨។

[66] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៤៥៤ (ដែលកំណត់លក្ខណៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ដោយដកស្រង់ទីតាំងវត្តអង្គស្រីមាលី ភូមិចក្រី វត្តព្រះនេត្រព្រះ ព្រៃសុខុន ចំការតាឡឹង និងព្រៃតារុតដែលសុទ្ធតែនៅក្រៅវិសាលភាពនៃអង្គហេតុដែល អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់) នៅកថាខណ្ឌ ៤៨២ (ដែលកំណត់លក្ខណៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការបាត់ខ្លួនដោយបង្ខំ ដោយដកស្រង់ទីតាំងទំនប់ត្រពាំងថ្ម ចំការខ្នុរ ភូមិចក្រី វត្តព្រះនេត្រព្រះ និងវត្តអង្គស្រីមាលី ដែលសុទ្ធតែស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុដែល អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់)។

ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងអង្គហេតុរងការចោទប្រកាន់ពីមុនប៉ុណ្ណោះ ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា៖

> ជាចុងក្រោយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះ ចំពោះអង្គហេតុណាដែលបុគ្គលនោះ *មិនត្រូវបានដាក់ឱ្យឋិតក្រោមការពិនិត្យជាមុននោះទេ* នោះការដាក់ឱ្យឋិតក្រោមការពិនិត្យមិនមែនជាបុរេវិនិច្ឆ័យ នៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ នៅក្នុងដំណាក់កាលនៃការបិទការស៊ើបសួរនោះឡើយ។
>
> ...
>
> ជនត្រូវចោទ អាចនឹងត្រូវបញ្ជូនទៅជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុទាំងមូល ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា *ក្នុងលក្ខខណ្ឌដែលថាបុគ្គលនោះ ត្រូវបានដាក់ឱ្យឋិតក្រោមការពិនិត្យជាមុន ដោយសហចៅក្រមស៊ើបអង្កេតចំពោះបទឧក្រិដ្ឋទាំងនេះ*[67]។

២៥. ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹងហើយថា អ្នកស្រី អ៊ឹម ចែម អាចនឹងត្រូវបញ្ជូនទៅជំនុំជម្រះតែចំពោះឧក្រិដ្ឋកម្មដែលអ្នកស្រីរងការចោទប្រកាន់តែប៉ុណ្ណោះ ពោលគឺឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង[68] ។ ការអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិបន្តចំណាត់ការនេះ នឹងមិនត្រឹមតែធ្វើឱ្យអន្តរាយដល់សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការដឹងពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រីនោះទេ[69] ប៉ុន្តែនឹងធ្វើឱ្យអំណាចរបស់សហចៅក្រម

---

[67] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ **D198/1** នៅកថាខណ្ឌ ១០-១១ (លុបចោលជើងទំព័រ, សេចក្តីបញ្ជាក់បន្ថែម)។

[68] ការជូនដំណឹងអំពីបទចោទប្រកាន់ឯកសារ **D239.1** នៅកថាខណ្ឌ ២-៨។

[69] វិធានផ្ទៃក្នុង វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦) ៩៩៩ UNTS ១៧១ (“ICCPR”), មាត្រា

ស៊ើបអង្កេតប្រើប្រាស់ក្នុងការចោទប្រកាន់លើដំណើរការនីតិវិធីមិនពាក់ព័ន្ធ និងជាការបំភ័ន្តទៅវិញ[70] ។ ហេតុដូច្នេះ រាល់ទឡ្ហីករណ៍ដែលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានស្ថាពរ គួរតែលើកឡើងពីបញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ដែលលេចឡើង*ក្នុងការកំណត់យុត្តាធិការលើវិសាលភាពបទឧក្រិដ្ឋ យុត្តាធិការពេលវេលា និងយុត្តាធិការភូមិសាស្ត្រ*នៃបទចោទប្រកាន់ដែលត្រូវបានជូនដំណឹងក្នុងសេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ ។

២៦. ដូច្នេះ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការពង្រីកវិសាលភាពនៃដីកាសន្និដ្ឋានស្ថាពរ និងពង្រីកវិសាលភាពនៃដីកាដំណោះស្រាយ គួរត្រូវបានច្រានចោលជាដាច់ខាត ។ ជាពិសេស សំណើខាងក្រោមទាំងអម្បាលម៉ានគួរត្រូវបានបដិសេធ៖

(i) សំណើសុំធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម *ពាក់ព័ន្ធនឹងអង្គហេតុទាំង ១០* ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតដើម[71]៖ មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ ២ ប៉ុណ្ណោះ

---

១៤ (៣) (ក) ។ *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៨-១១-២០១០-អវតក-អបជ (១៦), សាលដីកាសម្រេចលើសំណើសុំបកប្រែរាល់ឯកសារទាំងអស់ដែលលើកមកសំអាងក្នុងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ **២** នៅកថាខណ្ឌ ៧ ។ *រឿងក្ដី Pelissier និង Sassi ទល់នឹងប្រទេសបារាំង* (ពាក្យស្នើសុំលេខ ២៥៤៤៤/៩៤), ECtHR ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ នៅកថាខណ្ឌ ៥២ ("តុលាការយល់ថា ក្នុងបញ្ហាព្រហ្មទណ្ឌ បទប្បញ្ញត្តិ ដែលចែងពីព័ត៌មានពេញលេញ និងលម្អិតដែលពាក់ព័ន្ធនឹងបទចោទប្រកាន់លើជនជាប់ចោទ និងការកំណត់លក្ខណៈផ្លូវច្បាប់ដែលតុលាការអាចអនុវត្តក្នុងបញ្ហានេះ គឺជាបុរេលក្ខខណ្ឌដ៏សំខាន់សម្រាប់ការធានាថាដំណើរការនីតិវិធីធ្វើឡើងដោយយុត្តិធម៌") (ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២**)។

70 *សូមមើល* ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D239** នៅកថាខណ្ឌ ៧១។ *រឿងក្ដី Pelissier និង Sassi ទល់នឹងប្រទេសបារាំង* (ពាក្យស្នើសុំលេខ ២៥៤៤៤/៩៤), ECtHR ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩នៅកថាខណ្ឌ ៥៤ ("តុលាការយល់ថា វាក្យខណ្ឌរង (ក) និង (ខ) នៃមាត្រា ៦ (៣) មានភាពពាក់ព័ន្ធគ្នា ហើយសិទ្ធិទទួលបានព័ត៌មានស្ដីពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ត្រូវពិចារណាដោយយោងតាមសិទ្ធិរបស់ជនជាប់ចោទក្នុងការរៀបចំមេធាវីការពារក្ដីរបស់ខ្លួន") (ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២**)។ *សូមមើល* កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់មាត្រា ១៤(៣)(ខ)។

71 *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ឯកសារ **D1** (ដែលរៀបរាប់ពីការបោសសម្អាតភូមិភាគពាយព្យ មន្ទីរសន្តិសុខភ្នំទ្រយោង មន្ទីរសន្តិសុខភ្នំចក្រី វត្តព្រះនេត្រព្រះ និងចម្ការតាឡឹង ទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងទំនប់ព្រៃរនាម)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ ឯកសារ **D65** (ដែលរៀបរាប់ពីការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម និងទីតាំងសម្លាប់ព្រៃសុខុន)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដែលបានបំពេញលក្ខខណ្ឌតម្រូវនៃភស្តុតាង ដើម្បីអាចឈានដល់ចំណាត់ការចោទប្រកាន់បាន ពោលគឺ ភស្តុតាងពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ។ អង្គហេតុសេសសល់ចំនួន ៨ ទៀត មិនអាចយកមកធ្វើការចោទប្រកាន់បានឡើយ ។ អង្គហេតុទាំងនោះរួមមាន អង្គហេតុដែលពាក់ព័ន្ធនឹង៖ i) ការធ្វើទុក្ខបុកម្នេញខ្មែរក្រោម[72] ii) មន្ទីរសន្តិសុខវត្តអង្គស្រីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន[73] iii) ការបោសសម្អាតនៅតំបន់៥ ក្នុងភូមិភាគពាយព្យ (ដោយផ្នែក)[74] iv) ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម[75] v) មន្ទីរសន្តិសុខចក្រី និងទីតាំងពាក់ព័ន្ធនឹងការសម្លាប់មនុស្សមួយចំនួនទៀត រួមមានដូចជា ព្រៃតារុត[76] vi) មន្ទីរសន្តិសុខវត្តចម្ការខ្នុរ និងទីតាំងពាក់ព័ន្ធ

---

បន្ថែមលើកទី ២ឯកសារ **D191** (ដែលរៀបរាប់ពីអំពើហិង្សាផ្លូវភេទលើខ្មែរក្រោម ជនជាតិវៀតណាម និងក្រុមគោលដៅផ្សេងទៀត)។

72 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៥៧-៦២ (ដែលរៀបរាប់ពីការធ្វើទុក្ខបុកម្នេញខ្មែរក្រោម ក្នុងទម្រង់ជាឧក្រិដ្ឋកម្មមួយដែលរងការចោទប្រកាន់ថាបានប្រព្រឹត្ត) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុ ទាំងអស់)។

73 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៦៣-៧២ (ដែលរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តអង្គស្រីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។

74 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៣-៧៨ (ដែលរៀបរាប់ពីការបោសសម្អាតតំបន់ ៥ ក្នុងភូមិភាគពាយព្យ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។ *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** នៅកថាខណ្ឌ ៧ (អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទបោសសម្អាតតំបន់៥ ដែលស្ថិតក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង មិនមែនជាការចោទប្រកាន់ដាច់ដោយឡែកឡើយ៖ អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ដោយសារ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ...(ដូចជា ការធ្វើទុក្ខបុកម្នេញលើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) នៅភូមិភាគពាយព្យ និងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ រួមបញ្ចូលទាំងមន្ត្រីស៊ីវិល និងអតីតទាហាន...ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង")។

75 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៩-៩២ (ដែលរៀបរាប់ពីការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ក្នុងទម្រង់ជាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើអង្គហេតុសំខាន់ៗទាំងអស់)។

76 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១៧-២៨ (ដែលរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធ ដូចជា ព្រៃតារុត) កថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។

នានា[77] vii) វត្តព្រះនេត្រព្រះ ព្រមទាំងទីតាំងឃុំឃាំង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធមួយចំនួន[78] និង viii) ទំនប់ត្រពាំងថ្ម[79] ។

(ii) សំណើសុំធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម *ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលអ្នកស្រីមិនត្រូវបានរងការចោទប្រកាន់៖* សញ្ញាណនៃ "បទចោទប្រកាន់" ក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ត្រូវ "ចាត់ទុកជាការបង្ហាញពីលក្ខណៈផ្លូវច្បាប់ដែលកំណត់ទុក"[80] ។ ទោះបីជាសំណើសុំឱ្យកំណត់លក្ខណៈផ្លូវច្បាប់ឡើងវិញ នៃបទចោទប្រកាន់ដែលត្រូវបានចោទអាចនឹងត្រូវបានអនុញ្ញាតក្តី[81] ក៏សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចស្នើឱ្យមានការចោទ

---

77 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២២៩-៤១ (ដែលរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តចំការខ្នុរ និងទីតាំងពាក់ព័ន្ធផ្សេងទៀត) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។

78 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៤២-៥៦ (ដែលរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅវត្តព្រះនេត្រព្រះ និងទីតាំងឃុំឃាំង និងទីតាំងសម្លាប់ពាក់ព័ន្ធផ្សេងទៀត) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។

79 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧២-៩៣ (ដែលរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានទំនប់ត្រពាំងថ្ម) នៅកថាខណ្ឌ ៥៣៩ (១) (ដែលស្នើឱ្យមានការចោទប្រកាន់លើគ្រប់អង្គហេតុទាំងអស់)។

80 *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ឯកសារ **D198/1** នៅកថាខណ្ឌ ១០ (ជើងទំព័រទី ១០)។

81 ក្រុមការពារក្តីកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនបានផ្តល់អំណាចដល់សហព្រះរាជអាជ្ញាក្នុងការលើកឡើង ឬស្នើឱ្យមានការកំណត់ឧក្រិដ្ឋកម្មជាថ្មីឡើងវិញឡើយ ប៉ុន្តែកន្លងមក សំណើទាំងនេះអាចទទួលយកបាននៅ អ.វ.ត.ក ។ *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E100/6** (ដែលយល់ថា សំណើសុំការកំណត់លក្ខណៈផ្លូវច្បាប់ឡើងវិញដោយសហព្រះរាជអាជ្ញា គឺអាចទទួលយកបាន)។ ប៉ុន្តែ ការកំណត់ឧក្រិដ្ឋកម្មឡើងវិញអាចអនុញ្ញាតទៅបាន ប្រសិនបើមិនមានការបង្ហាញពីធាតុផ្សំគ្រប់គ្រាន់ថ្មីៗ។ *សូមប្រៀបធៀបជាមួយ* វិធានផ្ទៃក្នុង, វិធាន ៩៨ (២) នៃវិធានផ្ទៃក្នុង។ *សូមមើល* Guery C. និង Chambon P., Droit et Pratiquede l'Instruction Prepratoire (Dalloz, ២០១៣) កថាខណ្ឌ ២១៤.៨១ ["Si la qualification est toujours provisoire et peut être modifiée tout au long de l'information, encore faut-il que la personne mise en examen ait pu en discuter les éléments … Mais il ne faut pas que les éléments constitutifs de l'infraction nouvelle soient trop éloignés de la qualification initiale retenue."], [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ៣** ដោយមានការបកប្រែ

ប្រកាន់លើបទចោទប្រកាន់*បន្ថែម*ដែលជាការណែនាំនូវធាតុផ្សំពិសេសជាសារវន្ត[82] លើបទចោទប្រកាន់ដែលមានស្រាប់នៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ឡើយ[83] ។ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម ដែលពាក់ព័ន្ធនឹងធាតុផ្សំពិសេសជាសារវន្តពីបទឧក្រិដ្ឋរងការចោទប្រកាន់ ដូចមាននៅក្នុងសេចក្តីជូនដំណឹងពីបទចោទប្រកាន់ ហើយអង្គហេតុដែលគួរឲ្យកត់សម្គាល់បំផុតគឺ៖ ការបង្កើតជាសម្ព័ន្ធមេត្រីភាពប្តីប្រពន្ធដោយបង្ខំក្នុងទម្រង់ជាធាតុផ្សំនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[84] ការបញ្ចូលប្រដាប់ភេទពីសំណាក់ជនបង្ក ដោយ

---

ក្រៅផ្លូវការ៖ "ខណៈដែលការកំណត់លក្ខណៈផ្លូវច្បាប់នៅតែមានលក្ខណៈបណ្តោះអាសន្ន និងអាចត្រូវបានកែប្រែក្នុងកិច្ចស៊ើបសួរ ជនត្រូវចោទត្រូវតែអាចពិភាក្សាពីធាតុផ្សំទាំងនេះ...ប៉ុន្តែធាតុផ្សំគ្រប់គ្រាន់នៃបទឧក្រិដ្ឋថ្មីមិនត្រូវខុសគ្នាខ្លាំងពេកពីធាតុផ្សំមួយដែលត្រូវបានកំណត់លក្ខណៈផ្លូវច្បាប់ពីដំបូងឡើយ"]។

82 *សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Zdravko Mucic *និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-៩៦-២១-A, សាលាឧទ្ធរណ៍, សាលក្រម ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤១២ ("ធាតុផ្សំមួយ មានលក្ខណៈពិសេសជាសារវន្តពីធាតុផ្សំមួយផ្សេងទៀត ប្រសិនបើធាតុផ្សំនោះតម្រូវឱ្យមានការបញ្ជាក់ពីអង្គហេតុមួយដែលមិនតម្រូវដោយធាតុផ្សំផ្សេងទៀត") [ត្រូវបានភ្ជាប់ជា**ឯកសារយោងទី ៤**]។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Mladen Naletilic* *និង* *Vinko Martinovic,* សំណុំរឿងលេខ IT-៩៨-៣៤-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រមចុះនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ នៅកថាខណ្ឌ ៧១៨ ("ក្នុងការកំណត់ ថាតើបទប្បញ្ញត្តិមួយមានធាតុផ្សំពិសេសជាសារវន្ត គេត្រូវពិចារណាពីធាតុផ្សំទាំងអស់នៃបទឧក្រិដ្ឋ រួមទាំងលក្ខខណ្ឌតម្រូវ*ទូទៅ")* [ត្រូវបានភ្ជាប់ជា**ឯកសារយោងទី ៥**]។

83 *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** នៅកថាខណ្ឌ ៧ (អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយសារ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ... និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមានដូចជា ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស ដោយសារការមិនឱ្យមានអាហារគ្រប់គ្រាន់) ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង") នៅកថាខណ្ឌ ៨ ("អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជា ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស ដោយសារការមិនឱ្យមានអាហារគ្រប់គ្រាន់) ដែលបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែង")។

84 *សូមប្រៀបធៀបជាមួយសំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស, ដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ឯកសារ **D427** ("ដីកាដោះស្រាយសំណុំរឿង ០០២ឯកសារ **D427**") នៅកថាខណ្ឌ ១៤៤៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Alex Tamba Brima* *និងអ្នកផ្សេងទៀត* (សំណុំរឿងលេខ SCSL-០៤-១៦-A-៦៧៥), សាលាឧទ្ធរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨នៅកថាខណ្ឌ ១៩៥ [ត្រូវបានភ្ជាប់ជា**ឯកសារយោងទី ៦**]។

គ្មានការយល់ព្រមពីជនរងគ្រោះក្នុងទម្រង់ជាធាតុផ្សំនៃការរំលោភសេពសន្ថវៈ[85] និងការបង្កការឈឺចាប់ ឬការរងគ្រោះធ្ងន់ធ្ងរដើម្បីទទួលបានលទ្ធផលជាក់លាក់ ឬគោលបំណងផ្សេងទៀតក្នុងទម្រង់ជាធាតុផ្សំនៃការធ្វើទារុណកម្ម[86] ។ ដូច្នេះ អ្នកស្រី អ៊ឹម ចែម មិនអាចរងការចោទប្រកាន់សម្រាប់ឧក្រិដ្ឋកម្មខាងក្រោមណាមួយ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងឡើយ ពោលគឺ បទឧក្រិដ្ឋទាក់ទងនឹង៖ i) អាពាហ៍ពិពាហ៍ដោយបង្ខំ[87] ii) ការរំលោភសេពសន្ថវៈ[88] និង iii) ការធ្វើទារុណកម្ម[89] ។

(iii) សំណើសុំឱ្យធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលមិនមែនជាកម្មវត្ថុនៃការស៊ើបអង្កេតដើម៖ i) ការបោសសម្អាតនៅតំបន់៥ ក្នុងភូមិភាគពាយព្យ[90] ii) ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម[91] iii) មន្ទីរសន្តិសុខចក្រី និង

---

85 *សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសរ,* សាលក្រមចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ **E188** ("សាលក្រមជំនុំជម្រះក្នុងសំណុំរឿង ០០១ ឯកសារ **E188**") នៅកថាខណ្ឌ ៣៦២។

86 សាលក្រមជំនុំជម្រះក្នុងសំណុំរឿង ០០១ឯកសារ **E188**នៅកថាខណ្ឌ ៣៥៤ ៣៥៦។

87 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៤៧៦-៧៧ (ដែលកំណត់លក្ខនិងកថាខណ្ឌ ណ:ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអាពាហ៍ពិពាហ៍ដោយបង្ខំនៅទីតាំងផ្សេងៗ *រួមទាំង*នៅការដ្ឋានស្ពានស្រែង) នៅកថាខណ្ឌ ៥៣៩ (១) (ឆ) (ដែលស្នើ ឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអាពាហ៍ពាហ៍ដោយបង្ខំ)។

88 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៧៨-៨១ (ដែលកំណត់លក្ខណៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការរំលោភផ្លូវភេទនៅទីតាំងផ្សេងៗ *រួមទាំង*នៅមន្ទីរសន្តិសុខភ្នំទ្រយោង) នៅកថាខណ្ឌ ៥៣៩(១)(ជ) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការរំលោភផ្លូវភេទ)។

89 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៦៨-៧១ (ដែលកំណត់លក្ខណៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការធ្វើទារុណកម្មនៅទីតាំងផ្សេងៗ *រួមទាំង* នៅមន្ទីរសន្តិសុខភ្នំទ្រយោង) នៅកថាខណ្ឌ ៥៣៩ (១)(ង) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការធ្វើទារុណកម្ម)។

90 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់អង្គហេតុសំខាន់ៗទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ

ទីតាំងសម្លាប់មនុស្សពាក់ព័ន្ធមួយចំនួនទៀត រួមមានដូចជា ព្រៃតាវុត[92] iv) មន្ទីរសន្តិសុខ វត្តចម្ការខ្នុរ និងទីតាំងពាក់ព័ន្ធនានា[93] v) វត្តព្រះនេត្រព្រះ និងទីតាំងឃុំឃាំង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា[94] vi) ទំនប់ត្រពាំងថ្ម[95] vii) ការដ្ឋានស្ពានស្រែង[96] និង ៨) មន្ទីរ

---

៥៣៩(២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់អង្គហេតុសំខាន់ៗទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

91 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

92 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

93 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

94 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

95 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

96 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើ ឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ីម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

សន្តិសុខភ្នំទ្រយោង[97] គឺជាការប៉ុនប៉ងពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ *ដែលកើតក្រោយមកទៀត* ។ ទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣[98] ទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២[99] សុទ្ធតែមិនបានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបំពេញកិច្ចស៊ើបសួរលើឧក្រិដ្ឋកម្មសង្គ្រាម ដែលពាក់ព័ន្ធនឹងអង្គហេតុទាំងនេះឡើយ[100] ។ ខណៈដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី១ មានការចោទប្រកាន់ជាក់លាក់មួយចំនួន ទាក់ទងនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[101] អ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ដោយសារការចោទទាំងនេះទេ[102] ។ វាច្បាស់ណាស់ថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនអាចចាត់ទុកជាការកំណត់លក្ខណៈផ្លូវច្បាប់ឡើងវិញ លើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំង

---

[97] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

[98] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ឯកសារ **D1**។

[99] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ២ ឯកសារ **D191**។

[100] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ឯកសារ **D1** នៅកថាខណ្ឌ ១១៩ (ការបើកការស៊ើបអង្កេតលើអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលបានលើកឡើង ដូចជា ៖ ការរំលោភក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ២ ឯកសារ **D191** នៅកថាខណ្ឌ ១៣ (ការបើកការស៊ើបអង្កេតលើអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលបានលើកឡើង ដូចជា ៖ ការរំលោភក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

[101] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ ឯកសារ **D65** នៅកថាខណ្ឌ ២២ (ការបើកការស៊ើបអង្កេតលើអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលបានលើកឡើង ដូចជា៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)។

[102] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** នៅកថាខណ្ឌ ៤ ("[អ្នកស្រី] អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទរំលោភបំពានលើមាត្រា ៥០១ និង មាត្រា ៥០៦ (មនុស្សឃាត) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែល បានប្រព្រឹត្តទាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ទាំងនៅការដ្ឋានស្ពានស្រែង") នៅកថាខណ្ឌ ៦ ("អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ ឱ្យស្ថិតក្រោមការពិនិត្យដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្ត ជាផ្នែកមួយនៃការវាយប្រហារជាទូទៅនិងជាប្រព័ន្ធមកលើប្រជាជនស៊ីវិល (ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង)")។

មនុស្សជាតិឡើយ ។ ដូច្នេះ អ្នកស្រី អ៊ឹម ចែម មិនអាចទើបតែត្រូវបានចោទប្រកាន់ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវនៅពេលនេះបានទេ ពោលគឺ ការចោទប្រកាន់ពាក់ព័ន្ធនឹង៖ i) ការធ្វើទុក្ខបុកម្នេញខ្មែរក្រោម[103] និង ii) មន្ទីរសន្តិសុខវត្តអង្គស្រីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន[104] ។

២៧. សង្ខេបសេចក្តីទៅ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងបំណងឱ្យមានការចោទប្រកាន់លើបទចោទនានា ក្រៅពីបទចោទទាំងឡាយដែលកំណត់ក្នុងសេចក្តីជូនដំណឹងពីបទចោទប្រកាន់គប្បីត្រូវបានច្រានចោល ។ អ្នកស្រី អ៊ឹម ចែម ប្រឈមនឹងបទចោទប្រកាន់តែ ១២ ករណីប៉ុណ្ណោះ[105] ។

២៨. លើសពីនេះ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិស្វះស្វែងឱ្យការពង្រីកដីកាដំណោះស្រាយលើសពីវិសាលភាពនៃសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ឬព្យាយាមពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ*ដែលកើតក្រោយមកទៀត*ក្តី ក៏អ្នកស្រី អ៊ឹម ចែម នៅតែមានសិទ្ធិទទួលបានព័ត៌មាន

---

103 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុ ទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

104 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៦-៥០៣ (ដែលកំណត់លក្ខណៈនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ) នៅកថាខណ្ឌ ៥៣៩ (២) (ដែលស្នើឱ្យមានការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់គ្រប់អង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរ)។

105 *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** នៅកថាខណ្ឌ ៧ (អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយសារ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ... និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជា ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស ដោយសារការមិនឱ្យមានអាហារគ្រប់គ្រាន់) ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង") កថាខណ្ឌ ៨ ("អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរ ឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជា ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស ដោយសារការមិនឱ្យមានអាហារគ្រប់គ្រាន់) ដែលបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែង")។

ភ្លាមៗស្តីពីលក្ខណៈ និងមូលហេតុនៃបទចោទប្រកាន់ទាំងនោះដែរ ។ ផ្ទុយទៅវិញ ផលប៉ះពាល់ដោយផ្ទាល់ពីការប្រើវិធីសាស្ត្រ *ហួសពីអំណាចច្បាប់*របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ នាំឱ្យការស្នើសុំឱ្យពិចារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងកថាខណ្ឌ ៥៣៩ ខកខានមិនបានផ្តល់នូវព័ត៌មានចាំបាច់ដែលត្រូវឱ្យមាននោះឡើយ ។ ម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំដោយមិនច្បាស់លាស់៖ “ដោយការពិចារណាពីអង្គហេតុសម្ភារៈ និងការកំណត់បទចោទ[ប្រកាន់] ដូចមានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនខ្លួន [អ្នកស្រី អ៊ឹម ចែម] ទៅជំនុំជម្រះទោសលើ...ឧក្រិដ្ឋកម្មដូចតទៅ៖ (១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...(២) បំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩...”[106] ។ ដោយសារតែផលប៉ះពាល់ដោយផ្ទាល់ពីការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការពង្រីកវិសាលភាពនៃបទចោទប្រកាន់ដែលមានរួចហើយក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ លក្ខណៈ និងវិសាលភាពនៃការចោទប្រកាន់ដែលបច្ចុប្បន្នសុំឱ្យមានការពិចារណា គឺជាចេតនាមិនប្រាកដ និង គ្មានការកំណត់ច្បាស់លាស់ ។

២៩. ដំណាក់កាលនេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនអាច (ឬមិនមានឆន្ទៈ) ក្នុងការលើកសំណើរបស់ខ្លួនឱ្យបានល្អិតល្អន់ ដើម្បីស្នើសុំឱ្យមានការចោទប្រកាន់បានឡើយ[107] ។ ហេតុដូច្នេះ វាមិនអាចប្រតិបត្តិទៅបានទេ ក្នុងការផ្ទៀងផ្ទាត់រកបទចោទណាមួយដែលគួរតែក្លាយជាកម្មវត្ថុនៃការចោទប្រកាន់ ។ ការពិនិត្យឡើងវិញលើដីកាសន្និដ្ឋានស្ថាពរបង្ហាញឱ្យឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិ ហាក់ព្យាយាមធ្វើឱ្យមានការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដែលរួម

---

106 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩។

107 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩ (“ដោយពិចារណាពីអង្គហេតុសម្ភារៈ និងការកំណត់បទចោទ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនខ្លួន (អ្នកស្រី អ៊ឹម ចែម) ទៅជំនុំជម្រះទោសលើ...ឧក្រិដ្ឋកម្មដូចតទៅ” និងស្នើឱ្យមានការចោទប្រកាន់អ្នកស្រីចំនួន ១៥ករណី សម្រាប់រាល់អង្គហេតុដែលត្រូវបានចោទប្រកាន់ទាំង ១០ ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតដើម)។

បញ្ចូលនូវបទចោទប្រមាណជា ១២០ និង១៥០ ករណី[108] ។ ភាពមិនច្បាស់លាស់ និង មិនប្រាកដប្រជានេះ ជាការបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង ។ យ៉ាងហោចណាស់ វាជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានព័ត៌មានស្ដីពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រីដែរ ដែលទង្វើនេះ ជាការធ្វើឱ្យវិនាសដល់ការធានាផ្នែកនីតិវិធី ហើយនៅទីបំផុត វាជាការដកហូតចេញនូវដំណើរការសច្ចភាពដូចបានតម្រូវ សម្រាប់បង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់ដែលមានសុពលភាព ឬគោរពនូវគោលការណ៍ទំនួលខុសត្រូវក្នុងពិរុទ្ធភាពមួយ ។

## គ. សហព្រះរាជអាជ្ញាអន្តរជាតិខកខានក្នុងការជួយតុលាការក្នុងការរកឱ្យឃើញការពិត

៣០. លក្ខណៈពិសេសមួយក្នុងចំណោមលក្ខណៈពិសេសនៃប្រព័ន្ធស៊ើបសួរ ដែលជាកិច្ចដំណើរការនីតិវិធីមួយត្រូវបានប្រើជាមូលដ្ឋាននៅចំពោះមុខ អ.វ.ត.ក គឺកាតព្វកិច្ចក្នុងការរកឱ្យឃើញការពិត ។ ការពិត "គឺជាអ្វីៗដែលមនុស្សមានហេតុផលអាចទទួលយកបាន បន្ទាប់ពីការបង្ហាញឱ្យឃើញយ៉ាងពេញលេញ និងយុត្តិធម៌"[109] ។ បើទោះបីជាសហចៅក្រមស៊ើបអង្កេតមានតួនាទីជាចម្បងក្នុងការធ្វើឱ្យសម្រេចគោលដៅនេះនៅដំណាក់កាលមុនជំនុំជម្រះក្ដី[110] ក៏ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធីទាំងនេះ ចាំបាច់ត្រូវតែជួយតុលាការដើម្បីរកឱ្យឃើញការពិត[111] ។

---

108 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៩។ *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២៦ (ជើងទំព័រ ៧២-៧៩, ៨៧-៩៧, ១០៣-០៤)។

109 Weigend T., *តើយើងគួរស្វែងរកការពិតឬទេ និងតើអ្នកណាគួរធ្វើកិច្ចការនេះ?* (North Carolina Journal of International Law, Volume 36, Issue 2, 2011), ត្រង់ទំព័រ ៣៩៥ [ភ្ជាប់ជា**ប្រភពព័ត៌មាន** ៧]។

110 វិធានផ្ទៃក្នុង វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

111 សេចក្ដីសម្រេចលើសំណើរួម របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្ដល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ក្នុងសំណុំរឿង ០០១ ឯកសារ **E72/3** នៅកថាខណ្ឌ ២០-២១ និងកថាខណ្ឌ ២៤។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពីសិទ្ធិរបស់សហមេធាវី

៣១. កាតព្វកិច្ចនេះចាំបាច់ត្រូវតែធ្វើឱ្យបានសម្រេច តាមរយៈការប្រកាន់ភ្ជាប់យ៉ាងតឹងរ៉ឹងទៅនឹងភាពពេញលេញ ភាពប្រត្យក្ស និងឥតលម្អៀងក្នុងការប្រមូលភស្តុតាង និងដំណើរការវាយតម្លៃ[112] ។ អាស្រ័យហេតុនេះហើយ ទើបចៅក្រម Bohlander បានប្តេជ្ញាចិត្តថា គាត់នឹងអនុវត្តឱ្យបានតឹងរ៉ឹងនូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅពេលវាយតម្លៃភស្តុតាង[113] បូករួមទាំងការគាំទ្រដល់ភស្តុតាងផ្ទាល់ នៅពេលភស្តុតាងទាំងនោះអាចរកបាន[114] ។ ជាងនេះទៀត ចៅក្រម Bohlander បានកត់សម្គាល់ថា គាត់នឹងប្រើប្រាស់ "វិធីសាស្ត្រយ៉ាងប្រយ័ត្នប្រយែង" ក្នុងការគណនាពីចំនួនជនរងគ្រោះពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ណាមួយ[115] និងថា នៅក្នុងស្ថានភាពដែលសាក្សីផ្តល់ការប៉ាន់ស្មានពីចំនួនជនរងគ្រោះតាមរយៈលំដាប់នៃចំនួន

---

ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ក្នុងសំណុំរឿង ០០១ ឯកសារ **E72/3**នៅកថាខណ្ឌ ៣៤។

112 *សូមមើល* វិធានផ្ទៃក្នុង វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ["ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ"]។

113 *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **D188/1/1** នៅកថាខណ្ឌ ៤៨។ *សំណុំរឿង អោ អាន និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ ១៧ និងកថាខណ្ឌ ២៦។

114 *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **D188/1/1** នៅកថាខណ្ឌ ៤៨។ *សូមមើលផងដែរ* សំណុំរឿង *អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ ២៣។ *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត*, ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣ របស់ អោ អាន ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **D189/2** នៅកថាខណ្ឌ ២០។

115 *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ ២៤។

នោះ ការកំណត់តួលេខទាបជាងនឹងត្រូវយកមកប្រើប្រាស់[116] ។ ការបង្ហាញនូវវិធីសាស្ត្រនេះជាក់ស្តែង នៅពេលដែលចៅក្រម Bohlander បានរកឃើញថា ការយោងលើការប៉ាន់ស្មាននូវចំនួនលលាដ៍ក្បាលមនុស្ស ៨.០០០ ដែលស្ថិតនៅទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ គឺជាការយោង "មិនអាចជឿជាក់" បាន ពីព្រោះពុំមានភស្តុតាងចង្អុលបង្ហាញថា សាក្សីបានដឹងឮដោយផ្ទាល់នូវឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ណាមួយ ហើយសាក្សីនោះទៀតសោត ក៏មិនត្រូវបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ[117] ។

៣២. ដូចបានសង្កេតខាងលើ ភាគីទាំងអស់ក្នុងកិច្ចដំណើរការនីតិវិធី ដែលក្នុងនោះរួមទាំងសហព្រះរាជអាជ្ញាផង មានភារកិច្ចក្នុងការបំពេញការងារក្នុងការបញ្ជាក់ការពិត[118] ។ អាស្រ័យហេតុនេះ នៅពេលពិភាក្សាពីតួនាទីរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០១ សំឡេងភាគច្រើននៃអង្គចៅក្រម ជំនុំជម្រះសាលាដំបូងបានថ្លែងដូច្នេះថា៖

> អាជ្ញាធរអយ្យការក៏តំណាងឱ្យ "ផលប្រយោជន៍យុត្តិធម៌" និងមានតួនាទីអនុវត្តបណ្តឹងអាជ្ញានៅក្នុង "ផលប្រយោជន៍ទូទៅរបស់សង្គម"។
>
> ...
>
> ដូចដែលមាននៅក្នុងយុត្តាធិការភាគច្រើនគឺថា តួនាទីរបស់អយ្យការ រួមមានភារកិច្ចក្នុងការជួយតុលាការឱ្យស្វែងរកបាននូវការពិត និងបម្រើផល

---

[116] *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ 00៤/0៧-0៩-២00៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ ២៥-២៦។

[117] *សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ 00៤/0៧-0៩-២00៩/អវកត/កសចស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **D188/1/1** នៅកថាខណ្ឌ ៣៣។

[118] សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០១ ឯកសារ **E72/3** កថាខណ្ឌ ២០ - ២១, ២៤, ៣៤។

ប្រយោជន៍យុត្តិធម៌ពាក់ព័ន្ធនឹងសហគមន៍ផង និងជនជាប់ចោទផង ដោយអនុលោមតាមច្បាប់ និងវិធានយុត្តិធម៌[119]។

៣៣. ក្រុមការពារក្តីទទួលស្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនតម្រូវឱ្យប្រកាន់ខ្ជាប់អព្យាក្រឹតភាពខានមិនបាននោះឡើយនៅក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ។ សហព្រះរាជអាជ្ញា គឺជាភាគីមួយនៃកិច្ចដំណើរការនីតិវិធី ។ ទោះជាយ៉ាងណា គាត់មិនមែនជា*អ្នកប្រកាន់បក្សពួក*[120]នោះទេ ។ ដូចបានពន្យល់នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាដូច្នេះថា រដ្ឋអាជ្ញា "គួរតែដឹងខ្លួនឯងថា ក្នុងនាមជាមន្ត្រីយុត្តិធម៌ ពួកគេត្រូវជួយដល់ការគ្រប់គ្រងលើវិស័យយុត្តិធម៌[121] ។ សញ្ញាណនេះត្រូវបានពង្រីកឡើងនៅឯតុលាការឧក្រិដ្ឋមកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលចៅក្រម Shahabuddeen បានពន្យល់ដូច្នេះថា ៖

> រដ្ឋអាជ្ញាគឺជាភាគីមួយ ប៉ុន្តែគាត់ត្រូវបានទទួលស្គាល់ថា ជាតំណាងឱ្យផលប្រយោជន៍សាធារណៈនៃសហគមន៍អន្តរជាតិ ហើយត្រូវបំពេញការងារដោយគ្មានលម្អៀង និងយុត្តិធម៌ សមស្របទៅតាមកាលៈទេសៈ ។ គាត់មានវិចារណញ្ញាណពិតជាជាមន្ត្រីយុត្តិធម៌មួយរូប ។ បេសកកម្មរបស់គាត់ គឺមិនមែនធ្វើការធានាឱ្យមានការចោទប្រកាន់ ទោះជាស្ថិតក្នុងរូបភាពណាក៏ដោយនោះទេ ដែលករណីនេះ ស្តែងឱ្យឃើញនៅក្នុង

---

119 សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តី សន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០១ ឯកសារ **E72/3** នៅកថាខណ្ឌ ២០-២១ (លុបចោលឯកសារយោង)។

120 *សូមមើល រឿងក្តី Jean Bosco Barayagwiza ទល់នឹង រដ្ឋអាជ្ញា* (ICTR-97-19-AR72), សាលដីកាលើបណ្តឹងឧទ្ធរណ៍, មតិដោយឡែករបស់ចៅក្រម Shahabuddeen, តុលាការឧទ្ធរណ៍ (សំណើរបស់រដ្ឋអាជ្ញាក្នុងការពិនិត្យឡើងវិញនៃការពិចារណាឡើងវិញ) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០ នៅកថាខណ្ឌ ៦៨ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ៨**]។

121 រឿងក្តី *Jean Bosco Barayagwiza ទល់នឹង រដ្ឋអាជ្ញា*, (ICTR-97-19-AR72), សាលដីកាលើបណ្តឹងឧទ្ធរណ៍, មតិដោយឡែករបស់ចៅក្រម Shahabuddeen, តុលាការឧទ្ធរណ៍ (សំណើរបស់រដ្ឋអាជ្ញាក្នុងការពិនិត្យឡើងវិញនៃការពិចារណាឡើងវិញ) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០ នៅកថាខណ្ឌ ៦៨ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ៨**]។

វិធាននានាទាក់ទងនឹងការដាក់បង្ហាញភស្តុតាងដោះបន្ទុក ។ ធាតុសំខាន់នៃកត្តានេះ បានអនុវត្តក្នុងប្រព័ន្ធច្បាប់កំមិនឡ [Common Law] និងមានតម្លៃស្មើគ្នាក្នុងប្រព័ន្ធច្បាប់នានានៃទ្វីបអឺរ៉ុប[122] ។

៣៤. នៅ អ.វ.ត.ក កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបំពេញការងារក្នុងនាមជាមន្ត្រីយុត្តិធម៌ មានបង្ហាញនៅ *ក្នុងប្រការផ្សេងៗ* តាមរយៈភារកិច្ចក្នុងការបង្ហាញភស្តុតាង ឬសម្ភារៈតឹកតាងដោះបន្ទុក ដែលអាចមានអនុភាពដល់ភាពអាចជឿទុកចិត្តបាននៃភស្តុតាងចោទប្រកាន់[123] មានជម្រើសក្នុងការស្នើសុំឱ្យតុលាការច្រានចោលនូវសំណុំរឿងណាមួយ[124] និងលទ្ធភាពក្នុងការស្នើសុំឱ្យជនជាប់ចោទរួចខ្លួនពីបទចោទនៅចុងបញ្ចប់នៃការជំនុំជម្រះ[125] ។ ដូចបានលើកឡើងដោយចៅក្រមភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ សហព្រះរាជអាជ្ញាចាំបាច់ត្រូវតំណាងឱ្យផលប្រយោជន៍យុត្តិធម៌ ហើយដើម្បីធ្វើដូច្នេះបាន សហព្រះរាជអាជ្ញាចាំបាច់ត្រូវដាក់បង្ហាញ និងជជែកការពារនូវអំណះអំណាងរបស់ខ្លួនប្រកបដោយឥរិយាបថសត្យានុម័ត[126] ។

៣៥. ក្រុមការពារក្តីសន្និដ្ឋានថា វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិលើភស្តុតាងនៅក្នុងដីកាសន្និដ្ឋានស្ថាពរមានកំហុសជាហូរហែរក្នុងការបំពេញនូវបទដ្ឋានអប្បបរមាទាំងនេះ។ ដីកាសន្និដ្ឋានស្ថាពរ ខ្វះនូវភាពប្រត្យក្សដែលជាលក្ខខណ្ឌតម្រូវ ដើម្បីរួមចំណែកដល់ការស្វែរកការពិត ។ ការមិនយកចិត្តទុកដាក់ជាប្រចាំនូវភាពអាចជឿជាក់បាននៃភស្តុតាង និងការពិត គឺត្រូវបានបង្ហាញឱ្យ

---

122 រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević,* (IT-02-54-AR73.2) តុលាការឧទ្ធរណ៍, មតិជំទាស់អនាគតិរបស់ចៅក្រម Shahabuddeen ដីកាសម្រេចស្តីពីភាពអាចទទួលបាននៃភស្តុតាងស៊ើបអង្កេតរបស់រដ្ឋអាជ្ញា ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ នៅកថាខណ្ឌ ១៨ (លុបចោលជើងទំព័រ) [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ៩**]។

123 *សូមមើល*វិធានផ្ទៃក្នុង វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។

124 *សូមមើល* វិធានផ្ទៃក្នុង វិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង។

125 *សូមមើល* វិធានផ្ទៃក្នុង, វិធាន ៩៤(១)(ខ) នៃវិធានផ្ទៃក្នុង។

126 *សូមមើល* សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០១, ឯកសារ **E72/3** នៅកថាខណ្ឌ ២០។

ឃើញយ៉ាងច្បាស់នៅគ្រប់ទីកន្លែងទាំងអស់ក្នុងដីកាសន្និដ្ឋានស្ថាពរ ដែលមានទទ្បីករណ៍នាំមុខមួយចំនួន គ្មានភស្តុតាងគាំទ្រ ជានិច្ចជាកាលយល់ខុសទៅលើភស្តុតាង ធ្វើសេចក្តីសន្និដ្ឋានទាញទៅរកស្ថានភាពធ្ងន់ធ្ងរ និងអនុវត្តខុសពីវិធីសាស្ត្រដ៏ប្រយ័ត្នប្រយែងរបស់ចៅក្រម Bohlander ចំពោះការវាយតម្លៃភស្តុតាង ។ វាមិនមែនជាការតស៊ូមតិដែលអាចទទួលយកបានឡើយ ក្នុងការ៖ មិនអើពើចំពោះខ្សែអាត់ថតយកសំឡេង និងប្រតិចារឹក*ត្រង់ៗតាមពាក្យពេចន៍* ជំនួសដោយការយកកំណត់ហេតុជាលាយលក្ខណ៍អក្សរមិនពេញលេញ[127] យោងលើទម្រង់នៃភស្តុតាងដែលត្រូវបាន

---

[127] *សូមមើលជាឧទាហរណ៍* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១១ (ជើងទំព័រ ៥៣១), កថាខណ្ឌ ១១៣ (ជើងទំព័រ ៥៤៨), ១២០ (ជើងទំព័រ ៥៨១), កថាខណ្ឌ ១២៦ (ជើងទំព័រ ៦២៧), កថាខណ្ឌ ១២៧ (ជើងទំព័រ ៦៣០, ៦៣១, ៦៣៤), ១៤៦ (ជើងទំព័រ ៧១៩, ៧២៦), កថាខណ្ឌ ១៤៧ (ជើងទំព័រ ៧៣១), កថាខណ្ឌ ១៩៤ (ជើងទំព័រ ៩៦១, ៩៦២, ៩៦៤), កថាខណ្ឌ ១៩៥ (ជើងទំព័រ ៩៧០, ៩៧២), កថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥), កថាខណ្ឌ ១៩៨ (ជើងទំព័រ ៩៨៧), កថាខណ្ឌ ១៩៩ (ជើងទំព័រ ៩៩៣) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/5**។ *សូមមើលប្រៀបធៀបជាមួយ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤៦ (ជើងទំព័រ ៧២៦), កថាខណ្ឌ ១៩៨ (ជើងទំព័រ ៩៨៧), កថាខណ្ឌ ១៩៩ (ជើងទំព័រ ៩៩៣, ៩៩៦), កថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៧), កថាខណ្ឌ ២០១ (ជើងទំព័រ ១០១៣, ១០២២), កថាខណ្ឌ ២១៤ (ជើងទំព័រ ១០៨៧) *ដោយយោងទៅលើ* ប្រតិចារឹកបទសម្ភាសន៍របស់ ទុំ សឿន ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/422.9**។ ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៣), កថាខណ្ឌ ៥៩ (ជើងទំព័រ ២២២), កថាខណ្ឌ ៩៩ (ជើងទំព័រ ៤៥៦, ៤៦០), កថាខណ្ឌ ១១៤ (ជើងទំព័រ ៥៥២) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ប៉ោ បណ្តែត ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D101/1.1**។ *សូមមើលប្រៀបធៀបជាមួយ* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៨៤ (ជើងទំព័រ ៣៥៦), កថាខណ្ឌ ១១៤ (ជើងទំព័រ ៥៥២), កថាខណ្ឌ ១២១ (ជើងទំព័រ ៥៩១), កថាខណ្ឌ ១៥០ (ជើងទំព័រ ៧៤៧), កថាខណ្ឌ ១៧៤ (ជើងទំព័រ ៨៧២), កថាខណ្ឌ ១៧៦ (ជើងទំព័រ ៨៨៧), កថាខណ្ឌ ២១២ (ជើងទំព័រ ១០៧២), កថាខណ្ឌ ២៣២ (ជើងទំព័រ ១១៨៥) *ដោយយោងទៅលើ* ប្រតិចារឹកបទសម្ភាសន៍របស់ ប៉ោ បណ្តែត, គ្មានកាលបរិច្ឆេទ ឯកសារ **D85/4.1.5**។ ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៩ (ជើងទំព័រ ៤៥៨), កថាខណ្ឌ ១១៤ (ជើងទំព័រ ៥៥២), កថាខណ្ឌ ១៤៦ (ជើងទំព័រ ៧១៩), កថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ **D43**។ *សូមមើលប្រៀបធៀបជាមួយ* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ២១៦ (ជើងទំព័រ ១០៩៩) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ថ្ងៃទី ២៩ ខែ កក្កដា ២០១១ ឯកសារ **D219/422.14**។ *សូមមើលផងដែរ* ញត្តិរបស់[អ្នកស្រី] អ៊ឹម ចែម ស្នើសុំសហចៅក្រមស៊ើបអង្កេត ឱ្យបន្តថត យកសំឡេង ឬរូបភាពនូវរាល់ការស្តាប់យកចម្លើយទាំងអស់ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ **D252** កថាខណ្ឌ ១៥-១៨, ២១, ២៤, ២៦-៣០ ។ ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសារណារបស់សហព្រះរាជអាជ្ញា

ទទួលស្គាល់ដោយតុលាការថាមិនអាចជឿជាក់បាន[128] សំអាងលើមតិយោបល់ដែលជាការឆ្លើយដាក់បន្ទុកលើខ្លួនឯង ខណៈដែលមានមតិយោបល់ដោះបន្ទុកស្ថិតក្នុងឯកសារស្តាប់ចម្លើយដូចគ្នា[129] ចាត់ទុកភស្តុតាងចចាមអារ៉ាមថាជាភស្តុតាងផ្ទាល់[130] មិនអើពើនឹងក្តីកង្វល់ជាក់ស្តែង និងភាពមិន

---

អន្តរជាតិលើបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ **D251/5/3** នៅកថាខណ្ឌ ១៥។

128 *សូមមើលជាឧទាហរណ៍* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ១៩៣ (ជើងទំព័រ ៩៥៦), នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥), នៅកថាខណ្ឌ ១៩៧ (ជើងទំព័រ ៩៨២) *ដោយយោងទៅលើ* អត្ថបទរបស់ D. Gillison *ភាពអយុត្តិធម៌វិសាមញ្ញ,* មូលនិធិស៊ើបអង្កេត ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ **A165.1.14**។ *ប៉ុន្តែសូមមើល សំណុំរឿងរបស់ អៀង ធីរិទ្ធ និងអ្នកផ្សេងទៀត,* ០០២/១៩-០៩-២០០៧/អវកត/កសចស (អបជ ៤២), សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំង នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យធ្វើកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារលេខ **D264/2/6** នៅកថាខណ្ឌ ៣៨ ["អង្គបុរេជំនុំជម្រះក៏បានសម្រេចលើបញ្ហាទាំងនេះរួចហើយក្នុងសេចក្តីសម្រេចពីមុន ដែលក្នុងនោះខ្លួនបានសម្រេចថាសេចក្តីថ្លែងការណ៍របស់បុគ្គលដែលសារព័ត៌មានបានដកស្រង់ មិនមែនជាភស្តុតាងអាចជឿជាក់បានទេ ហើយអង្គបុរេជំនុំជម្រះក៏បានបដិសេធបណ្តឹងមិនតិចដែលផ្អែកលើភ័ស្តុតាងបែបនេះដែរ"] *ដោយយោងទៅលើ* សាលដីកាលើបណ្តឹងមិនតិចរបស់ [លោក] ខៀវ សំផន ចំពោះ សហចៅក្រមស៊ើបអង្កេត[អន្តរជាតិ] Marcel Lemonde ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារលេខ 7 នៅកថាខណ្ឌ ៣០។

129 *សូមមើលជាឧទាហរណ៍* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/8 ឆ:**35 [ផ្នែកដំបូងនៃចម្លើយសាក្សីត្រង់ចំណុចដែលគាត់បាននិយាយថា៖ គាត់*មិនច្បាស់ទេ* គឺមិនត្រូវបានយោងឡើយ ប៉ុន្តែបានយោងជំនួសទៅវិញត្រង់ចុងឃ្លា ដែលសាក្សីសន្និដ្ឋាន ថា៖ គាត់អាចដឹងបានថា យាយ ចែម ជាមេរបស់ ទុំ សឿន ផ្អែកលើសំបុត្រដែលគាត់បានអាន]។ កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/567 ឆ:**131 ["យាយ ចែម ធំជាង"] តែមិនយោងតាម **ឆ:**129-30 [ដោយនិយាយថា សាក្សីមិនដឹងពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ឬពីទំនាក់ទំនងរវាងអ្នកស្រី និង ទុំ សឿននោះទេ]។

130 *សូមមើលជាឧទាហរណ៍* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153 ឆ:**20 ["ខ្ញុំ*ឮ*ពីអ្នកយាម និងអ្នកទោស នៅភ្នំទ្រយោង និយាយថាយាយ ចែម ជាមេរបស់តាសឿន ។" (បញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយ របស់សាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144 ឆ:**69 ["ខ្ញុំធ្លាប់*ឮ*ឈ្មោះ ភ្នំទ្រយោង។ ភ្នំ ទ្រយោងស្ថិតនៅក្រោមការគ្រប់គ្រងរបស់*យាយចែម*។" (បញ្ជាក់បន្ថែម)] ។ កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី មី គាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/256 ឆ:**25 ["ខ្ញុំដឹងថាយាយចែមជាអ្នកគ្រប់គ្រងគុកភ្នំត្រយ៉ូង ដោយផ្ទាល់ ព្រោះអ្នកបរទេះមួយចំនួនដែលដឹកស្បៀងពីស្រុកទៅគុក

ស៊ីសង្វាក់គ្នានៃភស្តុតាង[131] ឬបើមិនដូច្នេះទេ បោះបង់ចោលកាតព្វកិច្ចក្នុងការបង្ហាញទឡ្ហីករណ៍ដោយយកចិត្តទុកដាក់ និងជួយដល់ការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។

៣៦. ដូចនឹងបង្ហាញជូននៅខាងក្រោម[132] ដីកាសន្និដ្ឋានស្ថាពរបានបោះបង់ចោលនូវរាល់ចេតនាទាំងពួង

---

ភ្នំត្រយ៉ូងជាអ្នក*ប្រាប់ខ្ញុំអំពីរឿងនេះ*" (បញ្ជាក់បន្ថែម) ។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:59-62 [គាត់ថាគាត់*អត់ចាំ*អ្នកណាជាប្រធានគុកទេ ហើយ*ត្រូវបានប្រាប់*ថា [អ្នកស្រី] អ៊ឹម ចែម ជាអ្នកគ្រប់គ្រងនៅមន្ទីរ សន្តិសុខនៅភ្នំត្រយ៉ូង] ។

131 សហព្រះរាជអាជ្ញាអន្តរជាតិយោងទៅលើភាពមិនស៊ីសង្វាក់មួយចំនួន ដែលបានលើកឡើងដោយក្រុមការពារក្តីក្នុងញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំសហចៅក្រមស៊ើបអង្កេតបន្តថតយកសំឡេង ឬរូបភាព នូវរាល់ការស្តាប់យកចម្លើយទាំងអស់ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D252** ដែលទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយ និងការថតសំឡេង ។ *សូមមើលជាឧទាហរណ៍* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៤ (ជើងទំព័រ ៥៥២) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី អ៊ិល ភាព ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **D47**, EN ERN 00727243 នៅកថាខណ្ឌ ១២០ (ជើងទំព័រ ៥៨១)។ *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/5** ឆ:29។ នៅកថាខណ្ឌ ១២៦-២៧ (ជើងទំព័រលេខ: ៦២៧, ៦៣០, ៦៣១, ៦៣៤)។ នៅកថាខណ្ឌ ១៩៨ (ជើងទំព័រ ៩៨៧) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសា **D106/5** ឆ:28។ នៅកថាខណ្ឌ ១៤៦ (ជើងទំព័រ ៧១៩) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/4** ឆ:18។ នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **D43**, EN ERNs 00727233-34។ នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៧, ៩៨០, ៩៨១), នៅកថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៨) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/4**, ឆ:23។ នៅកថាខណ្ឌ ២០១៦ (ជើងទំព័រ ១០៩៩) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/4** ឆ:24។ *សូមមើលផងដែរ* ដីកាសម្រេចលើញត្តិរបស់ អ៊ឹម ចែម ស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបន្តថតយកសំឡេង ឬ រូបភាពនៃការស្តាប់ចម្លើយទាំងអស់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D252/1** នៅកថាខណ្ឌ ១០ ["ដោយសារ ខ្ញុំបានឆ្លើយតបទៅនឹងសំណើនីមួយៗនៃសំណើមេធាវីការពារក្តីហេតុនេះ ខ្ញុំមិនដោះស្រាយលើអង្គសេចក្តីនៃការចោទប្រកាន់អំពើកំហុសឆ្គងនៅក្នុងការអនុវត្តការស្តាប់ចម្លើយ និងភាពមិនស៊ីសង្វាក់គ្នា រវាងខ្សែអាត់ជាសំឡេង ឬ រូបភាព ជាមួយនឹងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរនៃការស្តាប់ចម្លើយដែលមេធាវីការពារក្តី បានលើកឡើងទេ ។ ខ្ញុំនឹងពិចារណាលើការចោទប្រកាន់នានារបស់មេធាវីការពាក្តី នៅពេលដែលវាយតម្លៃភ័ស្តុតាង"]។

132 *សូមមើល ជាទូទៅ* ចម្លើយតប នៅកថាខណ្ឌ ៦៦-២២៦។

សម្រាប់ការផ្តល់ព័ត៌មានឱ្យបានពេញលេញ និងដោយយុត្តិធម៌ចំពោះភស្តុតាងដែលមានក្នុងសំណុំរឿង០០៤/១ ក៏ដូចជាព័ត៌មានស្តីពីតួនាទីអ្នកស្រី អ៊ឹម ចែម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សហព្រះរាជអាជ្ញាអន្តរជាតិមិនត្រឹមតែមិនចូលរួមតស៊ូមតិឱ្យបានខ្លាំងក្លាប៉ុណ្ណោះទេ តែថែមទាំងរំលោភបំពានដល់កាតព្វកិច្ចចម្បងក្នុងនាមជាមន្ត្រីយុត្តិធម៌មួយរូប ដែលគប្បីរួមចំណែកដល់ការគ្រប់គ្រងវិស័យយុត្តិធម៌ដោយត្រឹមត្រូវ និងមិនមែនជាការព្យាយាមធ្វើយ៉ាងណាឱ្យតែមានការចោទប្រកាន់ ទោះស្ថិតក្នុងករណីណាក៏ដោយនោះទេ ។

## ឃ. សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវ លើបទដ្ឋានបង្ហាញភស្តុតាងដែលបានតម្រូវ ក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ

៣៧. អនុលោមតាមវិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងការចោទប្រកាន់ ក្នុងករណីគ្មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ។ ផ្ទុយទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[133] បទដ្ឋាននៃការបង្ហាញភស្តុតាងត្រូវបានកំណត់និយមន័យយ៉ាងត្រឹមត្រូវ និងជាក់ច្បាស់នៅ អ.វ.ត.ក ។

៣៨. នៅក្នុងសំណុំរឿង០០២ សហចៅក្រមស៊ើបអង្កេតបានកំណត់លក្ខខណ្ឌដើម្បីចោទប្រកាន់ ដែលត្រូវតែបំពេញនៅពេលភស្តុតាង "ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់" ដែលមាន "ភវនីយភាព" នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានជាធម្មតា) នៃជនត្រូវចោទ[134] ។ អ្នកស្រាវជ្រាវជនជាតិបារាំងចាត់ទុកថា "ភស្តុតាងគ្រប់គ្រាន់" តម្រូវឱ្យមានអត្ថិភាពនៃលក្ខណៈខ្លាំងក្លាគ្រប់គ្រាន់ដែលឈានដល់ *សច្ចធារណ៍យ៉ាងសំខាន់នៃពិរុទ្ធភាព* ជាជាងលទ្ធភាពដែលគ្រាន់តែអាចកើតមាន[135] ។ ការក្សាឱ្យ

---

133 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៥, ២៧។

134 ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ឯកសារ **D427** នៅកថាខណ្ឌ ១៣២៣។

135 *សូមមើល* Guéry C., 'Titre 21 La fin de l'information et sa réouverture', *Droit et Pratique de l'Instruction Préparatoire*, (Dalloz, ២០១៣) នៅកថាខណ្ឌ ២៣១.១២ [« Que faut-il entendre par charges suffisantes ? Il doit s'agir de charges suffisamment graves pour *entraîner une présomption « considérable » de culpabilité*, et non pas une simple possibilité. Elles doivent résulter d'éléments objectifs tirés de la

បានន្ទូវបទដ្ឋានកម្រិតខ្ពស់នៃការបង្ហាញភស្តុតាង គឺជាការចាំបាច់បំផុតនៅក្នុងសំណុំរឿងធំៗ ដែលជាសំណុំរឿងទាក់ទាញដល់ការដកស្រង់ព័ត៌មានសំខាន់ៗ ពីសំណាក់ប្រព័ន្ធសារព័ត៌មាននានា សាធារណជនទូទៅ និងសហគមន៍ជាតិ និងអន្តរជាតិ ដូយ៉ាងក្នុងសំណុំរឿងបច្ចុប្បន្ន ។ នៅក្នុងករណីអស់នេះ ការចោទប្រកាន់ណាមួយបង្កឱ្យមានផលវិបាកដែលមិនអាចជួសជុលបានទេ ទៅលើជនជាប់ចោទ ទោះបីជានៅទីបំផុតនៃនីតិវិធីមានលទ្ធផលយ៉ាងម៉េចក៏ដោយ[136] ។

---

procédure, de simples indices vagues et imprécis, de simples analogies ou coïncidences ne suffiraient pas. … Les charges s'apprécient par rapport à la personne mise en examen. Leur existence signifie qu'il y a *présomption sérieuse* que ce dernier est l'auteur des faits objets de la poursuite, dont les éléments constituent une infraction à la loi pénale. La juridiction d'instruction, qui constate l'existence de charges suffisantes, doit renvoyer devant la juridiction de jugement. (ឯកសារយោងត្រូវបានលុបចោល និងមានការបញ្ជាក់បន្ថែម)] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ៣** ដោយមានការបកប្រែក្រៅផ្លូវការ៖ "តើការចោទប្រកាន់គ្រប់គ្រាន់មានន័យដូចម្ដេច? ការចោទប្រកាន់ត្រូវតែមានស្ថានទម្ងន់គ្រប់គ្រាន់ដើម្បីទទួលបាន "សារៈសំខាន់" សម្រាប់សច្ចធារណ៍នៃពិរុទ្ធភាព ជាជាងការគ្រាន់តែគិតពីភាពអាចទៅរួច ។ វាត្រូវជាលទ្ធផលកើតចេញពី ធាតុផ្សំសត្យានុម័តទទួលបានមកពីកិច្ចដំណើរការនីតិវិធី ដែលការបង្ហាញភស្តុតាងត្រូវបានធ្វើឡើងដោយគ្មានភាពស្រពិចស្រពិល និងតម្រុយមិនត្រឹមត្រូវ ហើយបើគ្រាន់តែជាការយល់ឃើញស្រដៀងគ្នា ឬគ្រាន់តែជាហេតុការណ៍ចៃដន្យនោះ គឺវាមិនគ្រប់គ្រាន់ ឡើយ ។ … ការចោទប្រកាន់ទាំងនេះ ត្រូវបានវាយតម្លៃដោយទាក់ទងនឹងមុខងារជាជនត្រូវចោទ។ អត្ថិភាពរបស់ជនត្រូវចោទ មានន័យថា វាជាការចាំបាច់ក្នុងការសន្មតជាមុនថា ដំណាក់កាលក្រោយទៀត គាត់គឺជាជនប្រព្រឹត្តល្មើសនៃអង្គហេតុក្រោមការស៊ើបអង្កេតតាមផ្លូវច្បាប់ ដែលធាតុផ្សំទាំងនេះអាចនឹងបង្កើតបានជាបទល្មើសឧក្រិដ្ឋ ដូចដែលបានកំណត់។ ចៅក្រមស៊ើបអង្កេត ដែលបានរកឃើញការចោទប្រកាន់មានគ្រប់គ្រាន់ហើយ ត្រូវតែបញ្ជូនជនត្រូវចោទទៅសវនាការ"]។ *សូមមើលផងដែរ*, Locré J.G., *La législation civile, commerciale, et criminelle de la France* (Edition Treuttel et Würtz, Volume 25, 1827-1832), p. 566 [« Aussitôt [que la Cour] a reconnu sa compétence, elle examine s'il existe des *présomptions suffisantes contre le prévenu*. Ces présomptions sont-elles vagues ou légères, n'existe-t-il aucun moyen d'en acquérir de plus fortes, elle doit mettre le prévenu en liberté ; une rigueur plus longue ne serait pas seulement inutile, elle serait encore injuste à l'égard de la personne poursuivie, et alarmante pour la société entière. » (បញ្ជាក់បន្ថែម)] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១០** ដោយមានការបកប្រែក្រៅផ្លូវការ៖ "ក្នុងរយៈពេលឆាប់បំផុតនៅពេលដែល [តុលាការ] ទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួនហើយនោះ គេនឹងពិនិត្យពិច័យមើលថាតើមានមូលដ្ឋានដាក់លាក់គម្រូវឱ្យមានការសន្មតគ្រប់ គ្រាន់ដើម្បីប្រឆាំងនឹងជនជាប់ចោទដែរ ឬ ទេ។ តើការសន្មតទាំងនេះ នៅមានភាពស្រពិចស្រពិល ឬមិនបានគាំទ្រ ឬយ៉ាងណា ហើយតើអាចទៅរួចឬទេក្នុងការទទួលបានការសន្មតកាន់តែខ្លាំងថែមទៀត ប្រការនេះ ជនជាប់ចោទត្រូវតែបានដោះលែង ដោយ សារថា ភាពតឹងតែងយូរអង្វែងមិនត្រឹមតែគ្មានប្រយោជន៍នោះទេ វាថែមទាំងមិនមានភាពយុត្តិធម៌ចំពោះបុគ្គលដែលកំពុងតែ ចោទប្រកាន់ និងធ្វើឱ្យសង្គមទាំងមូលរងការភ្ញាក់ផ្អើល"]។

[136] *សូមមើល* ទាក់ទងនឹងនេះ Helie F., *Traité de l'Instruction Criminelle* (Henri Plon, Tome 5, 1867) កថាខណ្ឌ ២០៧៧ [« ce serait infliger à un individu la flétrissure d'une mise en accusation inutile, et dont

៣៩. លក្ខណៈវិនិច្ឆ័យនៅ អ.វ.ត.ក មានកម្រិតខ្ពស់ជាងលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅសាលាក្តីផ្សេងៗដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកជាសំអាង[137] ពោលគឺស្តីពី "ភស្តុតាងគ្រប់គ្រាន់

l'acquittement ne peut pas toujours effacer les traces. »] »] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១១** ជាមួយនឹងការបកប្រែក្រៅផ្លូវការ៖ "វានឹងបង្កឱ្យមានការខូចខាតដល់ស្ថានភាពបុគ្គលឯកជនតាមរយៈពាក្យពេចន៍នៃការចោទប្រកាន់ដែលធ្វើឡើងឥតប្រយោជន៍ ហើយតាមរយៈនេះ ការលើកលែងការចោទប្រកាន់អាចនឹងមិនលុបបាត់នូវស្លាកស្នាមទាំងអស់នោះឡើយគ្រប់ពេលវេលានោះទេ"]។

137 អង្គបុរេជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានពិភាក្សាពីបទដ្ឋាននៃភស្តុតាងនៃពាក្យ, ក្នុងចំណោមពាក្យផ្សេងទៀត "ពិត" ផ្ទុយពីការ "ស្រមើស្រមៃ"។ *សូមមើល, រដ្ឋអាជ្ញា ទល់នឹង Jean-Pierre Bemba Gombo* (ICC-01/05-01/08), អបជ II, សាលដីកាធ្វើឡើងដោយអនុលោមតាម មាត្រា ៦១(៧)(ក) និង(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់ការចោទប្រកាន់រដ្ឋអាជ្ញា ប្រឆាំងទៅនឹង Jean-Pierre Bemba Gombo ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ នៅកថាខណ្ឌ ២៩ ["យោងតាមវចនានុក្រម Oxford ពាក្យ "មានខ្លឹមសារជាអាជ ឬភាពធំដុំ" អាចយល់បានថា "សំខាន់" "រឹងមាំ" "វត្ថុធាតុដើម", 'បង្កើតឡើងដោយ មានមូលដ្ឋានរឹងមាំ" "ពិត" ជាជាង "ការស្រមើស្រមៃ""] ។ (លុបចោលជើងទំព័រ) [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១២**]។ ដូច្នេះ បទដ្ឋាននៃភស្តុតាងក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដែលផ្តល់ដោយមាត្រា ៦១(៥) នៃលក្ខន្តិកៈទីក្រុងរ៉ូម គ្រាន់តែ តម្រូវឱ្យមានការរំពឹងទុកចំពោះសំណុំរឿងរបស់រដ្ឋអាជ្ញាក្នុងការឆ្លងកាត់លក្ខខណ្ឌនៃភាពមិនពិតប្រាកដទៅជាភាពប្រត្យក្ស។ ខុសពីបទដ្ឋានលក្ខន្តិកៈនៃភស្តុតាងនៅចំពោះមុខ អ.វ.ត.ក, វាមិនតម្រូវឱ្យមានការពិចារណាបន្ថែមឡើងវិញ ពីការបង្កើតពិរុទ្ធភាពនៃជនជាប់ចោទដែលអាចឈានទៅដល់កម្រិត*សក្តានុពល* ឬយ៉ាងណានោះទេ ។ ដោយពឹងផ្អែកលើបទប្បញ្ញត្តិនៃ MICT, តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាក៏មិន បានជួយអ្វីកើតដែរ ដោយតុលាការជម្រះក្តីទាំងនេះផ្តល់បទដ្ឋាននៃភស្តុតាងទាបជាងអ្វីដែលចែងក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ អង្គជំនុះជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិយល់ឃើញថា នៅពេលប្រៀបធៀបលក្ខន្តិកៈទីក្រុងរ៉ូម ជាមួយនឹងលក្ខន្តិកៈនៃភ័ស្តុតាង និងនិតិវិធីក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាកការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។ ម៉្យាងវិញទៀត វាមានការចំបាច់ក្នុងការពិនិត្យលើមាត្រា ៦១(៥) នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលចែងពីលក្ខខណ្ឌភ័ស្តុតាងខ្ពស់ជាង ថាជាការមាន "មូលដ្ឋានយ៉ាងសំខាន់" នៅពេលធៀបនឹងលក្ខខណ្ឌក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី
និងតុលាកការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ចំពោះលក្ខខណ្ឌ "មូលដ្ឋានសមរម្យ" ។ *សូមមើល* សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Callixte Mbarushimana* (ICC-01/04-01/10 OA4) *តុលាការឧទ្ធរណ៍,* សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ព្រះរាជអាជ្ញាជំទាស់ទៅនឹងសាលដីកាអង្គបុរេជំនុំជម្រះ I នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១១ ក្រោមឈ្មោះ "សាលដីកាពីការទទួលស្គាល់នៃការចោទប្រកាន់" ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៤៣ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៣**]។

ដើម្បីបង្ហាញពីមូលដ្ឋានសំខាន់ៗ" នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ[138] ភស្តុតាងគ្រប់គ្រាន់សម្រាប់មូលដ្ឋានសមហេតុផល" នៅក្នុងវិធាននៃនីតិវិធី និងភស្តុតាងនៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ[139] និង "ករណីដែលអាចជឿជាក់បាន *ជាបឋម*" ដូចមានចែងក្នុងលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវាន់ដា[140] ។

៤០. បើទោះបីជាអាចស្វែងរកការណែនាំពីយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាក៏ដោយ ក៏ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបន្ទាបបទដ្ឋានបង្ហាញភស្តុតាង តាមរយៈការយោងទៅលើបទដ្ឋានផ្សេងៗនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវាន់ដានោះ[141] គឺសុទ្ធតែមានការពាក់ព័ន្ធតិចតួច ឬគ្មានពាក់ព័ន្ធទៅនឹង អ.វ.ត.ក ឬសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ឡើយ ។

---

138 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ២៨ *ដោយយោងទៅលើ* មាត្រា ៦១ (៥) នៃលក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, អនុម័តថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨។

139 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ២៩ (ជើងទំព័រ ៧៧) *ដោយយោងទៅលើ* វិធានស្តីពីនីតិវិធី និងយន្តការភស្តុតាងសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, (វិសោធនកម្មលើកទី ២), អនុម័តថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១២ (កែសម្រួលនៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៦), វិធាន ៤៨(ខ)។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី, (វិសោធនកម្មលើកទី ៥០), អនុម័តថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ (កែសម្រួលនៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៥), វិធាន ៤៧ (ខ)។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវាន់ដា, អនុម័តថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ (វិសោធនកម្មនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៥, វិធាន ៤៧ (ខ)។

140 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៣០ (ជើងទំព័រ ៧៩) *ដោយយោងទៅលើ* ការធ្វើបច្ចុប្បន្នភាពនៃលក្ខន្តិកៈសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ (វិសោធនកម្មនៅថ្ងៃទី ៧ កក្កដា ឆ្នាំ ២០០៩), មាត្រា ១៩(១)។ ការធ្វើបច្ចុប្បន្នភាពនៃលក្ខន្តិកៈសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវា ន់ដា ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ (វិសោធនកម្មនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៥), មាត្រា ១៨ (១)។

141 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៨-៣០។

៤១. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានផ្តល់ពីហេតុផលអ្វីសោះ ទោះសម ឬមិនសមទំនងក្តី ចំពោះការងាកចេញពីការប្រើប្រាស់លក្ខណៈវិនិច្ឆ័យដ៏សំខាន់របស់ អ.វ.ត.ក ឬក៏ផ្តល់នូវហេតុផលអ្វីមួយ ដែលបណ្តាលឱ្យមានការបដិសេធប្រើនូវលក្ខណៈពិសេសដោយឡែករបស់ អ.វ.ត.ក[142] ។ ការធ្វើដូចនេះ គឺជាការធ្វើឱ្យមានភាពស្មុគស្មាញយ៉ាងខ្លាំងនៅពេលជំរុញឱ្យមានការប្រើប្រាស់បទដ្ឋានពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ដែលយកច្បាប់កុំមិនឡជាមូលដ្ឋាន[143] ។

**ខ. សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវពីតួនាទីរបស់ជនរងគ្រោះ នៅ អ.វ.ត.ក**

៤២. សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា *ពាក្យសុំតាំងខ្លួន*ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨៧ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ថាមានភាពពាក់ព័ន្ធនឹងសំណុំរឿង០០៤/១[144] ជាពិសេស បានធ្វើការប្រៀបធៀបចំនួននេះ ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៩ នាក់ ដែលត្រូវបានទទួលយកក្នុងការជំនុំជម្រះក្នុងសំណុំរឿង០០២[145] ដោយចង្អុលបង្ហាញថា មានការ "បង្ហាញឱ្យឃើញពីចំណាប់អារម្មណ៍ដ៏ខ្លាំងរបស់ជនរងគ្រោះក្នុងការចោទប្រកាន់ [អ្នកស្រី] អ៊ឹម

---

142 *សូមមើល សំណុំរឿង មាស មុត* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អវកត/កសចស, ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **D297.1** ("ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពី យុត្តាធិការបុគ្គល ឯកសារ **D297.1**") នៅកថាខណ្ឌ ៣៧។ នៅក្នុងសេចក្តីលម្អិតរបស់ អ.វ.ត.ក ទាក់ទងទៅនឹងបទដ្ឋានបង្ហាញភស្តុតាង៖ *សូមមើល* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ឯកសារ **D427** នៅកថាខណ្ឌ ១៣២៣។

143 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៨-៣០។

143 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៨-៣០។

144 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៣ *ដោយយោងទៅលើ* ដីកាសន្និដ្ឋានស្ថាពរ, ឧបសម្ព័ន្ធ ៧។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៣។

145 *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/អជសដ, សាលក្រមថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** ("សាលក្រមនៃសំណុំរឿង ០០២/០១ ឯកសារ **E313**") នៅកថាខណ្ឌ ១១១១។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៣ (ជើងទំព័រ ២៣៥១) *ដោយយោងទៅលើ* សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ **D427** នៅកថាខណ្ឌ ៣២២, ៣៦៨, ៣៨២, ៣៩៩, ៤៨៨, ៥៨៨។

ថែម[146] ។ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងការបង្ហាញពីផលប្រយោជន៍សាធារណៈ គឺផ្អែកលើការសន្មតដែលមានបញ្ហាមួយចំនួន និងការបកស្រាយមិនសមហេតុសមផល ។ តាមពិត ទោះបីជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*ពាក់ព័ន្ធទាំងអស់* ត្រូវបានទទួលយកទៅការជំនុំជម្រះក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ក៏ដោយ ក៏ការប្រៀបធៀបពីតួលេខនៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ និងសំណុំរឿង០០៤/១ គឺជាការបង្ហាញពីផលប្រយោជន៍ក្នុងកម្រិតទាបមួយនៅក្នុងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ។

៤៣. ទីមួយ គេចាំបាច់ត្រូវកត់សម្គាល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនដូចគ្នាទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ ចំនួននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនគួរមានការភ័ន្តច្រឡំគ្នានឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ មានន័យថា ពួកគេ គឺជាអ្នកដាក់ពាក្យសុំ ដែលបានបំពេញនូវលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបានដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត សម្រាប់ឱ្យពួកគេចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ អនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ។ នៅក្នុងចំណោមលក្ខខណ្ឌដើម្បីបំពេញលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលបាន គឺលុះត្រាណាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវបង្ហាញថា ពួកគាត់បានទទួលរងនូវព្យសនកម្មខាងរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្តដែលជាលទ្ធផលដោយផ្ទាល់ពីឧក្រិដ្ឋកម្ម យ៉ាងហោចណាស់ពីឧក្រិដ្ឋកម្មមួយនៃឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ[147] ។ នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានសម្រេចទទួលយកបាននៅពេលណា "អង្គហេតុដែលបានអះអាងដើម្បីគាំទ្រដល់ពាក្យសុំនោះថា អាចជាការពិតជាមុនសិន"[148] ។

---

146 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៣។

147 *សូមមើល* វិធានផ្ទៃក្នុង, វិធាន ២៣*ស្ទួន* (១)(ខ) នៃវិធានផ្ទៃក្នុង។

148 *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អបជ៧៦, អបជ១១២, អបជ១១៣, អបជ១១៤, អបជ១១៥, អបជ១៤២, អបជ១៦៤, អបជ១៦៥ និងអបជ១៧២),

៤៤. ការយោងទៅលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង គឺសំដៅទៅដល់ឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ[149] ។ អាស្រ័យហេតុនេះ ការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបាន ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវកម្រិតត្រឹមវិសាលភាពនៃដីកាដំណោះស្រាយ ដែលនឹងត្រូវបានរឹតត្បិតត្រឹមបទចោទនូវទំហំឧក្រិដ្ឋកម្ម កត្តាពេលវេលា និងកត្តាភូមិសាស្ត្រ ដែលបានបង្ហាញនៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់[150] ។ ប្រសិនបើសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ត្រូវបានបញ្ជូនទៅជំនុំជម្រះ នោះនឹងមានតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានបំពេញនូវលក្ខខណ្ឌតម្រូវទាំងអស់នៃវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ដោយរួមទាំងការបង្ហាញពីព្យសនកម្មដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ពោលគឺឧក្រិដ្ឋកម្មមួយនៃឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង ឬការដ្ឋានស្ពានស្រែង ពីអំឡុងខែ មេសា ឆ្នាំ ១៩៧៧ ដល់ចុងបញ្ចប់នៃរបបនេះ (ដូចបានកំណត់នៅក្នុងការជូនដំណឹងពីបទចោទប្រកាន់) អាចនឹងត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ។

---

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D411/3/6** នៅកថាខណ្ឌ ៩៤។

[149] *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អបជ ៧៦, អបជ ១១២, អបជ ១១៣, អបជ ១១៤, អបជ ១១៥, អបជ ១៤២, អបជ ១៦៤, អបជ ១៦៥ និង អបជ ១៧២), សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D411/3/6** នៅកថាខណ្ឌ ៨១ ["អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលដូចគ្នាចំពោះឧក្រិដ្ឋកម្មនៅក្នុងបរិបទនៃដីកាដំណោះស្រាយ"]។ *សូមមើលផងដែរ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស, សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត **D250/3/3** ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និង ដីកាសម្រេចលេខ **D250/3/2**, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារ **D250/3/2/1/5** នៅកថាខណ្ឌ ៥១។

[150] *សូមប្រៀបធៀបជាមួយ* ចម្លើយតប នៅកថាខណ្ឌ ២០-២៥។

៤៥. ការពិនិត្យបញ្ជីដែលមានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ[151] បង្ហាញឱ្យឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋវេណីចំនួន ២៨៧ មានតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៨៣ ប៉ុណ្ណោះដែលបានរៀបរាប់ថា ព្យសនកម្មដែលខ្លួនទទួលរងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង ឬនៅការដ្ឋានស្ពានស្រែង ស្ថិតក្នុងពេលវេលាត្រឹមត្រូវ[152] ។ និយាយម្យ៉ាងទៀត ការគណនារបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបាន

---

[151] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ, ឧបសម្ព័ន ៧។

[152] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អោម ចាន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1331**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុក បួយ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1500**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុន ហឿន ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1111**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុត សមឿត ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/859**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចង់ សារ៉ូ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/908**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចេក ភីវ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/931**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈឿម ឈួរ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D5/1508**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈូ រុន ថ្ងៃទី ១០ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1071**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆយ គីម ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1629**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆើយ គត់ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/926**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈន់ ឈឿន ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣, **D5/1105**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [កោសលុប] ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1247**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈុត ង៉ឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1085**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈុត សារឿត ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/899**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈិន អួន ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1515**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជុំ ជីម ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1015**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជួន ចាន់រឿម ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/953**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ដន ឈិញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D5/1014**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ដន តំ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/964**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ដែង យើត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1073**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឌិប ផល្លា ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1065**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហួយ សារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១០ ឯកសារ **D5/1200**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហ៊ុក សារឿន ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/974**។ ពាក្យសុំតាំងខ្លួនជា

ដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហុន សៀងហៃ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **D5/1262**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ុន អ៊ីស ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1028**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឃៀន ចន្ត្រា ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1076**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឃ្លោត សាមឿត ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/918**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [កោសលុប] ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1246**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គាំ បុប្ផា ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1045**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កន ចែង ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/973**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គង់ អារ៉ែន ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/851**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឡាត យ៉ង់ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **D5/1380**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឡុត សាមិច ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D5/1632**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឡី ស៊ាន ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/982**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ លិវ ពៅ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D5/888**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ម៉ក់ ថូវ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1074**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ម៉ន បាន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/880**។ ពាក្យសុំតាំងខ្លួនជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ម៉ាត់ ឆឹយ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1251**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ មាក គក់ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1068**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ មាន លឿយ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **D5/1206**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ មឹះ ភួត ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/898**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ម៉ូះ អ៊ិត ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1093**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ញ៉ឹក សារ៉ែន ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D5/900**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ញ៉ឹក បទ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1108**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នឿ ម៉ុច ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/1185**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នូ ខាំ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/903**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អោម ហឿង ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1090**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អោម ម៉ក ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1202**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ុក ណារី ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D5/1078** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ មឿ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D5/994** [នៅឆ្នាំ ១៩៧៧, អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការនៅប្រឡាយស្ពានស្រែងអស់រយៈពេលមួយឆ្នាំ]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ពៃ សាម ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1101**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ព្រាប ហ៊ិន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/872** [បងប្អូនដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានសម្លាប់នៅភ្នំទ្រយោង និងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបញ្ជូនទៅជីកប្រឡាយស្ពានស្រែង]។ ពាក្យសុំ

---

តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊្លិញ មិត ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **D5/999**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ផុន ផ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/937**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ភួង ផៃ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D5/998**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប្រាំង សរៀម ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/867**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប្រាក់ ការ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **D5/1000**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រិន ខេង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/988** [ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានឃុំខ្លួននៅភ្នំទ្រយោង]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រស់ ធុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/928**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រួម សារ៉េត ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/938**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រស់ បុន ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/922**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រស់ អឿត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/935**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាំង ឈួត ថ្ងៃទី ១០ ឧសភា ២០១៣ ឯកសារ **D5/958**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សម ស័ក្ត ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/76**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៅ ហាក់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០០៨ ឯកសារ **D5/1044**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សោម ថូ ថ្ងៃទី ២១ មិថុនា ឆ្នាំ ២០០៩ ឯកសារ **D5/1199**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុខ មួយ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/967**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុំ ឈឿន ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/930**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សោម ធឿម ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/1204**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ិន សប ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/979**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តាំង ផាត ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1226**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តត ចំប៉ី ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1329**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ធឹក ម៉ុន ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/939**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ថួន ធី ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1024** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ថុង ឈាត ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D5/1463**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ទូន សារឿន ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1059**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ទូន ឆួន ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1332**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ុន ឆុំ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1499**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វ៉ាន់ សុផល ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1109**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វិញ សឿ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1193**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វិញ តឿ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D5/1370**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វុន សារ៉ោន ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1017**។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យូ សាមៀន ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/1016**។

បង្កើនរហូតដល់ទៅជាងបីដង នៅពេលប្រៀបធៀបជាមួយនឹងតួលេខដែលត្រូវបានយល់ថាមានការពាក់ព័ន្ធនឹងការគណនាពី "ផលប្រយោជន៍"[153] ក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ប្រសិនបើសំណុំរឿងនេះត្រូវបានបញ្ជូនទៅជំនុំជម្រះ ។

៤៦. ទីពីរ ប្រសិនបើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទាំងអស់ដែលបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/១ ត្រូវបានទទួលយកសម្រាប់ការជំនុំជម្រះនោះ ចំនួននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម នឹងមិនគ្រប់គ្រាន់ដើម្បីបង្ហាញពីផលប្រយោជន៍សាធារណៈយ៉ាងច្រើន ដើម្បីចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ឡើយ "ជាពិសេស នៅពេលប្រៀបធៀបជាមួយនឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២" ។ ចំណុចជាក់លាក់គឺថា នៅក្នុងការប្រៀបធៀបជាមួយនឹងសំណុំរឿង ០០២ ប្រសិនបើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ៨៣ ដែលបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតអាចបំពេញនូវលក្ខខណ្ឌទាំងអស់នៃវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ហើយត្រូវបានទទួលយកសម្រាប់ការជំនុំជម្រះនោះ ចំនួននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/១ នឹងមានចំនួនតែ ២% ប៉ុណ្ណោះ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៩ នាក់ ដែលបានទទួលស្គាល់ក្នុងសំណុំរឿង ០០២[154] ។

៤៧. និយាយម្យ៉ាងទៀត នៅពេលទស្សនទានសំខាន់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលាតត្រដាង ហើយការប្រៀបធៀបដោយយុត្តិធម៌មួយត្រូវបានធ្វើឡើងនោះ ផលប្រយោជន៍សាធារណៈក្នុងសំណុំរឿង ០០៤/១ មានកម្រិតទាបជាងយ៉ាងលើសលុប បើធៀបនឹងផលប្រយោជន៍សាធារណៈក្នុងសំណុំរឿង ០០២ ។

---

153 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៣។

154 សាលក្រមសាលាដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ **E313** នៅកថាខណ្ឌ ១១១១។

## V. ចម្លើយតប

### ក. ការពិចារណាលើយុត្តាធិការបុគ្គល

៤៨. សហចៅក្រមស៊ើបអង្កេតមានភារកិច្ចធានាថា អ.វ.ត.ក មានយុត្តាធិការបុគ្គល *ពោលគឺ* ធានាថា ជនត្រូវចោទស្ថិតនៅក្នុងប្រភេទមួយ ក្នុងចំណោមប្រភេទទាំងពីរនៃបុគ្គលដែលអាចត្រូវបានចោទប្រកាន់ ។ អនុលោមតាមក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក *មានតែ* "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ដែលអាចនាំមកជំនុំជម្រះ[155] ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ជនត្រូវចោទពុំស្ថិតនៅក្នុងប្រភេទបុគ្គលណាមួយទេនោះ សហចៅក្រមស៊ើបអង្កេតត្រូវតែលើកលែងការចោទប្រកាន់លើបទចោទទាំងអស់ ។

៤៩. សហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា អ្នកស្រី អ៊ឹម ចែម មិនស្ថិតនៅក្នុងប្រភេទ ជា "មេដឹកនាំជាន់ខ្ពស់" [156] ទេ ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតគួរចោទប្រកាន់អ្នកស្រីដោយផ្អែកលើមូលដ្ឋានដែលថា អ្នកស្រីជាជនម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" លើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[157] ។ អាស្រ័យហេតុនេះ ក្រុមការពារក្តីនឹងលើកឡើងតែអំពីប្រភេទបុគ្គលទីពីរតែប៉ុណ្ណោះ នៅក្នុងចម្លើយតបនេះ ។ ដូចនឹងត្រូវពិភាក្សាខាងក្រោម ការពិនិត្យមើលឡើងវិញលើប្រវត្តិនៃការចរចាដែលនាំឱ្យបង្កើតបានជាប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់

---

155 កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២00៣ ('កិច្ចព្រមព្រៀង') ផ្នែកបុព្វកថា មាត្រា១ មាត្រា៥(៣) និងមាត្រា៦(៣)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៤ ('ច្បាប់ អ.វ.ត.ក') មាត្រា១ និងមាត្រា២ ថ្មី។ វិធានផ្ទៃក្នុង ផ្នែកបុព្វកថា។

156 *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២៩ និងមាត្រា៥៣៦។ *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៨។

157 *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣0-៣៨។

បំផុត” នៅ អ.វ.ត.ក បង្ហាញថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងចំណោម “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានសន្និដ្ឋានលើកំហុស អង្គច្បាប់ធ្ងន់ធ្ងរចំនួនពីរ ពាក់ព័ន្ធនឹងលក្ខណៈ និងការអនុវត្តនៃការកំណត់លក្ខខណ្ឌសាកល្បង ។

៥០. ទីមួយ ដូចបានកត់សម្គាល់ខាងលើ[158] ក្រុមការពារក្តីយល់ឃើញថា វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិបានផ្អែកលើកំហុសអង្គច្បាប់ ពោលគឺ ការវាយតម្លៃនេះ អាចត្រូវបានធ្វើឡើងដោយប្រើប្រាស់ភស្តុតាងដែលស្ថិតនៅក្រៅដែនកំណត់ដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ឡើយ ។ ការពិនិត្យមើលលើកត្តាប្រវត្តិសាស្ត្រ និងដំណើរវិវឌ្ឍន៍ទៅផ្នែកយុត្តិសាស្ត្រនៃលក្ខណៈវិនិច្ឆ័យស្តីពី “ការទទួលខុសត្រូវខ្ពស់បំផុត” រិតតែបានបង្ហាញបន្ថែមអំពីកំហុសអង្គច្បាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានពិចារណាថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងចំណោមប្រភេទ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ផ្អែកតាមបទដ្ឋាននៃភស្តុតាងជាធរមានឬយ៉ាងណា ពោលគឺ ថាតើភស្តុតាង “មានលក្ខណៈខ្លាំងក្លាគ្រប់គ្រាន់ និងស៊ីសង្វាក់អាចផ្តល់តម្លៃភស្តុតាងក្នុងកម្រិតជាក់លាក់មួយដែរឬទេ” ចំពោះទង្វើពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ។ កំហុសអង្គច្បាប់ទាំងនេះ នឹងត្រូវពិភាក្សានៅផ្នែកខាងក្រោម ។

### ១. ប្រវត្តិចរចាដែលនាំឱ្យឈានដល់ការកំណត់និយមន័យនៃប្រភេទ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” នៅ អ.វ.ត.ក

៥១. យោងតាមការពិនិត្យមើលឡើងវិញលើប្រវត្តិពាក់ព័ន្ធនឹងការកំណត់និយមន័យនៃប្រភេទ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”[159] បានបង្ហាញថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មាន

---

158 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧-១៨។

159 *សូមមើល សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស, សេចក្តីជូនដំណឹងអំពីការដាក់ទៅក្នុងសំណុំរឿងនូវកំណត់ហេតុដែលមានស្រាប់ពាក់ព័ន្ធនឹងការបង្កើត អ.វ.ត.ក ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ **ឯកសារ D324** និងឧបសម្ព័ន្ធពាក់ព័ន្ធ។

លក្ខណៈចង្អៀត ហើយពុំមានបំណងដាក់បញ្ចូលជនទាំងឡាយ ឬក្សរួមទាំងអ្នកស្រី អ៊ឹម ចែម ទៅក្នុងប្រភេទជនទទួលខុសត្រូវខ្ពស់បំផុតឡើយ ។

៥២. នៅមុនពេលមានការផ្តួចផ្តើមការចរចានាំឱ្យឈានដល់ការបង្កើត អ.វ.ត.ក ក្រុមអ្នកជំនាញ (ដែលត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ បានពិនិត្យមើលជម្រើសនានា ដើម្បីនាំជនដែលដល់ខ្មែរក្រហមមកជំនុំជម្រះ[160]) កត់សម្គាល់ថា ការចោទប្រកាន់ពុំគួរផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែគួររួមបញ្ចូលជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ផងដែរ[161] ។ ក្រោយមក ការពណ៌នានេះត្រូវបានទទួលយក ហើយត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ[162] ។

៥៣. ក្រុមអ្នកជំនាញបានបញ្ជាក់ថា ជនទាំងឡាយដែលស្ថិតនៅក្នុងប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាជនដែលទាំងឡាយ *ដែលស្ថិតនៅថ្នាក់ទាបជាង* រួមមាន *មេដឹកនាំភូមិភាគ និងកម្មាភិបាលនៃមន្ទីរនានាទទួលបន្ទុកផ្នែកធ្វើទារុណកម្ម និងសួរចម្លើយ ដូចជា កម្មាភិបាលនៃ [គុក]ទួលស្លែង* ដែលត្រូវបាន *ឆ្លើយដាក់ដោយផ្ទាល់ ពីការប្រព្រឹត្តអំពើឃោរឃៅធ្ងន់ធ្ងរ* ប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[163] ។ ដូចបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាន

---

160 សេចក្តីសម្រេចដែលបានអនុម័តដោយមហាសន្និបាតស្តីពីស្ថានភាពនៃសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ឯកសារ អ.ស.ប A/RES/52/135 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧ កថាខណ្ឌ ១៦ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៤**]។

161 *សូមមើល សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ 00៤/0៧-0៩-២00៩-អវតក/កសចស, របាយការណ៍របស់ក្រុម អ្នកជំនាញទទួលបន្ទុកប្រទេសកម្ពុជាដែលបានបង្កើតឡើង អនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ១៥/១៣៥ ឯកសារ អ.ស.ប A/53/850-S/1999/231 ចុះថ្ងៃ ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ [នៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងលិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ១៩៩៩ ដែលអគ្គលេខាធិការផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ១៩៩៩ **ឯកសារ D324.15**] នៅកថាខណ្ឌ ១១0។

162 កិច្ចព្រមព្រៀង ផ្នែក: បុព្វកថា មាត្រា ១ មាត្រា៥(៣) និងមាត្រា៦(៣)។ ច្បាប់ អ.វ.ត.ក មាត្រា ១ និងមាត្រា២ ថ្មី។ វិធានផ្ទៃក្នុង ផ្នែក: បុព្វកថា។

163 *សូមមើល សំណុំរឿង អោ អាន និងអ្នកផ្សេងទៀត* សំណុំរឿងលេខ 00៤/0៧-0៩-២00៩-អវតក/កសចស, របាយការណ៍របស់ក្រុមអ្នកជំនាញទទួលបន្ទុកប្រទេសកម្ពុជាដែលបានបង្កើតឡើង អនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ១៥/១៣៥ ឯកសារ អ.ស.ប *A/53/850-S/1999/231* ចុះថ្ងៃ ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

របស់ក្រុមការពារក្ដីស្ដីពីយុត្តាធិការបុគ្គល[164] គឺថា កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ("ឌុច") ត្រូវបានប្រើប្រាស់ជា "ចំណុចយោងជាប់ជានិច្ច"[165] នៅក្នុងការកំណត់ប្រភេទ "ជនទាំងឡាយទទួលខុសត្រូវខ្ពស់បំផុត" ដែលក្រោយមកអាចក្លាយជា អ.វ.ត.ក ។ អ្នកចរចាបានព្យាយាម "ធ្វើយ៉ាងណាឱ្យបុគ្គលទាំងឡាយដូច ឌុច ដែលអាចជាជនមិនស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកទទួលខុសត្រូវលើការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅក្នុងទ្រង់ទ្រាយធំ" អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេត និងចោទប្រកាន់នៅ អ.វ.ត.ក[166] ។

## ២. ការវាយតម្លៃថាតើជនសង្ស័យស្ថិតនៅក្នុងប្រភេទជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា

៥៤. ដើម្បីអាចឱ្យរឿងក្ដីមួយដំណើរការទៅជំនុំជម្រះបាន សហចៅក្រមស៊ើបអង្កេតត្រូវតែជឿជាក់នៅពេលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[167] ថា ក្រោយពីពិចារណាលើលក្ខណៈវិនិច្ឆ័យ*រួមគ្នា*ចំនួនពីរ ("ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់

---

[នៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងលិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ដែលអគ្គលេខាធិការធ្វើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩ **ឯកសារ D324.15**] នៅកថាខណ្ឌ ១០៩-១១០។

[164] សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីស្ដីពីយុត្តាធិការបុគ្គល **ឯកសារ D251/4** នៅកថាខណ្ឌ ១៥-១៨ (យោងទាំងស្រុង)។

[165] Scheffer D., "The Negotiating History of the ECCC's personal Jurisdiction" អង្គការតាមដានសាលាក្ដីនៅកម្ពុជាចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១, ត្រង់ទំព័រ ៤ [ត្រូវបានដាក់ភ្ជាប់ជា **ឯកសារសំអាងទី ១៥**]។

[166] Scheffer D., "The Negotiating History of the ECCC's personal Jurisdiction" អង្គការតាមដានសាលាក្ដីនៅកម្ពុជាចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១១, ត្រង់ទំព័រ ៤ [ត្រូវបានភ្ជាប់ជា **ឯកសារសំអាងទី ១៥**]។

[167] សេចក្ដីសម្រេចរួមលើយុត្តាធិការបុគ្គល **ឯកសារ D297.1** នៅកថាខណ្ឌ ២៩-៣០ និងកថាខណ្ឌ ៣២។ *សូមមើលផងដែរ សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក, សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ **F28** នៅកថាខណ្ឌ ៦២ ["ការកំណត់ថាតើជនជាប់ចោទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណាតម្រូវឱ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន...។ ផ្ទុយទៅវិញ ទាំងជនសង្ស័យ និង អ.វ.ត.ក មិនអាចបង្ហាញថាតើជនសង្ស័យគឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬក៏មិនមែនដោយអនុលោមតាមទៅតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់អរូបី និងមានស្វ័យភាពបានឡើយ"]។

ចោទ”[168]) ដែលត្រូវបានបង្កើតឡើងនៅតាមបណ្តាតុលាការអន្តរជាតិនានា[169] និងដែលត្រូវបានអនុម័តនៅ អ.វ.ត.ក[170] ក្នុងករណីជនសង្ស័យស្ថិតនៅក្នុងប្រភេទជន “ដែលទទួលខុសត្រូវខ្ពស់បំផុត” ។ ដូចបានបង្ហាញត្រង់ៗតាមការយល់ទៅតាមពាក្យពេចន៍ និងទៅតាមគោលបំណងនៃ

---

168 សាលក្រមលើសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២២ ( លុបចោលលេខយោងជើងទំព័រ) ។

169 *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Milan Lukić* *និង* *Sredoje Lukić* (IT-98-32/1-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចបង្វិលរឿងក្តីអនុលោមតាមវិធាន ១១*ស្ទួន*រួមជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ក និងឧបសម្ព័ន្ធ ខ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៧ នៅកថាខណ្ឌ ២៦ [“នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចតម្រូវជាពិសេសឱ្យពិចារណា (១) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង (២) កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ”] [ដែលត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៦**]។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Rahim Ademi* *និង* *Mirko Norac* (IT-04-78-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចបង្វិលរឿងក្តីទៅអាជ្ញាធរនៃសាធារណរដ្ឋនៃប្រទេសក្រូអាដអនុលោមតាមអនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ នៅកថាខណ្ឌ ២៨ [“ចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនឹងយកដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកសារយោងបទចោទទាំងនោះនឹងត្រូវបង្ហាញដដែលនៅពេលជំនុំជម្រះ...”] កថាខណ្ឌ ៣១ [“ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចជឿជាក់ថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ជនជាប់ចោទទាំងពីរ និងកម្រិតនៃការទទួលខុសត្រូវរៀងៗខ្លួនរបស់ពួកគេ *យោងតាមអង្គហេតុផ្ទាល់តែម្តងនោះ* ពុំមែនពុំមានវិសមភាពជាមួយនឹងការបង្វិលរឿងក្តីនេះទេ...”] [ដែលត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៧**]។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Paško Ljubičić* (IT-00-41-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចបង្វិលរឿងក្តីទៅប្រទេ Bosnia និង Herzegovina អនុលោមតាមអនុលោមតាមវិធាន ១១*ស្ទួន* នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ នៅកថាខណ្ឌ ១៨ [“នៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនឹងពិចារណាលើអង្គហេតុទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះ”] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៨**]។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Sam Hinga Norman, Moinina Fofana,* និង *Allieu Kondewa* (SCSL-04-14-PT) អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីស្តីពីនត្ថិភាពនៃយុត្តាធិការបុគ្គលដែលបានដាក់ក្នុងនាមជនជាប់ចោទ Fofana ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៤ នៅកថាខណ្ឌ ២២ (*ដែលបានយោងលើ* របាយការណ៍របស់អគ្គលេខាធិការស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន S/2000/915 ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០០ កថាខណ្ឌ ៣០) [“ដូច្នេះ “ការទទួលខុសត្រូវបំផុត” បង្ហាញទាំងមុខតំណែងដឹកនាំ និងមានសិទ្ធិអំណាចរបស់ជនជាប់ចោទ និងស្ថានទម្ងន់ ភាពធ្ងន់ធ្ងរ ឬ លក្ខណៈទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្ម”] កថាខណ្ឌ ៣១ [“ចៅក្រមដែលត្រូវបានចាត់តាំង មានឆន្ទានុសិទ្ធិទទួលស្គាល់ ឬ ច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងស្រុង ឬផ្នែកខ្លះ។ អង្គជំនុំជម្រះយល់ឃើញថា នីតិវិធីពិនិត្យមើលឡើងវិញលើដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវយកមកលក្ខណៈយុត្តាធិការបុគ្គលមកពិចារណា...”] [ត្រូវបានដាក់ភ្ជាប់ជា**ឯកសារសំអាងទី ១៩**]។

170 *សាលក្រមលើសំណុំរឿង ០០១* ឯកសារ **E188** នៅកថាខណ្ឌ ២២។

លក្ខណៈវិនិច្ឆ័យរួមគ្នា ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការកែប្រែការកំណត់លក្ខខណ្ឌសាកល្បង ដើម្បីដាក់បញ្ចូលការវាយតម្លៃ*ក្នុងនោះរួម*មានស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដូច*ដែលបានអះអាង*[171] ជាជាងបទចោទប្រកាន់ គឺជាការអានច្បាប់ខុស និងគួរត្រូវបានច្រានចោល ។

៥៥. យោងតាមភស្តុតាងជាក់ស្តែង ការកំណត់លក្ខខណ្ឌសាកល្បង ត្រូវបានសំអាងលើការពិចារណាពីបទចោទប្រកាន់នានា និងមិនមែនត្រឹមតែលើវិសាលភាពនៃកិច្ចស៊ើបសួរដូចបានស្នើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាំងពីរនោះឡើយ ។ ដូចបានកត់សម្គាល់ដោយក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅពេលពិចារណាលើការផ្ទេររឿងក្តីមួយចំនួនទៅយុត្តាធិការតុលាការជាតិ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមគ្នាចំនួនពីរ ពួកគាត់យល់ឃើញថា៖

> នៅពេលវាយតម្លៃពីកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីនឹងពិចារណាតែលើអង្គហេតុទាំងឡាយដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ពោលគឺ អង្គហេតុទាំងនោះ ក្លាយជារឿងក្តីសំខាន់ដូចបានលើកឡើងដោយស្ថាប័នអយ្យការ ដើម្បីជំនុំជម្រះក្តី ដើម្បីអាចសម្រេចថាតើគួរនឹងបង្វិលរឿងក្តីដែរឬយ៉ាងណា ។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី *នឹងមិនពិចារណាលើអង្គហេតុដែលភាគីបានលើកឡើងនៅក្នុងសារណារបស់ពួកគេ ដែលហួសវិសាលភាពនៃអង្គហេតុ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ*[172] ។

---

171 *សូមមើល* សេចក្តីសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ៤៣៧ [កត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យចំនួនពីរដែលបានទទួលស្គាល់គឺ "(i) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងបុគ្គលម្នាក់ និង (ii) កម្រិតនៃការទទួលខុសត្រូវរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ"]។

172 រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Radovan Stanković* (IT-96-23/2-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចលើការបង្វិលរឿងក្តីអនុលោមតាមវិធាន ១១*ស្ទួន* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ នៅកថាខណ្ឌ ១៨

៥៦. វិធីសាស្ត្រនេះ គឺស្របគ្នាទាំងស្រុងជាមួយនឹងសំអាងហេតុរបស់ចៅក្រម Bohlander នៅក្នុងសំណុំរឿង០០៣ នៅពេលដែលលោកចៅក្រមបានសម្រេចថា ក្នុងការកំណត់ទាំងឡាយលើយុត្តាធិការបុគ្គលគឺនឹងត្រូវធ្វើឡើងនៅពេល "បិទកិច្ចស៊ើបសួរ ដោយផ្អែកលើភស្តុតាងសរុប នៅក្នុងសំណុំរឿង"[173] ជាមួយនឹងសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ[174] ។ និយាយឱ្យចំទៅ ចៅក្រម Bohlander ពុំបានស្នើថា លក្ខខណ្ឌវិនិច្ឆ័យពាក់ព័ន្ធនឹងតម្លៃនៃភស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[175] អាចនឹងត្រូវបានមើលរំលងនោះទេ ។ គាត់គ្រាន់តែបានសម្រេចយ៉ាងជាក់លាក់ថា ការកំណត់ពេលវេលានៃការវាយតម្លៃលើយុត្តាធិការបុគ្គលដោយផ្អែកលើអ្វីដែលសហចៅក្រមស៊ើបអង្កេតបានសម្រេចលើដែនកំណត់នៃរឿងក្តី គឺតាមរយៈសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់តែប៉ុណ្ណោះ ។ ការបកស្រាយណាមួយផ្សេងពីនេះ នឹងធ្វើឱ្យអំណាចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលមានកំហុស

---

(ការគូសបញ្ជាក់បន្ថែម)] [ត្រូវបាន ភ្ជាប់ជា**ឯកសារសំអាងទី ២០**]។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gojko Janković* (IT-96-23/2-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចលើការបង្វិលរឿងក្តីអនុលោមតាមវិធាន ១១ *ស្ទួន* រួមជាមួយនឹងឧបសម្ព័ន្ធ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ១៨ ["នៅក្នុងការវាយតម្លៃលើកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនឹងពិចារណាលើអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ ពោលគឺ អង្គហេតុទាំងនេះគឺជារឿងក្តីសំខាន់ដែលត្រូវបានលើកឡើងដោយស្ថាប័នអយ្យការសម្រាប់ការជំនុំជម្រះ ដើម្បីឈានដល់ការសម្រេចថាតើការបង្វិលរឿងក្តីដូច្នេះសមស្របដែរឬទេ"] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២១**]។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Paško Ljubičić* (IT-00-41-PT) ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សេចក្តីសម្រេចលើការបង្វិលរឿងក្តីអនុលោមតាមវិធាន ១១ *ស្ទួន* ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ នៅកថាខណ្ឌ ១៨ ["នៅក្នុងការវាយតម្លៃលើកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនឹងពិចារណាលើអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ ពោលគឺ អង្គហេតុទាំងនេះគឺជារឿងក្តីសំខាន់ដែលត្រូវបានលើកឡើងដោយស្ថាប័នអយ្យការសម្រាប់ការជំនុំជម្រះ ដើម្បីឈានដល់ការសម្រេចថាតើការបង្វិលរឿងក្តីដូច្នេះសមស្របដែរឬទេ"] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៨**]។

173 សេចក្តីសម្រេចរួមលើយុត្តាធិការបុគ្គល ឯកសារ **D297.1** នៅកថាខណ្ឌ ២៧ ។

174 សេចក្តីសម្រេចរួមលើយុត្តាធិការបុគ្គល ឯកសារ **D297.1** នៅកថាខណ្ឌ ២០ និងកថាខណ្ឌ ៣៨ ។

175 *សូមមើល* វិធាននៃផ្ទៃក្នុង វិធាន ៥៥(៤) នៃវិធាននៃផ្ទៃក្នុង [ដែលចែងថា ដើម្បីចោទប្រកាន់ជនសង្ស័យបាន សហចៅក្រមស៊ើបអង្កេតត្រូវជឿជាក់ថា "មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"] ។

ដោយសារសហព្រះរាជអាជ្ញាអាចបង្ហាញការយល់ឃើញរបស់ខ្លួន តាមរយៈការស្នើសុំឱ្យពង្រីកការស៊ើបអង្កេត ដោយពុំគិតថាតើការស៊ើបអង្កេតនោះនឹងបង្ហាញភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ជនសង្ស័យដែរឬយ៉ាងណា ។

៥៧. ក្រោយពីការស៊ើបសួរអស់រយៈពេលជាង ៧ ឆ្នាំ លើសំណុំរឿងក្តីរបស់អ្នកស្រី អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរ ដោយពុំបានដាក់បន្ថែមបទចោទប្រកាន់ណាមួយ នៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់នោះទេ មានន័យថា សហចៅក្រមស៊ើបអង្កេតជឿជាក់តែលើភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដែលមានអត្ថិភាពប្រាកដមែនចំពោះបទចោទប្រកាន់ជាក់លាក់ដែលមាន នៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ *ពោលគឺ* បទចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ។ ភស្តុតាងជាក់ស្តែងបានបង្ហាញថា ករណីនេះ ក៏មានន័យផងដែរថា សហចៅក្រមស៊ើបអង្កេត*ពុំ*ជឿជាក់ថា ភស្តុតាងនៅសេសសល់ផ្សេងទៀតនៅក្នុងសំណុំរឿង ០០៤/១ មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់គ្រប់គ្រាន់ដែលអាចបង្កើតបានជាមូលដ្ឋាននៃបទចោទបន្ថែមនោះទេ ។ ដូច្នេះ វាបានធ្វើឱ្យភស្តុតាងនេះ គឺមិនពាក់ព័ន្ធអ្វីសម្រាប់យកមកប្រើក្នុងការវាយតម្លៃថាតើអ្នកស្រី អ៊ឹម ចែម គឺជាជន "ដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬក៏អត់នោះទេ ។

៥៨. សរុបសេចក្តីមក ការសម្រេចថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ" គួរធ្វើឡើងនៅក្នុងដែនកំណត់នៃសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ។ ដូចបានកត់សម្គាល់ខាងលើ សេចក្តីសម្រេចគប្បីរួមបញ្ចូលទាំង៖

- ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង និង
- ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ដូចបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនោះ ។

៥៩. ការកំណត់នេះ បានផ្អែកជាពិសេសលើអំណាចផ្លូវការ និងឋានានុក្រមប្រកបដោយប្រសិទ្ធភាព

និងការចូលរួមរបស់បុគ្គលនៅក្នុងឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់គ្រប់គ្រាន់[176] ។ ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង និងសហចៅក្រមស៊ើបអង្កេត ដែលថា ឌុច ត្រូវបានចាត់ទុកថាជាជនស្ថិតនៅក្នុងប្រភេទបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត"[177] ដោយផ្អែកលើកត្តានានា ដូចបានអនុវត្តកន្លងមកនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី៖

> នៅពេលវាយតម្លៃអំពី *ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានផ្អែកលើកត្តានានា ដូចជា ចំនួនជនរងគ្រោះ ដែនកំណត់ភូមិសាស្ត្រ និងពេលវេលារបៀបដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង។ ចំណែកឯ*កម្រិតនៃការទទួលខុសត្រូវ*របស់ជនជាប់ចោទត្រូវបានវាយតម្លៃ ដោយផ្អែកលើមូលដ្ឋាននៃការពិចារណានានា ដូចជា កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម ឋានានុក្រម ឬ មុខតំណែងរបស់ជនជាប់ចោទ រួមបញ្ចូលទាំងចំនួននៃអ្នកក្រោមបង្គាប់ និងថ្នាក់លើរបស់គាត់ និងភាពអចិន្ត្រៃយ៍នៃមុខតំណែងរបស់គាត់[178]។

---

[176] *សូមមើលប្រៀបធៀបជាមួយ*សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ, ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ **D99** ("ដីកាដំណោះស្រាយលើសំណុំរឿង ០០១ ឯកសារ **D99**" នៅកថាខណ្ឌ ១២៩ ["ការស៊ើបសួរបានបង្ហាញថា ទោះជា [ឌុច] អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តក្នុងចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន ក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខា ក៏ដូចជាតាមរយៈការចូលរួមរបស់គាត់ដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ដែលជាមន្ទីរគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា" ក្រោយពីបានសង្ខេបអង្គហេតុទាំងអស់ រួមទាំងការទទួលខុសត្រូវរបស់ ឌុច លើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅស-២១ (*សូមមើល* នៅកថាខណ្ឌ ២០-១២៨)])។

[177] *សូមមើល* សាលក្រមលើសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២២-២៥។

[178] សាលក្រមលើសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២២ (លុបចោលលេខយោងជើងទំព័រ, គូសបញ្ជាក់បន្ថែម)។



**សំណៅកោសលុបសាធារណៈនៃចម្លើយតបរបស់ អ៊ឹម ចែម នៅនឹងដីកាសន្និដ្ឋានស្ថាពរ**
Original EN: 01352856-01352998

៦០. ការអនុវត្តលក្ខណៈវិនិច្ឆ័យទាំងនេះលើបទចោទនានានៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបសេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖

> ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែបានចោទប្រកាន់ថា ក្នុងនាមជាអនុលេខាមន្ទីរស-២១ ជនជាប់ចោទ *បានដឹកនាំ*ក្រុមសួរចម្លើយ និងបានចូលរួមនៅក្នុង*ការរៀបចំផែនការ*បង្កើតមន្ទីរស-២១ និងបង្រៀនបុគ្គលិករបស់គាត់អំពីបច្ចេកទេសសួរចម្លើយ ។ ក្នុងនាមជាប្រធានមន្ទីរស-២១ តួនាទីរបស់គាត់គឺ*ពិនិត្យមើលប្រតិបត្តិការទាំងមូល*ដោយរួមបញ្ចូលទាំងការធ្វើចំណារលើចម្លើយសារភាព និងបញ្ជាសម្លាប់។ មន្ទីរស-២១ គឺជៀមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា *ដោយរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញប្រទេស* និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ។ មានមនុស្សយ៉ាងតិច*ចំនួន ១២.០០០ នាក់* ត្រូវបានឃុំខ្លួននៅមន្ទីរស-២១។ ជនរងគ្រោះត្រូវបានបញ្ជូនស្ទើរតែពីគ្រប់ទីកន្លែងទូទាំងប្រទេសទៅមន្ទីរស-២១ ដែលមានន័យថា វិសាលភាពនៃសកម្មភាពរបស់មន្ទីរស-២១ *មានទូទាំងប្រទេស*។ មន្ទីរស-២១ បានធ្វើប្រតិបត្តិការចាប់ពីខែតុលា ឆ្នាំ ១៩៧៥ រហូត ដល់ដើម ខែមករាឆ្នាំ ១៩៧៩ ដូច្នេះ *វាគ្របដណ្តប់ស្ទើរតែទាំងមូលនៃអត្ថិភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ*[179]។

## ៣. បទដ្ឋានបង្ហាញភស្តុតាងសម្រាប់វាយតម្លៃថាតើជនត្រូវចោទស្ថិតនៅក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅ អ.វ.ត.ក ដែរ ឬយ៉ាងណា

៦១. ច្បាប់បច្ចុប្បន្នជាធរមាននៅ អ.វ.ត.ក កំណត់និយមន័យនៃបទដ្ឋានបង្ហាញភស្តុតាងសម្រាប់សម្រេចពីបញ្ហាយុត្តាធិការបុគ្គល ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់នោះទេ ។ មានសេចក្តីសម្រេច

---

[179] សាលក្រមលើសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២៣ (គូសបញ្ជាក់បន្ថែម)។

មួយធ្វើឡើងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានលើកឡើងថា "ដើម្បីផ្តល់យុត្តិកម្មលើការបន្តការស៊ើបអង្កេត*លើបុគ្គលបាន*" សហចៅក្រមស៊ើបអង្កេតគួរវាយតម្លៃពីការជឿជាក់បាន*ជាបឋម*ថាតើខ្លួនមានយុត្តាធិការបុគ្គលលើជនសង្ស័យដែរឬទេ[180]។ ទោះជាយ៉ាងណា សេចក្តីសម្រេចនេះត្រូវបានច្រានចោលដោយសារចៅក្រម Bohlander ដោយគាត់បានផ្តល់សំអាងហេតុថា វាគឺជាការវាយតម្លៃ "លឿនពេក" លើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ចំពោះករណី មាស មុត ដែលនៅពេលនោះ ជននេះមិនទាន់ត្រូវបានរងការចោទប្រកាន់នៅឡើយ[181] ។

៦២. វាត្រូវបានយល់ឃើញថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet មានកំហុសយ៉ាងច្បាស់ក្រឡែតតែម្តង ។ ដោយហេតុថា យុត្តាធិការបុគ្គលអាចនឹងត្រូវបានយកមកវាយតម្លៃតែនៅចុងបញ្ចប់នៃកិច្ចស៊ើបសួរប៉ុណ្ណោះ[182] ហើយវាជាធាតុផ្សំមួយដ៏ចាំបាច់សម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះ ក្រុមការពារក្តីស្នើឱ្យអនុវត្តនូវបទដ្ឋានបង្ហាញភស្តុតាងដូចគ្នានឹងបទដ្ឋានបង្ហាញភស្តុតាងដែលជាលក្ខខណ្ឌតម្រូវ ដើម្បីបញ្ជូនរណាម្នាក់ទៅជំនុំជម្រះ[183] ។ ក្រុមការពារក្តីស្នើថា សហចៅក្រមស៊ើបអង្កេតត្រូវតែមានការជឿជាក់ជា

---

[180] *សូមមើល រឿងក្តី មាស មុត* សំណុំរឿង 003/07-09-2009-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរពាក់ព័ន្ធនឹងជនសង្ស័យ [កោសលុប] ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ **D48** នៅកថាខណ្ឌ ១៣។

[181] សេចក្តីសម្រេចរួមលើយុត្តាធិការបុគ្គល ឯកសារ **D297.1** នៅកថាខណ្ឌ ២៧ និងកថាខណ្ឌ ៤៣។

[182] *សូមមើល* សេចក្តីសម្រេចរួមលើយុត្តាធិការបុគ្គល ឯកសារ **D297.1** នៅកថាខណ្ឌ ២០, ២៧, ៣៤។

[183] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣៧-៤១។ ដោយសារបទដ្ឋាននៃ "ភស្តុតាងគ្រប់គ្រាន់ និងស៊ីសង្វាក់គ្នា" គឺជាលក្ខខណ្ឌអប្បបរមាដាច់ណាត់សម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ បទដ្ឋាននៃភស្តុតាងដូចគ្នាដើម្បីវាយតម្លៃលើ "ជនទាំងឡាយដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត" គួរយកមកអនុវត្តនៅក្នុងន័យនេះយ៉ាងហោចណាស់តាមរយៈការប្រៀបធៀប។ ដូច្នេះ បទដ្ឋានតែមួយត្រូវយកមកអនុវត្តលើធាតុផ្សំសម្ភារៈទាំងអស់។ *សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mrkšić និងអ្នកផ្សេងទៀត* (IT-95-13/1-A) អង្គជំនុំជម្រះតុលាការកំពូល, សាលដីកា ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០០៩ នៅកថាខណ្ឌ ២២០ ["បទដ្ឋាននៃភស្តុតាងនៅក្នុងពេលជំនុំជម្រះទាមទារនូវលក្ខខណ្ឌថា អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថាជនជាប់ចោទមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មប្រសិនបើស្ថាប័នអយ្យការបានបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្មនីមួយៗ និងទម្រង់នៃការទទួលខុសត្រូវ ហើយអង្គហេតុណាដែលសំខាន់សម្រាប់សម្រេចឱ្យមានពិរុទ្ធភាពហួសពី

មុនសិន ថាភស្តុតាងពាក់ព័ន្ធ គឺ "មានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់"[184] ក្នុងការបង្ហាញថា អ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងប្រភេទជន "ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត" ។ ការទាមទារឱ្យមានបទដ្ឋានភស្តុតាងស៊ីសង្វាក់គ្នាមួយសម្រាប់ធាតុផ្សំសម្ភារៈទាំងអស់នឹងការពារដល់ជនត្រូវចោទ និងធ្វើឱ្យដំណើរការជំនុំជម្រះចៀសផុតពីកិច្ចដំណើរការនីតិវិធីចំណាយពេលយូរ និងចំណាយថវិកាច្រើនដោយសារផ្អែកលើការវាយតម្លៃបញ្ហាយុត្តាធិការមិនបានហ្មត់ចត់ និងពុំមានលក្ខណៈស៊ីសង្វាក់ខ្លាំងក្លា ។

៦៣. សរុបមក ដូចនឹងត្រូវពិភាក្សានៅផ្នែកខាងក្រោម[185] ការអនុវត្តបទដ្ឋានបង្ហាញភស្តុតាងសមស្របចំពោះបទចោទប្រកាន់ និងភស្តុតាងពាក់ព័ន្ធ វាច្បាស់ណាស់ដែលអ្នកស្រី អ៊ឹម ចែម ពុំស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ ។ ភស្តុតាងនេះបង្ហាញថា ឧក្រិដ្ឋកម្មដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានរងការចោទប្រកាន់នៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ពុំមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ហើយភស្តុតាងទាំងនេះបង្ហាញថា អ្នកស្រីមិនបានចូលរួមនៅក្នុងឧក្រិដ្ឋកម្ម អ្នកស្រីមិនស្ថិតនៅជិតនឹងឧក្រិដ្ឋកម្ម ហើយក៏មិនគួរទម្លាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះនោះទេ ។ សរុបសេចក្តីទៅ ភស្តុតាងទាំងនេះមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ពុំស៊ីសង្វាក់គ្នា និងមានតម្លៃភស្តុតាងតិចតួច ឬ គ្មានតែម្តង ដើម្បីគាំទ្រលើការលើក

---

វិមតិសង្ស័យ"] ៣២៥ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២២**]។ ម្យ៉ាងវិញទៀត បទដ្ឋាននៃភស្តុតាងតែមួយត្រូវអនុវត្តលើយុត្តាធិការបុគ្គល និងយុត្តាធិការលើកម្មវត្ថុ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Sam Hinga Norman, Moinina Fofana, និង Allieu Kondewa* (SCSL-04-14-PT) អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីស្តីពីនត្ថិភាពនៃយុត្តាធិការបុគ្គលដែលបានដាក់ក្នុងនាមជនជាប់ចោទ Fofana ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៤ នៅកថាខណ្ឌ ៣៧ ["បញ្ហាទីបី...ដែលត្រូវយកមកដោះស្រាយគឺលក្ខណៈវិនិច្ឆ័យណាដែលគួរបំពេញ ឬ បទដ្ឋានអ្វីដែលត្រូវប្រើប្រាស់នៅពេលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងការសម្រេចថាតើលក្ខខណ្ឌយុត្តាធិការបុគ្គលចាំបាច់បានបំពេញដែរឬទេនៅក្នុងរឿងក្តីនេះ" (គូសបញ្ជាក់បន្ថែម)] ៣៨ ["អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បទដ្ឋានដែលត្រូវយកមកប្រើប្រាស់ដើម្បីបំពេញយុត្តាធិការបុគ្គលពុំគួរខុសពីបទដ្ឋានសម្រាប់បង្ហាញលក្ខខណ្ឌយុត្តាធិការលើកម្មវត្ថុនោះឡើយ" (គូសបញ្ជាក់បន្ថែម)"] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ១៩**]។

184 ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ឯកសារ **D427** នៅកថាខណ្ឌ ១៣២៣។

185 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៦៦-២២៦។

ឡើងដែលថា អ.វ.ត.ក មានយុត្តាធិការបុគ្គលក្នុងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នោះឡើយ ។ ចំណុចនេះនឹងយកមកពិភាក្សានៅផ្នែកខាងក្រោម ។

៦៤. ទីមួយ ក្រុមការពារក្តីនឹងពិភាក្សាលើការពិចារណាទូទៅចំនួនពីរ ដែលបង្ហាញនូវការអះអាងមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម និងការចោទប្រកាន់អ្នកស្រីអំពីការចូលរួមនៅក្នុងឧក្រិដ្ឋកម្មមួយចំនួន ។ ចំណុចទាំងនេះ នឹងរួមបញ្ចូលទាំងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សិទ្ធិអំណាច*ជាក់ស្តែង* របស់អ្នកស្រី អ៊ឹម ចែម មួយផ្នែក គឺផ្អែកលើការមានទំនាក់ទំនងពិសេសរបស់អ្នកស្រីជាមួយនឹង *តា ម៉ុក* ហើយនិយាយជារួមទៅ គឺតួនាទីជាកម្មាភិបាលស្រ្តី ជាពិសេស លទ្ធភាពដែលថា កម្មាភិបាលស្រ្តីទាំងនេះនឹងកាន់កាប់តួនាទីនៃការទទួលខុសត្រូវនៅក្នុងវិស័យសន្តិសុខ ។

៦៥. ទីពីរ ក្រុមការពារក្តីនឹងបង្ហាញឱ្យឃើញថា គ្មានលក្ខណៈវិនិច្ឆ័យលើអង្គហេតុសមហេតុផលណាមួយ អាចអនុវត្តនូវវិធីសាស្រ្តដែលសហព្រះរាជអាជ្ញាអន្តរជាតិជំរុញឱ្យអនុវត្តលើភស្តុតាងដែលនៅសេសសល់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ឡើយ ។ ក្រុមការពារក្តីនឹងលើកឡើងអំពីវិធីសាស្រ្តដែលមានកំហុសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះអង្គហេតុពាក់ព័ន្ធនឹងការវាយតម្លៃលើមុខតំណែង និងសិទ្ធិអំណាច*តាមផ្លូវច្បាប់* និង*ជាក់ស្តែង* របស់អ្នកស្រី អ៊ឹម ចែម នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បូករួមទាំងការទទួលខុសត្រូវរបស់អ្នកស្រីក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះជាដើម ។ ក្រុមការពារក្តីនឹងលើកឡើងអំពីវិធីសាស្រ្តមានកំហុសរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះអង្គហេតុពាក់ព័ន្ធនឹងការវាយតម្លៃលើហេតុការណ៍ និងឧក្រិដ្ឋកម្មដែលអាចកើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ព្រមទាំងកម្រិតនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម លើហេតុការណ៍ និងឧក្រិដ្ឋកម្មទាំងនោះ ។

## ខ. ការពិចារណាទូទៅពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម

៦៦. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចធំធេង ទាំងនៅថ្នាក់ស្រុក និងថ្នាក់តំបន់នៃភូមិភាគនិរតី និងពាយព្យ ដោយរួមទាំងការទទួលខុសត្រូវលើមន្ទីរសន្តិសុខ

នានា និងទីតាំងសម្លាប់មនុស្សមួយចំនួន[186] ។ ការចោទប្រកាន់ទាំងនេះបានបង្ហាញលក្ខខណ្ឌយោង ដោយផ្អែកលើការអះអាងទូទៅចំនួនពីរ ពោលគឺ មុខតំណែងមានអំណាចដែលអ្នកស្រី អ៊ឹម ចែម កាន់កាប់[187] ត្រូវបាន *តា ម៉ុក* ប្រគល់ឱ្យអ្នកស្រី[188] ដោយសារអ្នកស្រី "គឺជាកម្មាភិបាលម្នាក់ក្នុងចំណោមអ្នកជិតស្និទ្ធបំផុតរបស់ *តា ម៉ុក*"[189] ហើយថា ទោះបីអ្នកស្រី គឺជាកម្មាភិបាលស្ត្រីម្នាក់ក៏ដោយ ក៏អ្នកស្រីមានសិទ្ធិអំណាចលើបញ្ហាសន្តិសុខដែរ[190] ។ តាមការបង្ហាញហេតុផលរបស់សហព្រះរាជអាជ្ញាអន្តរជាតិគឺថា កាលៈទេសៈទូទៅសំខាន់ៗទាំងនេះ ធ្វើឱ្យអ្នកស្រី អ៊ឹម ចែម បាន កាន់កាប់តួនាទីមួយចំនួន និងមានការទទួលខុសត្រូវជាក់លាក់ ដែលបានផ្តល់សិទ្ធិអំណាចធំធេងដល់អ្នកស្រី ហើយនៅចុងក្រោយ ធ្វើឱ្យអ្នកស្រីក្លាយជាបុគ្គលទទួលខុសត្រូវលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅក្នុងភូមិភាគទាំងពីរ[191] ។

៦៧. ទោះបីជាយ៉ាងនេះក្តី ការវិភាគដោយសត្យានុម័តលើភស្តុតាងបានបង្ហាញ ការពណ៌នារបស់

---

[186] *សូមមើលជាឧទាហរណ៍* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១០១-០៧ (នៅភូមិភាគនិរតី)។ នៅកថាខណ្ឌ ១១៤-១១៧ (នៅភូមិភាគពាយព្យ) និងនៅកថាខណ្ឌ ២, ៥៣០-៣២ (នៅភូមិភាគនិរតី និងភូមិភាគពាយព្យ)។

[187] *សូមមើលជាឧទាហរណ៍* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ៥២, ៥៤, ១០១-០៧ (នៅភូមិភាគនិរតី) ។ នៅកថាខណ្ឌ ៥៨-៥៩, ១១៤-១១៧ (នៅភូមិភាគពាយព្យ) និងនៅកថាខណ្ឌ ២, ៥៣០-៣២ (នៅភូមិភាគនិរតី និងភូមិភាគពាយព្យ)។

[188] *សូមមើល* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ៩៦ ["តួនាទីរបស់ អ៊ឹម ចែម ត្រូវបានកត់សម្គាល់ដោយសារទំនាក់ទំនងរបស់គាត់ជាមួយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គឺ តា ម៉ុក។ រាល់តួនាទីដែល អ៊ឹម ចែម ទទួលបាន នៅក្នុងភូមិភាគនិរតី និងពាយព្យ សុទ្ធតែត្រូវបានតែងតាំងដោយតាម៉ុក"]។

[189] សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ៩៦។

[190] *សូមមើល ឧទាហរណ៍ក្នុង* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២, ១០៦ (សិទ្ធិអំណាចលើមន្ទីរសន្តិសុខវត្តអង្គស្រីមាលី) ។ នៅកថាខណ្ឌ ១៣១, ១៤០-១៤៨, ១៩៦ (សិទ្ធិអំណាចលើអ្នកទោសនៅ PTSC) ។ នៅកថាខណ្ឌ ១៤៩-១៥១, កថាខណ្ឌ ១៥៦, និងកថាខណ្ឌ ១៦១ (សិទ្ធិអំណាច ក្នុងការបញ្ជាឱ្យកាប់សម្លាប់) ។ នៅកថាខណ្ឌ ១៦៦ (សិទ្ធិអំណាចលើមន្ទីរសន្តិសុខអង្គស្រីមាលី) ។ នៅកថាខណ្ឌ ២២១ (សិទ្ធិអំណាចលើមន្ទីរសន្តិសុខចក្រី និងវាលពិឃាតព្រៃតារ៉ុត) ។ នៅកថាខណ្ឌ ២៣៣, និងកថាខណ្ឌ ២៣៩ (សិទ្ធិអំណាចលើមន្ទីរសន្តិសុខចម្ការខ្នុរ) ។ នៅកថាខណ្ឌ ២៤៨ (សិទ្ធិអំណាចលើវត្តព្រះនេត្រព្រះ) ។ នៅកថាខណ្ឌ ២៩០ (សិទ្ធិអំណាចលើការដ្ឋានការងារ) និងកថាខណ្ឌ ៤៤០, និងកថាខណ្ឌ ៥៣០-៥៣៣។

[191] *សូមមើល* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១០៨-៥៦។

សហព្រះរាជអាជ្ញាបានផ្អែកលើការសន្មតទុកជាមុន និងមិនមែនជាភស្តុតាងនោះទេ។ ដូច្នេះ តាំងពីដើមដំបូងមក សំណុំរឿងប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ពុំមានមូលដ្ឋាននោះឡើយ ។ ទីមួយ អ្នកស្រី អ៊ឹម ចែម ពុំមានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ។ ទីពីរ ក្នុងនាមជាកម្មាភិបាលស្ត្រី វាមិនទំនងសោះឡើយដែលថា អ្នកស្រីអាចទំនងជាមានតួនាទីសំខាន់នៅក្នុងបញ្ហានានាពាក់ព័ន្ធនឹងការងារសន្តិសុខ ។

### ១. អ្នកស្រី អ៊ឹម ចែម ពុំមានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ទេ

៦៨. ការអះអាងដែលថា "តួនាទីរបស់អ្នកស្រី អ៊ឹម ចែម ត្រូវបានកត់សម្គាល់ដោយសារទំនាក់ទំនងរបស់អ្នកស្រីជាមួយសមាជិកគណៈរអចិន្ត្រៃយ៍ គឺ *តា ម៉ុក*"[192] គឺជាការអះអាងដែលគ្មានមូលដ្ឋានត្រឹមត្រូវ ។ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិចង់បង្ហាញថា អ្នកស្រី អ៊ឹម ចែម គឺជាកម្មាភិបាលជិតស្និទ្ធបំផុតជាមួយនឹង *តា ម៉ុក* ថាអ្នកស្រីគឺជា "មនុស្សទីពីរបន្ទាប់ពី *តា ម៉ុក*" ថាអ្នកស្រីគឺជា "ដៃស្តាំរបស់ *តា ម៉ុក*" ហើយនិងជា "មនុស្សពិសេសរបស់ *តា ម៉ុក*"[193] គឺជាឧបាយកលឥតលាក់លៀម ធ្វើឡើងក្នុងបំណងបិទបាំងនូវកង្វះភស្តុតាងមានតម្លៃសម្រាប់បង្ហាញយុត្តាធិការបុគ្គល ។ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ផ្អែកលើការរៀបរាប់រឿងរ៉ាវតៗគ្នាពីមួយទៅមួយរបស់សាក្សីបីរូប (មូល អេង, ហែម មាន និង ញ៉ែម អេន) និងសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ខ្លួនឯង ដែលបានច្របាច់បញ្ចូលគ្នាយ៉ាងប្រយ័ត្នប្រយែងដើម្បីបិទបាំងនូវវិការៈនេះ ។ ទោះបីជាបានប្រើប្រាស់វិធីសាស្ត្រនេះដូចម្តេចក្តី វាច្បាស់ណាស់ដែលថារឿងរ៉ាវទាំងនេះ បើទោះជាបានពិនិត្យយ៉ាងល្អិតល្អន់ ដោយផ្តោតលើរឿងរ៉ាវមួយៗ ឬ រួមបញ្ចូលគ្នាក៏ដោយ ក៏មិនអាចគាំទ្រការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម មានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ដែរ កុំថាឡើយដែលព័ត៌មានទាំងនោះមានអានុភាពលើសិទ្ធិអំណាច ឬ ការទទួលខុសត្រូវ *ស្របច្បាប់* ឬ *ជាក់ស្តែង* ចំពោះឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ។ ចំណុចទាំងនេះនឹងត្រូវធ្វើការបកស្រាយម្តងមួយៗនៅផ្នែកខាងក្រោម ។

---

192 សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦។

193 *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦។

៦៩. នៅក្នុងការពណ៌នាថា អ្នកស្រី អ៊ឹម ចែម គឺជា*កម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលជិតស្និទ្ធបំផុតរបស់ តា ម៉ុក* សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងលើចម្លើយ មូល អេង[194] ។ ការផ្អែកលើសាក្សីរូបនេះ ដើម្បីបង្ហាញថា អ្នកស្រី អ៊ឹម ចែម គឺជា*គូកនម្នាក់*ក្នុងចំណោមគូកនជិតស្និទ្ធរបស់ *តា ម៉ុក* ខណៈខកខានក្នុងការពន្យល់ពីមុខតំណែងថ្នាក់ទាបរបស់អ្នកស្រីក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះក្នុងភូមិភាគពាយព្យ[195] បង្កឱ្យមានការមន្ទិលសង្ស័យធ្ងន់ធ្ងរចំពោះសេចក្ដីអះអាងនេះ ។ ម្យ៉ាងវិញទៀត ដូច មូល អេង បានបញ្ជាក់រួចមកហើយថា សូម្បីតែសិទ្ធិអំណាចថ្នាក់ទាបនេះ ក៏ត្រូវបានថមថយដែរ នៅពេលកម្មាភិបាលភូមិភាគនិរតីបានចូលមកដល់ក្នុងភូមិភាគពាយព្យ[196] ។ ចំពោះមូលហេតុអ្វីដែល *តា ម៉ុក* ចាត់ឱ្យគូកនជិតស្និទ្ធរបស់គាត់ត្រឹមតែមុខតំណែងថ្នាក់ស្រុកដែលជាមុខតំណែងមិនទៀងទាត់ និងមិនផ្ដល់នូវមុខតំណែងខ្ពស់ ឬប្រសើរជាងនេះ គឺពុំបានពន្យល់នៅក្នុងដីកាសន្និដ្ឋានស្ថាពរឡើយ ។

៧០. ចំពោះការសំអាងលើចម្លើយរបស់សាក្សី ហែម មាន ដែលជានីរសារកម្មាភិបាលថ្នាក់តំបន់របស់ *តា ចាយ* ជាអ្នកមានមុខងាររត់សំបុត្រពី *តា ម៉ុក* នៅបាត់ដំបងទៅឱ្យអ្នកស្រី អ៊ឹម ចែម សហព្រះរាជអាជ្ញាអន្តរជាតិក៏បានអះអាងថា អ្នកស្រី អ៊ឹម ចែម "គឺជាបុគ្គលទីពីរបន្ទាប់ពី *តា ម៉ុក*"[197] ។ បើទោះបីជាសាក្សីបានបញ្ជាក់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយតែមួយថា ទំនាក់ទំនង

---

194 *សូមមើល* សេចក្ដីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦ (លេខយោងជើងទំព័រ ៤៣២) ដែលបានយោងលើកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ស-ឆ:63 ["ស៖ តើកម្មាភិបាលដែល តាម៉ុកនាំពីនិរតីដើម្បីឱ្យមកគ្រប់គ្រងនៅភូមិភាគពាយព្យដែលស្និទ្ធស្នាលជាមួយ តា ម៉ុក ជាងគេនោះមានអ្នកណាខ្លះ? ឆ:63៖ កម្មាភិបាលដែល តាម៉ុក នាំពីនិរតីមកគ្រប់គ្រងនៅពាយព្យគឺ៖ ១ យាយចែម ២ តាចាយ ៣ តាទិត ៤ គឺ តាអាន"]។

195 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៩៩-១១០។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ១១១-១៤២។

196 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤- ៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ស-ឆ:185។

197 *សូមមើល* សេចក្ដីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦ (លេខយោងជើងទំព័រ ៤៣៣) *ដែលយោងទៅលើ*កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម មាន ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/123** ឆ:20 ["ខ្ញុំដឹងថា យាយចែម ជា មនុស្ស ទី២ បន្ទាប់ពី តា ម៉ុក ពីព្រោះនៅពេលក្រោយៗមកខ្ញុំបាននាំសំបុត្រពី តា ម៉ុក នៅបាត់ដំបងទៅឱ្យ

ដោយផ្ទាល់រវាងអ្នកស្រី អ៊ឹម ចែម និង *តា ម៉ុក* គឺ "មិនអាចទៅរួច"[198] នោះទេ ហើយថាលិខិតពី *តា ម៉ុក* នឹងត្រូវបានប្រគល់ទៅថ្នាក់តំបន់មុនគេ ដែលក្រោយមកថ្នាក់តំបន់បានប្រគល់លិខិតទាំងនោះបន្តទៅអ្នកស្រី អ៊ឹម ចែម នៅថ្នាក់ស្រុក[199] ក៏ដោយ ក៏សហព្រះរាជអាជ្ញាអន្តរជាតិនៅតែទទូចដដែលៗថា ទំនាក់ទំនងជិតស្និទ្ធ និងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ពិតជាមាន ។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាអន្តរជាតិខកខានពុំផ្តល់ការពន្យល់ណាមួយ ពាក់ព័ន្ធនឹងហេតុផលអ្វីខ្លះដែលអ្នកស្រី អ៊ឹម ចែម និង *តា ម៉ុក* មានទំនាក់ទំនងបែបនេះ ប្រការដែលអាចទាក់ទងគ្នាដោយមិនផ្ទាល់តាមរយៈថ្នាក់តំបន់ ដោយសារថ្នាក់ស្រុក និងថ្នាក់ភូមិភាគមានទម្លាប់ទាក់ទងគ្នាទៅវិញទៅមកដូច្នេះ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ[200] ។

៧១. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានពន្យល់ហេតុផលនៃភាពមិនប្រក្រតីជាក់ស្តែងទាំងនេះទេ ប៉ុន្តែបែរជាបានព្យាយាមផ្តល់នូវមូលដ្ឋានលើរឿងរ៉ាវដែលបានពីការបំផ្លើស តាមរយៈការសំអាងបន្ថែមលើភស្តុតាងរបស់ ញ៉ែម អេន[201] ដែលបានធ្វើការជាជាងថតរូបនៅមន្ទីរស-២១[202] ហើយបាន

---

យាយ ចែម នៅព្រះនេត្រព្រះ។ ជួនកាល តា ម៉ុក បានឱ្យនិរសាររបស់គាត់យកសំបុត្រពីបាត់ដំបងមកឱ្យខ្ញុំ ហើយខ្ញុំក៏បាននាំសំបុត្រនោះបន្តទៅឱ្យ យាយ ចែម"]។

198 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន, ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/123** ឆ:18។

199 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/123** ឆ:18 ឆ:20។

200 *សូមមើល ឧទាហរណ៍ក្នុង* សាលក្រមសំណុំរឿង ០០២ ឯកសារ **E313** នៅកថាខណ្ឌ ២៧០ ["ក្នុងការអនុវត្តជាក់ស្តែង កម្រិតនីមួយៗនៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជាបានទំនាក់ទំនងគ្នា ភាគច្រើនត្រឹមតែជាមួយថ្នាក់លើ និងថ្នាក់ក្រោមផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ។ ទំនាក់ទំនងខ្សែទទឹងនៅក្រៅគណៈកម្មាធិការមជ្ឈិមគឺមានតិចតួចបំផុត។ ជាទូទៅ តំបន់ (លើកលែងតែតំបន់ស្វយ័ត) ស្រុក និងឃុំមិនទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការមជ្ឈិមដោយផ្ទាល់ទេ តែបញ្ជូន និងទទួលព័ត៌មានពីថ្នាក់លើ ឬថ្នាក់ក្រោមរបស់ខ្លួនផ្ទាល់តាមរយៈខ្សែសង្វាក់នៃការបញ្ជា" (លុបចោលលេខយោងជើងទំព័រ)]។

201 *សូមមើល* សេចក្តីសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ៩៦ (លេខយោងជើងទំព័រ ៤៣៤-៣៥) *ដែលបានយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/124**, ស-ឆ:22, ស-ឆ:35។

202 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/124** ឆ:2។

ជួបអ្នកស្រី អ៊ឹម ចែម តែម្តងគត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[203] ។ នៅពេលសាកសួរថាតើគាត់បានដឹងដោយរបៀបណាថា អ្នកស្រី អ៊ឹម ចែម គឺជាដៃស្តាំរបស់ *តា ម៉ុក* សាក្សី ញ៉ែម អេន បានលើកឡើងថា គាត់ស្មានដូច្នោះ ពីព្រោះផ្អែកលើមូលដ្ឋានថា អ្នកទាំងពីរនោះគឺជា "កម្មាភិបាលនិរតី ហើយគាត់បានចូលរួមការតស៊ូបដិវត្តន៍ជាយូរយារណាស់មកហើយ"[204] ។ និយាយឱ្យចំទៅ ភស្តុតាងដូច្នេះ គ្មានតម្លៃជាភស្តុតាងទេ ។ ការពិតដែលសហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានបង្ខំចិត្តក្នុងការសំអាងលើភស្តុតាងនេះ វាជាការបង្ហាញនូវកម្រិតនៃភាពអាចទុកចិត្តបាននៃការអះអាងជារួមថា ភស្តុតាងនេះ ត្រូវបានកាត់តម្រឹមដើម្បីធ្វើជាមូលដ្ឋានគាំទ្រ ។

៧២. ចម្លើយរបស់អ្នកស្រី អ៊ឹម ចែម ដែលបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីកម្រិតនៃទំនាក់ទំនងរវាង *តា ម៉ុក* និងអ្នកស្រី ក៏មិនអាចយកការអ្វីកើតដែរ ។ ការពិតទៅ ទោះបីជាសំណៅបកប្រែជាភាសាអង់គ្លេសនៃកិច្ចសម្ភាសន៍របស់អ្នកស្រី កត់សម្គាល់ការនិយាយរបស់អ្នកស្រីដូច្នេះថា អ្នកស្រី "មិនខ្លាច *តា ម៉ុក* ទេ ពីព្រោះ [អ្នកស្រី] និយាយតែពីរឿងត្រឹមត្រូវ"[205] ក៏ដោយ ក៏សំណៅដើមជាភាសាខ្មែរបានត្រឹមតែបញ្ជាក់ថា "អ្នកស្រីអត់ខ្លាចទេ ពីព្រោះ [អ្នកស្រី] និយាយពីត្រឹមត្រូវ"[206] ដោយពុំបាននិយាយសំដៅលើ *តា ម៉ុក* នោះឡើយ ។ ទោះក្នុងករណីណាក៏ដោយ

---

[203] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/124** ឆ:19។

[204] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/124** ឆ:38។

[205] *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦ (លេខយោងជើងទំព័រ ៤៣៦) *ដែលយោងទៅលើ* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1b** KH ERN 00929834 ["ប៉ុនខ្ញុំ ខ្ញុំប៉ានព្រោះខ្ញុំស្គាល់គាត់ជិតស្និទ្ធជាមួយគាត់។... គាត់ថាម៉ាម៉ាត់ ហើយខ្ញុំដាក់ពីរម៉ាត់ទៅវិញ។... ជាមួយតាម៉ុកហ្នឹង ខ្ញុំអត់ខ្លាចទេ ព្រោះខ្ញុំនិយាយពីត្រឹមត្រូវ ចឹងគាត់ថាខ្ញុំដឹកនាំមិនល្អ ហើយខ្ញុំថាបើខ្ញុំដឹកនាំមិនល្អ ហើយខ្ញុំថាតាឯងឱ្យខ្ញុំដឹកនាំធ្វើអ្វី ខ្ញុំប៉ានតវ៉ាជាប់ជាមួយតាម៉ុក ខ្ញុំអត់ខ្លាចទេ ដល់ចឹងខ្ញុំយកមកដោះស្រាយប្រជាជនហ្នឹង គាត់បានហូបបានចុកហ្នឹង"]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a** EN ERNs 00089777, 00089779។

[206] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b** KH ERN 00929834 ["ប៉ុនខ្ញុំ ខ្ញុំប៉ានព្រោះខ្ញុំស្គាល់គាត់ជិតស្និទ្ធជាមួយគាត់។... គាត់ថាម៉ាម៉ាត់ ហើយខ្ញុំដាក់ពីរម៉ាត់ទៅវិញ...។ ខ្ញុំអត់ខ្លាចទេ ព្រោះខ្ញុំនិយាយពីត្រឹមត្រូវ ចឹងគាត់ថាខ្ញុំដឹកនាំមិនល្អ ហើយខ្ញុំថាបើ

ចម្លើយនេះមានតម្លៃភស្តុតាងតិចតួចលើបញ្ហាចំពោះមុខ ពោលគឺ ចម្លើយនេះ មិនបានឆ្លើយក្រោមការធ្វើសម្បថ ហើយជាក់ស្តែងគឺ វាពុំបានបង្ហាញនូវសិទ្ធិ ឬ អំណាចធំធេងអ្វីនោះទេ ។ ផ្ទុយមកវិញ អ្នកស្រី អ៊ឹម ចែម បានកត់សម្គាល់ថា ទំនាក់ទំនងរបស់អ្នកស្រីជាមួយ *តា ម៉ុក* បានអនុញ្ញាតឱ្យអ្នកស្រីផ្តល់ស្បៀងអាហារជូនប្រជាជន។ ចម្លើយនេះ ពុំអាចផ្តល់ការគាំទ្រប្រកបដោយអត្ថន័យចំពោះការអះអាងដែលថា ទំនាក់ទំនងនេះមានភាពស៊ីជម្រៅ កុំថាឡើយការលើកឡើងដូច្នេះ បង្កឱ្យទៅជាការមានសិទ្ធិអំណាច ឬ ការទទួលខុសត្រូវ*ស្របច្បាប់* ឬ *ជាក់ស្តែង* ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ។

៧៣. ជាចុងក្រោយ សេចក្តីសំអាងហេតុរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹង *តា ម៉ុក* គឺបានមកពីការការចាត់ទុកនូវសម្តីអះអាងនានាថាជាការពិត ហើយបែរជាច្រានចោលនូវភស្តុតាងដែលបង្ហាញពីបរិបទសំខាន់ទៅវិញ ។ ដូចបានលាតត្រដាងដោយ ណុប ង៉ឹម ជាកម្មាភិបាលស្ត្រីដែលត្រូវបានបញ្ជូនពីភូមិភាគនិរតីទៅភូមិភាគពាយព្យ ជាកន្លែងដែលអ្នកស្រីបានធ្វើការងារជាអនុលេខាស្រុកសំឡូតក្នុងតំបន់១ ចាប់ពីដើមឆ្នាំ ១៩៧៨ រហូតដល់ឆ្នាំ ១៩៧៩[207] ។ ជាទូទៅ *តា ម៉ុក* មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកម្មាភិបាលនៅថ្នាក់ទាបៗជាច្រើន ហើយគេអាចទាញការសន្និដ្ឋានបានតិចតួចប៉ុណ្ណោះ ពាក់ព័ន្ធនឹងសិទ្ធិអំណាច*ជាក់ស្តែង* ដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងនេះ ។ សាក្សីជាច្រើនបញ្ជាក់ថា កិច្ចប្រជុំនានារវាង *តា ម៉ុក* និងកម្មាភិបាលថ្នាក់ទាបឃើញធ្វើឡើងជាធម្មតាទៅហើយ[208] ។ អ្នកស្រី ណុប ង៉ឹម ពិពណ៌នាពីការរស់នៅជិត *តា ម៉ុក* នៅខេត្ត

---

ខ្ញុំដឹកនាំមិនល្អ ហើយខ្ញុំថាតាឯងឱ្យខ្ញុំដឹកនាំធ្វើអ្វី ខ្ញុំហ៊ានតវ៉ាជាប់ជាមួយតាម៉ុក ។ ខ្ញុំអត់ខ្លាចទេ ដល់ចឹងខ្ញុំយកមកដោះស្រាយប្រជាជនហ្នឹង គាត់បានហូបបានចុកអាហ្នឹង"] ។

[207] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ណុប ង៉ឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285**, ឆ:31-59។

[208] *សូមមើល ជាឧទាហរណ៍ក្នុង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ឿន ចុះថ្ងៃទី ២១ ដល់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៤ ឯកសារ **D118/242** ស-ឆ:55 [ខឹម ឿន គឺជាប្រធានគណៈឃុំជាងទង និងក្រោយមកបានក្លាយជាសមាជិកស្រុកត្រាំកក់រហូតដល់របបនេះដួលរលំ៖ "ស៖ តើលោកស្រីស្គាល់ តា ម៉ុក ដែរឬទេ? ឆ:55៖ ចាស ខ្ញុំស្គាល់។ តា ម៉ុក ជាអ្នកដើរមើលការងារតាមសហករណ៍ និងតាមឃុំ"] ស-ឆ:56 ["ស៖ តើលោកស្រីស្គាល់ តា ម៉ុក ដោយផ្ទាល់ទេ? ឆ:56៖ ចាស ខ្ញុំស្គាល់គាត់ផ្ទាល់។ មានពេលខ្លះគាត់ចុះមកមើលកន្លែងបាយនៅតាមសហករណ៍ គាត់បានសួរប្រជាជន

បាត់ដំបង និងក៏ជាអ្នកមានស្រុកកំណើតដូចគ្នានៅភូមិភាគនិរតី[209] ហើយថា *តា ម៉ុក* គឺជាអ្នកដែលបានចាត់តាំងអ្នកស្រីឱ្យធ្វើការងារនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយព្យ[210] ហើយថាលេខាស្រុកសំឡូតជាអ្នកបានចូលរួមប្រជុំជាប្រចាំជាមួយ *តា ម៉ុក* បូករួមទាំងកិច្ចប្រជុំទ្រង់ទ្រាយធំនានា[211] ។ យោងតាមសម្តីរបស់អតីតប្រធានឃុំម្នាក់បានឱ្យដឹងថា "នរណាៗក៏ស្គាល់ *តា ម៉ុក*

---

អំពីការហូបចុកឆ្អែតដែរឬទេ។ តា ម៉ុក ចុះមើលគ្រប់ទីកន្លែងទាំងអស់។ ខ្ញុំធ្លាប់ជួបតា ម៉ុក"]។ កំណត់ហេតុនៃការស្តាប់ចម្លើយ មូល អេង, ចុះថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:55 [មូល អេង គឺជាលេខាស្រុកបវេលក្នុងតំបន់ ៣៖ "គេហៅមកជួបនៅសាកលវិទ្យាល័យបាត់ដំបង ដែលមាន តា ម៉ុក មករៀបចំការប្រជុំ ហើយមានអ្នកមកចូលរួមប្រជុំគឺ យាយ ចែម តា បូ ប្រហែលជាមាន តាអាន មួយទៀត។] ឆ:56 ["កាលនោះគេប្រជុំស្រុក និងតំបន់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយ នាង អ៊ួច ហៅ សាន ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D118/172** ឆ:33 [នាង អ៊ួច និយាយថា គាត់គឺជាជំនួយការនៅក្រោមស្រុកកោះអណ្តែត៖ "តា ម៉ុក បានហៅខ្ញុំមកជួបនៅទីរួមខេត្តតាកែវ ហើយប្រាប់ថាមានមនុស្សរាយការណ៍ពីខ្ញុំច្រើនរឿងណាស់។ ខ្ញុំបានសួរគាត់ថា "រឿងអីខ្លះ?" តា ម៉ុក ឆ្លើយថា "មិនបាច់ដឹងទេ ឯងដឹងហើយ"។ គាត់និយាយទៀតថា "ឥឡូវជួយធ្វើការគេ មិនបាច់តែងតាំងអីទេ"។ គាត់ឱ្យខ្ញុំទៅជួយធ្វើនៅលាយបូរក្នុងស្រុកត្រាំកក់ ព្រោះកន្លែងនេះនៅជិតនឹង តាម៉ុក។ ក្រោយមកទើបខាងស្រុកគេហៅខ្ញុំទៅប្រជុំជាមួយនឹងគេ។] ឆ:34 ["គាត់មិនបានប្រាប់ខ្ញុំនោះទេ គ្រាន់តែប្រាប់រឿងខ្ញុំមួយប៉ុណ្ណោះគឺថាខ្ញុំរពិសដៃ ប្រហែលជារឿងជាមួយមនុស្សស្រីហើយ។"] ឆ:35-36, ស:37 ["ស៖ ដូច្នេះមានន័យថា តា ម៉ុក មានគំនិតចង់ការពារលោកទើប តា ម៉ុក ដកលោកពីស្រុកកោះអណ្តែតមកលាយបូរវិញ។ តើត្រឹមត្រូវដែរឬទេ? ឆ:37៖ បាទ គាត់ចង់ការពារខ្ញុំ"] ឆ:38 ["បើសិនជា តា ម៉ុក ចង់ផ្លាស់ខ្ញុំមកនៅលាយបូរ គឺគាត់អាចនិយាយដូច្នេះបាន។"] ឆ:39 ["មិនដែលមានការប្រេះឆាអ្វីជាមួយនឹង [តាម៉ុក] នោះទេ។ តា ម៉ុក គាត់ជាអ្នកដឹកនាំ"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ រុំ, ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108** ឆ:134 ["អត់ទេ ខ្ញុំមិនមែនជាប្រធានកងទេ។ ប៉ុន្តែ ដោយសារខ្ញុំស្នាក់នៅជាមួយនឹងប្រធានកង នៅពេលពួកគាត់ត្រឡប់មកពីប្រជុំវិញ ខ្ញុំក៏សួរនាំគាត់អំពីរឿងប្រជុំជាមួយ តា ម៉ុក។ ប្រធានដែលប្រាប់ខ្ញុំហ្នឹងគឺឈ្មោះភាព (ស្រី)។ សព្វថ្ងៃនេះ ខ្ញុំមិនដឹងថាគាត់រស់នៅទីណាទេ"]។

209 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ង៉ឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:2 ឆ:29។

210 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ង៉ឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:41។

211 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ង៉ឹម ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/298** ឆ:13-14។ កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ង៉ឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:55-56។

ដែរ"[212] ។

៧៤. ដូចបានពិភាក្សាខាងលើ ហេតុសេចក្តីទាំងនោះ មានតម្លៃភស្តុតាងតិចតួចណាស់ ឬក៏គ្មានតែម្តង ដែលអាចគាំទ្រលើការសន្និដ្ឋានដែលថា អ្នកស្រី អ៊ឹម ចែម មានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ។ ទោះក្នុងករណីណាក៏ដោយ ដូចនឹងគ្រោងយកមកពិភាក្សានៅផ្នែកខាងក្រោម បើទោះជាអ្នកស្រីមានទំនាក់ទំនងពិសេសជាមួយនឹង *តា ម៉ុក* ក្តី ក៏គ្មានភស្តុតាងណាមួយបង្ហាញថា ទំនាក់ទំនងនេះបានផ្តល់សិទ្ធិអំណាច ឬការទទួលខុសត្រូវបន្ថែមណាមួយ ហួសពីការចាត់តាំង *ស្របច្បាប់*[213] ដែលអ្នកស្រីមាននោះទេ ។

### ២. ភាពមិនសមទំនងទាល់តែសោះដែលថា អ្នកស្រី អ៊ឹម ចែម អាចមានតួនាទីសំខាន់ទាក់ទងនឹងបញ្ហាសន្តិសុខក្នុងនាមជាកម្មាភិបាលនារី

៧៥. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចនៅថ្នាក់ស្រុក និងតំបន់ និងទាំងក្នុងភូមិភាគនិរតី និងពាយព្យ[214] ព្រមទាំងមានសិទ្ធិអំណាចគ្រប់គ្រងលើមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា[215] ។ ទោះជាយ៉ាងណាក្តី ក្រុមការពារក្តីសូមអះអាងថា ភស្តុតាងបង្ហាញឱ្យឃើញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចបន្តិចបន្តួចតែប៉ុណ្ណោះ ហើយដែលមួយផ្នែកធំ គឺដោយសារប្រព័ន្ធយេនឌ័រជាទូទៅ ដែលតាមរយៈកត្តានេះ វាមិនសមទំនងទាល់តែសោះដែលថាកម្មាភិបាល*នារី* អាចមានតួនាទីសំខាន់ណាមួយក្នុងកិច្ចការទាក់ទងនឹងបញ្ហាសន្តិសុខ ។

---

212 កំណត់ហេតុនៃការស្តាប់ចម្លើយ នុត នៅ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D118/34** ឆ:30។

213 *សូមមើល* ជារួម ចម្លើយតប នៅកថាខណ្ឌ ៨៣-១៤២។

214 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៥-៩៦ និងកថាខណ្ឌ ១០១-១០ (ក្នុងផ្នែកពិភាក្សាពីភូមិភាគនិរតី)។ នៅកថាខណ្ឌ ៩៧-១០០, ១១៤-១៨ (ក្នុងភូមិភាគពាយព្យ)។ នៅកថាខណ្ឌ ២ និងកថាខណ្ឌ ៥៣០-៣១ (ក្នុងផ្នែកពិភាក្សាពីភូមិភាគនិរតី និងភូមិភាគពាយព្យ)។

215 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៥៧-៧២ (ក្នុងផ្នែកពិភាក្សាពីភូមិភាគនិរតី)។នៅកថាខណ្ឌ ១៧៣-២៩៣ (ក្នុងផ្នែកពិភាក្សាពីភូមិភាគពាយព្យ)។ នៅកថាខណ្ឌ ២ និងកថាខណ្ឌ ៥៣០-៣១ (ក្នុងផ្នែកពិភាក្សាពីភូមិភាគនិរតី និងភូមិភាគពាយព្យ)។

៧៦. បើទោះបីជាគោលដៅដែលបានកំណត់ដោយ*អង្គការ* ថា បុរស និងស្ត្រី មានភាពស្មើគ្នានៅលើគ្រប់ផ្នែកក៏ដោយ[216] ក៏តវិយាបថវប្បធម៌ចំពោះស្ត្រីនៅតែមិនបាត់បង់ឡើយ ពោលគឺ ស្ត្រីមានទំនាក់ទំនងជាមួយ "តួនាទីចិញ្ចឹមបីបាច់គ្រួសារ"[217] ។ ត្រង់ប្រការនេះ មានភស្តុតាងជាច្រើនដែលបានភ្ជាប់កម្មាភិបាលនារីទៅនឹងតួនាទីជាពេទ្យ និងគិលានុបដ្ឋាយិកា បង្ហាញឱ្យឃើញថា ស្ត្រីត្រូវបានរំពឹងថានឹងត្រូវបំពេញតួនាទីដែលត្រូវបានចាត់ទុកថាសមស្របសម្រាប់ភេទរបស់ពួកគាត់[218] ។ ក្នុងការអនុវត្តជាក់ស្តែង បុរស និងស្ត្រីត្រូវបានបែងចែកយ៉ាងតឹងរ៉ឹង ជាវចនាសម្ព័ន្ធស្របគ្នាចំនួនពីរ ដែលតួនាទីរបស់ពួកគេត្រូវបានបែងចែងដាច់ពីគ្នាយ៉ាងច្បាស់លាស់[219] ។ ខ្មែរក្រហមខកខាន

---

216 ឯកសារច្បាប់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមានចំណងជើង "រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារ **D1.3.20.2**, មាត្រា ១៣ ["ត្រូវមានសមភាពពេញទីរវាង ប្រជាជនកម្ពុជាទាំងអស់ ក្នុងសង្គមកម្ពុជាមួយស្មើភាពយុត្តិធម៌ ប្រជាធិបតេយ្យ សុខដុមរមនា មានសុភមង្គល ក្នុងសាមគ្គីភាពជាតិទាំងមូល ដើម្បីការពារប្រទេស និងកសាងប្រទេសទាំងអស់គ្នា ។ បុរសស្ត្រីមានភាពស្មើគ្នាលើគ្រប់វិស័យទាំងអស់"]។

217 Jacobson T., 'Into the Fields', *Lost Goddesses: The Denial of Female Power in Cambodian History* (Nordic Studies of Asian Studies, 2008), ទំព័រ ២៣១ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៣**]។

218 *សូមមើល ជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ81។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាន់ គីម ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D118/47** ឆ:1-2។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែត ដួង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/152** ឆ:4, ឆ:22។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/150** ឆ:4។ កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី ប៊ិន សាឯម ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/576** ឆ:37-38។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង សុខឃី ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D118/60** ឆ:4។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សារុន ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥, ឯកសារ **D219/142** ឆ:73។ ទស្សនាវដ្តីទង់បដិវត្ត-លេខ ១០ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ **D6.1.748**, EN ERNs 00574386, 00574388។ ទស្សនាវដ្តីទង់បដិវត្ត លេខ ៣-៤, ខែ មីនា-មេសា ឆ្នាំ ១៩៧៨ ឯកសារ **D6.1.769**, EN ERN 00529440។

219 *សូមមើលជាឧទាហរណ៍* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D123/1/5.1c**, EN ERN 00951839 [ដែលនិយាយថា "ខាងយុវជន អប់រំយុវជន នារីអប់រំនារី។"] ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:28 [សាក្សីកត់សម្គាល់ថាគាត់គ្រប់គ្រង "ខាងនារី"]។ *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី (សក្ខីកម្មសាក្សី វង្ស សារុម (ស្រី))

មិនបានរៀបចំ "តួនាទីប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ត្រីក្នុងបដិវត្ត"[220] ឡើយ ប៉ុន្តែជ្រើសយកជម្រើសកេងប្រវ័ញ្ចកម្លាំងពលកម្មលើស្ត្រី ដោយថា វាជាការវិវឌ្ឍន៍សម្រាប់ស្ត្រីទៅវិញ[221] ។ អ្នកស្រី អ៊ឹម ចែម ខ្លួនឯងបានពន្យល់ដូច្នេះថា ស្ត្រីត្រូវបានចាត់ទុកថាទន់ខ្សោយជាងបុរស ហើយថាតួនាទីរបស់ស្ត្រីចៀសមិនផុតពីការងារផ្ទះសម្បែងទេ[222] ។ ជាឧទាហរណ៍ ខណៈដែលអ្នកស្រីស្ថិតក្នុងភូមិភាគនិរតី អ្នកស្រីទទួលបន្ទុកលើកងនារី ហើយក្នុងពេលនោះ អ្នកស្រីមានមុខងារចុះអប់រំស្ត្រីអំពីការងារកសិកម្ម និងការដាំដុះផ្សេងៗ[223] ។

៧៧. សូម្បីតែការទទួលខុសត្រូវដែលបានប្រគល់ឱ្យឥស្សរជននារីជាន់ខ្ពស់ ក៏ទាក់ទងជាមួយ "បញ្ហានានាដែលត្រូវបានគិតថាតើការទទួលខុសត្រូវទាំងនោះសមស្របសម្រាប់ស្ត្រីដែរឬទេ ដូចជា ការងារផ្នែកសង្គមកិច្ច ការអប់រំ និងវប្បធម៌"[224] ។ ទំនាក់ទំនងរបស់ស្ត្រីជាមួយបុរសដែលមានឋានៈខ្ពស់ ជាញឹកញាប់បំផុតតាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលការនេះ បង្កើតបានជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់ការទទួលបាននូវតួនាទីនៃសិទ្ធិអំណាច ឬការទទួលបានឋានៈជាន់

ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/300.1**, EN ERN 01098216 ["ប្តីខ្ញុំនៅសមរភូមិមុខ ចំណែកខ្ញុំនៅសមរភូមិក្រោយដើម្បីព្យាបាលទាហានរបួស"]។

220 Karkaria, Z. *Failure through Neglect: The Women's Policies of the Khmer Rouge in Comparative Perspective* (Concordia University Department of History, 2003) ត្រង់ទំព័រ ១ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៤**]។

221 Karkaria, Z. *Failure through Neglect: The Women's Policies of the Khmer Rouge in Comparative Perspective* (Concordia University Department of History, 2003), ទំព័រ ៣២-៣៣, ៣៩ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៤**]។

222 កិច្ចសម្ភាសន៍របស់ Smiling Toad Productions ជាមួយ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217516 ["នយោបាយចេញម៉ោថា នែ! កាលហ្នឹងនារីយើងក៏ ធ្វើការបាន អញ្ចឹងបានខំដឹកនាំស្ត្រី យើងដើម្បីតស៊ូហ្នឹង! ឈើចាប់នឹងខ្លួន (ដែល) គេមើលងាយមើលថោកថានែ! *"បង្វិលចង្ក្រានមិនជុំ"* ហើយគេចង់ ធ្វើបាប បុរសធ្វើបាប រ៉ៃ និងស្តីបន្ទោសបានតាមចិត្ត"] ។

223 កិច្ចសម្ភាសន៍របស់ Smiling Toad Productions ជាមួយ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217520។ *សូមមើលផងដែរ ជាទូទៅ* ចម្លើយតប នៅកថាខណ្ឌ ៨៤-៩១។

224 Jacobson T., 'Into the Fields', *Lost Goddesses: The Denial of Female Power in Cambodian History* (Nordic Studies of Asian Studies, 2008), ទំព័រ ២៣១ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៣**]។

ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[225] ។ អ្នកស្រី អ៊ឹម ចែម ពុំបានទទួលផលប្រយោជន៍ពីវប្បធម៌នេះទេ ។ ផ្ទុយទៅវិញ ប្ដីរបស់អ្នកស្រី អ៊ឹម ចែម ឈ្មោះ ណុប ញ៉ែន បានកាន់កាប់តួនាទីទាបជាងអ្នកស្រី[226] ។

៧៨. ការបែងចែកយេនឌ័រដ៏តឹងរ៉ឹង ត្រូវបានបង្ហាញជាក់ស្ដែងតាមរយៈបញ្ជីឈ្មោះអ្នកទោសស្ត្រីនៅមន្ទីរស-២១ ដែលត្រូវបានប្រមូល និងចងក្រងដោយសហព្រះរាជអាជ្ញា[227] និងតាមរយៈភស្តុតាងដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខមួយចំនួន ដែលស្ថិតនៅក្នុងភូមិភាគពាយព្យ ក៏ដូចជាតាមបណ្ដាទីតាំងដទៃទៀតនៃប្រទេសកម្ពុជា[228] ។ ភស្តុតាងទាំងនោះបង្ហាញឱ្យឃើញថា ស្ត្រីមិនត្រូវបានប្រគល់ឱ្យមានតួនាទីទាក់ទងនឹងផ្នែកសន្តិសុខ[229] ឬទទួលបន្ទុកលើមន្ទីរសន្តិសុខឡើយ[230] ។ ចំណុចស៊ីសង្វាក់

225 Jacobson T., 'Into the Fields', *Lost Goddesses: The Denial of Female Power in Cambodian History* (Nordic Studies of Asian Studies, 2008), ទំព័រ ២១៨, ២៣១-៣៣ [ដែលនិយាយថា យន់ យ៉ាត (ស្រី) បានរៀបការជាមួយ សុន សេន, ខៀវ ធីរិទ្ធ (ស្រី) បានរៀបការជាមួយ អៀង សារី, ហើយ ខៀវ ប៉ុណ្ណារី (ស្រី) បានរៀបការជាមួយ ប៉ុល ពត] [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៣**]។ *សូមមើលផងដែរ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ (ឯក ហឿន) ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៥ឯកសារ **E1/298.1**, EN ERNs 01096813-14 [ដែលកត់សម្គាល់ថា *យាយ* ខុម គណៈស្រុក ១០៥ រៀបការជាមួយ មាស មុត]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ តូ សេម ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D119/70/3**, EN ERN 01113667-68 [ដែលកត់សម្គាល់ថា *យាយ* កាន, ប្រពន្ធរបស់ អោ អាន, ជាអនុលេខាស្រុកជើងព្រៃ]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ណុប ធឹម ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ **D123/2/2.17a**, EN ERNs 01155559, 01155607 [ដែលនិយាយថា ណុប ធឹម (ស្រី) អនុលេខាស្រុកសំឡូត បានរៀបការជាមួយ ព្រាប កាប គណៈស្រុកសំឡូត]។

226 *សូមមើល* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D123/1/5.1c**, EN ERN 00951863។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់យុវសន្តិភាពជាមួយ អ៊ឹម ចែម, គ្មានចុះកាលបរិច្ឆេទ ឯកសារ **D219/264.1**, EN ERNs 01117949-51, 01117957។

227 បញ្ជីអ្នកទោសស្ត្រីនៅមន្ទីរស-២១ របស់ ក.ស.ព ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **E68.6**។

228 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ឯកសារ **D1**, EN ERNs 00292449-53។ 'ទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០៣ & ០០៤' (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី តុលា ឆ្នាំ ២០១៣), ដែលមាននៅលើគេហទំព័រ <https://www.eccc.gov.kh/sites/default/files/Case%20003-004%20Crime%20Sites_ENG_OCT%202013.pdf> បានចូលមើលលើកចុងក្រោយនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦។

229 ក្រុមការពារក្ដីកត់សម្គាល់ឃើញថា គ្មានអ្នកទោសស្ត្រីណាម្នាក់ក្នុងចំណោមអ្នកទោសស្ត្រីទាំង៤៩នាក់ ដែលត្រូវបានចុះបញ្ជីថាត្រូវបានចាប់ខ្លួនក្នុងភូមិភាគពាយព្យ មានតួនាទីដែលទាក់ទងនឹងសន្តិសុខឡើយ។ ប៉ុន្តែ ពួកគាត់ត្រូវបានចុះបញ្ជី

ជាមួយសក្ខីកម្មនៅសវនាការនៃសំណុំរឿង០០២/០២ របស់សាក្សី ខឹម បឿន ជាសមាជិកនៃគណៈស្រុកត្រាំកក់ក្នុងភូមិភាគនិរតី ដែលអ្នកស្រីត្រូវបានតុលាការសួរថាតើ អ្នកស្រីបានជាប់ពាក់ព័ន្ធក្នុងកិច្ចការសន្តិសុខនៅក្នុងស្រុកដែលគាត់ធ្វើការឬទេ ។ អ្នកស្រី ខឹម បឿន បានឆ្លើយដោយការភ្ញាក់ផ្អើលថា "[ខ្ញុំអត់ទទួលបន្ទុកខាងយោធាទេ] ព្រោះខ្ញុំជាស្រី "[231] ។ កម្មាភិបាលនារី ដូចជាអ្នកស្រី អ៊ឹម ចែម និង ខឹម បឿន ពុំត្រូវបានផ្តល់តួនាទី ដ៏គួរជាទុកចិត្តលើផ្នែកសន្តិសុខឡើយ ។ ពួកគាត់

---

ជាប្រពន្ធ អតីតសាស្ត្រាចារ្យ អតីតវេជ្ជបណ្ឌិត ឬពេទ្យ។ *សូមមើល* បញ្ជីអ្នកទោសមន្ទីរស-២១ ដែលត្រូវបានកំណត់អត្តសញ្ញាណជាស្ត្រី របស់ ក.ស.ព ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **E68.6**។

230 ក្រុមការពារក្តីបានពិនិត្យឡើងវិញនូវភស្តុតាងដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងគុកចំនួន ២៤ ដែលស្ថិតនៅទាំងក្នុង និងក្រៅភូមិភាគពាយព្យ និងបានរកឃើញថាទីតាំងទាំងនោះត្រូវបានគ្រប់គ្រងដោយបុរសក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ឈឿន ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D219/517** ឆ:41 [ដែលនិយាយថាមន្ទីរសន្តិសុខវត្តភ្នំធិបតី (ដែលស្ថិតក្នុងតំបន់១ នៃភូមិភាគពាយព្យ) ស្ថិតក្រោមការគ្រប់គ្រងរបស់ *តា* ជេវ មុនត្រូវបានជំនួសដោយ ភឿក]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៣ឯកសារ **D134/4** ឆ:14 [ដែលនិយាយថាមន្ទីរសន្តិសុខថ្កូល (ដែលស្ថិតនៅក្នុងតំបន់ ២ នៃភូមិភាគពាយព្យ) ត្រូវបានគ្រប់គ្រងដោយបុរសម្នាក់ឈ្មោះ ឃិន]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ ជួន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/147** ឆ:188 [ដែលនិយាយថាប្រធានមន្ទីរសន្តិសុខវត្តកណ្តាល (ដែលស្ថិតក្នុងតំបន់ ៣ នៃ ភូមិភាគពាយព្យ) គឺ *តា* ម៉ៅ]។ របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស (ឆោម សុជា) ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/399**, EN ERN 01114736, [ដែលនិយាយថាប្រធានគុកវត្តពោធិលង្ការ (ដែលស្ថិតក្នុងតំបន់ ៤ នៃភូមិភាគពាយព្យ) ឈ្មោះ *តា* ម៉ៅ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** ឆ:20 [ដែលនិយាយថា *តា* សឿន គឺជា "ប្រធានធំ" នៅមន្ទីរសន្តិសុខភ្នំត្រយូង (ដែលស្ថិតក្នុងតំបន់ ៥ នៃភូមិភាគពាយព្យ)។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/118**, EN ERN 00982278 [ដែលលើកឡើងអំពីសាក្សីម្នាក់ដែលនិយាយថាគុក និងកន្លែងសម្លាប់មនុស្សនៅចម្ការខ្នុរ (ដែលស្ថិតក្នុងតំបន់ ៥ នៃភូមិភាគពាយព្យ) ត្រូវបានគ្រប់គ្រងដោយ *តា* ញ៉ន]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ាង ភឿន ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D105/9** ឆ:33 [ដែលនិយាយថាប្រធានគុកលេខ ៨ (ដែលស្ថិតក្នុងតំបន់ ៧ នៃភូមិភាគពាយព្យ) គឺ *តា* មី]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន គឹមសេង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/522** ឆ:45 [ដែលនិយាយថា "អាន (បុរស) ជាប្រធាន" នៃមន្ទីរសន្តិសុខក្រាំងតាចាន់ (ដែលស្ថិតក្នុងតំបន់ ១៣ នៃភូមិភាគនិរតី)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខែក ញ៉េ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ឯកសារ **D107/11**, EN ERN 00804701 [ដែលនិយាយថា ផល ប្អូនថ្លៃរបស់ យ៉ុន ជាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខចម្ការស្វាយចន្ទី (ដែលស្ថិតក្នុងតំបន់ ៤២ នៃភូមិភាគកណ្តាល)]។

231 *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ,ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ (សក្ខីកម្មសាក្សី ខឹម បឿន) ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/296.1**, EN ERN 01095594។

ត្រូវបានចាត់តាំងឱ្យធ្វើការងារលើផ្នែកកសិកម្ម និងការងារទុកដាក់ផ្ទះសម្បែង ។

៧៩. សរុបសេចក្តីមក ដោយសារថា អ្នកស្រី អ៊ឹម ចែម ជាស្ត្រីមួយរូបបានកាន់កាប់តួនាទីកម្រិតទាប ក្នុងភូមិភាគទាំងពីរដែលអ្នកស្រីបានធ្វើការងារក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការឆ្លើយតបដ៏មានអានុភាពមួយ ប្រឆាំងទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងទំនាក់ទំនងរងការចោទរវាងអ្នកស្រីនឹង *តា ម៉ុក* ព្រមទាំងការជាប់ពាក់ព័ន្ធរបស់អ្នកស្រីជាមួយកិច្ចការសន្តិសុខ ដែលផ្ទុយទៅវិញ វាជាការនិយាយអំពីការមិនជាប់ពាក់ពិននឹងឧក្រិដ្ឋកម្មពាក់ព័ន្ធ និងភាពមិនអាចជឿជាក់បាននៃការចោទប្រកាន់ជារួមមកលើអ្នកស្រីទៅវិញទេ ។ បន្ទាប់ពីបានលើកឡើងនូវការពិចារណាជាទូទៅចំនួនពីរនេះ ក្រុមការពារក្តីនឹងងាកមកពិនិត្យលើបញ្ហាជាក់លាក់មួយចំនួន ដែលកើតមានឡើងនៅក្នុងសំណុំរឿងប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម វិញម្តង ។

៨០. ចំណុចជាក់លាក់៖ ជាបឋម ក្រុមការពារក្តីនឹងឆ្លើយតបទៅនឹងទឡ្ហីករណ៍សំខាន់ៗនៃសំណុំរឿងទាំងមូលរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច*ជាក់ស្តែង* និង*ស្របច្បាប់* ដែលបានផ្តល់ឱ្យអ្នកស្រីនូវទំនួលខុសត្រូវដ៏ធំធេង ក្នុងការធ្វើសេចក្តីសម្រេចនានាលើថ្នាក់ស្រុក និងតំបន់ ទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយព្យ ។ ទីពីរ ក្រុមការពារក្តីនឹងធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍ស្នូលរបស់សហព្រះរាជអាជ្ញាអន្តរជាតិមួយចំនួន ទាក់ទងនឹងការវាយតម្លៃលើបញ្ហាការ "ទទួលខុសត្រូវខ្ពស់បំផុត" ជាអំណះអំណាងដែលសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថាព្រោះតែអ្នកស្រី អ៊ឹម ចែមមានតួនាទី*ស្របច្បាប់ និងជាក់ស្តែង* នៅក្នុងភូមិភាគពាយព្យ ហើយថាអ្នកស្រី អ៊ឹម ចែម មានតួនាទីដ៏សំខាន់មួយទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ។

### គ. អ្នកស្រី អ៊ឹម ចែម មិនបានកាន់កាប់តួនាទីសំខាន់ណាមួយឡើយ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

៨១. ដីកាសន្និដ្ឋានស្ថាពរទាំងមូលរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺផ្អែកលើទឡ្ហីករណ៍មិនពិតដែល

ថា អ្នកស្រីមានតួនាទីនៃសិទ្ធិអំណាចជាក់លាក់ទាំង *ស្របច្បាប់* និង *ជាក់ស្តែង*[232] ហើយដែលតាមរយៈសិទ្ធិអំណាចនេះ អនុញ្ញាតឱ្យអ្នកស្រី "ជាប់ពាក់ព័ន្ធនឹងរាល់ការធ្វើសេចក្តីសម្រេចទាំងអស់ទាក់ទងនឹងស្រុក និងតំបន់" ទាំងនៅក្នុងភូមិភាគនិរតី[233] និងភូមិភាគពាយព្យ[234] ។ ដូចបានលើកសំអាងហេតុដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយផ្អែកលើតួនាទីប្រភេទកិច្ចការត្រួតពិនិត្យទាំងនេះ អ្នកស្រី អ៊ឹម ចែម ត្រូវបានចោទថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅក្នុងភូមិភាគទាំងពីរ[235] ។

៨២. ដូចនឹងពិភាក្សានៅខាងក្រោម ការវិភាគសត្យានុម័តលើភស្តុតាង បង្ហាញឱ្យឃើញថា អំណះអំណាងទាំងនេះត្រូវបានធ្វើឡើងដោយគ្មានមូលដ្ឋាន ។ ទីមួយ ភស្តុតាងនេះបង្ហាញថា អ្នកស្រី អ៊ឹម ចែម ពុំមានតួនាទីសំខាន់ៗក្នុងភូមិភាគនិរតីទេ និងជាពិសេស អ្នកស្រីមិនមែនជាសមាជិក *ស្របច្បាប់ និងជាក់ស្តែង* នៃគណៈតំបន់១៣ ឡើយ ។ ផ្ទុយទៅវិញ អ្នកស្រី អ៊ឹម ចែម មានតួនាទីក្នុងកងនារីនៃតំបន់១៣ ហើយការទទួលខុសត្រូវរបស់អ្នកស្រីត្រូវបានកំហិតត្រឹមការធានានូវសុខុមាលភាពរបស់ស្ត្រីប៉ុណ្ណោះ ។ ទីពីរ ភស្តុតាងនេះបង្ហាញឱ្យឃើញថា អ្នកស្រី អ៊ឹម ចែម មិនមានតួនាទីសំខាន់ៗនៅក្នុងភូមិភាគពាយព្យទេ និងជាពិសេស អ្នកស្រី មិនមែនជាសមាជិក ឬអនុលេខា *ស្របច្បាប់* និង *ជាក់ស្តែង* នៃគណៈតំបន់៥ ដែរ ។ ទីបី ភស្តុតាងនេះបង្ហាញឱ្យឃើញថា ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគពាយព្យ ត្រូវបានកំហិតតឹងរ៉ឹងត្រឹមតួនាទី *ស្របច្បាប់* និង *ជាក់ស្តែង* ជាលេខាស្រុក ដែលរួមទាំងការលើកកម្ពស់កម្រិតជីវភាពរស់នៅក្នុងស្រុកនេះ ។

---

232 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០១-០៧ (ក្នុងភូមិភាគនិរតី)។ នៅកថាខណ្ឌ ១១៤-១៨ (ក្នុងភូមិភាគពាយព្យ) ។ នៅកថាខណ្ឌ ២ និងកថាខណ្ឌ ៥៣០-៣១ (ក្នុងភូមិភាគនិរតី និងភូមិភាគពាយព្យ)។

233 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០៧។

234 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៧។

235 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០១-៥៦។

### ១. អ្នកស្រី អ៊ឹម ចែម ពុំមានតួនាទីសំខាន់ៗ នៅក្នុងភូមិភាគនិរតីឡើយ

៨៣. ក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា អ្នកស្រី អ៊ឹម ចែម មានតួនាទីដំណាលគ្នាជា "លេខាស្រុកកោះអណ្តែតផង ជាអ្នកគ្រប់គ្រងស្ត្រីនៅក្នុងតំបន់១៣ និងសមាជិកគណ:តំបន់១៣"[236] និងហេតុដូច្នេះ មានតួនាទីដ៏សកម្មក្នុងកិច្ចប្រជុំថ្នាក់តំបន់ដែល "មេដឹកនាំតំបន់រួមទាំង [អ្នកស្រី] អ៊ឹម ចែម បាននិយាយ...អំពីបញ្ហានានាដូចជាការកំណត់អត្តសញ្ញាណ 'ខ្មាំង' ផ្ទៃក្នុង"[237] ។ ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម "ជាប់ពាក់ព័ន្ធនឹងរាល់ការធ្វើសេចក្តីសម្រេចទាំងអស់ដែលទាក់ទងនឹងតំបន់" នៅភូមិភាគនិរតី[238] ជាការបង្ហាញពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មក្នុងភូមិភាគនិរតី[239] (ដែលឧក្រិដ្ឋកម្ម

---

236 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០៧។

237 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦៥ (ជើងទំព័រ ២៦៤)។

238 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០៧។

239 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥២-៥៨ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើមនុស្សឃាត ដោយយោងទៅវត្តអង្គស្រីមាលី ព្រៃសុខុន ស្រុកកោះអណ្តែត តំបន់ ១៣ និងខ្មែរក្រោម] នៅកថាខណ្ឌ ៤៥៩-៦១ [ដែលកំណត់បទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ការសម្លាប់រង្គាលដោយយោងទៅកតំបន់ ១៣ វត្តអង្គស្រីមាលី ព្រៃសុខុន និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៦៤-៦៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ការដាក់ក្នុងមន្ទីរឃុំឃាំង ដោយយោងទៅវត្តអង្គស្រីមាលី និងខ្មែរក្រោម] ។ នៅកថាខណ្ឌ ៤៦៨-៧១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ការធ្វើទារុណកម្មដោយយោងទៅវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៧២-៧៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយយោងទៅវត្តអង្គស្រីមាលី, ស្រុកកោះអណ្តែត, តំបន់ ១៣ និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៧៦-៧៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការរំលោភផ្លូវភេទដោយយោងទៅវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៨២-៨៣ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការបាត់ខ្លួនដោយបង្ខំដោយយោងទៅវត្តអង្គស្រីមាលី និងតំបន់១៣]។ នៅកថាខណ្ឌ ៤៨៤-៨៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិក្នុងទម្រង់អំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ដោយយោងទៅវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៩៣-៩៤ [ដែលកំណត់ជាឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយចេតនា ជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវដោយយោងទៅវត្តអង្គស្រីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៥-៩៦ [ដែលកំណត់ជាឧក្រិដ្ឋកម្មនៃការប្រព្រឹត្តិដោយអមនុស្សធម៌ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវដោយយោងទៅវត្តអង្គសិរីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៧ [ដែលកំណត់ជាបទល្មើសនៃការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ដែលជាការបំពានធ្ងន់ធ្ងរលើ

ទាំងអស់នោះពុំស្ថិតក្នុងការជូនដំណឹងអំពីបទចោទប្រកាន់នោះទេ[240]) ។ ការវាយតម្លៃដ៏សមហេតុផលលើភស្តុតាង បង្ហាញថា អ្នកស្រី អ៊ឹម ចែម ពុំត្រូវបានតែងតាំងជាសមាជិកនៃគណៈតំបន់១៣ នោះទេ និងមិនដែលមានសិទ្ធិ ឬអំណាចពាក់ព័ន្ធ ឬសិទ្ធិអំណាចស្រដៀងគ្នាទាំង *ស្របច្បាប់* និង *ជាក់ស្តែង* ឡើយ។

### i. *អ្នកស្រី អ៊ឹម ចែម ពុំមែនជាសមាជិកស្របច្បាប់នៃគណៈតំបន់១៣ ក្នុងភូមិភាគនិរតីនោះទេ*

៨៤. សហព្រះរាជអាជ្ញាអន្តរជាតិបានដកស្រង់ឯកសារសំអាងចំនួន២៤ឯកសារ[241] ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម "ត្រូវបានតែងតាំងជាសមាជិកនៃគណៈតំបន់១៣" ។ ទោះជាយ៉ាងណាក្តី ទំហំនៃឯកសារសំអាងពុំគួរត្រូវបានភ័ន្តច្រឡំជាមួយភាពអាចជឿជាក់បាន ឬភាពអាចទុកចិត្តបាននៃឯកសារទាំងនោះឡើយ ។ ដូចនឹងត្រូវគូសបញ្ជាក់ខាងក្រោម ឯកសារសំអាងទាំង២៤ឯកសារនោះ ផ្តល់ការគាំទ្រតិចតួចដល់ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបង្ហាញឱ្យឃើញពីសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចរបស់អ្នកស្រី អ៊ឹម ចែម តាមរយៈការប្រៀបធៀបនូវតួនាទីរបស់អ្នកស្រីក្នុងកងនារីនៃតំបន់១៣ ទៅនឹងសមាជិកភាពនៃគណៈតំបន់១៣ ។ ការសំអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើឯកសារសំអាងទាំងនេះ ខ្វះការតាំងចិត្តដូចដែលបានតម្រូវក្នុងការអះអាងដោយភាពប្រត្យក្ស និងការស្វែងរកឱ្យឃើញការពិត ។ ឯកសារសំអាងដែលត្រូវបានដកស្រង់ មិនអាចគាំទ្រសេចក្តីសន្និដ្ឋានដែលបានសំអាងចំពោះការដែលថា អ្នកស្រី អ៊ឹម ចែម ត្រូវបានតែងតាំងជាសមាជិកនៃគណៈតំបន់១៣ ឬជាជម្រើសម្យ៉ាងទៀតថា តួនាទីរបស់អ្នកស្រី

អនុសញ្ញាក្រុងហ្សឺណែវដោយយោងទៅរកវត្តអង្គស្រីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៨-០០ [ដែលកំណត់ជាបទល្មើសនៃការដកហូតដោយចេតនានូវការជំនុំជម្រះដោយយុត្តិធម៌ និងទៀងទាត់ ក្នុងលក្ខណៈជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកវត្តអង្គស្រីមាលី តំបន់១៣ និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៥០១-០៣ [ដែលកំណត់ជាបទល្មើសនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាហ្សឺណែវដោយយោងទៅរកតំបន់ ១៣ និងខ្មែរក្រោម]។

240 *ប្រៀបធៀប* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1**។

241 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) និងកថាខណ្ឌ ១០៧ (ជើងទំព័រ ៥០៩)។

នៅក្នុងកងនារីនៃតំបន់១៣ គឺមានន័យថាជាសមាជិកភាពក្នុងគណៈតំបន់១៣ ទៅកើតនោះទេ ។

៨៥. សាក្សី មូល អេង បានផ្តល់ការពិពណ៌នាដ៏មានប្រយោជន៍អំពីយុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាចំពោះការស្វែងរកការពិត ។ ដូចសាក្សីដទៃទៀតដែរ មូល អេង ដែលត្រូវបានសំអាង នឹងត្រូវលើកឡើងក្នុងការពិភាក្សាផ្នែកខាងក្រោម ស្តីពីការគាំទ្រលើអំណះអំណាងដែលថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកនៃគណៈតំបន់១៣[242] ។ តាមការសន្និដ្ឋានរបស់ខ្លួនពីដំបូង មូល អេង បានគូសបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម "អាច" ជាអ្នកបន្តវេនពី *តា* សោម (អតីតលេខានៃគណៈ[តំបន់]) ក្នុងគណៈតំបន់១៣[243] ។ ការសន្និដ្ឋានស្មានៗនេះ គឺពុំផ្អែកលើការដឹងឮដោយផ្ទាល់ឡើយ ប៉ុន្តែផ្អែកលើ "ការឮជាទូទៅ"[244] ។ វាកាន់តែច្បាស់នោះគឺថា "ជំនឿ" ដែល មូល អេង មាន គឺផ្អែកលើការផ្សាយសំឡេងរបស់វិទ្យុខ្មែរក្រហមតែមួយមុខគត់[245] ដែលក្នុងពេលនោះ មានការប្រកាសថា អ្នកស្រី អ៊ឹម ចែម រួមទាំងបុគ្គលចំនួន ២៩ រូបដទៃទៀតជា "តំណាងកសិករភូមិភាគនិរតី"[246] ។ ទីបំផុត តាមរយៈការឮដូច្នេះ មូល អេង បានពន្យល់ថា អ្នកស្រី អ៊ឹម ចែម ជាប្រធានគណៈដឹកនាំស្ត្រីនៃតំបន់១៣[247] ។

៨៦. ស្រដៀងគ្នានេះ ទាក់ទងនឹងឯកសារសំអាងផ្សេងៗទៀតចំនួន ២៣ សហព្រះរាជអាជ្ញាអន្តរជាតិ

---

242 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:26-29, ឆ:31 ឆ:127-30, ឆ:133, ឆ:135-37, ឆ:140-47, ឆ:187-88។

243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:28។

244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:140។

245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:31។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:130។

246 វិទ្យុភ្នំពេញ, 2300 GMT ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៦ SWB ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ FE/5166/B/2 ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ **D1.3.23.1**, EN ERN 00087743។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:138-39។

247 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:141-42។

សំអាងលើ៖

- ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំ[248] ដែលអ្នកដាក់ពាក្យសុំមិនដែលត្រូវបានស្ដាប់ចម្លើយដោយ ក.ស.ច.ស នោះទេ ។ ជាការឆ្លើយតបនឹងសំណួរ "តើអ្នកណាដែលអ្នកជឿថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ហើយមូលហេតុអ្វីបានជាអ្នកជឿជាក់បែបនេះ?" អ្នកដាក់ពាក្យសុំតាំងខ្លួននីមួយៗក្នុងចំណោមអ្នកដាក់ពាក្យសុំទាំងប្រាំបានផ្ដល់ចម្លើយម្នាក់មួយបន្ទាត់ ដោយចោទថា អ្នកស្រី អ៊ឹម ចែម មានតួនាទីក្នុងគណៈតំបន់១៣[249] ឬ បង្ហាញឱ្យឃើញថា អ្នកស្រីជា "ប្រធានធំ"[250] ។ ដោយភាពស៊ីសង្វាក់ជាមួយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការមិនស្ដាប់ចម្លើយពួកគាត់[251] ចម្លើយមួយបន្ទាត់នេះ គ្មានតម្លៃជាភស្ដុតាងឡើយ ។ ចម្លើយទាំងនេះមិនអាចបញ្ជាក់ការពិតឱ្យគ្នាទៅវិញទៅមកបានទេ ។ ចម្លើយទាំងនេះ

---

[248] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០៧ (ជើងទំព័រ ៥០៩) *ដោយយោងទៅលើ* ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យ៉ាយ គឹមលៀង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D5/1528**, EN ERN 01133186។ ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ធង ភួន ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1304**, EN ERN 01144492។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តែម ជ្រន ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **D5/1133**, EN ERN 01144435។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ភ្លី លី ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D5/1615**, EN ERN 01168228។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គង់ សាមី ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D5/1303**, EN ERN 01191036។

[249] *សូមមើល* ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ធង ភួន ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1304**, EN ERN 01144492។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តែម ជ្រន ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **D5/1133**, EN ERN 01144435។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ភ្លី លី ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **D5/1615**, EN ERN 01168228។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គង់ សាមី ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D5/1303**, EN ERN 01191036។

[250] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យ៉ាយ គឹមលៀង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D5/1528**, EN ERN 01133186។

[251] *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២៤), សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្ដុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ **D164/4/13** នៅកថាខណ្ឌ ៣៦ [សហចៅក្រមស៊ើបអង្កេតបានបញ្ចប់រាល់កិច្ចស៊ើបសួរទាំងអស់ដែលខ្លួនចាត់ទុកថាចាំបាច់ ដើម្បីបង្ហាញការពិតទាក់ទងទៅនឹងអង្គហេតុដែលចែងនៅក្នុងដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"]។ *សូមមើលផងដែរ* វិធានផ្ទៃក្នុង វិធាន ៥៥(៥)(ក)។

ពុំត្រូវបានបង្ហាញថាបានផ្អែកលើការដឹងឮដោយសាក្សីផ្ទាល់ភ្នែក ហើយក៏មិនអាចឱ្យជឿជាក់បានដែរ ។

- សាក្សីបីរូបដែលជាក់ស្តែងខ្វះការយល់ដឹងអំពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគនិរតី[252]៖ តួយ៉ាង អ៊ឹង ជឿន បានគូសបញ្ជាក់ចំនួនពីរលើកថា គាត់ "មិនដឹង" អំពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ច្បាស់លាស់ឡើយ[253] ។ ស្រដៀងគ្នានេះ សុខ រុំ បាននិយាយថា អ្នកស្រីនៅក្មេងពេកកាលពីពេលនោះ មិនអាចចាំឈ្មោះអ្នកធ្វើការក្នុងគណៈតំបន់១៣អស់ទេ[254] ។ ដូចការបញ្ជាក់អះអាងដោយ ជៀម ជ្រៀវ ដូច្នោះដែរ បើទោះបីជាគាត់បានសន្និដ្ឋានថា "អ្នកណាៗក៏ដឹងថា" អ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងគណៈតំបន់នៅខេត្តតាកែវក៏ដោយ[255] ក៏គាត់មិនបានដឹងអំពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ឡើយ[256] ។

- ឯកសារសំអាងចំនួន ១០៖ ឯកសារសំអាងទាំងនេះ មានការរៀបរាប់នូវដំណើររឿងរបស់សាក្សីចំនួន ៦ នាក់ ដែលអ្នកទាំងនេះ មិនបានបញ្ជាក់អះអាងថា អ្នកស្រី អ៊ឹម ចែម ជាសមាជិកនៃគណៈតំបន់១៣ ប៉ុន្តែផ្ទុយទៅវិញ ពួកគាត់បានបញ្ជាក់អះអាងថា អ្នកស្រីជាតំណាង

---

252 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:15-17។ កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108** ឆ:45-47។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀម ជ្រៀវ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **D119/13** ឆ:6-7។

253 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:15 ["ខ្ញុំធ្លាប់ឮឈ្មោះ*យាយ* ចែម។ ខ្ញុំមិនដឹងថាយាយចែម មានតួនាទីអ្វីច្បាស់ទេ"], ស-ឆ:16 ["ស៖...តើមានន័យថា យាយ ចែម មានតួនាទីនៅថ្នាក់តំបន់ ឬមួយក៏គាត់ត្រូវបានតែងតាំងធ្វើជាគណៈស្រុកផ្សេងៗជាបន្តបន្ទាប់គ្នា? ឆ៖ ខ្ញុំ មិនដឹងពីតួនាទីពិត ប្រាកដរបស់*យាយ* ចែម ទេ"]។

254 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108**, ស-ឆ:12 ["ស៖...តើលោកស្រីដឹងអ្វីខ្លះពីតំបន់១៣? ឆ:12៖ ខ្ញុំចាំមិនច្បាស់ទេ។ ខ្ញុំមិនចាំឈ្មោះគណៈតំបន់ ១៣ ទេ ព្រោះខ្ញុំនៅក្មេង"]។

255 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀម ជ្រៀវ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **D119/13** ឆ:6 ["មូលហេតុដែលខ្ញុំដឹងថា យាយ ចែម ហ្នឹងមានឋានៈជាគណៈខេត្តតាកែវ ដោយសារតែអ្នកណាៗ ក៏ដឹងថាគាត់ជាគណៈខេត្តដែរ ដោយសារតែគាត់តែងតែឱ្យខ្ញុំហៅមនុស្សក្នុងភូមិឃុំមកប្រជុំនៅតាមការដ្ឋានចល័ត"]។

256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀម ជ្រៀវ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **D119/13**, ស-ឆ:10 ["ស៖ តើប្រពន្ធរបស់ តា ញ៉ែន [អ្នកស្រី អ៊ឹម ចែម] មានតួនាទីអ្វីដែរ? ឆ:10៖ ខ្ញុំអត់ដឹងទេអំពីតួនាទីរបស់ប្រពន្ធតាញ៉ែន"]។

ស្ត្រីក្នុងតំបន់នោះ[257] ។ សាក្សី ខឹម បឿន[258] តឹប ភី[259] ពេជ្រ ជីម[260] ប៊ុន ធឿន[261] ម៉ឹង វេត[262] និង សៅ វ៉ន[263] សុទ្ធតែបានលើកឡើងស្របគ្នាថា អ្នកស្រី អ៊ឹម ចែម គឺជាអ្នកគ្រប់គ្រងស្ត្រីក្នុងតំបន់១៣[264] ។

257 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន, ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:74-77។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តឹប ភី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/521** ឆ:63។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជីម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D118/259** ឆ40-41 ឆ:45។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជីម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D118/79** ឆ:6។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D118/274** ឆ:28-32, ឆ:55, ឆ:72។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/83** ឆ:18-19។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/84** ឆ:19។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ វ៉ន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **D119/15** ឆ:12។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១-២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/488** ឆ:36, ឆ:109។

258 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:75 ["*យាយ* ចែម គាត់ជាអ្នកគ្រប់គ្រងនារីតំបន់ ១៣"] ឆ:108 ["ខ្ញុំបានឃើញគាត់នៅមន្ទីររបស់គាត់ដែលគ្រប់គ្រងខាងនារី"] ឆ:109 ["គាត់គ្រប់គ្រងកម្មាភិបាលនារីទាំងអស់នៅក្នុងតំបន់"]។

259 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តឹប ភី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/521** ឆ:63 ["គាត់កាន់កងនារីថ្នាក់តំបន់ ក្នុងតំបន់ ១៣"]។

260 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជីម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D118/259** ឆ:41 [ដែលនិយាយថាមានស្ត្រីចំនួន៤នាក់ រួមទាំងអ្នកស្រី អ៊ឹម ចែម ទទួលខុសត្រូវខាងនារីក្នុងតំបន់ ១៣]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជីម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D118/79** ឆ:6 ["គាត់នៅកាន់ខាងគណៈកៀងគរនារីរបស់តំបន់ ១៣ តែគាត់មិនមែនជាគណៈតំបន់ទេ"]។

261 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/274** ឆ:28-29 [ដែលនិយាយថាអ្នកស្រី អ៊ឹម ចែម ជាប្រធានសមាគមនារីរបស់តំបន់១៣ និង ប្រហែលបានក្លាយជាសមាជិកតំបន់១៣ទៀតក៏មិនដឹង] ។

262 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/83** ឆ:19 ["ខ្ញុំត្រូវបានគេចាត់តាំងឱ្យធ្វើការនៅមន្ទីរ ១៦០ នៅអំឡុងពេលនោះដែលខ្ញុំដឹងថា *យាយ* ចែម គាត់ទទួលខុសត្រូវអង្គភាពនារីតំបន់ ១៣"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១-២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/488** ឆ:36 ["*យាយ* ចែម ជាប្រធាននារីតំបន់ (តំណាងរាស្ត្រតំបន់)"]។ ឆ:109 ["*យាយ* ចែម គាត់ប្រធាននារីតំបន់១៣ ក្រោយមកគាត់ផ្លាស់មកតំបន់ពាយព្យ"]។

៨៧. វាមានសារៈប្រយោជន៍ក្នុងការពិនិត្យឱ្យកាន់តែល្អិតល្អន់ថែមទៀត លើឯកសារសំអាងមួយចំនួនក្នុងចំណោមឯកសារសំអាងទាំង១០នេះ ។ បើទោះបីជាឯកសារទាំងនេះត្រូវបានប្រើជាសំអាងក៏ដោយ ក៏ឯកសារទាំងនេះមិនត្រឹមតែពុំបានផ្តល់ការគាំទ្រណាមួយចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប៉ុណ្ណោះទេ គឺថែមទាំងបង្ហាញអំពីភាពមិនត្រឹមត្រូវនៃការចោទប្រកាន់ទៀតផង ។ ពេជ្រ ជឹម ជាសាក្សីម្នាក់ក្នុងចំណោមសាក្សីនានាដែលត្រូវបានសំអាងលើ[265] បាននិយាយយ៉ាងច្បាស់ថា អ្នកស្រី អ៊ឹម ចែម "មិនមែនជាគណៈតំបន់ទេ"[266] ។ ពេជ្រ ជឹម អាចគាំទ្រអំណះអំណាងប្រកបដោយអត្ថន័យពីភស្តុតាងផ្ទាល់ ដែលមានភាពសំខាន់ស៊ីសង្វាក់គ្នាដ៏លម្អិត ។ នៅពេលត្រូវបានសួរអំពីរចនាសម្ព័ន្ធនៃគណៈតំបន់១៣ សាក្សីបានបង្ហាញភាពខុសគ្នាដ៏ជាក់លាក់មួយរវាងកម្មាភិបាលទាំងឡាយដែលស្ថិតនៅក្នុងគណៈកម្មាធិការនេះ និងអ្នកដទៃទៀត រួមទាំងអ្នកស្រី អ៊ឹម ចែម ដូចតទៅនេះ៖

> ស៖...ចុះបើ [អ្នកស្រី] ចែម មិនមែនជាគណៈតំបន់ តើអ្នកណាជាគណៈតំបន់?
>
> ឆ៤១៖ គណៈតំបន់ឈ្មោះ សោម, មុត និងផែន។ យាយ ចែម គាត់ធ្វើការងារខាងនារីក្នុងតំបន់១៣។ មាននារីបីនាក់ដែលទទួលខុសត្រូវខាងនារីតំបន់គឺមានឈ្មោះ យាយចែម ឬ

---

263 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វ៉ន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **D119/15** ឆ:12 ["ខ្ញុំគ្រាន់តែដឹងថាពីចន្លោះឆ្នាំ ១៩៧០ ដល់៧៥ គាត់ជាគណៈអប់រំនារីប្រចាំតំបន់១៣"]។

264 កងនារីនេះត្រូវបានគេស្គាល់ក្រោមឈ្មោះផ្សេងៗដូចជា៖ សមាគមនារី [កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D118/274** ឆ:28] គណៈកៀងគរនារី [កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D118/79** ឆ:6]។ ប្រធាននារី [កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១-២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/488** ឆ:109] ឬគណៈនារីដឹកនាំ [កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:141]។

265 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ, នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D118/79** ឆ:6។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D118/259** ឆ:40-41, ឆ:45។

266 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D118/79**, ស-ឆ:6 ["ស៖ ពេលដែលលោកទៅភ្នំពេញក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៧ តើ អ៊ឹម ចែម គាត់មានតួនាទីជាអ្វីដែរ? ឆ:6៖ គាត់នៅតាកែវនៅឡើយទេ គាត់នៅកាន់ខាងគណៈកៀងគរនារីរបស់តំបន់១៣ តែគាត់មិនមែនជាគណៈតំបន់ទេ"]។

និង ភន។ នៅមាននារីម្នាក់ទៀតដែលធ្វើការជាមួយនឹងយាយ ចែម បូ និងភន ដែរតែខ្ញុំភ្លេចឈ្មោះហើយ[267]។

៨៨. សាក្សី តឹប ភី ដែលសហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមយកមកសំអាងដែរនោះ[268] ក៏បានបង្ហាញភាពខុសគ្នានេះដែរ តាមការលើកឡើងថា៖ វាមានភាពខុសគ្នាដាច់ស្រឡះ រវាងសមាជិកភាពនៃគណៈតំបន់១៣ និងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹង "កងនារីនៅថ្នាក់តំបន់១៣"[269] ។

៨៩. ដូចដែលភស្តុតាងបានបង្ហាញ សាក្សីអាចធ្វើការបែងចែកនូវភាពខុសគ្នារវាងតួនាទីទាំងពីរនេះ និងទំនួលខុសត្រូវលើការចូលរួម ។ ជាគណៈតំបន់ គឺទទួលបន្ទុកធ្វើសេចក្តីសម្រេចនានាក្នុងជួរតំបន់ទាំងមូល ពោលគឺ រាល់ថ្នាក់នីមួយៗនៃរចនាសម្ព័ន្ធចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ មានសមាជិកបីរូប (លេខា អនុលេខា និងសមាជិក) នៅក្នុងគណៈកម្មាធិការមួយ ដែលគ្រប់គ្រងតំបន់នោះ[270] ។ យោងតាមលក្ខន្តិកៈរបស់ ប.ក.ក គណៈតំបន់មានភារកិច្ច *ក្នុងចំណោមប្រការផ្សេងៗ* គឺ "កំណត់ផែនការការងារក្នុងចំណោមមហាជនឱ្យច្បាស់ និងការងារផ្ទៃក្នុងឱ្យច្បាស់ក្នុង

---

[267] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D118/259**, ស-ឆ:41។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:58-59 [ដែលរៀបរាប់ថា *តា* សោម អាចជាលេខានៃគណៈតំបន់១៣ ដែលក្រោយមកត្រូវបានជំនួសដោយ សំ ប៊ិត ដែលក្រោយមកទៀតជំនួសដោយ រ៉ន និងដែលបញ្ជាក់អះអាងថា មុត ក៏ស្ថិតក្នុងគណៈកម្មាធិការនេះដែរ]។

[268] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២ (ជើងទំព័រ ១៨០) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹប ភី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/521** ឆ:63។

[269] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹប ភី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/521** ឆ:59-60 ["ស៖ តើលោកស្រីចាំថាអ្នកណាជាគណៈតំបន់១៣ ហ្នឹង? ឆ:59៖ គឺ *តា* សោម។ ស៖ តើគាត់ជាលេខាតំបន់១៣ ឬ? ឆ:60៖ គេហៅគណៈតំបន់"] ឆ:62-63 ["ស៖ តើលោកស្រីស្គាល់ស្រីម្នាក់ឈ្មោះ អ៊ឹម ចែម នៅតំបន់១៣ ទេ? ឆ:62៖ ខ្ញុំស្គាល់ត្រឹមឈ្មោះ ហើយឃើញមុខ តែខ្ញុំគ្មានការទំនាក់ទំនងជាមួយគ្នាទេ។ ខ្ញុំគ្រាន់តែដឹងថាគាត់កាន់តួនាទីអីតែប៉ុណ្ណឹងទេ។ ស៖តើគាត់កាន់តួនាទីអ្វី? ឆ:63៖ គាត់កាន់កងនារីថ្នាក់តំបន់ក្នុងតំបន់១៣។ តែខ្ញុំមិនដែលនិយាយគ្នាជាមួយគាត់ទេ"]។

[270] *សូមមើល* របាយការណ៍អ្នកជំនាញការដោយ Craig C. ETCHESON ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ **D1.3.15.1** នៅកថាខណ្ឌ ៨។ សាលក្រមជំនុំជម្រះ, សំណុំរឿង ០០២/០១ ឯកសារ **E313** នៅកថាខណ្ឌ ២១៨។

ក្របខណ្ឌតំបន់-ក្រុងរបស់ខ្លួន”[271] ។ ពួកគាត់មាន “អំណាចទូលំទូលាយទៅលើបញ្ហាបុគ្គលិក និងបញ្ហាអង្គការចាត់តាំងសន្តិសុខ និងសេដ្ឋកិច្ចក្នុងតំបន់រៀងៗខ្លួន”[272] ។

៩០. បន្ថែមលើនេះ ដូចដែលភស្តុតាងបង្ហាញ តួនាទី*ផ្ទាល់ខ្លួន*របស់អ្នកស្រី អ៊ឹម ចែម បានធ្វើឱ្យអ្នកស្រីទទួលបន្ទុកលើផ្នែកសុខុមាលភាពស្ត្រីក្នុងតំបន់នេះ ។ អ្នកស្រីបានអប់រំស្ត្រីអំពី “វិធីដាំស្រូវ និងថែសួនដោយខ្លួនឯង”[273] តាមរយៈវគ្គរៀនសូត្រនៅតាមបណ្ដាឃុំ និងភូមិនានា[274] ។ អ្នកស្រី ខឹម បឿន ដែលជាអ្នកទទួលបន្ទុកកងនារីនៅថ្នាក់ភូមិ[275] និងនៅថ្នាក់ស្រុក[276] បានពិពណ៌នាអំពីភារកិច្ចដូចគ្នានេះ ដូច្នេះថា៖ អ្នកស្រីបានធ្វើការអប់រំស្ត្រី និងបានចែកវេនគ្នាដាំស្រូវ ព្រមទាំងបន្លែបង្ការផ្សេងៗ[277] ។ កងនារីទទួលបន្ទុកដេរសម្លៀកបំពាក់ ចែកចាយក្រណាត់ទៅតាមបណ្ដាភូមិ និងធ្វើស្រូវប្រាំង[278] ។

៩១. សរុបសេចក្ដីទៅ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីដាក់បន្ទុបសិទ្ធិអំណាចដ៏ធំធេងទៅឱ្យអ្នកស្រី អ៊ឹម ចែម តាមរយៈការប្រៀបធៀបតួនាទីមួយក្នុងកងនារីនៃតំបន់នោះ ជាមួយសមាជិកភាពនៃគណៈតំបន់១៣ គឺពុំបានផ្អែកលើភស្តុតាងឡើយ ។ អ្នកស្រី អ៊ឹម ចែម មិនបានចូលរួមក្នុងការ “ធ្វើសេចក្ដីសម្រេចណាទាំងអស់” នៅថ្នាក់តំបន់នៃភូមិភាគនិរតី ។ ដូចដែលភស្តុតាង

---

[271] ឯកសារច្បាប់ ប.ក.ក ដែលមានចំណងជើង “លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា”, គ្មានចុះកាលបរិច្ឆេទ ឯកសារ **D1.3.20.1** (“លក្ខន្តិកៈ ប.ក.ក ឯកសារ **D1.3.20.1**”) មាត្រា ១៥(២)។

[272] *សូមមើល* របាយការណ៍អ្នកជំនាញការ ដោយ Craig C. ETCHESON ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ **D1.3.15.1** នៅកថាខណ្ឌ ៥៨។

[273] កិច្ចសម្ភាសន៍ អ៊ឹម ចែម ជាមួយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217520។

[274] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D118/259** ឆ:42-43។

[275] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:8។

[276] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:28។

[277] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:8, ឆ:127។

[278] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:168។

បង្ហាញ តួនាទីរបស់អ្នកស្រី គឺស្ថិតក្នុងកងនារី និងផ្តោតជុំវិញលើការងារកសិកម្ម ។

### *ii. អ្នកស្រី អ៊ឹម ចែម ពុំមានតួនាទីជាសមាជិក ជាក់ស្តែង នៃគណៈតំបន់១៣ ឡើយ*

៩២. ដើម្បីគាំទ្របន្ថែមដល់អំណះអំណាងរបស់ខ្លួនដែលថា អ្នកស្រី អ៊ឹម ចែម គឺជា "មេដឹកនាំតំបន់១៣"[279] និងជាអ្នកបញ្ជាឱ្យមានអំពើឧក្រិដ្ឋកម្មមួយចំនួន កើតឡើងនៅភូមិភាគនិរតី[280] (ដែល

[279] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦៥។

[280] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥២-៥៨ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើមនុស្សឃាតដោយយោងទៅរកវត្តអង្គស្រីមាលី ព្រៃសុខុន ស្រុកកោះអណ្ដែត តំបន់ ១៣ និងខ្មែរក្រោម] ។ នៅកថាខណ្ឌ ៤៥៩-៦១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការសម្លាប់រង្គាលដោយយោងទៅរកតំបន់១៣, វត្តអង្គស្រីមាលី, ព្រៃសុខុន និងខ្មែរក្រោម] ។ នៅកថាខណ្ឌ ៤៦៤-៦៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការដាក់ក្នុងមន្ទីរឃុំឃាំងដោយយោងទៅរកវត្តអង្គសិរីមាលី និងខ្មែរក្រោម] ។ នៅកថាខណ្ឌ ៤៦៨-៧១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទារុណកម្មដោយយោងទៅរកវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៧២-៧៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយយោងទៅរកវត្តអង្គស្រីមាលី, ស្រុកកោះអណ្ដែត តំបន់១៣ និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៧៦-៧៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាអាពាហ៍ពិពាហ៍ដោយបង្ខំដោយយោងទៅរកតំបន់១៣]។ កថាខណ្ឌ ៤៧៨-៨១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការរំលោភសេពសន្ថវៈដោយយោងទៅរកវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៨២-៨៣ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការបាត់ខ្លួនដោយបង្ខំដោយយោងទៅរកវត្តអង្គស្រីមាលី និងតំបន់១៣]។ នៅកថាខណ្ឌ ៤៨៤-៨៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ដោយ យោងទៅរកវត្តអង្គស្រីមាលី]។ នៅកថាខណ្ឌ ៤៩៣-៩៤ [ដែលកំណត់ជាបទល្មើសនៃអំពើមនុស្សឃាតដោយចេតនាជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកវត្តអង្គស្រីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៥-៩៦ [ដែលកំណត់ជាបទល្មើសនៃការប្រព្រឹត្តិដោយអមនុស្សធម៌ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយយោងទៅរកវត្តអង្គស្រីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៧ [ដែលកំណត់ជាបទល្មើសនៃការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកវត្តអង្គស្រីមាលី និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៤៩៨-០០ [ដែលកំណត់ជាបទល្មើសនៃការដកហូតដោយចេតនានូវការជំនុំជម្រះដោយយុត្តិធម៌ និងទៀងទាត់ជាអំពើបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកវត្តអង្គស្រីមាលី តំបន់ ១៣ និងខ្មែរក្រោម]។ នៅកថាខណ្ឌ ៥០១-០៣ [ដែលកំណត់ជាបទល្មើសនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកតំបន់១៣ និងខ្មែរក្រោម]។

ឧក្រិដ្ឋកម្មទាំងអស់នោះ មិនស្ថិតក្នុងវិសាលភាពនៃការជូនដំណឹងអំពីបទចោទប្រកាន់[281]) សហ-ព្រះរាជអាជ្ញាអន្តរជាតិប៉ុនប៉ងបង្ហាញថា អ្នកស្រី អ៊ឹម ចែម បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់[282] ។ នៅត្រង់ប្រការនេះ សហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមសំអាងលើសាក្សីតែ*ម្នាក់គត់* ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម បាននិយាយ ពីបញ្ហានានានៅកិច្ចប្រជុំថ្នាក់តំបន់ ទាក់ទងនឹងការកំណត់អត្តសញ្ញាណខ្មាំងផ្ទៃក្នុង[283] ។ ប៉ុន្តែតាមរយៈការអានដោយត្រឹមត្រូវនូវកំណត់ហេតុស្តាប់ចម្លើយបានបង្ហាញឱ្យឃើញថា សូម្បីតែភស្តុតាងមួយចំណែកដាច់ពីគេនេះ ក៏មិនបានគាំទ្រអំណះអំណាងនេះដែរ ។

៩៣. នៅក្នុងការឆ្លើយតបទៅនឹងសំណួរដ៏ជាក់លាក់របស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ទាក់ទងទៅនឹងថាតើសាក្សីនេះធ្លាប់បានស្តាប់ឮអ្នកស្រី អ៊ឹម ចែម ជជែកជាចំហអំពី "ភាពចាំបាច់នៃការបោសសម្អាតខ្មាំង" នៅកិច្ចប្រជុំថ្នាក់តំបន់ដែរឬទេ[284] ជាដំបូង ខឹម បឿន បាននិយាយថាគាត់មិនចាំខ្លឹមសារនៃការពិភាក្សាទាំងនោះឡើយ[285] ។ ទោះជាយ៉ាងណាក្តី អ្នកស្រីបានពន្យល់ថា ទោះបីជាប្រធានបទនៃការបោសសម្អាតត្រូវបានពិភាក្សាក្នុងអំឡុងកិច្ចប្រជុំទាំងនោះក៏ដោយ ក៏ "នារីមិនសូវលើកឡើងអំពីបញ្ហាបោសសម្អាត ឬក៏ឃោជានោះទេ ព្រោះនារីមិនសូវយល់អំពីបញ្ហាទាំងអស់នេះ" "មានតែបុរសទេ ដែលជាអ្នកគ្រប់គ្រងបញ្ហាឃោជា ឬក៏អំពីបញ្ហាបោសសម្អាតជាដើម"[286] ។

281 *ប្រៀបធៀប* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1**។

282 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦៥ និង ១០៨។

283 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦៥ (ជើងទំព័រ ២៦៤) និង ១០៨ (ជើងទំព័រ ៥២៥)។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦៦ (ជើងទំព័រ ២៧២)។

284 កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242,** ស: 100។

285 កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:100។

286 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:100 ["ពិបាកនិយាយណាស់ ព្រោះពេលនោះគឺមាននិយាយច្រើនរឿងពេក។ ចំពោះរឿងបោសសម្អាតខ្ញុំពិបាកនិយាយណាស់ ព្រោះខ្ញុំចាំមិនច្បាស់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏រឿងបោសសម្អាតនេះគឺមានលើកឡើង។ នារីមិនសូវលើកឡើងអំពី

តាមពាក្យសម្ដីរបស់សាក្សី កម្មាភិបាលនារី "ភាគច្រើនគឺផ្នែកកុមារ មនុស្សចាស់ ឬអប់រំប៉ុណ្ណោះ"[287] ។ ជាការពិតណាស់ ការថ្លែងនេះ គឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអំណះអំណាងរបស់ក្រុមការពារក្ដីដែលត្រូវបានពិភាក្សាខាងលើ[288] ឥរិយាបថវប្បធម៌ប្រពៃណីចំពោះស្ត្រីមិនបានបាត់បង់ឡើយ ។ មុខងាររបស់ស្ត្រីផ្សារភ្ជាប់ជាមួយតួនាទី "បីបាច់ថែរក្សាគ្រួសារ"[289] ។

៩៤. ក្នុងករណីណាក៏ដោយ ខឹម បឿន ដែលធ្លាប់ជាលេខាឃុំជាងទង[290] និងដែលមានឋានានុក្រមទាបជាងតួនាទីថ្នាក់តំបន់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមដាក់បន្ទុកទៅឱ្យអ្នកស្រី អ៊ឹម ចែម[291] បានពន្យល់ថា អ្នកស្រីក៏បានចូលរួមកិច្ចប្រជុំជាមួយថ្នាក់តំបន់ដែរ[292] ។ ខឹម បឿន បានឱ្យដឹងថា ការប្រជុំទាំងនោះ ត្រូវបានដឹកនាំដោយប្រធានតំបន់ដែលជាបុរសម្នាក់[293] ។ អ្នកចូលរួមនានា ដូចជាអ្នកស្រី អ៊ឹម ចែម ឬសាក្សីដែលជារូបគាត់ផ្ទាល់ ត្រូវបានអនុញ្ញាតឱ្យសម្ដែងចំណាប់

---

បញ្ហាបោសសម្អាត ឬក៏យោធានោះទេ ព្រោះនារីមិនសូវយល់អំពីបញ្ហាទាំងនេះ។ នារីគេឱ្យធ្វើការភាគច្រើនគឺផ្នែកកុមារ មនុស្សចាស់ ឬអប់រំប៉ុណ្ណោះ។ សូម្បីតែខ្ញុំក៏ខ្ញុំមិនសូវយល់អំពីបញ្ហាយោធាដែរ។ មានតែបុរសទេដែលជាអ្នកគ្រប់គ្រងបញ្ហាយោធា ឬក៏អំពីបញ្ហាបោសសម្អាតជាដើម"។

287 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:100 ["ពិបាកនិយាយណាស់ ព្រោះពេលនោះគឺមាននិយាយច្រើនរឿងពេក។ ចំពោះរឿងបោសសម្អាតខ្ញុំពិបាកនិយាយណាស់ ព្រោះខ្ញុំចាំមិនច្បាស់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏រឿងបោសសម្អាតនេះគឺមានលើកឡើង។ នារីមិនសូវលើកឡើងអំពីបញ្ហាបោសសម្អាត ឬក៏យោធានោះទេ ព្រោះនារីមិនសូវយល់អំពីបញ្ហាទាំងនេះ។ នារីគេឱ្យធ្វើការភាគច្រើនគឺផ្នែកកុមារ មនុស្សចាស់ ឬអប់រំប៉ុណ្ណោះ។ សូម្បីតែខ្ញុំក៏ខ្ញុំមិនសូវយល់អំពីបញ្ហាយោធាដែរ។ មានតែបុរសទេដែលជាអ្នកគ្រប់គ្រងបញ្ហាយោធា ឬក៏អំពីបញ្ហាបោសសម្អាតជាដើម"។

288 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៧៥-៧៩។

289 Jacobson T., "Into the Fields", *Lost Goddesses: The Denial of Female Power in Cambodian History* (Nordic Studies of Asian Studies, 2008) ត្រង់ទំព័រ ២៣១ [ត្រូវបានភ្ជាប់ជា**ឯកសារសំអាងទី ២៣**]។

290 *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:17។

291 *សូមមើល* សេចក្ដីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២, ៥២, ១០៧, ៥១២, ៥១៤។

292 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:87។

293 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:98។

អារម្មណ៍ *នៅចុងបញ្ចប់នៃ*កិច្ចប្រជុំទាំងនោះ[294] ផ្អែកលើប្រធានបទដែលត្រូវបានលើកឡើងដោយប្រធានតំបន់[295] និងរាយការណ៍អំពីបញ្ហានានាជូនអង្គប្រជុំ ដូចជា "បញ្ហាខ្វះបាយខ្វះទឹក ជំងឺជាដើម"[296] ។ ការចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ និងការធ្វើរបាយការណ៍ផ្ទាល់មាត់ មិនមែនជារឿងចម្លែកអ្វីឡើយ ។ ប៉ុន្តែផ្ទុយទៅវិញ ការរាយការណ៍ពី "សភាពការណ៍ និងការងារដែលបានធ្វើ" ទៅថ្នាក់លើ គឺមានចែងជាក់លាក់នៅក្នុងលក្ខន្តិកៈ ប.ក.ក[297] ។ ការមានវត្តមាននៅក្នុងកិច្ចប្រជុំដែលធ្វើឡើងដោយលេខាគណៈតំបន់១៣ គឺវាគ្មានអ្វីចម្លែក ឬពិសេសទាល់តែសោះ សម្រាប់អ្នកស្រី អ៊ឹម ចែម ឬ ខឹម បឿន ។

៩៥. ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម មានតួនាទីដ៏សកម្មនៅឯកិច្ចប្រជុំថ្នាក់តំបន់ និងថា ចំណុចនេះបញ្ជាក់អំពីសិទ្ធិអំណាច *ជាក់ស្តែង* របស់អ្នកស្រី គឺជាអំណះអំណាងឥតសមហេតុផល ។ តាមពិតទៅ បើទោះបីជាភស្តុតាងមួយចំណែកនេះ អាចឱ្យជឿជាក់បាន ឬអាចបញ្ជាក់អំពីអ្វីមួយបានក៏ដោយ ក៏យោងទៅលើបន្ទុក និងបទដ្ឋានបង្ហាញភស្តុតាងអំណះអំណាងដ៏សំខាន់ និងដ៏ទូលាយបែបនេះ មិនអាចពឹងផ្អែកតែទៅលើភស្តុតាងរបស់សាក្សីត្រឹមតែម្នាក់ដូច្នេះបានឡើយ ។ ភាពសមទំនងមួយតម្រូវថា អង្គហេតុបែបនេះត្រូវតែគាំទ្រដោយសាក្សី

---

[294] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:91 ["ពេលដែលខ្ញុំឡើងនិយាយនៅក្នុងការប្រជុំនៅមន្ទីរតំបន់ គឺខ្ញុំធ្វើការចាប់អារម្មណ៍ទៅលើការលើកឡើងរបស់ ប្រធានអង្គប្រជុំ ថាតើត្រឹមត្រូវដែរឬទេ ហើយមានអ្វីបន្ថែមទៀត។...ចំពោះការប្រជុំថ្នាក់តំបន់ ភាគច្រើនគឺថ្នាក់ស្រុកជាអ្នកឡើងធ្វើការ ចាប់អារម្មណ៍ និងមានមតិយោបល់"] ឆ:98 ["អ្នកឡើងនិយាយដំបូងគឺជាប្រធានតំបន់ដែលជាមនុស្សប្រុស។ ចំណែក អ៊ឹម ចែម គឺគាត់ឡើងចាប់អារម្មណ៍នៅពេលចុងក្រោយ មានន័យថាគេឱ្យគាត់ឡើងមានមតិយោបល់លើការឡើងរបស់ប្រធានអង្គប្រជុំនោះ យ៉ាងម៉េចខ្លះ"]។

[295] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:98, ឆ:99 ["ការចាប់អារម្មណ៍ គឺវាអាស្រ័យទៅលើការលើកឡើងរបស់ប្រធានអង្គប្រជុំ។ ប្រសិនបើប្រធានអង្គប្រជុំលើកឡើងអំពី បញ្ហាទាំងអស់នេះ គឺមានន័យថា អ៊ឹម ចែម នឹងចាប់អារម្មណ៍ទៅលើបញ្ហាទាំងអស់នោះដែរ"]។

[296] កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ខឹម បឿន ថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D118/242** ឆ:88។

[297] លក្ខន្តិកៈ ប.ក.ក ឯកសារ **D1.3.20.1** មាត្រា ៦(៥) ["តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពី កិច្ចការដែលខ្លួនបានធ្វើ"] ។

ដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែក ឬឯកសារយោងដទៃទៀត ។ តាមធម្មតា សាក្សីម្នាក់មិនអាចផ្តល់ភស្តុតាងខ្លាំងក្លាគ្រប់គ្រាន់ ភាពស៊ីសង្វាក់ ឬអាចបញ្ជាក់បានពីការពិតចំពោះបញ្ហាដ៏សំខាន់មួយ ដែលសមល្មមផ្តល់ទម្ងន់លើសពីតម្លៃជាភស្តុតាងបន្តិចបន្តួចនោះឡើយ។ ជំនួសមកវិញភស្តុតាងពាក់ព័ន្ធបង្ហាញថា តួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅកិច្ចប្រជុំថ្នាក់តំបន់ ត្រូវបានកំហិតត្រឹមការតម្រូវឱ្យរាយការណ៍ និងសមត្ថភាពផ្តល់មតិយោបល់ផ្សេងៗទាក់ទងនឹងប្រធានបទទាំងឡាយ ដែលបានលើកឡើងដោយប្រធានតំបន់ ។

៩៦. សរុបមក សហព្រះរាជអាជ្ញាអន្តរជាតិពុំបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម បានអនុវត្តតួនាទី*ស្រប ច្បាប់ ឬជាក់ស្តែង* ក្នុងគណៈតំបន់១៣ នៃភូមិភាគនិរតីឡើយ ។ អ្នកស្រីមិនអាច "ជាប់ពាក់ព័ន្ធនឹងរាល់ការធ្វើសេចក្តីសម្រេចទាំងអស់ដែលមានឥទ្ធិពលទៅលើស្រុក និងតំបន់នោះ"[298] ក្នុងភូមិភាគនិរតីនោះទេ ។ ភស្តុតាងបង្ហាញថា រង្វង់នៃសិទ្ធិអំណាចរបស់អ្នកស្រីត្រូវបានកំហិតត្រឹមការជំរុញការងារកសិកម្មក្នុងចំណោមស្ត្រី ។ ក្នុងករណីណាក៏ដោយ ដោយហេតុថា អ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ពីបទល្មើសដែលបានប្រព្រឹត្តក្នុងភូមិភាគនិរតី[299] ក្រុមការពារក្តីសូមកម្រិតនូវការសង្កេតរបស់ខ្លួន ក្នុងការឆ្លើយតបនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដូចដែលបានលើកឡើងមុននេះ ។

### ២. អ្នកស្រី អ៊ឹម ចែម គ្មានតួនាទីសំខាន់ក្នុងភូមិភាគនិរតី

៩៧. ក្នុងការប៉ុនប៉ងបង្ហាញអំពីការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តក្នុងភូមិភាគនេះ[300] (ដែលឧក្រិដ្ឋកម្មភាគច្រើនក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះ

---

298 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១០៧។

299 *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1**។

300 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥២-៥៨ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើមនុស្សឃាតដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៥៩-៦១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការសម្លាប់រង្គាលដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ

---

ភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៦៤-៦៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការដាក់ក្នុងមន្ទីរឃុំឃាំង ដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៦៨-៧១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទារុណកម្មដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមបញ្ចូលទីតាំងនានាមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៧២-៧៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមបញ្ចូលទីតាំងនានា ដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៧៦-៧៧ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាអាពាហ៍ពិពាហ៍ដោយបង្ខំដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៧៨-៨១ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការរំលោភសេពសន្ថវៈដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមបញ្ចូលទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៨២-៨៣ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការបាត់ខ្លួនដោយបង្ខំដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៨៤-៨៥ [ដែលកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត-ការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៩៣-៩៤ [ដែលកំណត់ជាបទល្មើសនៃការធ្វើមនុស្សឃាតដោយចេតនាជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាហ្សឺណែវដោយយោងទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៩៥-៩៦ [ដែលកំណត់ជាឧក្រិដ្ឋកម្មនៃការប្រព្រឹត្តិដោយអមនុស្សធម៌ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាហ្សឺណែវ ដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៩៧ [ដែលកំណត់ជាបទល្មើសនៃការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាពជាការ បំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៤៩៨-០០ [ដែលកំណត់ជាបទល្មើសនៃការដកហូតដោយចេតនានូវការជំនុំជម្រះដោយយុត្តិធម៌ និងទៀងទាត់ដែលជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង]។ នៅកថាខណ្ឌ ៥០១-០៣ [ដែលកំណត់ជាបទល្មើសនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយយោងទៅរកទីតាំងនានាក្នុងភូមិភាគពាយព្យ រួមទាំងទីតាំងនានាដែលមិនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និង ការដ្ឋានស្ពានស្រែង]។

សោះ[301]) សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា អ្នកស្រី អ៊ឹម ចែម "បំពេញការងារជាលេខាស្រុកព្រះនេត្រព្រះផង និងជាសមាជិកតំបន់ ៥ ហើយបន្ទាប់មកជា អនុលេខាទៀត"[302] នៃតំបន់៥ និងថា អ្នកស្រីបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់[303] ព្រមទាំងថា អ្នកស្រីមានទំនាក់ទំនងពិសេសជាមួយ *តា ម៉ុក*[304] ។

៩៨. ដោយផ្អែកលើការចោទប្រកាន់ទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម បាន "ចូលរួមក្នុងរាល់ការសម្រេចទាំងអស់ដែលមានឥទ្ធិពលលើស្រុក និងតំបន់"[305] ធ្វើឱ្យអ្នកស្រីជាអ្នកទទួលខុសត្រូវចំពោះរាល់ឧក្រិដ្ឋកម្មដែលត្រូវបានចោទទាំងអស់ក្នុងភូមិភាគពាយព្យ ។ ដូចដែលយើងខ្ញុំនឹងពិភាក្សាខាងក្រោម វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលញ៉ាំងឱ្យមានការសន្និដ្ឋានដូច្នេះ គឺមានវិការៈជាមូលដ្ឋានតាំងពីដំបូង ។ អ្នកស្រី អ៊ឹម ចែម ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ និងបានបន្តស្ថិតក្នុងមុខតំណែងនេះរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ភស្តុតាងដែលសហព្រះរាជអាជ្ញាអន្តរជាតិលើកមកសំអាង មិនបានបង្ហាញឱ្យឃើញថា អ្នកស្រី អ៊ឹម ចែម មានតួនាទីណាមួយនៅថ្នាក់តំបន់ ឬអាចបានចូលរួមក្នុងការធ្វើសេចក្ដីសម្រេចនានានៅថ្នាក់ស្រុក ឬថ្នាក់តំបន់ ក្នុងកម្រិតដែលធ្វើឱ្យអ្នកស្រីទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងប៉ុន្មានក្នុងភូមិភាគពាយព្យឡើយ ។

### *i. អ្នកស្រី អ៊ឹម ចែម មិនមានតួនាទី ស្របច្បាប់ ជាសមាជិក ឬជាអនុលេខាគណៈតំបន់ ៥ ឡើយ*

៩៩. ការកំណត់វិសាលភាពសម្ភារៈ និងវិសាលភាពពេលវេលានៃសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគពាយព្យ មានសារៈសំខាន់បំផុតសម្រាប់ការវាយតម្លៃយ៉ាងត្រឹមត្រូវលើការទទួលខុស

---

301 *ប្រៀបធៀប* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1**។

302 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៧។

303 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៧២-៧៣។

304 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៦។

305 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៧។

ត្រូវរបស់អ្នកស្រីពីឧក្រិដ្ឋកម្មស្ថិតនៅទីតាំងឧក្រិដ្ឋកម្មថ្នាក់តំបន់ចំនួន ២ ដែលគាត់ត្រូវបានរងការចោទប្រកាន់ ដូចជានៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ។ ប្រសិនបើគ្មានសិទ្ធិអំណាចពាក់ព័ន្ធ*ស្របច្បាប់* ឬអំណាច*ជាក់ស្តែង*សមស្របទេនោះ វាច្បាស់ណាស់ថា អ្នកស្រី អ៊ឹម ចែម ប្រាកដជានៅឆ្ងាយដាច់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានាដែលស្ថិតនៅក្នុងទីតាំងទាំងនេះ និងមិនអាចចាត់ទុកអ្នកស្រីថា "ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងអត្ថន័យនៃពាក្យពេចន៍នៅ អ.វ.ត.ក បានដែរ ។

១០០. នៅក្នុងការប៉ុនប៉ងទម្លាក់កំហុសលើអ្នកស្រី អ៊ឹម ចែម សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថាអ្នកស្រី អ៊ឹម ចែម ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះនៅពាក់កណ្តាលឆ្នាំ ១៩៧៧[306] និងជាសមាជិកមួយរូបនៃគណៈតំបន់៥ "ភ្លាមៗបន្ទាប់ពី" អ្នកស្រីបានមកដល់ភូមិភាគពាយព្យ[307] និងបានក្លាយជាអនុលេខាគណៈតំបន់៥ "ចាប់ពីពាក់កណ្តាលឆ្នាំ រហូតដល់ចុងឆ្នាំ ១៩៧៧"[308] ។ នៅទីបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញកាលបរិច្ឆេទកំណត់នៃការចោទប្រកាន់ទាំងអម្បាលម៉ានដែលជាការចង្អុលបង្ហាញឡើងដោយមិនត្រឹមត្រូវ[309] ។

១០១. ចាប់តាំងពីដំបូង វាច្បាស់ណាស់ថាសេចក្តីសំអាងហេតុរបស់សហព្រះរាជអាជ្ញាអន្តរជាតិផ្អែកលើការគិតពិចារណាតាមឆន្ទៈរបស់ខ្លួន ។ សហព្រះរាជអាជ្ញាអន្តរជាតិប៉ុនប៉ងសំអាងលើកាលបរិច្ឆេទនៃការតែងតាំងអ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ ទៅនឹងតួនាទីជាសមាជិក និង

---

[306] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២ ["អ៊ឹម ចែម បានក្លាយទៅជាលេខាស្រុកព្រះនេត្រព្រះ...ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧"] នៅកថាខណ្ឌ ៦០ ["អ៊ឹម ចែម គឺជាលេខាស្រុកព្រះនេត្រព្រះចាប់ ពីពេលដែលគាត់បានមកដល់នៅពាក់កណ្តាលឆ្នាំ ១៩៧៧"] នៅកថាខណ្ឌ ១៣៤ ["អ៊ឹម ចែម បានជំនួសអតីតលេខាស្រុកឈ្មោះ អាន ម៉ោង ជាគណៈស្រុកព្រះនេត្រព្រះ...។ អ៊ឹម ចែម ប្រាកដជាបានមកដល់ស្រុកព្រះនេត្រព្រះយ៉ាងហោចណាស់នៅពាក់កណ្តាលខែមិថុនា ឆ្នាំ ១៩៧៧"]។

[307] *សូមមើល* ដីការសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១១៥ ["អ៊ឹម ចែម បានក្លាយជាសមាជិកគណៈតំបន់៥ ភ្លាមៗក្រោយពេលមកដល់ភូមិភាគពាយព្យ"] ។ *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២ និង ៥៨ ។

[308] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១១៥ ["បន្ទាប់មក នៅពាក់កណ្តាលឆ្នាំ ១៩៧៨ ដល់ចុងឆ្នាំ១៩៧៨, អ៊ឹម ចែម បានក្លាយជាអនុលេខាតំបន់ ៥"] ។ *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២ និង ៥៨។

[309] ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ៥៨ និង ១១៥។

ក្រោយមកទៀត ជាអនុលេខាគណៈតំបន់៥ លើ "ឯកសារដែលនៅសេសសល់ពីសម័យនោះ បង្ហាញពីកាលបរិច្ឆេទ ដែលអតីតសមាជិកគណៈតំបន់៥ ត្រូវបានចាប់ខ្លួន"[310] ។ ទោះជាយ៉ាង នេះក្តី តាមការវិភាគចុងក្រោយបង្ហាញឱ្យឃើញថា ការអះអាងនេះ គឺគ្មានមូលដ្ឋានអ្វីទាល់តែសោះ ក្រៅតែពីការស្មាន៖ ដូចជាថា អ្នកស្រី អ៊ឹម ចែម "ទំនងបំផុត"[311] ជាអ្នកបានឡើងជំនួសតំណែង តា ឡៃ ក្នុងនាមជាសមាជិកគណៈតំបន់៥ មិនលើសពីខែកញ្ញា ឆ្នាំ១៩៧៧ ឡើយ *ពីព្រោះ* តា ឡៃ ត្រូវបានចាប់ខ្លួននៅពេលនោះ[312] ។ អ្នកស្រី អ៊ឹម ចែម "អាចនឹង "[313] ជាអ្នកជំនួសតំណែង តា ជាល ក្នុងនាមជាអនុលេខាតំបន់មិនលើសពីខែ មិថុនា ឆ្នាំ ១៩៧៨ *ពីព្រោះ* តា ជាល ត្រូវបានចាប់ខ្លួននៅពេលនោះ[314] ។ ភស្តុតាងជាក់ស្តែងបង្ហាញឱ្យឃើញថា ការសំអាងស្តីពីសិទ្ធិអំណាច និងការទទួលខុសត្រូវយ៉ាងធំធេងចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរដែលថា "បានប៉ះពាល់ដល់មនុស្សរាប់សិប ពាន់នាក់ និងបានបណ្តាលឱ្យមានមនុស្សស្លាប់រាប់ពាន់នាក់"[315] ផ្អែកលើការអះអាងដូច្នេះថា ជន សង្ស័យ "ទំនងបំផុត" និង "អាចនឹង" ជាអ្នកកាន់តួនាទីជាក់លាក់ គឺមិនអាចគ្របដណ្តប់លើភាព ចាំបាច់នៃភស្តុតាងធ្ងន់ធ្ងរ ឬភាពជាក់លាក់ដែលផ្តល់កម្រិតត្រឹមត្រូវនៃតម្លៃជាភស្តុតាងបន្ទាល់ ឡើយ ។

១០២. ក្រៅពីចំណុចទាំងនេះ សាក្សីដែលសហព្រះរាជអាជ្ញាអន្តរជាតិយកប្រើជាសំអាងក្នុងការបញ្ជាក់ អះអាងដែលថា អ្នកស្រី អ៊ឹម ចែម មានតួនាទីកម្រិតតំបន់នៅតំបន់៥ នឹងត្រូវពិភាក្សាវាយតម្លៃក្នុង កថាខណ្ឌ **១០៥** និង **១០៦** នៃចម្លើយតបនេះ ។ ទោះជាយ៉ាងនេះក្តី ជាបឋម វាចាំបាច់ត្រូវមានការ បញ្ជាក់ ពោលគឺ ការបញ្ជាក់ពាក់ព័ន្ធនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគពាយព្យ ដោយ ផ្អែកលើការយល់ខុសនានា ដូចជាថា៖ i) តា រិន គឺជាលេខាតំបន់៥ នៅពេលដែលអ្នកស្រី អ៊ឹម

---

[310] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥។

[311] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥។

[312] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៦០)។

[313] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥។

[314] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៦១)។

[315] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥, ៥២៩, ៥៣៦។

ចែម បានមកដល់ភូមិភាគពាយព្យ (មានន័យថា តា រិន ទទួលខុសត្រូវលើការតែងតាំងអ្នកស្រី) និង ii) អ្នកស្រី អ៊ឹម ចែម បានឡើងតំណែងជំនួស តា ម៉ោង ភ្លាមៗក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ ។ ចំណុចទាំងនេះ នឹងត្រូវលើកយកមកពិភាក្សាក្នុងផ្នែកខាងក្រោម៖

(i) សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងខុសថា តា រិន គឺជាលេខាតំបន់៥ ចាប់ពីអំឡុងខែ មិថុនា ឆ្នាំ ១៩៧៧ រហូតដល់អំឡុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨[316] ។ ទោះបីជាមិនមានការបញ្ជាក់ច្បាស់លាស់ក្នុងដីកាសន្និដ្ឋានស្ថាពរក្តី ក៏មានការឆ្លើយដាក់ថា តា រិន ដែលជាកម្មាភិបាលជាន់ខ្ពស់បំផុតក្នុងតំបន់៥ គឺជាតួអង្គដ៏សំខាន់ក្នុងការតែងតាំងតួនាទីនីមួយៗរបស់អ្នកស្រី អ៊ឹម ចែម នៅភូមិភាគពាយព្យ ពោលគឺ អំឡុងពេលនេះគ្របដណ្តប់លើកាលបរិច្ឆេទទាំងអស់ដែលត្រូវបានចោទប្រកាន់ចំពោះការតែងតាំងអ្នកស្រី អ៊ឹម ចែម ជាលេខាស្រុក (ពាក់កណ្តាលខែ មិថុនា ឆ្នាំ ១៩៧៧)[317] ជាសមាជិកគណៈតំបន់ (ខែ កញ្ញា ឆ្នាំ ១៩៧៧)[318] និងអនុលេខាតំបន់ (ខែ មិថុនា ឆ្នាំ ១៩៧៨)[319] ។ សម្មតិកម្មនេះ គ្មានមូលដ្ឋានជាភស្តុតាងសោះ ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានដាក់នូវសំអាងហេតុណាមួយពាក់ព័ន្ធនឹងការតែងតាំងអ្នកស្រី អ៊ឹម ចែម ដែលគាំទ្រទស្សនៈដែលថា តា រិន បានជួយដល់ការដំឡើងតំណែងរបស់អ្នកស្រី[320] ។ តាមពិតសាក្សី សួន ម៉ុត បាន

---

316 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ ("កម្មាភិបាលភូមិភាគនិរតីឈ្មោះ ហេង រិន បានជំនួស ហ៊ឹង ក្នុងឋានៈជាលេខាតំបន់ ៥ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧។ រិន បន្ទាប់មក ត្រូវបានបោសសម្អាតក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨") ។

317 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៤ ("អ៊ឹម ចែម បានជំនួសតំណែងអតីតលេខាស្រុកឈ្មោះ អាន ម៉ោង ជាគណៈស្រុកព្រះនេត្រព្រះ...កំណត់ត្រានៅមន្ទីរស-២១ បញ្ជាក់ថា លេខាស្រុកព្រះនេត្រព្រះឈ្មោះ អាន ម៉ោង បានចូលទៅមន្ទីរស-២១ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយត្រូវបានចាប់ខ្លួនយ៉ាងហោចណាស់ ១០ ថ្ងៃមុន ។ ដូច្នេះ អ៊ឹម ចែម ប្រាកដជាបានមកដល់ស្រុកព្រះនេត្រព្រះយ៉ាងហោចណាស់ក្នុងពាក់កណ្តាលខែ មិថុនា ឆ្នាំ ១៩៧៧") ។

318 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ ("ជាលទ្ធផល អ៊ឹម ចែម ពិតជាបានក្លាយជាសមាជិកគណៈតំបន់ ៥ មុន ឬក្នុង ខែ កញ្ញា ឆ្នាំ ១៩៧៧") ។

319 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ ("ជាលទ្ធផល អ៊ឹម ចែម....ទំនងជាបានក្លាយជាអនុគណៈតំបន់មិនយូរជាងអំឡុងខែ មិថុនា ឆ្នាំ ១៩៧៨")។

320 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ ("ជើងទំព័រ ២១៨-១៩) នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៥៦-៥៧) នៅកថាខណ្ឌ ១៧៤ (ជើងទំព័រ ៨៧២)។

ជំទាស់នឹងការសន្និដ្ឋាននេះ[321] ។ ទីពីរ តាមរយៈការបង្ហាញក្នុងភស្តុតាង លេខាតំបន់៥ ដែលបានតែងតាំង អ្នកស្រី អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ គឺ តា ជាល *មិនមែន* តា រិន នោះទេ[322] ។ វាច្បាស់ណាស់ថា តា ជាល គឺជាលេខាតំបន់៥ស្តីទី[323] ចាប់ពីពេលដែលអ្នកស្រី អ៊ឹម ចែម បានមកដល់ភូមិភាគពាយព្យរហូតដល់ "អំឡុងខែមីនា ឬមេសា ឆ្នាំ ១៩៧៨[324]" ។ គ្មានភស្តុតាងណាមួយដែលបង្ហាញថា តា ជាល បានតួនាទីរបស់

---

321 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨) *ដែលយោងទៅលើ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន ម៉ុត ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D219/4.1,** KH 01025156 (ស៖ គាត់ធ្វើអី តា រិន ដែរត្រង់? ឆ៖ គាត់គណៈតំបន់ដែរ។ គាត់នៅកន្លែងមន្ទីរ គាត់គណៈតំបន់ដែរ។ ស ៖ គណៈតំបន់ជាមួយយាយចែម? ឆ ៖ មិនទេ ដូចអ្នកនៅខាងហ្នឹង សៀមរាប)។

322 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65 ឆ:**62-63 ["*តា*ជៀល លេខាតំបន់ ៥ ជាអ្នកចាត់តាំង យាយ ចែម (ឱ្យធ្វើជាគណៈស្រុកព្រះនេត្រព្រះ)"]។

323 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33 ឆ:**13 ("នៅតំបន់ ៥ ក្រោយពេល តា ហ៊ីង ត្រូវបានចាប់ខ្លួន។ តា ជៀល បានឡើងជំនួសពីរបីខែ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈ្លង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29 ឆ:**17 ["ក្រោយការចាប់ខ្លួនរបស់តា ហ៊ីង តា ជៀល ឡើងជាគណៈតំបន់ (មិនមានអនុទេ)"]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាន ឈ្លង ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.6**, KH 00734093, 00734095 [ដែលបញ្ជាក់ថា តា ជាល បានក្លាយជាគណៈតំបន់ ៥ ក្នុងរយៈពេលប្រហែល ៣ ខែ បន្ទាប់ពី តាហ៊ីង ត្រូវបានចាប់ខ្លួន]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កៅ ផាន ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D123/1/2.62**, KH 00739780 ["បន្ទាប់ពី តា ហ៊ីង ត្រូវបានចាប់ខ្លួន គាត់ (តា ជៀល) បានឡើងជំនួសតាហ៊ីង ក្នុងនាមជាគណៈតំបន់។ គាត់ឡើងជំនួសតាហ៊ីង"]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D123/1/5.1c**, KH 00929882 [ដែលនិយាយថា តា ជៀល គ្រប់គ្រងខេត្តស្វាយស៊ីសុផុន នៅពេលដែលអ្នកស្រីមកដល់ ហើយ តា ហ៊ីង បានបាត់ខ្លួនរួចទៅហើយ]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, KH 00929783 [ដែលបញ្ជាក់ថា តារិន បានគ្រប់គ្រងតំបន់ ៥ ជំនួសតាជៀល]។ *សូមមើល* អង្គការលេខជាសម្ពតិកម្មរបស់តំបន់ ៥, ភូមិភាគពាយព្យ (ស្រុកព្រះនេត្រព្រះ), ធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/135.1**។

324 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33 ឆ**13។ *សូមមើល* ចម្លើយសារភាពរបស់ ចាន់ សំ ហៅ ចាប ហៅ សែ នៅមន្ទីរស-២១ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារ **D1.3.4.2**, EN 00223044, 00223046 [ដែលបញ្ជាក់ថា តារិនត្រូវបានផ្លាស់ទៅតំបន់ ៥ និងត្រូវបានណែនាំទៅ រស់ ញឹម នៅអំឡុងខែ កុម្ភៈ ឆ្នាំ ១៩៧៨ ហើយគាត់បានចូលរួមកិច្ចប្រជុំមួយនៅចុងខែ មីនា ឆ្នាំ ១៩៧៨ ក្នុងនាមជាលេខាតំបន់៥]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156**

អ្នកស្រី អ៊ឹម ចែម ឱ្យធ្វើជាគណៈតំបន់៥ ឡើយ ពោលគឺ អ្នកស្រីមានមុខងារ *ត្រឹមតែ*ជាថ្នាក់ស្រុកប៉ុណ្ណោះ[325] ។

(ii) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម បានឡើងជំនួស តា ម៉ោង ភ្លាមៗក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ[326] ។ តា ម៉ោង ត្រូវបានដកចេញពីតួនាទីជាលេខាស្រុកនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧[327] ។ ផ្ទុយស្រឡះពីទស្សនៈដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ[328] អ្នកស្រី អ៊ឹម ចែម មិនបានឡើងកាន់តួនាទីនេះភ្លាមៗ នៅពេលដែលអ្នកស្រីបានមកដល់ភូមិភាគពាយព្យទេ ។ ផ្ទុយទៅវិញ មានភស្តុតាងបង្ហាញថា អ្នកដែលឡើងជំនួសតំណែង តា ម៉ោង ភ្លាមៗក្នុងនាមជាលេខាស្រុក គឺឈ្មោះ ផុន[329] ។ អ្នកស្រី អ៊ឹម ចែម គ្រាន់តែត្រូវបានចាត់តាំងឱ្យក្លាយជាលេខា

---

ឆ:29 [ដែលបញ្ជាក់ថា តា រិន ត្រូវបានចាត់តាំង "ប្រហែលជានៅដើមរដូវវស្សា គឺប្រហែលជានៅខែ ឧសភា ឬខែ មិថុនា ឆ្នាំ ១៩៧៨"]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, KH 00929783។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29** ឆ:13 [ដែលនិយាយថា តា រិន បានឡើងជំនួស តា ជាល ដែលជាអតីតគណៈតំបន់៥]។

325 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:62- 63 ["តា ជៀល លេខាតំបន់៥ ជាអ្នកចាត់តាំង យាយ ចែម (ឱ្យធ្វើជាគណៈស្រុកព្រះនេត្រព្រះ)"]។

326 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៤ ("អ៊ឹម ចែម បានឡើងជំនួសអតីតលេខាស្រុកឈ្មោះ អាន ម៉ោង ក្នុងនាមជាគណៈស្រុកព្រះនេត្រព្រះ")។

327 ចម្លើយសារភាពរបស់ អាន ម៉ោង នៅមន្ទីរស ២១ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ **D 1.3.4.1**, KH 00204263-00204268 [ដែលកត់សម្គាល់ថា អាន ម៉ោង ត្រូវបានចាប់ខ្លួនដោយអង្គការ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧]។

328 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៤ ("អ៊ឹម ចែម បានឡើងជំនួសអតីតលេខាស្រុកឈ្មោះ អាន ម៉ោង ក្នុងនាមជាគណៈស្រុកព្រះនេត្រព្រះ")។

329 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13 ["នៅឆ្នាំ ១៩៧៧ តា ម៉ោង ត្រូវបានគេចាប់ខ្លួន ហើយ ផុន ឡើងជំនួស (អ្នកមកពីភូមិភាគបូព៌ា)"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:41 ["ដំបូងឈ្មោះ ផុន (ស្លាប់) ជាគណៈស្រុកព្រះនេត្រព្រះ ប៉ុន្តែក្រោយមកគឺ យាយ ចែម ជាគណៈស្រុកព្រះនេត្រព្រះ ពីព្រោះនៅពេលនោះ យាយ ចែម បានចាត់តាំងខ្ញុំជាគណៈឃុំ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាមុត ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/477** ឆ:29 ["ក្រោយពេលពួកនិរតីបានមកដល់ មានឈ្មោះ ផុន មកពីខាងខេត្តស្វាយរៀង មកជំនួស

ស្រុកព្រះនេត្រព្រះនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨[330] ដើម្បីជំនួស ផុន[331] ប៉ុណ្ណោះ ។ អ្នកស្រីបានបន្តកាន់តួនាទីនេះរហូតកងទ័ពវៀតណាមចូលមកដល់[332] ។ ដូច្នេះ ការវិភាគបែបសត្យានុម័តលើភស្តុតាងទាំងនេះ ធ្វើឱ្យយើងអាចសន្និដ្ឋានបានថា រយៈពេលកាន់តំណែងរបស់អ្នកស្រី អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ គឺយ៉ាងហោចណាស់ខ្លីជាងបទចោទប្រកាន់ប្រមាណជា១ ភាគ ៣ ។

១០៣. ដូចនឹងត្រូវលើកឡើងខាងក្រោម[333] សូម្បីតែត្រូវបានពិនិត្យនៅកម្រិតខ្ពស់បំផុតក្តី ក៏ភស្តុតាងដែលសំអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិ[334] មិនបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម កាន់តួនាទីក្នុង

---

ឈ្មោះ តា ម៉ោង"]។ *សូមមើល* អង្គការលេខជាសម្មតិកម្មរបស់តំបន់៥ ភូមិភាគពាយព្យ (ស្រុកព្រះនេត្រព្រះ) ធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/135.1**។

330 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13 ["នៅប្រហែលចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ យាយចែម ឡើងជាគណៈស្រុកព្រះនេត្រព្រះ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:12 ឆ:41 [ជុំ កាន់ គឺជាសមាជិកគណៈឃុំភ្នំលៀបនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ នៅពេលដែល ផុន គឺជាលេខាស្រុកព្រះនេត្រព្រះ។ គាត់ត្រូវបានចាត់តាំងជាគណៈឃុំភ្នំលៀបដោយ អ្នកស្រី អ៊ឹម ចែម ក្រោយពេលដែលអ្នកស្រីឡើងជំនួស ផុន]។

331 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:14។ *សូមមើល* អង្គការលេខជាសម្មតិកម្មរបស់តំបន់ ៥, ភូមិភាគពាយព្យ (ស្រុកព្រះនេត្រព្រះ), ធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/135.1**។

332 *សូមមើល* បទសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, KH 00234193 ["ហើយខ្ញុំទៅនៅស្រុកព្រះនេត្រព្រះចុងក្រោយបង្អស់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29** ឆ:9 ["ដែលបញ្ជាក់ថា គាត់បានភៀសខ្លួនជាមួយ អ៊ឹម ចែម នៅឆ្នាំ ១៩៧៩ ហើយគាត់បានជួយការពារ អ៊ឹម ចែម ព្រោះអ្នកស្រីជាគណៈស្រុក"]។ *សូមមើល រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, ប្រតិចារិកនៃដំណើរនីតិវិធីជំនុំជម្រះ (សក្ខីកម្មរបស់សាក្សី ឈិត យឿក) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/330.1**, KH 01130936 [ដែលបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម គ្រាន់តែធ្លាប់ធ្វើការនៅថ្នាក់ស្រុកប៉ុណ្ណោះ]។

333 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៥-១០។

334 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:93-94។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:118។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/112** ឆ:9។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/91** ឆ:15, ឆ:25។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:75, ឆ:77។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** ឆ:42។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុតសួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:94។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីន យង់ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:8។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/853**, KH 00956904។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រឿង សារួន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/865**, KH 00957090។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19-20។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន មុត ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D219/4.1,** KH 01025156 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/20** ឆ:16។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:57។ *សូមមើល* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងដល់ទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:18-19។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/91** ឆ:14, ឆ:20។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108** ឆ:107។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ម៉ុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** ឆ:42, ឆ:52-54។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហឺយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:12- 13។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D118/65** ឆ:29។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ក្រូច ទឹម ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ **D119/69/2**, KH 00969055។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហ៊ួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:118- 19។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:94។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ិន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:8។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/853**, KH 00956907។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រឿង សារួន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/865**, KH 00957090។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19-20។ បទសម្ភាសន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន ម៉ុត ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D219/4.1**, KH 01025152។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦

គណៈតំបន់៥ "ភ្លាមៗបន្ទាប់ពី" អ្នកស្រីបានមកដល់ភូមិភាគពាយព្យ ឬនៅពេលណាមួយឡើយ ។ លើសពីនេះ ការវាយតម្លៃសមហេតុផល និងយុត្តិធម៌លើ*ភាពគ្រប់ជ្រុងជ្រោយ* នៃសក្ខីកម្មរបស់សាក្សីពាក់ព័ន្ធនឹងការលើកឡើងនេះ បង្ហាញឱ្យឃើញថា ការលើកឡើងទាំងនោះត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវ ។

១០៤. ដូចបង្ហាញក្នុងផ្នែកខាងក្រោម វាគួរឱ្យសោកស្តាយដែលការវាយតម្លៃនេះ ក៏បង្ហាញពីវិធីសាស្ត្ររបស់ព្រះរាជអាជ្ញាលើភស្តុតាង ដែលត្រូវបានផាត់ចេញនូវអ្វីជាក្តីរំពឹងទុកពីភាគីមួយ ដែលត្រូវបានបង្គាប់ឱ្យជួយក្នុងការបញ្ជាក់ពីការពិត ។ វាគ្មានប្រយោជន៍ទាល់តែសោះក្នុងការផ្អែកលើការបង្ហាញដែលបំផ្លើស[335] ការប៉ាន់ស្មាន[336] ឬពាក្យចចាមអារ៉ាម[337] ដោយគ្មានការផ្តល់មតិយោបល់យោង ។ តាមគោលការណ៍ វាជាកំហុសឆ្គងក្នុងការចាត់ទុកពាក្យចចាមអារ៉ាមដែលគ្មានប្រភព

---

ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:57, ឆ:59។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៥៦) *ដែលយោងទៅកាន់* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:75, ឆ:77។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **118/153** ឆ:57, ឆ:59។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:117- 19។ កំណាត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ម៉ុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** ឆ:42។ កំណាត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:94។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ិន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:8-9។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធៀយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/853**, KH 00956907។ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រឿង សារួន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/865**, KH 00957090។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៥៧) *ដែលយោងទៅកាន់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/112** ឆ:9, ឆ:10។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/91** ឆ:15, ឆ:25។

[335] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៦ *ដែលកត់សម្គាល់ពីការសំអាងលើ* ទុំ សឿន, នៅ ចាត់, យង់ ស៊ិន។

[336] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៦ *ដែលកត់សម្គាល់ពីការសំអាងលើ* ឡុត សួយ, សួន មុត, រឿង សារួន។

[337] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៦ *ដែលកត់សម្គាល់ពីការសំអាងលើ* ជឹម ចាន់ធឿន។

ច្បាស់លាស់ជាភស្តុតាងផ្ទាល់[338] ឬវាកាន់តែធ្ងន់ធ្ងរណាស់ទៅទៀត ក្នុងការសំអាងតែលើផ្នែកនានានៃសេចក្តីថ្លែងការណ៍ សូម្បីតែដឹងគ្មានខ្វះចន្លោះហើយថា សាក្សីតែមួយ បានផ្តល់ការពន្យល់ផ្នែកខ្លះបានពេញលេញជាង ឬ ផ្តល់ភស្តុតាងផ្ទុយនានានៅក្នុងរង្វង់នៃសេចក្តីថ្លែងការណ៍ដូចគ្នាក៏ដោយ[339] ។

១០៥. សហព្រះរាជអាជ្ញាអន្តរជាតិយោងលើឯកសារសំអាងចំនួន១៥ ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកគណៈតំបន់៥ "ភ្លាមៗបន្ទាប់ពីអ្នកស្រីបានមកដល់ភូមិភាគពាយព្យនៅពាក់កណ្តាលឆ្នាំ ១៩៧៧[340]" និងគាំទ្រលើការអះអាងដែលថា អ្នកស្រី "បានក្លាយជាអនុលេខាតំបន់៥" ចាប់ពីពាក់កណ្តាលរហូតដល់ចុងឆ្នាំ ១៩៧៨[341] ។ ដូចនឹងពិភាក្សាខាងក្រោម ការគាំទ្រដែលផ្តល់ដោយឯកសារសំអាងយ៉ាងច្រើន គឺធ្វើឡើងដោយការបំភ័ន្ត ពោលគឺ ភស្តុតាងទាំងនេះសុទ្ធតែជាការបំផ្លើស ការប៉ាន់ស្មាន មិនស៊ីសង្វាក់គ្នា និងជាពិសេស ភស្តុតាងទាំងនោះគ្រាន់តែជាពាក្យចចាមអារ៉ាមដែលមិនអាចជឿជាក់បានប៉ុណ្ណោះ ។

១០៦. វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការប៉ុនប៉ងគ្របដណ្តប់លើគុណភាពនៃភស្តុតាងគឺជារឿងដែលគួរឱ្យសោកស្តាយបំផុត ។ ចំណុចជាក់លាក់គឺៈ

- ការសំអាងលើសាក្សី ទុំ សឿន គឺជាការបំភ័ន្ត[342] ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកយកចម្លើយរបស់សាក្សី ទុំ សឿន[343] ផ្តើយលើកដំបូងដាក់ក្នុងជើងទំព័រមួយដែលមាន

---

338 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៦ *ដែលកត់សម្គាល់ពីការសំអាងលើ* ពេជ្រ រស់, គ្រួច ទឹម, ទិល សេងលី, លី សិញ, សុខ រ៉ុ។

339 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០៦ *ដែលកត់សម្គាល់ពីការសំអាងលើ* ថង ធឿយ, អោម ហួន, ប៊ិន ហឹយ, ប្រាក់ សឹម, ឡុង វុន។

340 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩)។

341 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨)។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២, ១១៥។

342 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨) *ដែលយោងដល់*កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:93-94។

ការសំអាងលើការចោទប្រកាន់១៥ ចំណុច ជាការគាំទ្រការចោទប្រកាន់ដែលថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាអនុលេខាតំបន់៥[344] ដោយបង្ហាញនូវការយល់ឃើញថា នេះជាសិទ្ធិអំណាចពាក់ព័ន្ធមួយ ។ ទោះជាយ៉ាងណាក្តី ទុំ សឿន មិនបានលើកឡើងទេថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាអនុលេខាតំបន់៥ ។ ផ្ទុយទៅវិញ គាត់បានគូសបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម បានធ្វើការជាមួយអតីតរចនាសម្ព័ន្ធអង្គការថ្នាក់ស្រុករហូតដល់ឆ្នាំ ១៩៧៨[345] ។

- នៅ ចាត់ មិនបានលើកឡើងទេថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាអនុលេខាតំបន់ ៥[346]។ ប៉ុន្តែគាត់គ្រាន់តែយល់ថា អ្នកស្រី អ៊ឹម ចែម មានតួនាទីជាន់ខ្ពស់នៅភ្នំលៀប ភ្នំស្រុក និង ភ្នំទ្រយោង[347] ។ គាត់បានសម្តែងការទទួលស្គាល់យ៉ាងប្រុងប្រយ័ត្នថា គាត់មិនបានដឹងពីតួនាទីរបស់អ្នកស្រី[348] និងមិនបានដឹងថាតើអ្នកស្រីមានសិទ្ធិអំណាចលើស្រុកផ្សេងទៀត ឬយ៉ាងណានោះទេ[349] ហើយក៏លើកឡើងជាបន្តទៀតថា គាត់មិនធ្លាប់បានចូលរួមកិច្ចប្រជុំដែលមានវត្តមានរបស់អ្នកស្រី អ៊ឹម ចែម ឡើយ[350] ។

---

343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65**, ស-ឆ:93 (ស៖ "តើយាយចែមធ្វើការជាមួយរចនាសម្ព័ន្ធថ្នាក់ស្រុកចាស់រយៈពេលប៉ុន្មានដែរ? ឆ៖ រហូតដល់ឆ្នាំ ១៩៧៨ បាត់ខ្លួនកម្មាភិបាលចាស់។"), ស-ឆ:94 ("ស៖ តើបាត់ខ្លួននោះដោយសារអ្វី ដោយសារគេលោលឈប់ ឬ? ឆ ៖ ខ្ញុំមិនបានដឹងទេ។ គ្រាន់តែដឹងថា ពេលប្រជុំលែងឃើញមុខពួកគេ។ ហើយគណៈតំបន់ តា ជៀល ក៏បាត់ឈ្មោះដែរ")។

344 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨)។

345 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:93-94។

346 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨) *ដែលយោងដល់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:77។

347 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:75, ឆ:77។

348 កំណត់ហេតុនៃការស្តាប់ចម្លើយរបស់អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:65។

349 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:78។

350 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:91។

- សាក្សី ពេជ្រ រស់ មិនបានគាំទ្រការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក និង ជាអនុលេខាគណៈតំបន់៥ នោះទេ[351] ។ ផ្ទុយទៅវិញ សាក្សីរូបនេះ បាននិយាយថា "ខ្ញុំ ធ្លាប់បានឮអ្នកនៅក្នុងកងចល័តថា គាត់ក៏ជាកម្មាភិបាលថ្នាក់តំបន់ ហើយគាត់ស្នាក់នៅ ភ្នំលៀប[352]" ។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានជ្រើសយកដោយ អន្លើៗនូវផ្នែកនានានៃចម្លើយរបស់សាក្សីរូបនេះ ដើម្បីច្រានចោលផ្នែកដំបូងនៃចម្លើយ របស់សាក្សី (ដែលអះអាងថា "យាយចែម គឺជាគណៈស្រុកព្រះនេត្រព្រះថ្មី"[353]) ជាការ បំភ្លៃរឿងរ៉ាវនេះ ដើម្បីធ្វើឱ្យមើលទៅយល់ថា សាក្សីបានផ្តល់ភស្តុតាងដែលពាក់ព័ន្ធតែនឹង ថ្នាក់តំបន់តែប៉ុណ្ណោះ ។ ការពិត ភស្តុតាងដែលអាចទុកចិត្តបានតែមួយគត់ពីសាក្សី ទាក់ទងនឹងបញ្ហានេះ គឺនៅពេលដែលគាត់ ឆ្លើយថា អ្នកស្រី អ៊ឹម ចែម ធ្លាប់ធ្វើការនៅថ្នាក់ ស្រុក ។

- សាក្សី យង់ ស៊ីន មិនបានគាំទ្រទៅលើការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជា សមាជិក ឬអនុលេខាគណៈតំបន់៥ឡើយ[354]។ សេចក្តីថ្លែងការណ៍ក្នុងឯកសារដើមជា ភាសាខ្មែររបស់ យង់ ស៊ីន បញ្ជាក់ថា សាក្សីរូបនេះបានពិពណ៌នាអ្នកស្រី អ៊ឹម ចែម ថាជា តួអង្គសំខាន់ក្នុង*តំបន់*របស់គាត់ ដូច្នេះគាត់មិនបានសំដៅលើថ្នាក់*តំបន់* (ដូចការលើកឡើង ក្នុងការបកប្រែជាភាសាអង់គ្លេសនោះទេ)[355] ។ សាក្សីរូបនេះ បានបន្តគូសបញ្ជាក់ទៀតថា គាត់បានឃើញអ្នកស្រី អ៊ឹម ចែម តែនៅពីរទីតាំងតែប៉ុណ្ណោះ ដែលទីតាំងទាំងពីរនេះ សុទ្ធតែស្ថិតក្នុងស្រុកព្រះនេត្រព្រះ[356] ។

---

351 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) *ដែលយោងផល*កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22។

352 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22 (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:16 ("ខ្ញុំមិនដឹងអំពីការផ្លាស់ប្តូរមនុស្សនៅក្នុងថ្នាក់តំបន់៥ ទេ")។

353 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:22។

354 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) *ដែលយោងផល*កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:8។

355 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:8, ស-ឆ:9។

356 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/433** ឆ:9។

- សាក្សី ឡូត សួយ មិនបានផ្តល់ភស្តុតាងគាំទ្រអ្វី លើការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក និងអនុលេខាគណៈតំបន់៥ដូចគ្នា[357] ។ សាក្សីរូបនេះបានស្មានថា យាយ ចែម និង តា ម៉ុក មានតួនាទីជាគណៈតំបន់៥[358] ព្រោះយោងតាមសាក្សីរូបនេះ ពួកគេ "ល្បីឈ្មោះ" និង "គ្មានគណៈស្រុកថ្មី" មកជំនួសកម្មាភិបាលភូមិភាគពាយព្យដែលត្រូវបានចាប់ខ្លួនឡើយ[359] ។ សាក្សីរូបនេះបានគូសបញ្ជាក់ថា គាត់បានឃើញ អ្នកស្រី អ៊ឹម ចែម ពីចម្ងាយម្តង[360] ។ គាត់មិនចាំមុខអ្នកស្រី អ៊ឹម ចែម ក្នុងរូបថតដែលបង្ហាញឱ្យគាត់មើលឡើយ[361] ។

---

357 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) *ដែលយោងដល់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144**, ស-ឆ:94 (ស ៖ "យោងតាមមជ្ឈមណ្ឌលឯកសារកម្ពុជា **D67.7** ត្រង់ទំព័រ ERN 00728737 (ភាសាអង់គ្លេស) លោកបាននិយាយថា "បន្ទាប់ពីតាហ៊ីងដែលជាគណៈតំបន់ ៥ ត្រូវបានចាប់ខ្លួន ។ យាយចែម ឬតាម៉ុកជាអ្នកគ្រប់គ្រងតំបន់ ៥ ជំនួស។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ:94 ៖ "ខ្ញុំបាននិយាយដូច្នេះមែន ពីព្រោះក្រោយពេលដែលពួកកម្មាភិបាលពាយព្យទាំងអស់ត្រូវបានចាប់ខ្លួន ពុំទាន់មានគណៈស្រុកថ្មីណាមកជំនួសទេ ហើយនៅពេលនោះ ពួកយើងឮតែឈ្មោះមនុស្សពីរនាក់ប៉ុណ្ណោះ គឺឈ្មោះតាម៉ុក និងយាយ ចែម ហើយពួកគាត់ទាំងពីរនេះ មានឈ្មោះល្បីល្បាញណាស់នៅពេលនោះ។ ហេតុដូច្នេះហើយ បានខ្ញុំនិយាយថាគណៈតំបន់ ៥ អាចជាយាយ ចែម ក៏បាន តា ម៉ុក ក៏បាន")។

358 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144**, ស-ឆ:94 (ស៖ "យោងតាមមជ្ឈមណ្ឌលឯកសារកម្ពុជា... លោកបាននិយាយថា "បន្ទាប់ពីតា ហ៊ីង ដែលជាគណៈតំបន់ ៥ ត្រូវបានចាប់ខ្លួន ។ យាយចែម ឬតា ម៉ុក ជាអ្នកគ្រប់គ្រងតំបន់ ៥ ជំនួស។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ:94 ៖ "ខ្ញុំបាននិយាយដូច្នេះមែន ពីព្រោះក្រោយពេលដែលពួកកម្មាភិបាលពាយព្យទាំងអស់ត្រូវបានចាប់ខ្លួន ពុំទាន់មានគណៈស្រុកថ្មីណាមកជំនួសទេ ហើយនៅពេលនោះ ពួកយើងឮតែឈ្មោះមនុស្សពីរនាក់ប៉ុណ្ណោះ គឺឈ្មោះតា ម៉ុក និង យាយ ចែម ហើយពួកគាត់ទាំងពីរនេះ មានឈ្មោះល្បីល្បាញណាស់នៅពេលនោះ។ ហេតុដូច្នេះហើយ បានខ្ញុំនិយាយថាគណៈតំបន់៥ អាចជាយាយ ចែម ក៏បាន តា ម៉ុក ក៏បាន")។

359 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:94។

360 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:96។

361 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144**, KH01009219។

- សាក្សី សួន ម៉ុត មិនបានផ្តល់ការគាំទ្រមានអត្ថន័យណាមួយលើការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក និងអនុលេខាគណៈតំបន់៥ នោះទេ[362] ។ សាក្សីរូបនេះបានសារភាពថា គាត់ "មិនបានដឹងច្រើន" អំពីរចនាសម្ព័ន្ធតំបន់៥ និងគូសបញ្ជាក់ថាគាត់មិនបានដឹងពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅភូមិភាគពាយព្យឡើយ[363] ។ សួន ម៉ុតបានត្រឹមតែសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម ធ្វើការនៅថ្នាក់តំបន់ ដោយសារតែអ្នកស្រីបានចូលរួមប្រជុំនៅមន្ទីរថ្នាក់តំបន់៥[364] ដែលនេះ គឺជាភារកិច្ចរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការ

---

[362] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) នៅកថាខណ្ឌ ១១៥ (ជើងទំព័រ ៥៥៦) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** **ឆ:**42 ("ខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ ប៉ុន្តែខ្ញុំធ្លាប់បានឃើញ យាយចែម ចេញចូល និងប្រជុំនៅមន្ទីរស្វាយស៊ីសុផុន នៅពេលដែលខ្ញុំចូលរួមប្រជុំនៅទីនោះ") **ឆ:**44 (ដែលថ្លែងថា "ខ្ញុំមិនច្បាស់ទេថាតើមន្ទីរនៅស្វាយស៊ីសុផុន (មន្ទីរតំបន់៥) គឺជាមន្ទីររបស់យាយចែម ឬយ៉ាងណានោះទេ ប៉ុន្តែខ្ញុំគ្រាន់តែឃើញគាត់នៅទីនោះក្នុងពេលប្រជុំម្តងៗ") **ឆ:**52- 54 ("ស ៖ យោងតាមកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារលេខ D219/4.1 លោកនិយាយថា យាយ ចែមគឺជាគណៈតំបន់នៅព្រះនេត្រព្រះ។ តើលោកអាចបញ្ជាក់លម្អិតអំពីរឿងនេះបានដែរ ឬទេ? " **ឆ:**52 ៖ យាយ ចែម មានមន្ទីរធ្វើការច្រើនកន្លែង ពេលខ្លះ គាត់ធ្វើការនៅមន្ទីរស្វាយស៊ីសុផុន ហើយជួនកាលនៅស្រុកព្រះនេត្រព្រះ និងពេលខ្លះគាត់ធ្វើការនៅមន្ទីរស្រុកភ្នំស្រុក។ ស៖ តើយាយចែម ធ្វើដំណើរពីមន្ទីរមួយទៅមន្ទីរមួយដោយមធ្យោបាយអ្វីដែរ? **ឆ:**53 ៖ ពេលខ្លះ គាត់ធ្វើដំណើរតាមម៉ូតូ និងពេលខ្លះតាមឡានហ្សីប។ ភាគច្រើន គាត់តែងតែធ្វើដំណើរតាមម៉ូតូ និងរទេះសេះ។ ស ៖ តើលោកអាចពន្យល់ប្រាប់យើងបានទេថា តើកម្មាភិបាលថ្នាក់ណាដែលមានសិទ្ធិធ្វើដំណើរតាមឡានហ្សីប? **ឆ:**54៖ គឺមានតែថ្នាក់តំបន់ប៉ុណ្ណោះ")។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន មុត ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D219/4.1,** KH 01025152 ("ស ៖ តាចាយមកកាន់ជំនួស? ឆ ៖ តា ចាយ កាន់ជាមួយយាយចែម។ ស ៖ ហេង រិន ជាល ពីណាទៀត (ដែលជាគណៈតំបន់)? ឆ ៖ យាយ ចែម។ ស្អីគេខ្ញាក់ភ្លេកម្ខាងហ្នឹងចាប់មុន ជាល ទៀត"), KH 01025156 ("ស ៖ ដល់ពេលតាជាល គេចាប់ទៅ តា រិន ក្រោយមកគេចាប់ទៀតទៅនៅតែយាយចែម? ឆ ៖ នៅសល់ យាយ ចែម បាន តា ចាយ មក")។

[363] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** **ឆ:**42 ("ខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ")។

[364] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** **ឆ:**42 ("ខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ ប៉ុន្តែខ្ញុំធ្លាប់បានឃើញ យាយចែម ចេញចូល និងប្រជុំនៅមន្ទីរស្វាយស៊ីសុផុន នៅពេលដែលខ្ញុំចូលរួមប្រជុំនៅទីនោះ") **ឆ:**44 (ដែលនិយាយថា "ខ្ញុំមិនច្បាស់ទេថាតើមន្ទីរនៅស្វាយស៊ីសុផុន (មន្ទីរតំបន់ ៥) គឺជាមន្ទីររបស់យាយចែម ឬយ៉ាងណានោះទេ ប៉ុន្តែខ្ញុំគ្រាន់តែឃើញគាត់នៅទីនោះក្នុងពេលប្រជុំម្តងៗ")។

ចូលរួមកិច្ចប្រជុំក្នុងនាមជាលេខាស្រុក យោងតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា[365] និង ជាភារកិច្ចសាមញ្ញដែលត្រូវធ្វើ[366] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរណាផ្អែកលើទម្រង់បែបបទព័ត៌មានបន្ថែមរបស់ ថង ធឿយ ដែលបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម "កាន់កាប់តំបន់៥ទាំងមូល"[367] ជាការគាំទ្រ ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក និងក្រោយមកជាអនុលេខាគណៈ តំបន់៥ ឡើយ[368] ។ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹងហើយថា សាក្សីរូបនេះ បានផ្តល់ភស្តុតាងផ្ទុយលើបញ្ហានេះ ។ នៅក្នុងបទសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតនាពេលក្រោយមកទៀត អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានគូសបញ្ជាក់ថា គាត់ "មិនដឹងច្បាស់អំពីតួនាទីពិតប្រាកដរបស់ យាយ ចែម ទេ"[369] ។ ក្រៅពីនេះ អ្នកស្រីបានអះអាងថា គាត់គ្រាន់តែដឹងថា អ្នកស្រី អ៊ឹម ចែម មានតួនាទីជាប្រធានគ្រប់គ្រងកងចល័តកុមារដែលគាត់ធ្វើការប៉ុណ្ណោះ[370] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរផ្អែកលើការបញ្ជាក់អះអាងរបស់ អោម ហួន ដែលថា អ្នកស្រី អ៊ឹម ចែម ធ្វើការនៅ "គ្រប់កម្រិតទាំងអស់ ទាំងថ្នាក់តំបន់ផងដែរ" ដើម្បីគាំទ្រ លើសេចក្តីសំអាងហេតុរបស់ខ្លួនថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិក និងក្រោយ

---

365 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ **D1.3.20.1**, មាត្រា ៦ (៥), [១]៤។

366 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៩៤, ១១៣, ១១៧-១៨។

367 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ថង ធឿយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/853**, KH 00956907។

368 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) *ដែលយោងទៅលើ* អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D5/853**, KH 00956907។

369 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណី ថង ធឿយ ថ្ងៃទី ១៦-១៧ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/131** ឆ:69។

370 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណី ថង ធឿយ ថ្ងៃទី ១៦-១៧ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/131** ឆ:34 ("ខ្ញុំគ្រាន់តែដឹងថា យាយចែម មានតួនាទីជាប្រធានគ្រប់គ្រងកងចល័តកុមារតែប៉ុណ្ណោះ") ឆ:35 (ដែលបានសួរថាតើ អ្នកស្រី អ៊ឹម ចែម គ្រប់គ្រងកងចល័តកុមារក្នុងភូមិ ឃុំ ស្រុក ឬតំបន់, ថង ធឿយ ឆ្លើយថា៖ "ខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា គាត់បានគ្រប់គ្រងកងចល័តកុមាររបស់ខ្ញុំតែប៉ុណ្ណោះ)។

មកជាអនុលេខាគណៈតំបន់៥ ឡើយ[371] ។ អ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានបញ្ជាក់ថា គាត់គ្មានព័ត៌មានផ្ទាល់ពីអ្នកស្រី អ៊ឹម ចែម ទេ[372] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរផ្អែកលើពាក្យចចាមអារ៉ាមគ្មានប្រភព ដែលផ្ដល់ដោយ ទិល សេងលី និង លី សិញ ដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម បាន ក្លាយជាអនុលេខាតំបន់៥[373] ។ បុរសទាំងពីរនាក់នេះ បានបង្ហាញថា ពួកគាត់ *បានឮ* ថា អ្នកស្រី អ៊ឹម ចែម ជាអ្នកគ្រប់គ្រងតំបន់៥ និងថា *គេបានប្រាប់* ព័ត៌មាននេះដល់ពួក គាត់[374] ។ គ្មាននរណាម្នាក់ក្នុងចំណោមសាក្សីទាំងពីរនាក់នេះបានផ្ដល់ព័ត៌មានលម្អិត ដែលអាចផ្ទៀងផ្ទាត់ប្រភពនៃការដឹងឮរបស់ពួកគាត់ ឬបើមិនដូច្នេះទេ ក៏ត្រឹមអាចផ្ដល់ ព័ត៌មាននាំផ្លូវណាផ្សេងទៀតដែលអាចទុកចិត្តបាននោះឡើយ ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរផ្អែកលើពាក្យចចាមអារ៉ាមគ្មានប្រភព ដែលផ្ដល់ដោយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី រឿង សារួន ដើម្បីគាំទ្រដល់ការអះ អាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក ហើយក្រោយមកជាអនុលេខាតំបន់ ៥ នោះទេ[375] ។ រឿង សារួន មិនត្រូវបានសម្ភាសន៍ដោយ ក.ស.ច.ស ឡើយ និងគ្រាន់តែ

---

[371] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩) *ដែលយោងលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:118- 19។

[372] *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:64 ["ខ្ញុំធ្លាប់ឮឈ្មោះយាយ ចែម ប៉ុន្តែខ្ញុំមិនធ្លាប់ជួបគាត់ផ្ទាល់ទេ"] ឆ:88 ["ខ្ញុំធ្លាប់តែឮគេនិយាយពី (តាវ៉ាល់ និងយាយចែម)"] ឆ:92 ["ខ្ញុំឮគេនិយាយថា យាយចែម..."]។

[373] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/112** ឆ:9។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/20** ឆ:16។

[374] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/112** ឆ:9- 10 ឆ:18, ឆ:20។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/20** ឆ:16។

[375] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-២១៩) *ដែលយោងទៅលើ* ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រឿង សារួន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/865**, KH 00957090។

បានអះអាងថា *បើតាមគាត់ដឹង* អ្នកស្រីអ៊ឹម ចែម ជាអ្នក "ដឹកនាំថ្នាក់តំបន់"[376] ដោយមិនបានផ្ដល់ព័ត៌មានលម្អិតណាមួយ ដែលនឹងអាចអនុញ្ញាតឱ្យមានការធ្វើតេស្ដ ឬផ្ទៀងផ្ទាត់លើភស្តុតាងទទួលបានពីបុគ្គលនេះនោះឡើយ ។

- សាក្សី ជឹម ចាន់ធឿន មិនបានផ្តល់ព័ត៌មានដែលមានតម្លៃជាភស្តុតាងណាមួយ ដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់នោះទេ[377] ។ គាត់បានចង្អុលបង្ហាញថា គាត់មិនធ្លាប់ជួប ឬឃើញអ្នកស្រី អ៊ឹម ចែម ហើយគាត់ក៏មិនបានផ្ដល់ព័ត៌មានអ្វីដែលអាចយកមកផ្ទៀងផ្ទាត់ប្រភពនៃការដឹងឮរបស់គាត់ ទាក់ទងនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅ "គណៈដឹកនាំតំបន់៥"[378] ដូចដែលត្រូវបានចោទប្រកាន់នោះឡើយ ។

- សាក្សី សុខ រ៉ុំ មិនបានផ្ដល់ព័ត៌មានដែលមានតម្លៃជាភស្តុតាងណាមួយ ដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម មានតួនាទីជាសមាជិកគណៈតំបន់៥[379] ទេ ។ សាក្សីបានទទួលស្គាល់ថា គាត់មិនធ្លាប់ឃើញអ្នកស្រី អ៊ឹម ចែម នៅបរិវេណមន្ទីរតំបន់៥ ទេ ឬសូម្បីតែនៅក្នុងភូមិភាគពាយព្យ[380] ។ សាក្សី សុខ រ៉ុំ ក៏បានទទួលស្គាល់ផងដែរថា ក្នុងអំឡុងពេលអ្នកស្រីផ្ដល់បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មានអ្នកជិតខាងរបស់អ្នកស្រីបានជួយឆ្លើយសំណួរមួយចំនួន ទាក់ទងនឹងព័ត៌មានដែលត្រូវបានចោទអ្នកស្រី អ៊ឹម ចែម ថាអ្នកស្រីមានវត្តមាននៅក្នុងកិច្ចប្រជុំមួយជាមួយ តា ជាល តា រិន និង តា ចាយ ។ សាក្សីមិនបានបង្ហាញការដឹងឮរបស់គាត់ដោយឯករាជ្យនោះឡើយ[381] ។

---

376 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រឿង សារួន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D5/865,** KH00957090។

377 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D118/65 ឆ:**29។

378 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D118/65 ឆ:**29។

379 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ រ៉ុំ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108 ឆ:**107, **ឆ:**124។

380 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ រ៉ុំ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108 ឆ:**72-73។

381 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ រ៉ុំ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/108 ឆ:**78។

- ព្រះរាជអាជ្ញាអន្តរជាតិមិនគួរសំអាងលើភស្តុតាងដែលផ្តល់ដោយសាក្សី ចៀម តាប់ ជាការគាំទ្រដល់ការលើកឡើងដែលថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកតំបន់ ហើយក្រោយមកបានក្លាយជាអនុលេខាគណៈតំបន់៥ នោះទេ[382] ។ សាក្សីនេះបានអះអាងដោយភ័ន្តច្រឡំថា អ្នកស្រី អ៊ឹម ចែម បានជំនួសតំណែង តា ហ៊ីង ជាលេខាតំបន់៥ នៅដើមខែវិច្ឆិកា ឬ ខែសីហា ឆ្នាំ ១៩៧៧[383] ខណៈដែលមានភស្តុតាងបង្ហាញយ៉ាងច្បាស់[384] ថា តាជាល ហើយក្រោយមកគឺ តា រិន បានដើរតួនាទីជាលេខាតំបន់នៅក្នុងតំបន់៥ បន្ទាប់ពី តាហ៊ីង[385] ។

- ភស្តុតាងបានពីសាក្សី ទឹក សួង ដែលលើកឡើងថា អ្នកស្រី អ៊ឹម ចែម ត្រូវបានដំឡើងឱ្យធ្វើជាមេដឹកនាំថ្មីក្នុងស្រុកព្រះនេត្រព្រះ និងតំបន់៥[386] នៅពេលអ្នកស្រីមកដល់ភូមិភាគពាយព្យ (និងជាសាក្សីដែលត្រូវបានយកជាសំអាងផងដែរ ដើម្បីគាំទ្រដល់ការអះអាង

---

382 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-១៩)*ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/91** ឆ:14-15, ឆ:20-25។

383 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/91** ឆ:15។

384 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២។

385 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29** ឆ:17។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:29។ អង្គការលេខរបស់តំបន់ ៥ ភូមិភាគពាយព្យ (ស្រុកព្រះនេត្រព្រះ) ដែលត្រូវបានធ្វើបច្ចុប្បភាពចុងក្រោយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/135.1**។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាន ឈួង ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.6**, KH00734094, KH00734096។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កៅ ផាន ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D123/1/2.62**, KH00739780។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, KH00929783។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D123/1/5.1c**, KH00929882។ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ចាន់ សំ ហៅ កង ចាប ហៅ សែ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារ **D1.3.4.2**, EN 00223044, 00223046។

386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:16-19។

ដែលថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកគណៈតំបន់៥[387]) នោះ មានតម្លៃជឿជាក់បានជាភស្តុតាងក្នុងកម្រិតដ៏ស្តួចស្តើងបំផុត ។ ភស្តុតាងនេះមិនត្រូវបានបញ្ជាក់គាំទ្រដោយភស្តុតាងក្នុងសំណុំរឿង០០៤/១ នោះទេ[388] ។ ភស្តុតាងដែលបានប្រើនោះ ក៏ត្រូវបានប្រឆាំងដោយភស្តុតាងមានឧត្តមានុភាព ដែលបង្ហាញថា តា ជាល ជាអ្នកគ្រប់គ្រងតំបន់៥ នៅពេលដែលអ្នកស្រី អ៊ឹម ចែម មកដល់ ហើយត្រូវបានជំនួសដោយ តា រិន[389] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរសំអាងលើផស្តុតាង ដែលផ្តល់ដោយសាក្សី ក្រូច ទឹម ដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់ ៥[390] ឡើយ ។ សាក្សីរូបនេះបានបង្ហាញថា ភស្តុតាងដែលគាត់បានផ្តល់ក្នុងកិច្ចសម្ភាសន៍ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជានាពេលកន្លងមក ត្រង់ចំណុចដែលគាត់លើកឡើងថា អ្នកស្រី អ៊ឹម ចែម ត្រូវបានដំឡើងតំណែងជាគណៈតំបន់៥[391] នោះ គឺដឹងក្រោយពីការជួលរលំ

[387] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងដល់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក ស្លុង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:18-19។

[388] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២។

[389] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29** ឆ:17។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:29។ អង្គការលេខរបស់តំបន់ ៥ ភូមិភាគពាយព្យ (ស្រុកព្រះនេត្រព្រះ) ដែលត្រូវបានធ្វើបច្ចុប្បភាពចុងក្រោយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/135.1**។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាន ឈួង ថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ **D67.6**, KH 00734094, KH 00734096។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កៅ ផាន ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D123/1/2.62**, KH 00739780។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, KH 00929783។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D123/1/5.1c**, KH 00929882។ ចម្លើយសារភាពរបស់មន្ទីរស-២១ របស់ ចាន់ សំហៅ ចាប ហៅ សែ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារ **D1.3.4.2**, EN 00223044, 00223046។

[390] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងទៅលើ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ក្រូច ទឹម ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ **D119/69/2**, KH00969055។

[391] *សូមមើល* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ក្រូច ទឹម ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ **D119/69/2**, KH00969055។

របបកម្ពុជាប្រជាធិបតេយ្យពីមនុស្សម្នាក់ដែលគាត់មិនស្គាល់ឈ្មោះ[392] ។ ទីបំផុតទៅ គាត់បានអះអាងថា គាត់មិនដឹងប្រាកដទេថា អ្នកស្រី អ៊ឹម ចែម ធ្លាប់បានធ្វើការងារនៅថ្នាក់តំបន់[393] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរផ្អែកលើភស្តុតាង ដែលផ្តល់ដោយ ប៊ិន ហ៊ីយ ដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់៥[394] នោះទេ ។ ប៊ិន ហ៊ីយ បានចោទប្រកាន់ថា អ្នកស្រី អ៊ឹម ចែម បានក្លាយជា "ប្រធានតំបន់៥ នៅដើមឆ្នាំ ១៩៧៨[395]" ប៉ុន្តែក្រោយមកបានលើកឡើងថា គាត់ត្រូវបានចាប់ខ្លួននៅពេលនោះ ហេតុដូច្នេះហើយ ទើបគាត់ "មិនបានដឹងរឿងច្រើននោះទេ" អំពីអ្នកស្រី អ៊ឹម ចែម[396] ។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរសំអាងលើភស្តុតាងដែលផ្តល់ដោយសាក្សី ប្រាក់ ស៊ឹម ពាក់ព័ន្ធនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងគណៈតំបន់នេះទេ[397] ។ ភស្តុតាងដែលផ្តល់ដោយសាក្សីរូបនេះ គ្មានភាពស៊ីសង្វាក់គ្នាទាល់តែសោះ ។ សាក្សីបានថ្លែងថា អ្នកស្រី អ៊ឹម ចែម គឺជាអនុលេខានៃគណៈតំបន់ថ្មីស្ថិតក្រោមការដឹកនាំរបស់ តា ចាយ ហើយក៏បានអះអាងផងដែរថា តាមពិតអ្នកស្រី អ៊ឹម ចែម ទទួលបន្ទុកស្រុកព្រះនេត្រព្រះ[398] ។

---

[392] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:83, 87, ឆ:91-93, ឆ:96-97។

[393] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារលេខ **D119/69** ឆ:140 ["ពេលនោះ ខ្ញុំដឹងថា គាត់នៅថ្នាក់ស្រុក ខ្ញុំមិនច្បាស់ថា គាត់នៅថ្នាក់តំបន់ទេ"]។

[394] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៩) *ដែលយោងដល់*បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:12- 13។

[395] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:9។

[396] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:10។

[397] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨), កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19-20។

[398] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:19។

- សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរសំអាងលើភស្តុតាងដែលផ្តល់ដោយសាក្សី ឡុង វុន ដែលបានលើកឡើងថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកថ្មីនៃគណៈតំបន់៣ ស្ថិតក្រោមការដឹកនាំរបស់ តា ចាយ[399] (និងត្រូវបានយកមកសំអាងដើម្បីគាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិក ហើយក្រោយមកជាអនុលេខាតំបន់៥[400]) ។ កន្លងទៅ សាក្សីបានចង្អុលបង្ហាញថា តា ចាយ បានគ្រប់គ្រងតំបន់នេះតែម្នាក់ឯងគត់[401] ។ ឡុង វុន ដែលបានធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៣[402] ក៏បានទទួលស្គាល់ផងដែរថា គាត់ត្រូវបាន "គេប្រាប់អំពីតួនាទីរបស់ [អ្នកស្រី អ៊ឹម ចែម]"[403] ។ ប្រសិនបើអ្នកស្រី អ៊ឹម ចែម គឺជាសមាជិកនៃគណៈតំបន់៣ ដូចដែលត្រូវបានចង្អុលបង្ហាញមែននោះ វាទំនងជាថា ឡុង វុន នឹងបានដឹងឮដោយផ្ទាល់អំពីតួនាទីរបស់អ្នកស្រី ។ ឡុង វុន មិនត្រូវបានស្នើឱ្យកំណត់អត្តសញ្ញាណរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងរូបថត ឬក៏សូម្បីតែស្នើឱ្យពិពណ៌នាអំពីអ្នកស្រីដែរ ។ អ្នកស្រី អ៊ឹម ចែម ងាយស្រួលនឹងចំណាំណាស់ ក៏ព្រោះតែនៅពេលនោះ អ្នកស្រីកំពុងមានផ្ទៃពោះចាស់ខែ ។

១០៧. សរុបសេចក្តីមក វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាចំពោះភស្តុតាង គឺខកខានមិនបានវាយតម្លៃភស្តុតាង ដោយផ្តោតទៅលើភាពមិនលម្អៀង ឬការស្វែងរកការពិតនោះឡើយ ។ ភស្តុតាងដែលបានប្រើសំអាង មិនមានលក្ខណៈខ្លាំងក្លា ឬជាភស្តុតាងតែមួយ និងគ្មានភស្តុងតាងណាផ្សេងអាចបញ្ជាក់បន្ថែមបាន និងខ្វះតម្លៃជាភស្តុតាងបន្ទាល់ដែលមានអត្ថន័យរួមចូលគ្នាមួយ។ លើសពីនេះទៀត ដូចនឹងត្រូវពិភាក្សាខាងក្រោម នៅពេលធ្វើការពិចារណាធៀបជាមួយនឹងភស្តុតាងដែលអាចទុកចិត្តបានបន្ថែមផ្សេងៗទៀត វាបង្ហាញយ៉ាងច្បាស់ថា រាល់ព័ត៌មានទាំងឡាយណាដែលគ្មានតម្លៃជាភស្តុតាងត្រូវបានជម្រុះចោលភ្លាមៗដោយគ្មានការរារែក ។

---

399 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:57។

400 *សូមមើល* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ៥៨ (ជើងទំព័រ ២១៨-២១៩), *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:57, ឆ:59។

401 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:36។

402 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:32។

403 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:59 ["ព្រោះពេលដែលខ្ញុំឡើងមកប្រជុំ គឺខ្ញុំជួបគាត់ ហើយពេលនោះគេប្រាប់អំពីតួនាទីរបស់គាត់"]។

១០៨. ជាពិសេស បើទោះជាក្នុងនាមជាអតីតនីរសាររបស់ តា ចាយ និងជាសាក្សីដែលបានដឹងឮរឿងរ៉ាវច្រើនបំផុតអំពីរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យក្តី[404] ក៏សហព្រះរាជអាជ្ញាអន្តរជាតិមិនបានដកស្រង់សម្តីរបស់សាក្សី ហែម មាន ដែលមានព័ត៌មានទាក់ទងនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគពាយព្យនោះទេ ។ ហែម មាន បានបញ្ជាក់អះអាងថា អ្នកស្រី អ៊ឹម ចែម ជាគណៈស្រុកព្រះនេត្រព្រះ[405] ។ គាត់មិនបាននិយាយសោះឡើយថាអ្នកស្រី អ៊ឹម ចែម មានមុខងារនៅថ្នាក់តំបន់ កុំថាឡើយដល់ទៅកម្រិតអនុលេខាតំបន់៥ ។

១០៩. ដូចដែលភស្តុតាងបង្ហាញផងដែរ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ភូមិភាគពាយព្យបានស្ថិតក្រោមការធ្វើកំណែទម្រង់រដ្ឋបាលដ៏ធំ[406] ដោយផ្នែកខ្លះនៃតំបន់៥ (រួមទាំងស្រុកព្រះនេត្រព្រះ) ត្រូវបានរួមបញ្ចូលទៅក្នុងតំបន់៣[407] ស្ថិតក្រោមការគ្រប់គ្រងរបស់ តា ចាយ[408] ។ ទោះជាយ៉ាងណា នៅ

---

404 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/123** ឆ:7។

405 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/123** ឆ:6។

406 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, KH00929773 [ដែលកត់សម្គាល់ថា ភូមិភាគពាយព្យត្រូវបានរៀបចំឡើងវិញនៅខែ ធ្នូ ឆ្នាំ ១៩៧៨ ដោយសារតំបន់នេះស្ថិតក្នុងភាពច្របូកច្របល់]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:33-35, ឆ:55 [ដែលនិយាយថា ពីរខែមុនពេលវៀតណាមបានចូលមកដល់ស្រុកស្វាយស៊ីសុផុន ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះត្រូវបានរួមបញ្ចូលទៅក្នុងតំបន់៣]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:41 ឆ:47- 48 [ផ្នែកខ្លះនៃតំបន់៥ ត្រូវបានប្រគល់ទៅឱ្យតំបន់៣ ភ្លាមៗមុនពេលវៀតណាមចូលមកដល់]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:1, ឆ:16-19។

407 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:33-35, ឆ:55 [ដែលនិយាយថា ពីរខែមុនពេលពេលវៀតណាមបានមកដល់ស្រុកស្វាយស៊ីសុផុន ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះត្រូវបានរួមបញ្ចូលទៅក្នុងតំបន់៣]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:41, ឆ:47-48 [ផ្នែកខ្លះនៃតំបន់៥ ត្រូវបានប្រគល់ទៅឱ្យតំបន់៣ ភ្លាមៗមុនពេលវៀតណាមចូលមកដល់]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:1, ឆ:16-19។

ពេលដែលវៀតណាមចូលមកដល់ តំបន់នេះ "គេរៀបចំគណៈតំបន់មិនទាន់"[409] រួចនៅឡើយទេ ។ អ្នកស្រី អ៊ឹម ចែម អាចត្រូវបានគេរក្សាទុកសម្រាប់មុខតំណែងនាពេលអនាគតមួយចំនួននៅក្នុងគណៈតំបន់ថ្មីនេះ[410] ។ ការណ៍នេះមិនមានភាពច្បាស់លាស់បង្ហាញដោយភស្តុតាងឡើយ ។ អ្វីដែលច្បាស់លាស់នោះគឺថា ដំណើរនេះមិនបានកើតឡើងទេ ហើយផែនការបែបនេះណាមួយប្រសិនបើមានមែន វាក៏ត្រូវបានអាក់ខានទៅវិញដែរ ដោយការមកដល់របស់កងទ័ពវៀតណាម ។ ការណ៍នេះ មានភាពស៊ីសង្វាក់គ្នាជាមួយនឹងការថ្លែងរបស់អ្នកស្រី អ៊ឹម ចែម និងសាក្សីផ្សេងទៀតដែលនិយាយថា អ្នកស្រីបានទទួលខុសត្រូវលើស្រុកព្រះនេត្រព្រះរហូតទាល់តែចប់របបកម្ពុជា

---

408 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/37** ឆ:50 ["មុនដំបូង តា រិន ជាគណៈតំបន់ តែក្រោយពី តា រិន ត្រូវបានចាប់ខ្លួន តា ចាយ មកគ្រប់គ្រងជំនួស តា រិន ហើយធ្វើការជាមួយ យាយចែម"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ**D118/153** ឆ:26 [ដែលកត់សម្គាល់ថា តា ចាយ ជាប្រធានតំបន់៣ រហូតទាល់តែវៀតណាមមកដល់ក្នុងរយៈពេលពីរបីខែក្រោយមក] ឆ:36 [ដែលកត់សម្គាល់ថា តា ចាយ ជាគណៈតំបន់៣ នៅពេលតំបន់៥ ត្រូវបានរួមបញ្ចូលទៅក្នុងតំបន់៣]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:16-19, ឆ:33 [ដែលនិយាយថា តា ចាយ ជាប្រធានតំបន់ ដែលស្រុកមង្គលបុរី និងស្រុកស៊ីសុផុនស្ថិតនៅក្នុងតំបន់នេះ និងថា តា ចាយ ជាមេម្នាក់ក្នុងចំណោមមេផ្សេងៗទៀតក្នុងតំបន់នេះ ដោយយាយ ចែម ទទួលខុសត្រូវស្រុកព្រះនេត្រព្រះ]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/38** ឆ:18 [ដែលនិយាយថា តា ចាយ ជាគណៈតំបន់នៅមង្គលបុរី]។

409 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:36។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខ្មែត ម៉ៅ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **D219/638** ឆ:13 [ដែលនិយាយថា ប្រទេសស្ថិតក្នុងសភាពចលាចលខ្លាំងស្រុងនៅពេលជិតកងទ័ពវៀតណាមចូលមក]។

410 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **D118/93** ឆ:1, ឆ:19 [ដែលបង្ហាញថា អ្នកស្រី អ៊ឹម ចែម ជាអនុលេខាតំបន់៣ ទទួលខុសត្រូវស្រុកព្រះនេត្រព្រះ]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:59 [ដែលកត់សម្គាល់ថា អ្នកស្រី អ៊ឹម ចែម បានក្លាយជាសមាជិកនៃគណៈតំបន់៣]។ *ក៏ប៉ុន្តែសូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:36 [ដែលបង្ហាញថា តា ចាយ បានគ្រប់គ្រងគណៈតំបន់តែម្នាក់ឯង]។

ប្រជាធិបតេយ្យនោះឡើយ[411] ។ ការណ៍នេះ ក៏មានភាពស៊ីសង្វាក់គ្នាផងដែរនឹងចម្លើយសារភាពពីមន្ទីរស-២១ ទាក់ទងនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ដែលបញ្ជាក់ឱ្យឃើញថា អ្នកស្រីជាលេខាស្រុកព្រះនេត្រព្រះនៅខែ ធ្នូ ឆ្នាំ ១៩៧៨[412] ។

១១០. សរុបសេចក្តីមក ភស្តុតាងមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីតម្លៃជាភស្តុតាងបញ្ជាក់ក្នុងកម្រិតណាមួយថា អ្នកស្រី អ៊ឹម ចែម មានតួនាទី *ស្របច្បាប់* នៅក្នុងគណៈតំបន់៥ នោះទេ។ ដូចដែលនឹងចង្អុលបង្ហាញខាងក្រោម ភស្តុតាងក៏មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ផ្តល់ជម្រើសណាផ្សេងដល់សំណុំរឿងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែរ ពោលគឺបំណងដែលបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច *ជាក់ស្តែង* ប្រហាក់ប្រហែលទៅនឹងថ្នាក់តំបន់នោះ ។

### *ii. អ្នកស្រី អ៊ឹម ចែម គ្មានតួនាទីជាសមាជិក ឬអនុលេខា ជាក់ស្តែង នៃគណៈតំបន់៥*

១១១. សហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមបន្ថែមភាពរឹងមាំលើសេចក្តីសំអាងហេតុដែលថា អ្នកស្រី អ៊ឹម ចែម មានតួនាទីជាប្រធានតំបន់[413] និងជាពិសេសថា អ្នកស្រីជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង (ទីតាំងឧក្រិដ្ឋកម្មទាំងពីរស្ថិតក្នុងតំបន់៥ ដែលជាទីតាំងអ្នកស្រី

---

[411] *សូមមើល* បទសម្ភាសន៍របស់ អ៊ឹម ចែម ដែលធ្វើឡើងដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, KH00234193 ["ខ្ញុំត្រូវទទួលស្រុកហ្នឹង ហើយខ្ញុំទៅនៅស្រុកព្រះនេត្រព្រះចុងក្រោយបង្អស់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/29** ឆ:9 [ដែលថ្លែងថា គាត់បានរត់គេចខ្លួនជាមួយ អ៊ឹម ចែម នៅក្នុងឆ្នាំ ១៩៧៩ និងថា គាត់បានជួយការពារ អ៊ឹម ចែម ដោយគាត់ជាគណៈស្រុក]។ *សូមមើលផងដែរ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ (សក្ខីកម្មរបស់សាក្សី ឈិត យឿក) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/330.1**, KH01130937 [ដែលថ្លែងថា អ៊ឹម ចែម គាត់ជាស្រុក ឬជំនួយតំបន់អីអស់ហើយ]។

[412] *សូមមើល* ចម្លើយសារភាពនៅមន្ទីរស-២១ របស់ គង់ សុផល ហៅ កឺ ថ្ងៃ ៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ ឯកសារ **D1.3.4.6**, KH00024714 [ចុះឈ្មោះអ្នកស្រី អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៧៨]។

[413] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៧២ និងកថាខណ្ឌ ១២៣។

ត្រូវបានរងការចោទប្រកាន់ពីការជាប់ពាក់ព័ន្ធ[414]) ដោយអះអាងថា i) អ្នកស្រី អ៊ឹម ចែម មិនត្រឹមតែអាចចូលរួមក្នុងកិច្ចប្រជុំនៅថ្នាក់តំបន់ប៉ុណ្ណោះទេ តែថែមទាំងជាអ្នករៀបចំកិច្ចប្រជុំទាំងនោះទៀតផង[415] ដែលបញ្ហាខ្មាំងផ្ទៃក្នុងត្រូវបានលើកយកមកពិភាក្សា[416] និងថា ii) អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចធ្វើជាអធិបតីភាពក្នុងអង្គប្រជុំធំៗជាមួយ *តា ម៉ុក*[417] ។

១១២. ដូចនឹងធ្វើការពិភាក្សានៅផ្នែកខាងក្រោម ការអះអាងទាំងនេះមិនបានផ្អែកលើភស្តុតាងដែលមានលក្ខណៈខ្លាំងក្លា ឬស៊ីសង្វាក់គ្នានោះទេ ។ ទីមួយ ការវាយតម្លៃសមហេតុផលនៃភស្តុតាង គឺមិនគាំទ្រដល់ការអះអាងជាទូទៅដែលថា អ្នកស្រី អ៊ឹម ចែម ជាអ្នករៀបចំកិច្ចប្រជុំនានានៅថ្នាក់តំបន់ កុំថាឡើយថាដល់ទៅរៀបចំកិច្ចប្រជុំ ដែលពិភាក្សាអំពីបញ្ហាខ្មាំងផ្ទៃក្នុងនោះ ។ ទីពីរ ការអះអាងដែលថាអ្នកស្រី អ៊ឹម ចែម បានចូលរួមធ្វើជាអធិបតីក្នុងកិច្ចប្រជុំធំៗជាមួយនឹង *តា ម៉ុក* មានភាពពាក់ព័ន្ធតិចតួចណាស់ ។ បើទោះបីជាការអះអាងនេះ មិនត្រូវបានផ្អែកលើសេចក្តីថ្លែងការណ៍ដែលមិនស៊ីសង្វាក់គ្នារបស់សាក្សីតែម្នាក់ក៏ដោយ ក៏ការអះអាងនេះមិនអាចបង្ហាញនូវអ្វីដែលមានន័យទាក់ទងនឹងការមានសិទ្ធិអំណាច *ជាក់ស្តែង* ដូចដែលបានអះអាងចំពោះសកម្មភាព ឬឧក្រិដ្ឋកម្មនានាបានដែរ ។

<u>សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ថាជាអ្នករៀបចំកិច្ចប្រជុំនានានៅថ្នាក់*តំបន់*</u>

១១៣. បរិបទភស្តុតាងនៅខាងក្រោមគួរតែត្រូវបានចងចាំ នៅពេលពិចារណាលើបញ្ហានេះ ។ ដូចបានបង្ហាញរួចហើយនៅខាងលើ អ្នកស្រី អ៊ឹម ចែម បានបន្តស្ថិតនៅថ្នាក់ស្រុកចាប់ពីចុងឆ្នាំ ១៩៧៧ រហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[418] ហើយអ្នកស្រីមិនធ្លាប់បានទទួលតួនាទីណា

---

414 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦-៩៩ និង ២៦១-៦៣។ *សូមមើល* ការជូនដំណឹងអំពីការចោទប្រកាន់ ឯកសារ **D239.1**។

415 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤)។

416 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៦)។

417 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៧)។

418 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២-១០។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ១២២-៤២។

មួយនៅថ្នាក់តំបន់ឡើយ[419] ។ អ្នកស្រី ណុប ង៉ឹម ដែលជាអនុលេខាស្រុកមួយរូបនៅភូមិភាគពាយព្យ[420] បានកត់សម្គាល់ថា តាមបទបញ្ជាទូទៅ កម្មាភិបាលថ្នាក់ស្រុកមិនមានសិទ្ធិទៅជំនួសកម្មាភិបាលថ្នាក់តំបន់ឡើយ ដោយនិយាយថា "ការងារ គឺបែងចែកដាច់រវាងថ្នាក់តំបន់ និងថ្នាក់ស្រុក"[421] ។ ក្នុងនាមជាលេខាស្រុក*ស្របច្បាប់* និង*ជាក់ស្តែង* អ្នកស្រី អ៊ឹម ចែម មានទំនាក់ទំនងផ្ទាល់តែជាមួយនឹងថ្នាក់លើ និងថ្នាក់ក្រោមដែលនៅជាប់ផ្ទាល់នឹងអ្នកស្រីប៉ុណ្ណោះ ។ ស្រុកព្រះនេត្រព្រះ និងភូមិភាគពាយព្យ គឺត្រូវអនុវត្តដូចគ្នាតាមខ្សែសង្វាក់នៃការបញ្ជាតឹងរ៉ឹង ផ្អែកសេចក្តីបង្គាប់បញ្ជាតាមរយៈលក្ខន្តិកៈរបស់ ប.ក.ក និងត្រូវបានអនុវត្តជាក់ស្តែង នៅតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេស[422] ។

---

419 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២-១០។ ចម្លើយតប នៅកថាខណ្ឌ ១២២-៤២។

420 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី ១២-១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:31។

421 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី ១២-១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285**, ស-ឆ:47 ["ស: កម្មាភិបាលនៅថ្នាក់ស្រុក តើគេមានសិទ្ធិធ្វើការងារជំនួសថ្នាក់តំបន់ទេ? ឆ:47: ការងារ គឺបែងចែកដាច់រវាងថ្នាក់តំបន់ និងថ្នាក់ស្រុក"]។

422 *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** នៅកថាខណ្ឌ ២៧០។ *សូមមើលជាឧទាហរណ៍,* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/93** ឆ:10 ["សហករណ៍គិរីវ័ន្ត ត្រូវរាយការណ៍ទៅគណៈឃុំជប់វារី ឈ្មោះ តា រស់។ តា រស់ ត្រូវរាយការណ៍ទៅគណៈស្រុកព្រះនេត្រព្រះ ឈ្មោះ តា សំអាត។ តា សំអាត ត្រូវរាយការណ៍ទៅគណៈតំបន់បន្ត ប៉ុន្តែខ្ញុំមិនស្គាល់នរណាគេជាគណៈតំបន់៥ ទេ។ គណៈតំបន់ត្រូវរាយការណ៍ទៅគណៈភូមិភាគ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះគណៈភូមិភាគទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:41 ["តាមធម្មតាការរាយការណ៍គឺចេញពីប្រជាជន ទៅប្រធានក្រុម ទៅប្រធានភូមិ ទៅប្រធានឃុំ និងឡើងទៅស្រុក។"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:37 ["[នៅពេលនោះគណៈស្រុកទទួលព័ត៌មានពីថ្នាក់តំបន់អំពីចំនួនមនុស្សដែលទទួលបាន ក្រោយមកគណៈស្រុកបានកោះហៅគណៈឃុំនានាឱ្យមកចូលរួមប្រជុំ ហើយបន្ទាប់មកទៀត គេបានផ្តល់ព័ត៌មានទៅដល់គណៈឃុំអំពីចំនួនមនុស្សដែលត្រូវបែងចែកឱ្យទៅតាមឃុំនីមួយៗ"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី ១២-១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:44 ["ជាទូទៅរបបនៃការរាយការណ៍ គឺធ្វើពីសហករណ៍ទៅឃុំ ពីឃុំទៅស្រុក ពីស្រុកទៅតំបន់ ពីតំបន់ទៅភូមិភាគ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ថ្ងៃទី ៣-៥ ខែ សីហា ឆ្នាំ

១១៤. សហព្រះរាជអាជ្ញាអន្តរជាតិយោងលើឯកសារសំអាងចំនួន៧ ដើម្បីចោទថា អ្នកស្រី អ៊ឹម ចែម ជា *អ្នករៀបចំ* កិច្ចប្រជុំនៅថ្នាក់តំបន់[423] និងមានឯកសារសំអាងតែមួយគត់[424] សម្រាប់ការអះអាងដែលថា នៅក្នុងកិច្ចប្រជុំទាំងនេះមានការពិភាក្សាអំពីខ្មាំងផ្ទៃក្នុង[425] ។ ឡុង វុន ដែលបានរៀបរាប់អំពីកិច្ចប្រជុំមួយធ្វើឡើងនៅថ្នាក់តំបន់[426] គឺជាសាក្សីតែមួយគត់ ដែលត្រូវបានដកស្រង់សម្ដីទាក់ទងនឹងការអះអាងដែលថា "ការប្រជុំថ្នាក់តំបន់បានពិភាក្សាពីការស្វែងរកខ្មាំងផ្ទៃក្នុង"[427] ។ ទោះជាយ៉ាងនេះក្ដី វាជាការចាំបាច់ត្រូវកត់សម្គាល់ថា នៅពេលសួរគាត់ពីដំបូងអំពីប្រធានបទមួយចំនួនដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនោះ សាក្សី ឡុង វុន បានឆ្លើយថា៖ គេជជែកពី "ការកសាងទំនប់ ប្រឡាយ សាងសង់ផ្លូវ និងរោងអារឈើ ។ និយាយរួម គឺខាងកសិកម្ម ហើយនិងរៀបចំផែនការធ្វើការអ្វីទៀតងារនៅខែក្រោយ"[428] ។ មានតែក្រោយពីបានជជីកសួរដេញដោលអំពីថាតើអាចមានការពិភាក្សាពីបញ្ហាខ្មាំង ឬជនក្បត់ដែរឬទេ ទើបសាក្សីរូបនេះបានពង្រីកចម្លើយតបពីខាងដើម

---

២០១៥ ឯកសារ **D219/442** ឆ:43 ["អ្នកណាក៏ដឹងដែរសម្រាប់ការងារអ្វីក៏ដោយមិនថា តូច ឬ ធំទេអ្នកត្រូវរាយការណ៍ទៅថ្នាក់លើ"]។

[423] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម ម៉ន ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/96** ឆ74 ឆ:104, ឆ:105។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D119/76** ឆ:19-20, ឆ:23។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:17-18។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:59, ឆ:61។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:55, ឆ:58-59។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:147។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប ហ៊ិន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/473** ឆ:14។

[424] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៦) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:57, ឆ:59, ឆ:61-62។

[425] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤ និង ៦១៦)។

[426] *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:59-61។

[427] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៦)។

[428] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153** ឆ:60។

របស់ខ្លួន[429] ។ ជាការងាយយល់បំផុត បើទោះបីភស្តុតាងនេះ អាចគាំទ្របាន ដោយសាការគិតថា វាសំខាន់ និងមានឥទ្ធិពលក៏ដោយ ក៏ចរិតលក្ខណៈនៃទង្វើដែលនាំឱ្យទទួលបានភស្តុតាងរបៀបនេះ មិនអាចនឹងមិនអើពើបានឡើយ ។ វាជាភស្តុតាងមិនគ្រប់ជ្រុងជ្រោយដើម្បីប្រើសម្រាប់ការគាំទ្រ ដល់ចំណុចដ៏សំខាន់នៅក្នុងសេចក្តីសំអាងហេតុស្តីពីសិទ្ធិអំណាច *"ជាក់ស្តែង"* របស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

១១៥. លើសពីនេះទៀត ឯកសារសំអាងចំនួន ៧ ដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម ជាអ្នក*បានរៀបចំ* កិច្ចប្រជុំនៅថ្នាក់តំបន់ គឺជាភស្តុតាងដែលមិនបានផ្តល់នូវភាពស៊ីសង្វាក់គ្នាពេញលេញ ឬអាចគាំទ្រដល់ការអះអាងនេះឡើយ[430] ។ ផ្ទុយទៅវិញ ក្រៅតែពីកលឧបាយខាងផ្លូវច្បាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ភស្តុតាងបន្ថែមនេះគ្រាន់តែបង្ហាញថា សិទ្ធិអំណាច*ស្របច្បាប់* និង*ជាក់ស្តែង*របស់អ្នកស្រី អ៊ឹម ចែម គឺត្រូវបានកំណត់ត្រឹមជាលេខាស្រុកសាមញ្ញម្នាក់តែប៉ុណ្ណោះ ។

១១៦. ទីមួយ ចម្លើយរបស់ អ៊ឹង ជឿន[431] គឺមិនទាក់ទងទាល់តែសោះទៅតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ក្នុងភូមិភាគពាយព្យ ។ ចម្លើយរបស់គាត់បង្ហាញពីអង្គហេតុដែលថា អ្នក

---

[429] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D118/153**, ស-ឆ:61។

[430] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ម៉ន ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/96** ឆ:74, ឆ:104, ឆ:105។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D119/76** ឆ:19-20, ឆ:23។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:17-18។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:59, ឆ:61។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:55, ឆ:58-59។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ធួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:147។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ហ៊ិន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/473** ឆ:14។

[431] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:17, ឆ:18។

ស្រី អ៊ឹម ចែម បានរៀបចំប្រជុំជាមួយអ្នកធ្វើការងារ*នៅថ្នាក់ក្រោម*ស្រុក *ខណៈពេលដែលអ្នកស្រីនៅក្នុង*ភូមិភាគនិរតី[432] ។ ចម្លើយរបស់សាក្សី អ៊ឹម ម៉ន សាក្សី ប៊ូ គួក និង ព្រាប ហ៊ិន គ្រាន់តែផ្តល់ភស្តុតាងដែលថា អ្នកស្រី អ៊ឹម ចែម អាចធ្វើដំណើរតាមរយៈមធ្យោបាយមួយចំនួនដើម្បីទៅចូលរួមប្រជុំ[433] ។ បើទោះបីជាសាក្សី លៀម សារ៉េម បានអះអាងថា ខ្លួនធ្លាប់ចូលរួមក្នុងកិច្ចប្រជុំមួយដែលអ្នកស្រី អ៊ឹម ចែម *បាននិយាយ*ជាមួយនឹងប្រធានកងចល័តនៃតំបន់៥ ឈ្មោះ តា វ៉ាល់ ក៏ដោយ[434] ក៏សាក្សីរូបនេះមិនអាចកំណត់អត្តសញ្ញាណរបស់អ្នកស្រី អ៊ឹម ចែម តាមរយៈរូបថតជាច្រើនដែលបានដាក់បង្ហាញឱ្យគាត់មើលដែរ[435] ។ សាក្សីបានបន្តទទួលស្គាល់ថា គ្មានការនិយាយពីការសម្លាប់ឡើយ ហើយកិច្ចប្រជុំភាគច្រើនគ្រាន់តែលើកឡើងអំពី [អង្គការ]"មហាលោតផ្លោះមហាអស្ចារ្យ និងឱ្យ[ប្រជាពលរដ្ឋ] ជួយធ្វើការ *អង្គការ* ឱ្យឈានទៅសម្រេចផែនការ"[436] ។

១១៧. ការវិភាគចុងក្រោយបង្ហាញថា ក្នុងចំណោមការរៀបរាប់ចំនួនប្រាំពីរចំណុច គឺមានតែពីរចំណុចតែប៉ុណ្ណោះ ដែលផ្តល់ភស្តុតាងតិចតួចគាំទ្រលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម ជាអ្នក*បានរៀបចំ*ការប្រជុំថ្នាក់តំបន់ ។ ជាថ្មីម្តងទៀត ភស្តុតាងនេះមានភាពខ្វះខាតយ៉ាងខ្លាំង ។ ការពិត ការរៀបរាប់ទាំងពីរនោះ គ្រាន់តែបង្ហាញថា អ្នកស្រី អ៊ឹម

---

432 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផឹង ជឿន ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/156** ឆ:15-18។

433 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ម៉ន ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/96** ឆ:74, ស-ឆ:104, ឆ:105។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ គួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:147។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ហ៊ិន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/473** ឆ:14។

434 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D119/76** ឆ:19-20, ឆ:23។

435 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D119/76,** EN ERNs 00980712-13។

436 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D119/76** ឆ:21-22។

ចែម *បានចូលរួម*ការប្រជុំដែលមានវត្តមានកម្មាភិបាលមកពីថ្នាក់លើចូលរួមដែរ[437] ។ ការរៀបរាប់ទាំងនេះ មិនបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម អាច ឬបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ឡើយ ។ លើសពីនេះទៀត សាក្សីទាំងពីរមិនបានលើកឡើង ថាមានកិច្ចពិភាក្សាលើបញ្ហានានាទាក់ទងនឹងកិច្ចការសន្តិសុខក្នុងកិច្ចប្រជុំទាំងនោះទេ ប៉ុន្តែផ្ទុយទៅវិញ សាក្សីទាំងពីរបានបញ្ជាក់ពីពិភាក្សាលើការងារផ្នែកកសិកម្ម និងការជីកប្រឡាយ[438] ។ ដូចដែលបានពិភាក្សាខាងដើម ការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម ក្នុងកិច្ចប្រជុំថ្នាក់តំបន់ គ្មានអ្វីខុសប្លែកពីកម្មាភិបាលថ្នាក់ស្រុកធម្មតាឡើយ[439] ។

## <u>សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ថា អ្នកស្រីជាគណៈអធិបតីក្នុងអង្គប្រជុំធំៗជាមួយនឹង *តា មុក*</u>

១១៨. ការប្រាស្រ័យទាក់ទងជាមួយនឹងថ្នាក់លើដែលខ្ពស់ជាងថ្នាក់តំបន់ ដូចជាកម្មាភិបាលថ្នាក់ភូមិភាគមានជាអាទិ៍ *តា ម៉ុក* គឺអាចកើតមានឡើង នៅពេលប្រជុំធំដែលបានគ្រោងទុកប៉ុណ្ណោះ ។ ដូចភស្តុតាងបានបង្ហាញ អ្នកស្រី អ៊ឹម ចែម មិនបាននិយាយអ្វីឡើយ លើកលែងតែអ្នកស្រីចាំបាច់ត្រូវរាយការណ៍ជូនអង្គប្រជុំ[440] ។

---

[437] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៤) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:59, ស-ឆ:61។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:55, ឆ:58, ឆ:59។

[438] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:58 [ដោយនិយាយថា ក្នុងកិច្ចប្រជុំនោះយាយចែម បាននិយាយអំពីការធ្វើកសិកម្ម និងកង្វះស្បៀង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:58 ["គេបានបើកអង្គប្រជុំដើម្បីឱ្យយើងរើសកម្លាំងឱ្យទៅគេ"]។

[439] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៩៤, ១១៣, ១១៧-១៨។

[440] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:58-63 [រម្លឹកឡើងវិញពីកិច្ចប្រជុំដែលធ្វើឡើងនៅការិយាល័យស្រុកព្រះនេត្រព្រះ ដែលដោយកម្មាភិបាលនៃតំបន់ ស្នើសុំកម្លាំងមនុស្សពីមូលដ្ឋាន ពេលខ្ញុំនៅទីនោះ យាយ ចែម មិនបាននិយាយទេ]។ *សូមមើល*ផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី ១២-១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:55 ["នៅក្នុងកិច្ចប្រជុំ អ្នកតំណាងនីមួយៗត្រូវរាយការណ៍ពីស្ថានភាពនៅតាមតំបន់របស់ខ្លួន។ ជាឧទាហរណ៍ សម្រាប់ស្រុកខ្ញុំ យើងរាយការណ៍ពី

១១៩. សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើសាក្សីតែម្នាក់ប៉ុណ្ណោះ ឈ្មោះ ប៊ិន ហ៊ីយ ក្នុងការអះអាងថា នៅកិច្ចប្រជុំធំឆ្នាំ១៩៧៨ *តា ម៉ុក* និងអ្នកស្រី អ៊ឹម ចែម ជាគណៈអធិបតីនៃអង្គប្រជុំ[441] ។ ទោះបីភស្តុតាងនេះអាចជឿជាក់បានក៏ដោយ ក៏វាជាការប្រជុំតែមួយគត់ដែលផ្តល់តម្លៃជាភស្តុតាងតិចតួចទាក់ទងនឹងសិទ្ធិអំណាចទូទៅរបស់អ្នកស្រី កុំថាឡើយដល់ទៅការគ្រប់គ្រងលើការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ លើសពីនេះគឺថា ច្បាស់ណាស់ដែលសក្ខីកម្មដូច្នេះ មិនអាចជឿជាក់បាន ។ ទីមួយ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងទៅលើការរៀបរាប់របស់ ប៊ិន ហ៊ីយ និងការអះអាងដែលថា មានមនុស្ស*រាប់ពាន់នាក់* បានចូលរួមក្នុងកិច្ចប្រជុំនោះ[442] ក៏ដោយ ក៏ការរៀបរាប់នេះ មិនមានភាពស៊ីសង្វាក់គ្នាទាំងស្រុងឡើយ ។ ជាងនេះទៅទៀត ប្រការសំខាន់បំផុតគឺថា ប៊ិន ហ៊ីយ "មិនបានដឹងទៀតទេ" ពីអ្នកស្រី អ៊ឹម ចែម[443] ។ ដោយសារកង្វះខាតនូវភាពស៊ីសង្វាក់គ្នាទាំងខាងក្នុង និងខាងក្រៅក្នុងការរៀបរាប់របស់សាក្សីនេះ សំណួរចោទថា តើសាក្សីត្រូវបានកំណត់អត្តសញ្ញាណរបស់អ្នកស្រី អ៊ឹម ចែម ត្រឹមត្រូវដែរឬទេនោះបានកើតមាន និងនៅតែមិនទាន់មានចម្លើយ ។ សាក្សីរូបនេះ មិនត្រូវបានពិសោធន៍មើលនូវសមត្ថភាពស្តីពីក្នុងការកំណត់អត្តសញ្ញាណអ្នកស្រី អ៊ឹម ចែម ទេ ។

១២០. សរុបមក ស្របគ្នានឹងការកំណត់អត្តសញ្ញាណមិនត្រឹមត្រូវដែលអាចកើតមាននេះ គឺជាការពិតលាក់មិនជិតមួយដែលគ្មានសាក្សីណាម្នាក់បង្ហាញឱ្យឃើញថា *តា ម៉ុក* បានជួប ឬនិយាយជាមួយអ្នកស្រី អ៊ឹម ចែម ដោយផ្ទាល់ឡើយខណៈដែលគាត់នៅក្នុងភូមិភាគពាយព្យ ក្រៅពីការប្រជុំធំៗ

---

របាយការណ៍ប្រចាំថ្ងៃ និងប្រចាំខែ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D117/70** ឆ:5 ["ខ្ញុំត្រូវរាយការណ៍ដោយផ្ទាល់ [ទៅលេខាធិការថ្នាក់តំបន់] នៅពេលប្រជុំជារៀងរាល់ខែ"]។

441 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១២៣ (ជើងទំព័រ ៦១៧) *ដោយយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:15។

442 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:15។

443 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **D119/66** ឆ:10 (**កំណត់សម្គាល់អ្នកពិនិត្យការបកប្រែ៖** ឆ:១០ នៅក្នុងភាសាអង់គ្លេសត្រូវគ្នានឹងឆ:៩ជាភាសាខ្មែរ) ។

តាមការដែលបានគ្រោងទុក ។ ដូចបានពិភាក្សាខាងលើ[444] ការពិតទៅ វាជាការអនុវត្តធម្មតារបស់លេខាថ្នាក់ស្រុកក្នុងការចូលរួមក្នុងកិច្ចប្រជុំដែលបានគ្រោងទុក ក្រោមការចូលរួមពីកម្មាភិបាលនានាមកពីនៃគណៈតំបន់ និងភូមិភាគ[445] ។ កង្វះទំនាក់ទំនងដោយផ្ទាល់រវាងកម្មាភិបាលថ្នាក់ភូមិភាគ (*តា ម៉ុក*) និងអ្នកស្រី អ៊ឹម ចែម ត្រូវបានបញ្ជាក់ថែមទៀតដោយអតីតនីរសារនៃលេខាតំបន់៣ ដែលបាននិយាយ វា*មិនអាចទៅរួចទេ* ចំពោះការដែលអ្នកស្រី អ៊ឹម ចែម ក្នុងតួនាទីជាគណៈស្រុក អាចផ្ញើសំបុត្រ និងទទួលសំបុត្រពីលេខាភូមិភាគពាយព្យ ដោយ*មិនមាន*ការដឹងឮពីលេខាតំបន់[446] មានន័យថា សំបុត្រទាំងអស់ត្រូវឆ្លាក់ដល់ដៃគាត់ជាមុនគេសិន ។ គាត់បានបញ្ជាក់ឱ្យដឹងថា ការប្រាស្រ័យទាក់ទងរវាង *តា ម៉ុក* និងអ្នកស្រី អ៊ឹម ចែម ត្រូវបានធ្វើឡើងដោយប្រយោល[447] ។

១២១. សរុបសេចក្តីមក មិនមានព័ត៌មានអ្វីគាំទ្រដល់សក្ខីកម្មរបស់ ប៊ិន ហឹយ ឡើយ ។ សាក្សីបានប្រឌិត

---

444 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៦៨-៧៤។

445 *សូមមើលជាឧទាហរណ៍* កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈិត យឿក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.9**, EN ERNs 00731126-28 [ដែលពណ៌នាអំពីប្រជុំនៅស្រុកស្វាយស៊ីសុផន ក្នុងតំបន់ ៥ ដែលចូលរួមដោយលេខាភូមិភាគពាយព្យ, តា ញឹម, សមាជិកបក្សកណ្តាល, ប្រធានតំបន់ និងសមាជិកនៃគណៈកម្មាធិការស្រុកក្នុងឆ្នាំ១៩៧៧ ដើម្បីពិភាក្សាពីទំនប់ត្រពាំងថ្ម]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D6.1.707**, EN ERNs 00390074-75 ["ការប្រជុំមានការចូលរួមដោយ គណៈស្រុក គណៈតំបន់ និង គណៈឃុំ។ ក្នុងប្រជុំ ពួកគេរាយការណ៍ពីលទ្ធផលនៃការងាររបស់គេ។ របៀបវារៈនៃការប្រជុំនោះក៏មានផែនការក្នុងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ទំនប់ទឹក និងការជីកប្រឡាយ"]។ *សូមមើល*ផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:55 [ដោយនិយាយថាពេលដែលគាត់ជាលេខានៃស្រុកបាវិល ក្នុងតំបន់៣ គាត់បានចូលរួមការប្រជុំនៅសាកលវិទ្យាល័យបាត់ដំបងដែលមាន តា ម៉ុក។ គាត់ក៏និយាយទៀតដែរថា អ្នកស្រី អ៊ឹម ចែម តា បូ និងប្រហែលជាមាន តា អាន ចូលរួមផងដែរ។] ឆ56 [ដោយនិយាយថា គេប្រជុំស្រុក និងតំបន់។]។

446 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ឯកសារ **D119/123** ឆ:18 ["មិនបានទេ។ រាល់សំបុត្រពីយាយចែមត្រូវតែឆ្លងកាត់ តា ចាយ ជាមុនសិន ហើយក្រោយមកទើបបញ្ជូនបន្តទៅឱ្យតាម៉ុកនៅបាត់ដំបង"]។

447 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មានថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ឯកសារ **D119/123** ឆ:14, ឆ:18, ឆ:20។

ភស្តុតាងឡើង ឬផ្តល់ដោយការភ័ន្តច្រឡំ ។ ភស្តុតាងដទៃទៀតដែលសេសសល់ទាំងអម្បាលម៉ាន បង្ហាញយ៉ាងច្បាស់កំណត់ពីដែនពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់ ដោយសារតួនាទីរបស់អ្នកស្រីដែលជាលេខាស្រុកព្រះនេត្រព្រះ ។

### ៣. ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគពាយព្យត្រូវបានកំណត់យ៉ាងតឹងរ៉ឹងត្រឹមតែតួនាទី *ស្របច្បាប់* និង *ជាក់ស្តែង* របស់អ្នកស្រីជាលេខាស្រុក

#### *i. ក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម បានផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះតាមរយៈដោះស្រាយបញ្ហាកង្វះស្បៀង*

១២២. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា អ្នកស្រី អ៊ឹម ចែម បានរួមចំណែកដោយចេតនាក្នុងការធ្វើឱ្យជីវភាពអ្នករស់នៅស្រុកព្រះនេត្រព្រះកាន់តែដុនដាប[448] ។ ការអះអាងនោះបានបញ្ជាក់ថាអ្នកស្រីមានចេតនាបង្កើតលក្ខខណ្ឌនៃការរស់នៅ ដែលបណ្តាលឱ្យមានការស្លាប់ប្រជាជនក្នុងចំនួនដ៏ច្រើន ឬដោយការដឹងឮហើយថាស្ថានភាពទាំងនោះបាននាំឱ្យមានមនុស្សស្លាប់ជាច្រើននាក់ ប៉ុន្តែខកខានក្នុងការជួយទប់ស្កាត់នូវស្ថានភាពអមនុស្សធម៌មិនឱ្យកើតឡើង[449] ។ ក្រុមការពារក្តីសូមបញ្ជាក់ថា ការអះអាងទាំងនេះ ជាការអះអាងគ្មានមូលដ្ឋានសោះ ។ ដូចភស្តុតាងបង្ហាញស្រាប់ កង្វះស្បៀងអាហារ ជាបញ្ហាកើតមានជាយូរមកហើយដែលបានឈានដល់ដំណាក់កាលលំបាកលំបិនជាខ្លាំង តាំងពីមុនពេលអ្នកស្រី អ៊ឹម ចែម ទៅដល់ភូមិភាគពាយព្យមកម្ល៉េះ ។ លុះពេលអ្នកស្រីទៅដល់ អ្នកស្រីបានចាត់ចែងធ្វើការងារនានាដែលចាំបាច់តាមអំណាចរបស់គាត់ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

១២៣. នៅខែ ឧសភា ឆ្នាំ ១៩៧៧ ពោលគឺនៅមុនពេលដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានផ្លាស់ទៅភូមិភាគពាយព្យ មានសេចក្តីរាយការណ៍ពីគណៈតំបន់៥ ទៅ រស់ ញឹម លើកឡើងថា តំបន់ទាំងមូល រួម

---

[448] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៩។

[449] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥៧, ៤៦០-៤៦១, ៤៨៥។

ទាំងស្រុកព្រះនេត្រព្រះ កំពុងរងគ្រោះពីបញ្ហាកង្វះស្បៀងអាហារដោយសារកង្វះទឹកភ្លៀង និងកង្វះប្រព័ន្ធធារាសាស្ត្រដើម្បីធានាការបញ្ជូនទឹកទៅវាលស្រែ[450] ។ លេខាភូមិភាគពាយព្យក៏បានកត់សម្គាល់ពីគ្រោះរាំងស្ងួត ដែលប៉ះពាល់ទៅដល់ការផលិតស្បៀងនៅតំបន់៥[451] ។ ដំណោះស្រាយក្នុងរយៈពេលខ្លី ត្រូវបានធ្វើឡើងតាមរយៈការចែករំលែកស្រូវអង្ករផលិតបានក្នុងឃុំព្រះនេត្រព្រះ និងឃុំប្រាសាទ ជាមួយឃុំភ្នំលៀប ឃុំទឹកឈូ និងឃុំរហាល[452] ។ ដំណោះស្រាយក្នុងរយៈពេលវែង គឺការកសាងទំនប់ទឹក និងការសាងសង់បង្ហើយនូវការជីកប្រឡាយ និងអាងស្តុកទឹក[453] ។ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ ស្ថានភាពពុំបានប្រសើរឡើងឡើយ ពោលគឺ ស្រុកព្រះនេត្រព្រះដែលនៅក្រោមការគ្រប់គ្រងរបស់ តា ម៉ោង ត្រូវបានពិពណ៌នាថាជា "កន្លែងអត់អាហារខ្លាំងក្លាបំផុត" ដែលមានប្រជាជនស៊ីវិលស្លាប់សរុបជាង ២០.០០០ នាក់ សម្រាប់តែឆ្នាំ ១៩៧៦ ប៉ុណ្ណោះ[454] ។ អ្នកស្រី អ៊ឹម ចែម ក៏មើលឃើញស្ថានភាពប្រហាក់ប្រហែលគ្នាដែរ នៅពេលដែលអ្នកស្រីមកដល់តំបន់នេះ នៅពាក់កណ្តាលខែ មិថុនា ឆ្នាំ ១៩៧៧[455] ។

---

450 របាយការណ៍ប្រចាំសប្តាហ៍របស់គណៈតំបន់៥ ឯកសារ ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, EN ERNs 00342717-20។

451 សេចក្តីរាយការណ៍ដោយម-៥៦០ អំពីសភាពការណ៍ខ្លាំងនៅភូមិភាគពាយព្យ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧, **D1.3.27.3**, EN ERN 00183016។

452 របាយការណ៍ប្រចាំសប្តាហ៍របស់គណៈតំបន់៥ ឯកសារ ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, EN ERN 00342721។

453 សេចក្តីរាយការណ៍ប្រចាំសប្តាហ៍របស់គណៈតំបន់៥ ឯកសារ ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, EN ERNs 00342719-20។

454 ទិដ្ឋភាពរួមនៅថ្នាក់មូលដ្ឋាន ក្នុងតំបន់ ៥ ភូមិភាគពាយព្យ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.3**, EN ERN 00223176-77។

455 *សូមមើលជាឧទាហរណ៍* ប្រតិចារឹកនៃកិច្ចសម្ភាសជាមួយ អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERN 01040640 ["ពួកគេមិនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគឡើយ ព្រោះពួកគេចង់រៀបចំការហូបបាយរួម ... មិនមានអ្វីក្នុងឆ្នាំង និងខ្ទះឡើយ។ ក៏គ្មានទឹកក្នុងពាង.. អ្នកគ្រប់គ្នាគឺដែទទេ។"]។ សម្ភាសន៍របស់មជ្ឈមណ្ឌលកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, EN ERN 00951801 ["ពួកគេមិនឱ្យនរណាហូបអីទេ។ អ្នកនេសាទមិនអនុញ្ញាតឱ្យហូបត្រីដែលគេចាប់បានឡើយ... ចុងភៅក៏ដូចគ្នា។ គេមិនអនុញ្ញាតឱ្យហូបអាហាររបស់គេធ្វើឡើយ។"]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា

១២៤. អ្នកស្រី អ៊ឹម ចែម ដែលធ្លាប់មានបទពិសោធន៍ខាងការងារកសិកម្មនៅភូមិភាគនិរតី[456] បានកំណត់ការងារជាអាទិភាពរបស់អ្នកស្រី ដើម្បីដោះស្រាយបញ្ហាកង្វះស្បៀងនៅស្រុកព្រះនេត្រព្រះ ។ អ្នកស្រីបានអង្កេតឃើញថា ប្រជាជនរងការខ្វះខាតស្បៀងអាហារ និងធ្លាក់ខ្លួនឈឺ ដោយសារអ្នកកាន់តំណែងពីមុនបានរៀបចំរបបអាហាររួមដ៏តឹងរ៉ឹង[457] និងមិនបានផ្តល់ស្បៀងអាហារដែលស្តុកក្នុងឃ្លាំងសម្រាប់ប្រជាជនឡើយ[458] ។ ក្រោមការដឹកនាំរបស់អ្នកកាន់តំណែងមុន ប្រជាជនត្រូវបានហាមឃាត់មិនឱ្យបរិភោគអាហារដែលពួកគេផលិតបាននោះទេ[459] ។

១២៥. អ្នកស្រី អ៊ឹម ចែម ជ្រើសយកវិធីសាស្ត្រផ្ទុយពីអ្នកមុន ជាវិធីស្របច្បាប់ និងមានលក្ខណៈមនុស្ស-

---

ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, EN ERN 0089776 [“វាជាការលំបាករបស់ប្រជាជនដែលនៅក្នុងស្រុកព្រះនេត្រព្រះមុននឹងខ្ញុំទៅដល់។ គេថាបន្លែដែលនៅក្រោយត្រូវដាក់ចូលឃ្លាំងទាំងអស់៖ អង្ករ សាច់ជ្រូក និងដូង។ អ្វីដែលគេផលិតត្រូវដាក់ចូលឃ្លាំង ហើយអ្នកផលិតមិនមានអ្វីហូបឡើយ”]។

456 *សូមមើល* កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217520 [ដោយនិយាយថា ក្នុងឆ្នាំ ១៩៧៥ គាត់គ្រប់គ្រងក្រុមនារីដែលត្រូវបានជម្លៀសពីសមរភូមិជួរមុខ និងមានតួនាទីបង្រៀនពីរបៀបធ្វើកសិកម្ម និងដាំបន្លែ]។

457 *សូមមើលជាឧទាហរណ៍* ប្រតិចារឹកជាមួយ អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERN 01040640 [“ពួកគេមិនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគឡើយ ព្រោះពួកគេចង់រៀបចំការហូបបាយរួម ...មិនមានអ្វីក្នុងឆ្នាំង និងខ្ទះឡើយ។ ក៏គ្មានទឹកក្នុងពាង.. អ្នកគ្រប់គ្នាគឺដែរទទេ”]។

458 *សូមមើលជាឧទាហរណ៍* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, EN ERN 0089776 [“វាជាការលំបាករបស់ប្រជាជនដែលនៅក្នុងស្រុកព្រះនេត្រព្រះមុននឹងខ្ញុំទៅដល់។ គេថាបន្លែដែលនៅក្រោយត្រូវដាក់ចូលឃ្លាំងទាំងអស់៖ អង្ករ សាច់ជ្រូក និងដូង។ អ្វីដែលគេផលិតត្រូវដាក់ចូលឃ្លាំង ហើយអ្នកផលិតមិនមានអ្វីហូបឡើយ”]។

459 *សូមមើលជាឧទាហរណ៍* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, EN ERN 00951801 [“ពួកគេមិនអោយនរណាហូបអីទេ។ អ្នកនេសាទមិនអនុញ្ញាតឱ្យហូបត្រីដែលគេចាប់បានឡើយ.. ចុងភៅក៏ដូចគ្នា។ គេមិនអនុញ្ញាតឱ្យហូបអាហាររបស់គេធ្វើឡើយ។”]។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, EN ERN 0089776 [“វាជាការលំបាក របស់ប្រជាជនដែលនៅក្នុងស្រុកព្រះនេត្រព្រះមុននឹងខ្ញុំទៅដល់។ គេថាបន្លែដែលនៅក្រោយត្រូវដាក់ចូលឃ្លាំងទាំងអស់៖ អង្ករ សាច់ជ្រូក និងដូង។ អ្វីដែលគេផលិតត្រូវដាក់ចូលឃ្លាំង ហើយអ្នកផលិតមិនមានអ្វីហូបឡើយ”]។

ធម៌ ពោលគឺ អ្នកស្រីបានចែកចាយពាងដាក់ទឹកទៅតាមសហករណ៍[460] បានបញ្ចេញស្បៀងដែលស្តុកទុកទាំងអស់ចេញពីឃ្លាំងដើម្បីឱ្យប្រជាជនបរិភោគ[461] លើកទឹកចិត្តប្រជាជនដើររកបន្លែបង្ការសម្រាប់បរិភោគដោយខ្លួនឯង[462] និងបានធ្វើការស្នើសុំឱ្យមានការបរិច្ចាកអាហារសម្រាប់ចែកចាយដល់ប្រជាជនដែលរស់នៅក្នុងស្រុកនោះ[463] ។ នៅក្នុងថ្ងៃបុណ្យទាន មានការធ្វើបង្អែមនំចំណីសម្រាប់អ្នកស្រុកបរិភោគ[464] ។ សរុបសេចក្តីមក នៅពេលអ្នកស្រី អ៊ឹម ចែម ទៅដល់

---

460 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217519។ ប្រតិចារឹកបទសម្ភាសន៍អ្នកស្រីអ៊ឹម ចែម គ្មានចុះកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERN 01040641។

461 កិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERNs 00217521-22។ ប្រតិចារឹកបទសម្ភាសន៍អ្នកស្រីអ៊ឹម ចែម គ្មានចុះកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERN 01040643។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, EN ERN 00089780។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, EN ERN 00951802-04។

462 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត វិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/42** ឆ19 ["គាត់បញ្ជាឱ្យកាប់ធាងដូងណាដែលអាចប្រើប្រាស់បានព្រមទាំងឱ្យយើងបេះផ្លែដូងហូបផងដែរ ប្រសិនបើពួកយើងហេវហត់ខ្លាំង។"]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, EN ERN 00951805 ["ពេលខ្ញុំទៅដល់ ខ្ញុំអនុញ្ញាតឱ្យពួកគេរកអាហារដោយខ្លួនឯង។ ខ្ញុំឱ្យអង្ករនៅពេលដែលពួកគេត្រូវការ។ នៅពេលធ្វើស្រែ ពួកគេអាចរកចំណីនៅកន្លែងនោះ ហើយអាចបរិភោគតាមដែលគេត្រូវការ... ពួកគេអាចរកអាហារសំរាប់ខ្លួនឯង"]។

463 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217521។ ប្រតិចារឹកបទសម្ភាសន៍អ្នកស្រីអ៊ឹម ចែម គ្មានចុះកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERNs 01040642-43 ["ខ្ញុំស្នើសុំការដឹកជញ្ជូនដំណាំដូចជា ត្រាវ និងក្ដួច ពីភូមិភាគនិរតី និងពីខេត្តកណ្ដាល។ ខ្ញុំសុំដូចខ្ញុំកំពុងសុំទានអញ្ជើង។ ខ្ញុំស្នើសុំស្បៀងសម្រាប់មនុស្សរបស់ខ្ញុំ ដែលសុំបារគ្រាប់ល្ពៅពីភូមិភាគនិរតី។ ពេលដែលខ្ញុំទៅដល់ចម្ការម្រេច ខ្ញុំសុំម្រេច។ ខ្ញុំឃើញអ្វី ខ្ញុំសុំនឹង ដើម្បីចែកចាយទៅដល់ប្រជាជនរបស់ខ្ញុំ"]។

464 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b**, EN ERN 00951805 ["នៅថ្ងៃបុណ្យទាណ យើងធ្វើនំកូរអោយប្រជាជនហូប។ ដូចជាឧទាហរណ៍នៅថ្ងៃ ១០ យើងធ្វើនំកូរហើយដាក់វាក្នុងកញ្ជ្រែង មុននឹងកាត់វាជុំៗ ហើយយកឱ្យប្រជាជន។ យើងឱ្យនំកូរទៅអ្នកដែលធ្វើការនៅជួរមុខ និងជួរក្រោយ។ សម្រាប់អ្នកដែលធ្វើការក្នុងការដ្ឋានខាងមុខ យើងឱ្យស្ករ និងអង្ករដើម្បីឱ្យគេធ្វើហូបខ្លួនឯង។ តែរបស់ទាំងនេះត្រូវចែកឱ្យស្មើគ្នា... ជាឧទាហរណ៍ នៅថ្ងៃទី ២០ បើពួកគេចង់ធ្វើនំអន្សម ខ្ញុំឱ្យគេធ្វើ។ បើពួកគេចង់ហូបសាច់ជ្រូក ខ្ញុំក៏ឱ្យគេ។ គេសុំអី ក៏ខ្ញុំឱ្យគេដែរ"]។

អ្នកស្រីបានព្យាយាមដោះស្រាយតម្រូវការចាំបាច់នានា ចំពោះស្ថានភាពជីវភាពរបស់អ្នកស្រុក ដែលរស់នៅក្នុងស្រុកព្រះនេត្រព្រះ ។

១២៦. អ្នកស្រី អ៊ឹម ចែម ក៏បានកំណត់នូវដំណោះស្រាយសម្រាប់រយៈពេលវែងផងដែរ ។ អ្នកស្រីបានចុះតាមឃុំទាំងអស់ក្នុងស្រុក និងបានរាប់ចំនួនប្រជាជននៅទីនោះ[465] ព្រមទាំងសិក្សាពីទីតាំងភូមិសាស្ត្រនៃឃុំទាំងអស់ក្នុងស្រុក[466] ។ អ្នកស្រីក៏បានសួរនាំនូវព័ត៌មានដែលទាក់ទងទៅនឹងការងារកសិកម្ម ដើម្បីដឹងថា "កន្លែងណារាក់ និងជ្រៅ ពេលមានទឹកលិច តំបន់ណាជាតំបន់ខ្ពង់រាប និងទំនាបកណ្ដាល គួរដាំប្រភេទស្រូវមួយណា ។ល។ និង ។ល។"[467] បន្ទាប់មកអ្នកស្រី អ៊ឹម ចែម បានរៀបចំកម្លាំងដើម្បីធ្វើការផលិតស្បៀងអាហារនៅក្នុងស្រុកព្រះនេត្រព្រះ[468] ។

១២៧. ការលើកឡើងនេះ មិនមែនជាការតតាំង ឬបង្ហាញថា វិធានការដែលអ្នកស្រី អ៊ឹម ចែម បានធ្វើក្នុងការធ្វើឱ្យជីវភាពអ្នកស្រុកព្រះនេត្រព្រះល្អប្រសើរ វាអាចស្មើទៅនឹងការមានសិទ្ធិអំណាចទូលំទូលាយក្នុងការធ្វើសេចក្ដីសម្រេចជាទូទៅ ធ្វើដោយឯកតោភាគី ឬតាមទំនើងចិត្ត ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងឡើយ ហើយដែលប្រការនេះ យើងខ្ញុំនឹងបង្ហាញជូននៅ

---

[465] កិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ដោយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1**, EN ERN 00217518។ប្រតិចារឹកបទសម្ភាសន៍អ្នកស្រី អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERNs 01040639-40។

[466] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/443** ឆ:58, ឆ:65-66, ឆ:115។

[467] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/397** ឆ:12។

[468] *សូមមើលជាឧទាហរណ៍*, ប្រតិចារឹកបទសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D6.1.75**, EN ERN 01040642 ["ខ្ញុំចាប់ផ្ដើមរៀបចំមនុស្សជាពីរក្រុម៖ ក្រុមចល័តដែលបានរៀបចំមុនគឺជាកងឈ្លប ដែលខ្ញុំបានស្នើឱ្យដកអាវុធ និងចូលរួមជាមួយកងចល័តដែលធ្វើការនៅការដ្ឋានសាងសង់ទំនប់ ប្រឡាយ និងទំនប់ទឹក។ ក្រុមមួយទៀតរៀបចំមុនទំនប់ត្រពាំងថ្ម ដែលដាំស្រូវរដូវប្រាំង"]។ សម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, EN ERNs 00089777 ["ខ្ញុំចាត់កម្លាំងមនុស្សទៅធ្វើកសិកម្ម និងលើទំនប់ ហើយកម្លាំងដើម្បីជីកប្រឡាយដើម្បីរៀបចំសម្រាប់រដូវប្រាំង និងការដឹកជញ្ជូនស្រូវវស្សា។ ក្រុមផ្សេងទៀតដាំដំឡូង"]។

ខាងក្រោម[469] ។ គ្រប់ពេលទាំងអស់ អ្នកស្រី អ៊ឹម ចែម តែងតម្រូវឱ្យទទួលបានការអនុញ្ញាត ឬការណែនាំពីថ្នាក់លើជាមុន ពោលគឺ ពីថ្នាក់តំបន់ ដើម្បីអ្នកស្រីអាចធ្វើសកម្មភាពក្នុងដែនកំណត់នៃការទទួលខុសត្រូវ និងតួនាទីជាក់លាក់របស់អ្នកស្រីបាន ។

១២៨. ទីមួយ ផ្ទុយពីការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[470] អ្នកស្រី អ៊ឹម ចែម មិនបានធ្វើការដកហូតអាវុធពីកងឈ្លបដែលមានស្រាប់ ដោយខ្លួនអ្នកស្រីផ្ទាល់នោះទេ ។ អ្នកស្រីមិនមានសិទ្ធិអំណាចបែបនេះឡើយ ។ អ្នកស្រីបានស្នើសុំការអនុញ្ញាតពី តា ជាល ដែលជាលេខាតំបន់នាពេលនោះ ដើម្បីដកអាវុធពីឈ្លបទាំងអស់ និង បានបញ្ចូលពួកគេទៅក្នុងកងចល័តមានស្រាប់ ដែលកំពុងធ្វើការនៅតាមការដ្ឋាននានា និង តាមវាលស្រែ[471] ។ ការអនុញ្ញាតនេះ នាំឱ្យមានការចាត់តាំងការងារជាថ្មីៗ ទាក់ទងនឹងតម្រូវការបន្ថែមក្នុងការទទួលខុសត្រូវលើការងារផ្នែកកសិកម្មរបស់អ្នកស្រី ហើយវាមិនមែនជាសិទ្ធិអំណាចឯករាជ្យរបស់អ្នកស្រី អ៊ឹម ចែម ទេ ។ ជាឧទាហរណ៍ សាក្សី តឹក សួង ដែល តា ម៉ោង បានចាត់តាំងឱ្យធ្វើជាមេកងឈ្លបឃុំភ្នំលៀបនៅឆ្នាំ ១៩៧៥[472] បានផ្តល់សក្ខីកម្មថា ភ្លាមៗក្រោយពេលអ្នកស្រី អ៊ឹម ចែម បានទៅដល់តំបន់នោះ សាក្សីត្រូវបានដកចេញពីតំណែង និងត្រូវបានចាត់តាំងឱ្យទៅភ្ជួរស្រែ[473] ។ ស្រដៀងគ្នាដែរ សាក្សី ទ្រី មឿត ដែលជាឈ្លបម្នាក់ទៀតក្រោមការគ្រប់គ្រងរបស់ តា ម៉ោង បានឆ្លើយថា នៅពេលអ្នកស្រី អ៊ឹម ចែម ក្លាយជាលេខាស្រុកព្រះនេត្រព្រះ សាក្សីបានឈប់ធ្វើឈ្លប ហើយត្រូវបានបញ្ជូនទៅធ្វើការនៅរោង

469 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២៨។

470 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៦០, ១៤០, ១៧៨។

471 កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយ Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1** KH ERNs 00234195-96។ ប្រតិចារឹកបទសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ពុំមានចុះកាលបរិច្ឆេទ ឯកសារ **D6.1.75** KH ERNs 00978480-81។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a** KH ERNs 00929736-38។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b** KH ERNs 00929779, 00929781-82។

472 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/572** ឆ:19។

473 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:3។

ម៉ាស៊ីនកិនស្រូវ[474] ។ ដូចគ្នានឹងសាក្សី រស់ ហឹល ដែរ បានចង្អុលបង្ហាញថា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីទៅដល់ សាក្សីត្រូវបានដកចេញពីតំណែង និងត្រូវបានចាត់តាំងឱ្យទៅច្រូតស្រូវ[475] ។

១២៩. ទីពីរ អ្នកស្រី អ៊ឹម ចែម បានទទួលផែនការការងារពីថ្នាក់តំបន់[476] ។ អ្នកស្រីបានរៀបចំការប្រជុំស្ដីពីការបង្កបង្កើនផលស្រូវ រួមទាំងបានពិភាក្សាពាក់ព័ន្ធនឹងការលើកទំនប់ ជីកប្រឡាយ នៅស្រុកព្រះនេត្រព្រះ[477] ។ បើតាមសាក្សី ឈឹម ផន បានឱ្យដឹងថា មានប្រជាជនមួយចំនួនមានការកោត

---

474 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទ្រី គៀត ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/574** ឆ:17, ឆ:27-28។

475 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត (ROS Hil) ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579** EN ERN 01166380។

476 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a** KH ERNs 00929732, 00929736-38 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:100។

477 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:48 ["នៅក្នុងកិច្ចប្រជុំនោះគាត់និយាយពីផែនការដើម្បីឱ្យប្រជាជនមានហូបគ្រប់គ្រាន់"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម ម៉ន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/96** ឆ:74-77 [កត់សម្គាល់ថា អ្នកស្រី អ៊ឹម ចែម បាននិយាយ "អំពីការប្រមូលផលស្រូវ ការលើកទំនប់ជីកប្រឡាយ ដូចជា នៅស្ពានតាប៉ុន ។ល។" នៅក្នុងការប្រជុំដែលបានធ្វើឡើងរៀងរាល់ពីរបីខែម្ដងនៅថ្នាក់ស្រុក]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លី សិញ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/20** ឆ:9 ["កាលនោះ គាត់បានលើកឡើងអំពីការខិតខំធ្វើស្រែ និងលើកទំនប់ជីកប្រឡាយ"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន សុខ ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/397** ឆ:2 [កត់សម្គាល់ថា នៅពេល អ្នកស្រី អ៊ឹម ចែម បានទៅដល់ភ្នំល្វៀប គាត់បានណែនាំប្រជាជនឱ្យរៀបចំសេដ្ឋកិច្ច រៀបចំធ្វើស្រែចម្ការ។ បន្ទាប់មកគាត់ណែនាំពួកគេឱ្យលើកទំនប់ជីកប្រឡាយ]។ ប្រតិចារឹកបទសម្ភាសន៍ជាមួយ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.9** KH ERN 01121650 ["គាត់ [អ្នកស្រី អ៊ឹម ចែម] អត់មានឃើញនិយាយពីរឿងអីទេ។ និយាយតែពីរឿងយើងយកចិត្តទុកដាក់ធ្វើស្រែ ការពារផលដំណាំដែលធ្វើកើតហ្នឹង ធ្វើប្រឡាយដើម្បីដោះស្រាយទឹក យកទៅធ្វើស្រែ ជួយប្រជាជនហ្នឹង"]។ ប្រតិចារឹកបទសម្ភាសន៍ជាមួយ ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.2** KH ERN 01121608 ["គាត់និយាយឱ្យយើងធ្វើម៉េចបានម្ហូបម្ហូបបីមុខ។ គាត់ចេះតែថាទៅណា បាទ"]។

"សរសើរគាត់ [ដោយសារ] ចេះសណ្តោសមនុស្សច្រើនជាងគណៈស្រុកមុនៗ"[478] ។ ព្រោះតែវាជាចំណុចសំខាន់នៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ មានសាក្សីមួយចំនួនបានផ្តល់សក្ខីកម្មយ៉ាងស៊ីសង្វាក់គ្នាអំពីការណ៍ដែលអ្នកស្រី អ៊ឹម ចែម ផ្តោតការយកចិត្តទុកដាក់តែលើការផលិតស្បៀងនៅពេលប្រជុំ[479] ហើយការសរសើរនេះ ពុំមែនជាការនិយាយបំផ្លើសទេ ។

### *ii. ក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម ពុំបានទទួលខុសត្រូវលើការងារសន្តិសុខនៅស្រុកព្រះនេត្រព្រះឡើយ*

១៣០. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មាន "ភស្តុតាងយ៉ាងច្រើនលើសលុប" បង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចបញ្ជាឱ្យសម្លាប់[480] ដោយសារ*ក្នុងនោះ*អ្នកស្រីបានគ្រប់គ្រង "កងកម្លាំងប្រដាប់អាវុធ" នៅស្រុកព្រះនេត្រព្រះ[481] ។ នៅពេលលើកឡើងអំពីពាក្យ "កងកម្លាំងប្រដាប់អាវុធ"[482] សហព្រះរាជអាជ្ញាអន្តរជាតិចាត់ទុកពាក្យយោធា និងឈ្លបថាមានន័យដូចគ្នា[483] ។

---

[478] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:49។

[479] កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/438** EN ERN 01124203 [YONG Sann បានចូលរួមប្រជុំជាមួយអ្នកស្រី អ៊ឹម ចែម ដែលគាត់ "តែងតែនិយាយអំពីការបង្កបង្កើនផលស្រូវ និង ការពង្រឹងការរួបរួមគ្នាក្នុងឃុំ"។ និយាយផងដែរថា អ្នកស្រី អ៊ឹម ចែម មិនមែននិយាយពីបញ្ហាសន្តិសុខ និង/ឬ ខ្មាំងផ្ទៃក្នុងទេ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យៀក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:.20 ["ជួបម្តងៗគឺពិភាក្សាពីរឿងបញ្ហាដោះស្រាយអង្ករប៉ុណ្ណោះ"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/361** ឆ:76-79 [និយាយថា ការប្រជុំដែលអ្នកស្រី អ៊ឹម ចែម ដឹកនាំ និយាយពីការលើកទំនប់។ ក៏និយាយដែរថា គាត់បាននិយាយតែពីការប្តេជ្ញាចិត្តធ្វើការ និងមិនដែលនិយាយពីខ្មាំងទេ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/132** ឆ:24-27 [និយាយថា ការប្រជុំដែលអ្នកស្រី អ៊ឹម ចែម ដឹកនាំនៅតាមភូមិ ជំរុញឱ្យប្រជាជនខិតខំធ្វើការ និងពិភាក្សាពីការដាំដុះរួម និងហូបរួម]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:48 ["នៅក្នុងកិច្ចប្រជុំនោះគាត់និយាយពីផែនការដើម្បីឱ្យប្រជាជនមានហូបគ្រប់គ្រាន់"]។

[480] *សូមមើល* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១៥៦។

[481] សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១៤០, ១៥៦។

[482] សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១៤០, ១៥៦។

[483] *សូមមើលឧទាហរណ៍* សេចក្តីសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ១១១ (លេខយោងជើងទំព័រ ៥៣៧) [ដែលរៀបរាប់ថា អ្នកស្រី អ៊ឹម ចែម បានយកកងទ័ព ៥០០ នាក់ ទៅភូមិភាគពាយព្យ] នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ៦៩២)

ដូចនឹងយកមកពិភាក្សាខាងក្រោម យោធា និង ឈ្លប គឺជាអង្គភាពដាច់ដោយឡែកពីគ្នាស្រឡះ ។ ភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម គ្មានសិទ្ធិអំណាច*ស្របច្បាប់* ឬ *ជាក់ស្តែង* លើអង្គភាពណាមួយក្នុងចំណោមអង្គភាពទាំងពីរនេះទេ ។

១៣១. នៅក្នុងកថាខណ្ឌខាងក្រោម[484] ក្រុមការពារក្តីនឹងឆ្លើយតបទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចលើ "កងកម្លាំងប្រដាប់អាវុធ" ដែលតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា គឺវាពាក់ព័ន្ធទាំងយោធា និងឈ្លប ។ ដើម្បីគាំទ្រការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម បានកាន់កាប់កងកម្លាំងប្រដាប់អាវុធនៅក្នុងស្រុកព្រះនេត្រព្រះនោះ សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើឯកសារសំអាងចំនួន១៣ ដែលបំពេញបង្គ្រប់ឱ្យប្រយោគនៃការមាន "ភស្តុតាងយ៉ាងច្រើនលើសលុប" របស់ខ្លួន[485] ។ ការពិពណ៌នាចំនួនពីរដែលគាត់បានលើកយកមកសំអាង ជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងអ្នកស្រី អ៊ឹម ចែម និងសេចក្តីថ្លែងការណ៍ទទួលបានពីសាក្សី ទុំ សឿន គឺគ្មានភាពពាក់ព័ន្ធជិតស្និទ្ធនឹងយោធា ឈ្លប ឬ កងកម្លាំងប្រដាប់អាវុធនោះទេ[486] ដូច្នេះក្រុមការពារក្តីនឹងមិនឆ្លើយតបនឹង

---

[ដែលរៀបរាប់ថា អ្នកស្រី អ៊ឹម ចែម បានយកកងឈ្លងបំពាក់ដោយអាវុធទៅភូមិភាគពាយព្យ] កថាខណ្ឌ ១៧៨ (លេខយោងជើងទំព័រ ៩០៣) [ដែលរៀបរាប់ថា អង្គភាពយោធាផ្ទាល់របស់អ្នកស្រី អ៊ឹម ចែម បានអមដំណើរជាមួយអ្នកស្រីទៅភូមិភាគពាយព្យ] ចំណុចទាំងអស់នេះយោងលើឯកសារសំអាងតែមួយ (កិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយផលិតកម្ម Smiling Toad ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1** EN ERN 00217519)។ *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានស្ពាតរ កថាខណ្ឌ ៤៥០ ["កម្មាភិបាល/យោធា /ឈ្លប បកក ទាំងអស់នេះ បានប្រព្រឹត្តក្រោមអំណាច និងការគ្រប់គ្រងរបស់ អ៊ឹម ចែម ដោយផ្ទាល់ និង/ឬ ដោយប្រយោល ឬ ដោយឈរលើមូលដ្ឋាននៃឥទ្ធិពល ការលើកទឹកចិត្ត ឬ ជំនួយរបស់គាត់"]។

484 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៣៣-៣៨។

485 សេចក្តីសន្និដ្ឋានស្ពាតរ នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ៦៩៦) និងនៅកថាខណ្ឌ ១៥៦ (លេខយោងជើងទំព័រ ៧៧៣)។

486 សេចក្តីសន្និដ្ឋានស្ពាតរ នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ៦៩៦) នៅកថាខណ្ឌ ១៥៦ (លេខយោងជើងទំព័រ ៧៧៣) ដែលយោងលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b** EN ERN 00951815-16 [លើកឡើងថា ក្រោយពេលអ្នកស្រីទៅដល់ អ្នកស្រីបានបញ្ជាឱ្យអ្នកយាមដោះលែងបុរសចំណាស់ម្នាក់ដែលត្រូវបានចាប់ខ្លួន ហើយឱ្យបុរសនោះទៅផលិតឱសថបុរាណវិញ]។

បញ្ហាទាំងពីរនេះឡើយ ។ ឯកសារសំអាងដែលនៅសេសសល់ផ្សេងទៀត នឹងត្រូវលើកយកមកពិភាក្សាដូចខាងក្រោម ។

១៣២. ដូចដែលនឹងមើលឃើញស្រាប់ ផ្នែកខ្លះនៃការអះអាងដោយមានកំហុសរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថាអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចលើកងកម្លាំងប្រដាប់អាវុធទាំងមូលបានផ្អែកលើការយល់ឃើញខុស ត្រង់ចំណុចដែលថា យោធា និងឈ្លប គឺជាអង្គភាពតែមួយ ។ នៅមុនពេលឆ្លើយតបទៅនឹងភស្តុតាងជាក់លាក់ និងដាច់ដោយឡែកពីគ្នាប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងអង្គភាពស្រុកចំនួនពីរ វាមានប្រយោជន៍ត្រូវកែតម្រូវការយល់ឃើញនេះ ។ ដូចអង្គជំនុំជម្រះសាលាដំបូងបានរកឃើញនៅក្នុងសំណុំរឿង០០១ ថា យោធា និងកងឈ្លប គឺជាអង្គភាពពីរដាច់ដោយឡែកពីគ្នានៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[487] ។ ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ គាំទ្រការរកឃើញនេះ៖ សាក្សី តឹក ស្នួង ដែលជាកងទ័ព និងក្រោយមកក្លាយជាឈ្លប (នៅមុនពេលអ្នកស្រី អ៊ឹម ចែមបានទៅដល់ភូមិភាគពាយព្យ) បានពន្យល់ថា ពាក្យពីរនេះគឺខុសគ្នា[488] ។ សាក្សី ឡុត សួយ ដែលធ្វើជាទាហាននៅស្រុកភ្នំស្រុកបានបញ្ជាក់ថា ការងារដែល

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:82 [ដែលរៀបរាប់ថា អ្នកស្រី អ៊ឹម ចែម និងគណស្រុកបានរៀបចំកងទ័ពឡើងវិញនៅក្នុងស្រុកនោះពេលអ្នកស្រីបានទៅដល់]។

487 *សូមមើល* សាលក្រមសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ៩៦ ["ភូមិភាគ និងតំបន់ក៏ជាអ្នកបញ្ជាអង្គភាពកងទ័ពដែលស្ថិតនៅក្រោមសេនាធិការកងទ័ពដែលចំណុះភូមិភាគ និងតំបន់ ហើយស្រុកគ្រប់គ្រងកងទ័ពស្រុក និងកងជីវពល"]។ សាលក្រមសំណុំរឿង ០០២ ឯកសារ **E313** នៅកថាខណ្ឌ ២៤៥ ["ទាំងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យទាំងលក្ខន្តិកៈ ប.ក.ក បានបែងចែកកងទ័ពបដិវត្តន៍កម្ពុជាជាបីសាខាគឺ កងទ័ព "ស្រួច" កងទ័ព "តំបន់" ឬ កង "ឈ្លប"]។

488 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក ស្នួង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/572** ឆ:18 ["ពេលខ្ញុំធ្វើជាមេឈ្លប ខ្ញុំឈប់ធ្វើជាទ័ពហើយ"] ស-ឆ:21 ["ស៖ ដោយសារលោកធ្លាប់ធ្វើយោធាផង និងធ្វើធ្វើមេឈ្លបផង។ តើយោធា និងឈ្លបខុសគ្នាយ៉ាងម៉េច? ឆ:21៖ ខុសគ្នា ព្រោះពេលខ្ញុំធ្វើជាយោធាដេកតែក្នុងព្រៃ រើជាមួយទាហាន លន់ នល់ ហើយពេលខ្ញុំធ្វើជាមេឈ្លប ខ្ញុំដេកនៅក្នុងភូមិ រស់នៅធម្មតា"]។

ចាត់តាំងឱ្យកងទ័ព ខុសគ្នាពីអ្នកដែលត្រូវបានចាត់តាំងជាកងឈ្លប[489] ។

<u>សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើ*យោធា*</u>

១៣៣. ក្នុងចំណោមឯកសារសំអាងពាក់ព័ន្ធចំនួន ១១ ដែលបានសំអាងលើ ដើម្បីគាំទ្រការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម បានគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធ មានសាក្សីចំនួនប្រាំពីរនាក់ និងកិច្ចសម្ភាសន៍មួយដែលអ្នកស្រី អ៊ឹម ចែម បានផ្តល់ជូនផលិតកម្ម Smiling Toad ត្រូវបានដកស្រង់ដើម្បីគាំទ្រការចោទប្រកាន់ដែលថា អ្នកស្រីបានគ្រប់គ្រងយោធានៅស្រុកព្រះនេត្រព្រះ[490] ។ ចំណុចទាំងនេះ នឹងត្រូវឆ្លើយតបម្តងមួយៗនៅខាងក្រោម ។

១៣៤. ដោយមើលតែមួយភ្លែតនូវចម្លើយរបស់អ្នកស្រី អ៊ឹម ចែម ដែលបានផ្តល់ក្នុងកិច្ចសម្ភាសន៍ជាមួយផលិតកម្ម Smiling Toad អ្នកស្រីហាក់ដូចជាទទួលស្គាល់ថា អ្នកស្រីមានសិទ្ធិអំណាចខ្លះលើកងទ័ពមួយចំនួន ពោលគឺ អ្នកស្រីបានលើកឡើងថា អ្នកស្រីបាន "យក" កងទ័ពចំនួន ៥០០នាក់

---

489 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ស-ឆ:58 ["សះ លោកអាចបញ្ជាក់បានទេ ក្នុងនាមលោកជាទាហានរបស់ស្រុក តើការងាររបស់យោធាស្រុក និងការងាររបស់ឈ្លប វាមានលក្ខណៈខុសគ្នាដូចម្តេចដែរ? ឆ:58៖ ជាទូទៅ យោធាស្រុកមានតួនាទីការពារស្រុក ឃុំ និងភូមិ ហើយតួនាទីរបស់កងឈ្លប គឺជាអ្នកតាមដាន និងអ្នកចាប់មនុស្សនៅតាមមូលដ្ឋានឃុំ និងភូមិ"]។

490 *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ៦៩៦) នៅកថាខណ្ឌ ១៥៦ (លេខយោងជើងទំព័រ ៧៧៣) ដែលយោងលើកំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ដល់ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:65, ឆ:66-ឆ68, ឆ:267។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:87។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ឆ:37។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:53។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សា ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:124-25។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ចុះថ្ងៃទី ៦ ដល់ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:57-59។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/88** ឆ:30។ កិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយផលិតកម្ម Smiling Toad ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1 EN ERN** 00217519។

មកជាមួយនៅពេលអ្នកស្រីផ្លាស់មកភូមិភាគពាយព្យ[491] ។ យោងតាមការពិចារណា ចំណុចនេះមិនអាចយកមកធ្វើអ្វីកើតក្រៅតែពីភស្តុតាងបង្ហាញនូវការអនុវត្តសិទ្ធិអំណាចតែម្តងគត់ ចំពោះការប្រាប់ពីចំនួនកងទ័ពជាក់លាក់ ។ ម្យ៉ាងវិញទៀត ចម្លើយនេះត្រូវតែពិចារណាក្នុងបរិបទពាក់ព័ន្ធ ។ ទុំ សឿន បានស្រាយបំភ្លឺពីកាលៈទេសៈនៃហេតុការណ៍ទាំងនេះ ពោលគឺ ទាំង ទុំ សឿន ទាំងអ្នកស្រី អ៊ឹម ចែម និងមានមនុស្សសរុបប្រហែល ៥០០ ឬ ៦០០ គ្រួសារ រួមទាំងកងទ័ពផងដែរនោះត្រូវបានផ្លាស់ទៅភូមិភាគពាយព្យក្នុងពេលតែមួយ[492] ។ ដូច ទុំ សឿន បានពន្យល់ តាមពិតទៅមានមនុស្សម្នាក់ផ្សេងទៀតក្រៅពីអ្នកស្រី អ៊ឹម ចែម ជាអ្នកគ្រប់គ្រងលើកងទ័ពដែលបានផ្លាស់មកនោះ[493] ចំណែកអ្នកគ្រប់គ្រងលើគ្រួសារប្រជាជន គឺអ្នកស្រី អ៊ឹម ចែម[494] ។ ដូចយើងបានឃើញ

---

[491] កិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយផលិតកម្ម Smiling Toad ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1 EN ERN** 00217519។

[492] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:40 ["មានមនុស្សសរុបប្រហែល៥០០ ទៅ ៦០០ គ្រួសារ។...។ ក្នុងនោះ មានកងនារីស្រែអំបើល បីបួនរយនាក់ និងកងទ័ពបីរយនាក់"]។

[493] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ស-ឆ:44 ["ស៖ លោកនិយាយថា ពេលដែលចេញទៅភូមិភាគពាយព្យនោះមាន ៥០០ ទៅ ៦០០ គ្រួសារ មានកងនារីមកពីស្រែអំបិលប្រហែលចំនួនបីបួនរយនាក់ មានទាហានប្រហែលបីរយនាក់។ តើអ្នកណាដែលជាអ្នកគ្រប់គ្រងក្រុមគ្រួសារប្រជាជនស៊ីវិលទាំងនោះ? តើអ្នកណាគ្រប់គ្រងកងនារី? នរណាគ្រប់គ្រងទាហាន? ហើយអ្នកណាគ្រប់គ្រងរួមលើអ្នកទាំងអស់ដែលត្រូវបញ្ជូនទៅពាយព្យនោះ? ឆ:44៖ ការគ្រប់គ្រងផ្នែកនារី គឺប្រធានកងនារីជាអ្នកគ្រប់គ្រង។ ខ្ញុំមិនបានស្គាល់ឈ្មោះទេ។ ឯខាងផ្នែកទាហានមានអ្នកគ្រប់គ្រងរបស់គេ ដែលខ្ញុំមិនស្គាល់ទេ។ ចំណែកអ្នកគ្រប់គ្រងប្រជាជនគឺយាយចែម។ ឯអ្នកគ្រប់គ្រងរួមក្នុងការបញ្ជូនមនុស្សទាំងអស់ទៅភូមិភាគពាយព្យតែម្តងក៏យាយចែមហ្នឹងដែរ"]។

[494] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ ទុំ សឿន ចុះថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ["ស៖ លោកនិយាយថា ពេលដែលចេញទៅភូមិភាគពាយព្យនោះមាន ៥០០ ទៅ ៦០០ គ្រួសារ មានកងនារីមកពីស្រែអំបិល ប្រហែលចំនួនបីបួនរយនាក់ មានទាហានប្រហែលបីរយនាក់។ តើអ្នកណាដែលជាអ្នកគ្រប់គ្រងក្រុមគ្រួសារប្រជាជនស៊ីវិលទាំងនោះ? តើអ្នកណាគ្រប់គ្រងកងនារី? នរណាគ្រប់គ្រងទាហាន? ហើយអ្នកណាគ្រប់គ្រងរួមលើអ្នកទាំងអស់ដែលត្រូវបញ្ជូនទៅពាយព្យនោះ? ឆ:44៖ ការគ្រប់គ្រងផ្នែកនារី គឺប្រធានកងនារីជាអ្នកគ្រប់គ្រង។ ខ្ញុំមិនបានស្គាល់ឈ្មោះទេ។ ឯខាងផ្នែកទាហានមានអ្នកគ្រប់គ្រងរបស់គេ ដែលខ្ញុំមិនស្គាល់ទេ។ ចំណែកអ្នកគ្រប់គ្រង

នៅពេលយើងពិចារណាលើភស្តុតាងតាមបរិបទតូចតាចនោះ សក្ខីកម្មរបស់អ្នកស្រី អ៊ឹម ចែម ហាក់ដូចជាមានលក្ខណៈខុសគ្នាបន្តិចបន្តួច ។ សក្ខីកម្មរបស់អ្នកស្រី មិនទាំងបានលើកឡើងអំពីការអភិបាលលើចំនួនកងទ័ពជាក់លាក់នោះទេនៅពេលនោះ កុំថាឡើយថាបានផ្តល់សក្ខីកម្មលើទម្រង់នៃសិទ្ធិអំណាចទូទៅលើកងទ័ពទាំងនេះ ឬកងទ័ពណាម្នាក់ឡើយក្រោយពេលការផ្លាស់ទីតាំងបានធ្វើចប់សព្វគ្រប់។ ដូចអ្នកស្រី អ៊ឹម ចែម បានបញ្ជាក់នៅក្នុងសក្ខីកម្មមួយនាពេលក្រោយមកទៀត ថាអ្នកស្រីមិនបានគ្រប់គ្រងយោធានៅក្នុងស្រុកព្រះនេត្រព្រះនោះឡើយ[495] ។

១៣៩. លើសពីនេះទៀត ព្រោះតែការអះអាងជ្រុលហួសប្រមាណរបស់សហព្រះរាជអាជ្ញាអន្តរជាតិថាអ្នកស្រី អ៊ឹម ចែម ជាមេដឹកនាំ "កងកម្លាំងប្រដាប់អាវុធ" ទាំងអស់នៅក្នុងស្រុកព្រះនេត្រព្រះ[496] និងការពិតដែលភស្តុតាងសេសសល់ទាំងអម្បាលម៉ាន បរាជ័យនូវគ្រប់ទិដ្ឋភាពក្នុងការកំណត់អត្តសញ្ញាណហេតុការណ៍ពិតប្រាកដនៃការបញ្ជា និងការគ្រប់គ្រងនោះ គឺជាព័ត៌មានត្រូវយល់ដឹងមួយ ។ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ដោយឯកឯងថា ប្រសិនបើអ្នកស្រី អ៊ឹម ចែម បានគ្រប់គ្រងលើយោធា ឬកងកម្លាំងប្រដាប់អាវុធទាំងមូលនោះមែន យើងប្រាកដជានឹងបានឃើញរាប់មិនអស់ តាមកាលៈទេសៈជាច្រើនតាំងពីដំបូងមកម្ល៉េះ ។ ផ្ទុយមកវិញ ក្នុងចំណោមសាក្សីចំនួនប្រាំពីរនាក់ផ្សេងទៀតដែលបានសំអាងលើ មានសាក្សីចំនួនប្រាំនាក់បានរៀបរាប់រឿងរ៉ាវតាមពាក្យចចាមអារ៉ាមគ្មានប្រភពច្បាស់លាស់អំពីការបញ្ជាដូចបានអះអាង ដែលចំណុចនេះ មិនអាចមានតម្លៃជាភស្តុតាងសូម្បីតែបន្តិចក៏គ្មានផង[497] ។ ចំណែកសក្ខីកម្មបានពីសាក្សីពីរនាក់ផ្សេងទៀត គប្បីត្រូវ

---

ប្រជាជនគឺយាយចែម។ ឯអ្នកគ្រប់គ្រងរួមក្នុងការបញ្ជូនមនុស្សទាំងអស់ទៅភូមិភាគពាយព្យតែម្តងក៏ យាយ ចែម ហ្នឹងដែរ"]។

[495] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b** ERN ខ្មែរ ០០៩២៩៧៧៩ ["ខ្ញុំស្នើទៅខាងលើ ខ្ញុំសូមដកអាវុធពីឈ្លប ហើយពីសេនាជនអីទាំងអស់ដែរនៅក្នុងស្រុករបស់ខ្ញុំណាស់។...។ ព្រោះខាងយោធាគេ ហើយយើងចូលទៅ អាហ្នឹងខ្ញុំសុំដក គេអត់ឱ្យដក"]។

[496] សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤០ និង ១៥៦។

[497] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ដល់ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:66-70, ឆ:267 ["ដែលចង្អុលបញ្ជាក់ថា គាត់បានស្តាប់ឮថា អ្នកស្រី អ៊ឹម ចែម អាចបញ្ជាទាហាន"] ប៉ុន្តែត្រង់ ស-ឆ:65 ["ខ្ញុំមិនដឹងពីតួនាទី យាម ចែម ច្បាស់លាស់ទេ"] ។ ស-ឆ:265 ["សះ

ច្រានចោលដោយឥតបារម្ភអ្វីឡើយ ព្រោះតែសក្ខីកម្មទទួលបាននោះ គ្មានភាពពាក់ព័ន្ធនឹងបញ្ហានេះ ពោលគឺ សាក្សី កៅ ផាន បានត្រឹមតែផ្តល់សក្ខីកម្មពីការឃើញអ្នកស្រី អ៊ឹម ចែម នៅក្នុងឡានធំមួយជាមួយនឹងកងទ័ពដែលមិនបំពាក់អាវុធ ។ រីឯសាក្សី ពុំ ខូ បានត្រឹមតែកត់សម្គាល់ថា គាត់បានប្រគល់អាវុធរបស់គាត់វិញក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានទៅដល់តំបន់នោះ ។ គាត់មិនមែនប្រគល់អាវុធនោះទៅតាមសំណើសុំរបស់អ្នកស្រី អ៊ឹម ចែម នោះទេ គឺគាត់ជាអ្នកប្រគល់ដោយខ្លួនឯង[498] ។ ការពិតដែលសហព្រះរាជអាជ្ញាអន្តរជាតិបរាជ័យក្នុងការកំណត់

---

តើលោកដែលឃើញយាយចែមដែរឬទេ? ឆ៖ ទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ស-ឆ:37 ["តើលោកធ្លាប់ជួបយាយចែមដែរឬទេក្នុងរបបខ្មែរក្រហម? ឆ:37៖ ខ្ញុំមិនធ្លាប់ជួបគាត់ទេ ខ្ញុំគ្រាន់តែដឹងថាគាត់ជាអ្នកនិរតី។ ខ្ញុំចង់ធ្វើការបញ្ជាក់ថា កិច្ចសម្ភាសន៍របស់ខ្ញុំជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានៅទំព័រទី៣០ (00728637) គឺមានន័យថា ខ្ញុំមិនដែលបានជួបយាយចែមទេ។ នៅពេលនោះ ខ្ញុំបានសួរយោធានៅលើឡាន ហើយយោធានោះបានប្រាប់ខ្ញុំថា ពួកគេទៅដឹកយាយចែម"]។ កំណត់ហេតុនៃការស្តាប់ចម្លើយ ឡូត ស្វួយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:53 ["...ខ្ញុំឮតាមប្រជាជនដែលរស់នៅស្រុកព្រះនេត្រព្រះថា យាយ ចែម មានអំណាចគ្រប់គ្រងមនុស្សទាំងអស់នេះ ហើយប្រធានយោធាស្រុកក៏ត្រូវរាយការណ៍ជូនគាត់ដែរ" (គូសបញ្ជាក់បន្ថែម)] *ក៏ប៉ុន្តែសូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ ឡូត ស្វួយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:47 [ដែលលើកឡើងថា ក្រោយពីគាត់ត្រឡប់មកពីស្រុកភ្នំស្រុក ពុំត្រូវបានគេឱ្យធ្វើដំណើរទៅស្រុកព្រះនេត្រព្រះនោះទេ ហើយពុំបានដឹងថានរណាជាគណៈស្រុកនោះដែរ] និងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង ឡូត ស្វួយ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ **D67.7** ERN អង់គ្លេស 00728711 [ដែលបានលើកឡើងថា គាត់ពុំបានដឹងថានរណាកាន់កាប់កងទ័ពនៅក្នុងស្រុកព្រះនេត្រព្រះនោះឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:87 ["ខ្ញុំធ្លាប់ឮឈ្មោះយាយចែម នៅអាងត្រពាំងថ្ម។ ខ្ញុំធ្លាប់ឮគេនិយាយថា យាយ ចែម ជាអ្នកនាំកងទ័ព និងប្រជាជនឱ្យទៅធ្វើការនៅអាងត្រពាំងថ្ម។ យាយចែមក៏គ្រប់គ្រងកងទ័ពដែរ" [គូសបញ្ជាក់បន្ថែម] *ប៉ុន្តែសូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ64 ["ខ្ញុំធ្លាប់ [ឮឈ្មោះយាយចែម] ប៉ុន្តែខ្ញុំមិនធ្លាប់ជួបគាត់ផ្ទាល់ទេ" (គូសបញ្ជាក់បន្ថែម)] ស-ឆ:89 ["តើលោកស្រីដឹងថា [តា វ៉ាល់ និងអ្នកស្រី អ៊ឹម ចែម] មានតួនាទីអ្វីដែរឬទេ? ឆ:89៖ ខ្ញុំមិនដឹងទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:124-25 [ដែលបានលើកឡើងថា គាត់បានឮពីគេថា អ្នកស្រី អ៊ឹម ចែម គឺជាមេបញ្ជាការយោធា]។

498 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ចុះថ្ងៃទី ២៦ ដល់ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៤ ឯកសារ **D119/88** ឆ:30 [ដែលបានលើកឡើងថា គាត់បានឃើញលោកស្រី អ៊ឹម ចែម ក្នុងឡានហ្សេអ៊ឹមសេជាមួយនឹងកងទ័ពប្រដាប់ដោយអាវុធ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ចុះថ្ងៃទី ៦ ដល់ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ

អត្តសញ្ញាណសាក្សី សូម្បីតែម្នាក់ក៏ដោយដែលមានមុខងារជាយោធា និងជាអ្នកដែលបានទទួលបញ្ជាពីអ្នកស្រី អ៊ឹម ចែម ឬបើមិនដូច្នោះទេ ក៏ត្រឹមតែអាចផ្តល់ភស្តុតាងបឋមណាមួយ ដែលអាចភ្ជាប់ទៅនឹងការចោទប្រកាន់ថាអ្នកស្រីបានចេញបញ្ជាដល់ទាហានទាំងនោះ គឺជាការបង្ហាញដោយគ្មានសង្ស័យថា ការអះអាងទាក់ទងនឹងបញ្ហានេះ ជាការអះអាងគ្មានការពិត ។

១៣៦. ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ បង្ហាញថា ក្រោមរដ្ឋបាលដឹកនាំរបស់កម្មាភិបាលភូមិភាគពាយព្យ មេបញ្ជាការយោធាកំពូលៗនៅស្រុកព្រះនេត្រព្រះរួមមាន ធួក និងអនុរបស់គាត់ឈ្មោះ ហួរ[499] ។ ក៏ប៉ុន្តែ ពួកគាត់ត្រូវបានកម្មាភិបាលភូមិភាគនិរតីចាប់ខ្លួននៅក្នុងការបោសសម្អាតដែលបានចាប់ផ្តើមនៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ ១៩៧៧ (*ពោលគឺ* នៅមុនពេលអ្នកស្រី អ៊ឹម ចែម ត្រូវបានផ្លាស់មកភូមិភាគពាយព្យ)[500] ។ ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ ពុំបានបង្ហាញថា មានការជំនួសមុខតំណែងរបស់ពួកគាត់នោះទេ ។ យោងតាមសាក្សី ប្រាច់ គិត បានឱ្យដឹងថា គ្មានទីតាំងយោធានៅក្នុងស្រុកនេះទេ ក្រោយកម្មាភិបាលភូមិភាគនិរតីបានមកដល់[501] ។ ចំណុចនេះ ត្រូវបានបញ្ជាក់កាន់តែរឹងមាំថែមទៀតតាមរយៈចម្លើយរបស់សាក្សី ជុំ កាន់ ដែលជាទាហានមួយរូបផ្លាស់មកពីភូមិភាគនិរតីទៅភូមិភាគពាយព្យ ហើយត្រូវបានដកចេញពីជួរយោធា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់[502] ។ នៅពេលសួរថាតើអ្នកស្រី អ៊ឹម ចែម អាចកាន់កាប់ទាំង

---

**D219/23** ស-ឆ:59 ["សៈតើនៅពេលនោះ លោកប្រគល់ [កាំភ្លើង] ទៅឱ្យគេ [យាយចែម] មុន ឬក៏គេសុំដកពីលោក? ឆ:59៖ ខ្ញុំប្រគល់ឱ្យគេមុននៅឆ្នាំ១៩៧៧"] ឆ:66 ["នៅពេលនោះ យាយចែម មិនបានស្នើសុំដកអាវុធពីខ្ញុំទេ គឺខ្ញុំបានប្រគល់កាំភ្លើងរបស់ខ្ញុំទៅយាយចែមតែម្តង"]។

[499] របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស (សែម សៀត) ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/27 EN ERN** 00894530។

[500] របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស (សែម សៀត) ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/27 EN ERN** 00894530។

[501] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ **D106/2** ឆ:14។

[502] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី២៦ ដល់ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:41- 42។

យោធា និងរដ្ឋបាលបានដែរឬទេ សាក្សី ជុំ កាន់ បានឆ្លើយថា "យោងតាមការដឹងរបស់ខ្ញុំ នៅក្នុងស្រុកព្រះនេត្រព្រះមិនមានរចនាសម្ព័ន្ធយោធាទេ"[503] ។ សាក្សីក៏បានកត់សម្គាល់ផងដែរថា "នៅពេលនោះ រចនាសម្ព័ន្ធផ្នែកសន្តិសុខនៅផ្សេង ហើយផ្នែករដ្ឋបាលនៅផ្សេង"[504] ។ សាក្សី ប៊ូ ម៉ៅ ជាសាក្សីម្នាក់ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានយោងសម្រាប់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម ទទួលបន្ទុកលើ "កងកម្លាំងប្រដាប់អាវុធ"[505] ក៏បានបញ្ជាក់ផងដែរថា ខុសពី តា ម៉ោង (អតីតលេខាស្រុកព្រះនេត្រព្រះ) អ្នកស្រី អ៊ឹម ចែម គ្មានទំនួលខុសត្រូវអ្វីលើយោធាឡើយ[506] ។

## <u>សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើ*ឈ្លប*</u>

១៣៧. សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើការពិពណ៌នាចំនួនបី រួមទាំងចម្លើយដែលអ្នកស្រី អ៊ឹម ចែម បានឆ្លើយប្រាប់អង្គការយុវសន្តិភាព ដើម្បីគាំទ្រការអះអាងដែលថា អ្នកស្រីជាអ្នកគ្រប់គ្រងលើឈ្លប ដូច្នេះវាមានន័យថា អ្នកស្រីគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធទាំងមូលតែម្តង[507] ។

---

[503] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ដល់ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ស-ឆ:92។

[504] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ដល់ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:23។

[505] *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ១៥៦) និងនៅកថាខណ្ឌ ១៥៦ (លេខយោងជើងទំព័រ ៧៧៣) *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94** ឆ:54។

[506] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94** ឆ:42 ["តា ម៉ោង គឺជាគណៈស្រុកព្រះនេត្រព្រះ។ នៅពេលដែល យាយ ចែម មកដល់ស្រុកព្រះនេត្រព្រះ យាយចែម បានឡើងជំនួស តា ម៉ោង។ មូលហេតុដែលខ្ញុំនិយាយ តា ម៉ោង និង តា វ៉ាល់ កាចជាងយាយ ចែម ពីព្រោះពីមុនមក តា ម៉ោង គាត់គ្រប់គ្រងយោធា ហើយ តា ម៉ោង និងតា វ៉ាល់ តែងតែនិយាយខ្លាំងៗ ដូច្នេះ គេគ្រប់ៗគ្នា តែងតែខ្លាចគាត់"]។

[507] *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤០ (លេខយោងជើងទំព័រ ១៥៦) និងនៅកថាខណ្ឌ១៥៦ (លេខយោងជើងទំព័រ ៧៧៣) *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/121** ឆ:32។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94** ឆ:54។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយអង្គការយុវសន្តិភាព គ្មានចុះកាលបរិច្ឆេទ ឯកសារ **D219/26.1** EN ERN 01117960។

ការសំអាងលើចម្លើយរបស់អ្នកស្រី អ៊ឹម ចែម ដែលបានឆ្លើយប្រាប់អង្គការយុវសន្តិភាពមានប្រយោជន៍តិចតួចណាស់ ពោលគឺ ការរៀបរាប់នេះ មិនមែនជាការទទួលយកថាត្រឹមត្រូវអំពីការគ្រប់គ្រងនោះទេ ប៉ុន្តែវាគឺជាការពិភាក្សាលើភាពខុសគ្នានៃតួនាទីដែលបានប្រគល់ឱ្យកងឈ្លបនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[508] ។

១៣៨. ទោះបីជាសាក្សី ប៊ូ ម៉ៅ និង កោ ឡិន បានអះអាងថា អ្នកស្រី អ៊ឹម ចែម គ្រប់គ្រងកងឈ្លបផ្ទាល់ក៏ដោយ[509] ក៏ការអះអាងនេះមិនអាចឱ្យជឿបាននោះទេ ជាពិសេស នៅពេលយកមកធៀបនឹងភស្តុតាងយ៉ាងច្រើនលើសលុបផ្សេងៗទៀត ។ ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ បង្ហាញថា ក្រោយអ្នកស្រី អ៊ឹម ចែម បានមកដល់ស្រុកព្រះនេត្រព្រះ កងឈ្លបឃុំ ដែលពីមុនមកគ្រប់គ្រងផ្ទាល់ដោយគណៈស្រុក[510] ត្រូវបានរំសាយចោល ។ នៅពេលអ្នកស្រី អ៊ឹម ចែម ក្លាយជាលេខាស្រុកព្រះនេត្រព្រះនោះ សាក្សី ទុំ សឿន ដែលជាកម្មាភិបាលតំបន់៥ ឈរជើងនៅក្នុងស្រុកព្រះនេត្រព្រះ និងជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង បានបញ្ជាក់ថា គ្មានកងឈ្លបឯណាទៀតនៅក្នុងស្រុកនេះឡើយ[511] ។ ដូចបានពិភាក្សាខាងដើម[512] អ្នកស្រី អ៊ឹម ចែម *បានស្នើសុំការអនុញ្ញាត*ពី

---

[508] *សូមមើល* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយអង្គការយុវសន្តិភាព គ្មានចុះកាលបរិច្ឆេទ ឯកសារ **D219/26.1** EN ERN01117960 ["សៈ យកឈ្លបទៅដែរ? អ៊ឹម ចែម៖ ចាស។ ស្រេចតែយើងរៀបចំទេ។ សៈ ប៉ុន្តែយកទៅធ្វើអីឈ្លបហ្នឹង? អ៊ឹម ចែម៖ បានជាមានឈ្មោះថាឈ្លបភូមិ ការពារភូមិក្រែងលោមានចោរ មានឈ្មួញមានអី ដូចរាល់ ថ្ងៃអីចឹង។ បើថាគេត្រូវការកម្លាំងទៅស្រែប្រាំង ឬក៏ធ្វើអី"]។

[509] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/121 ឆ:**32។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94 ឆ:**54។

[510] របាយការណ៍នៃសម្ភាសន៍សៅ ឡង (SAU Lang) ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579** EN ERN 01166381 ["លេខាស្រុកកាន់កាប់តែអង្គភាពឈ្លបឃុំ ពុំកាន់កាប់យោធាមកពីស្រុកនោះទេពីព្រោះយោធាស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/572 ឆ:**22 [ដែលលើកឡើងថា នៅពេលគាត់ជាឈ្លប ពោលគឺ នៅមុនពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ ថ្នាក់ស្រុកទទួលខុសត្រូវ "ការងារគ្រប់ទាំងអស់" រួមទាំងឈ្លបឃុំផងដែរ]។

[511] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ស-ឆ:203 ["សៈ ជាលេខាស្រុកហ្នឹង តើគាត់ក៏កាន់ខាងយោធា ខាងឈ្លបផងដែរទេ? ឆ:203៖ ក្នុងស្រុកពេលហ្នឹងដូចអត់មានឈ្លបទេ មានតែកងនិរសារគាត់៦នាក់ប៉ុណ្ណឹង"] ស-ឆ:204 ["សៈ អីចឹងអត់មានកងកម្លាំងសន្តិសុខ និងឈ្លប

ថ្នាក់តំបន់ក្នុងការចាត់តាំងអតីតកងឈ្លបទាំងអស់ឱ្យទៅធ្វើស្រែ[513] ។

សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ទៅលើការងារសន្តិសុខ នៅក្នុងស្រុកព្រះនេត្រព្រះ

១៣៩. ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ បង្ហាញថា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគពាយព្យ តាមស្រុកនានាឈប់ទទួលបន្ទុកលើការងារសន្តិសុខជារួមទៀតហើយ ហើយអាចស្នើសុំការអន្តរាគមន៍ពីថ្នាក់តំបន់ប្រសិនបើមានកង្វល់ផ្នែកសន្តិសុខកើតឡើង ។ សាក្សី ណុប ងឹម ដែលត្រូវបានផ្លាស់ទៅភូមិភាគពាយព្យនៅក្នុងខែ សីហា ឆ្នាំ ១៩៧៧[514] និងបានក្លាយជាអនុលេខាស្រុកសំឡូតក្នុងតំបន់១[515] បានចង្អុលបញ្ជាក់ថា "ឈ្លប និងយោធាខ្មែរក្រហមត្រូវបានថ្នាក់

---

នៅស្រុកហ្នឹងទេឬ? ឆ204៖ អត់មានទេ។ ប៉ុន្តែមានកម្លាំងទាហានដើរកាត់តាមស្រុកហ្នឹងដែរ។ ពេលដែលគេដើរមកហ្នឹងបានជួបខ្ញុំដែរ ខ្ញុំសួរគេមកធ្វើអី។ គេថាមកដើរលេង"]។

512 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២៨។

513 កិច្ចសម្ភាសន៍ អ៊ឹម ចែម ដោយផលិតកម្ម Smiling Toad ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ **D1.3.12.1 EN ERN** 00217520-21។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D6.1.75 EN ERN** 01040642 ["...ខ្ញុំសុំគេដកអាវុធ ហើយរៀបចំពួកហ្នឹងទៅជាកងចល័តមួយនៅការដ្ឋានធ្វើទំនប់ ធ្វើប្រឡាយ ហើយលើកភ្លឺស្រែ"]។ កិច្ចសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D123/1/5.1b EN ERN** 00929779 ["ខ្ញុំស្នើទៅខាងលើ ខ្ញុំសូមដកអាវុធពីឈ្លប ហើយពីសេនាជនអីទាំងអស់ដែរនៅក្នុងស្រុករបស់ខ្ញុំណាស់...ហើយគេ ហើយយើងទៅថ្មីហ្នឹងគេយល់ព្រម គេអត់ហ៊ាន"] **EN ERN** 00929782 ["ដែលបានលើកឡើងថា គាត់បានដាក់សំណើសុំទៅតំបន់ឱ្យដកអាវុធពីឈ្លប"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:3។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទ្រី ភឿត ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/574** ឆ:17 ឆ:27-28។ របាយការណ៍នៃសម្មភាពស៊ើបអង្កេត (ROS Hil) ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579** EN ERN 01166380។

514 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:8។

515 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:41 [ដែលបានលើកឡើងថា តាម៉ុក បានតែងតាំងគាត់ជាអនុលេខាស្រុកសំឡូត] ឆ:59 [ដែលបានលើកឡើងថា គាត់នៅធ្វើជាអនុលេខាស្រុកសំឡូតរហូតដល់បែករបបកម្ពុជាប្រជាធិបតេយ្យ]។

តំបន់ចាត់តាំងឱ្យមកធ្វើការយាមកាមនៅស្រុក"[516] ។ ស្រដៀងគ្នានេះដែរ សាក្សី មូល អេង ដែលបានក្លាយជាលេខាស្រុកបវិលក្នុងតំបន់៣ នៃភូមិភាគពាយព្យក្រោយពេលផ្លាស់គាត់មកនោះ[517] បានលើកឡើងត្រង់ផ្នែកពាក់ព័ន្ធដូចខាងក្រោម៖

**ស៖** ក្នុងនាមលោកជាគណៈស្រុក តើលោកមានឈ្លបនៅក្នុងស្រុកទេ?

**ឆ182៖** បើមកថ្មីអីចឹង មិនមានទេ។ បើថ្នាក់តំបន់អីគឺមាន។ តែប្រហែលជាគណៈស្រុកចាស់ៗហើយអីអាចជាមានឈ្លប តែខ្ញុំមកថ្មី គឺមិនមានទេ។

**ស៖** អីចឹង បើសិនជាមានបញ្ហាសន្តិសុខនៅក្នុងស្រុកហ្នឹង ហើយលោកត្រូវការជំនួយ តើលោកត្រូវទៅទាក់ទងអ្នកណាមកជួយ?

**ឆ183៖** បាទ ទៅសុំជំនួយពីកងទ័ពតំបន់តែម្តង ។

...

**ស៖** លោកបាននិយាយថា បើសិនជាមានបញ្ហាសន្តិសុខនៅក្នុងស្រុករបស់លោក លោកនឹងទៅរកជំនួយពីទ័ពតំបន់?

**ឆ189៖** បាទ បើមានបញ្ហានៅក្នុងស្រុករបស់ខ្ញុំ។ ខ្ញុំនឹងទៅរកជំនួយពីទ័ពតំបន់[518]។

១៤០. ម្យ៉ាងវិញទៀត ភស្តុតាងនៅក្នុងសំណុំរឿង០០៤/១ បង្ហាញឱ្យឃើញថា ខ្សែសង្វាក់នៃការបញ្ជា

---

[516] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី ១២ ដល់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D118/285** ឆ:50។

[517] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:36។

[518] ក្រុមការពារក្តីកត់សម្គាល់អំពីកំហុសបកប្រែរវាងសំណៅភាសាអង់គ្លេស និងភាសាខ្មែរត្រង់ផ្នែកនេះនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង។ យោងតាមហេតុផលនេះហើយទើបមេធាវីការពារក្តីបានផ្តល់ការបកប្រែពីសំណៅភាសាខ្មែរដើមនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** (សំណៅដើមជាភាសាខ្មែរ) ឆ:182-83 ឆ:189។

ដែលបានពិពណ៌នាដោយសាក្សី មូល អេង ឃើញមានដូច្នោះមែននៅក្នុងស្រុកព្រះនេត្រព្រះ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីចូលមកដល់ ។ សរុបសេចក្តីមក ការងារផ្នែកសន្តិសុខស្ថិតនៅក្រោមសិទ្ធិអំណាចកម្មាភិបាលថ្នាក់តំបន់ គឺ តា ជាល[519] និង ទុំ សឿន ។ ទុំ សឿន ដែលជាយោធា[520] ត្រូវបាន តា ជាល[521] តែងតាំងឱ្យក្លាយជាប្រធានកងចល័តតំបន់៥ ហើយសាក្សី ជុំ កាន់ បានបង្ហាញឱ្យដឹងថា "អ្នកគ្រប់គ្រងមន្ទីរសន្តិសុខជាអ្នកដើរចាប់មនុស្ស" នៅក្នុងស្រុកនោះ[522] ។ ទុំ សឿន ក៏ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង ដែលជាមន្ទីរសន្តិសុខតំបន់៥ ហើយចំណុចនេះ នឹងលើកឡើងនៅកថាខណ្ឌ **១៤៨** ដល់ **១៥២** នៅក្នុងចម្លើយតបនេះ ។

១៤១. សរុបមកវិញ ការអះអាងទាំងឡាយណាដែលថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចជាទូទៅលើយោធា កងឈ្លប ឬ កងកម្លាំងប្រដាប់អាវុធ គឺប្រាកដណាស់ ដែលការអះអាងទាំងនោះមិនត្រូវបានគាំទ្រដោយភស្តុតាងអាចជឿទុកចិត្តបានយ៉ាងច្បាស់ក្រឡែត ។ ផ្ទុយមកវិញ ភស្តុតាងបង្ហាញច្បាស់ និងស៊ីសង្វាក់គ្នាថា អ្នកស្រី អ៊ឹម ចែម ពុំមានសិទ្ធិអំណាចលើបញ្ហាសន្តិសុខនៅក្នុងស្រុកព្រះនេត្រព្រះនោះឡើយ ។ ដូចបានពិភាក្សាខាងលើ ក្រោយពេលផ្លាស់អ្នកស្រីទៅទីនោះ ក្នុងនាមជា

---

519 *សូមមើលជាឧទាហរណ៍ សំណុំរឿង* នួន ជា *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូង (សក្ខីកម្មសាក្សី ប៉ាន ឈួង) ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/360.1** EN ERN 01176176-77 [ដែលលើកឡើងថា តាជាល ធ្លាប់ធ្វើការចាប់ខ្លួននៅក្នុងតំបន់នោះ ហើយនៅពេល តាវ៉ាល់ អតីតប្រធានកងចល័តតំបន់៥ ត្រូវបានចាប់ខ្លួន គាត់បានចូលឡានរបស់ តាជាល]។ *សូមមើល*ផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ដល់ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:225-26 [ដែលបានលើកឡើងថា តា វ៉ាល់ ត្រូវបានចាប់ខ្លួនដោយថ្នាក់តំបន់មុនពេលភូមិភាគនិរតីមកដល់]។

520 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ដល់ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:17 ["ខ្ញុំស្គាល់ សឿន ច្បាស់ណាស់ដោយសារយើងទាំងពីរនាក់ធ្លាប់ធ្វើជាទ័ពជាមួយគ្នាពីមុនមក"]។

521 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:85 ឆ:87។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102** ឆ:28។

522 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ដល់ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:17។

អ្នកចំណូលថ្មីនៅក្នុងស្រុកព្រះនេត្រព្រះ អ្នកស្រី អ៊ឹម ចែម ពុំមានយោធា ឬកងឈ្លបសម្រាប់ប្រើប្រាស់នោះទេ ។ ផ្ទុយមកវិញ នៅពេលណាមានបញ្ហាសន្តិសុខកើតឡើង អ្នកស្រីនឹងស្នើសុំថ្នាក់តំបន់ឱ្យជួយ ។ ជាសង្ខេប ភស្តុតាងបានបង្ហាញថា តួនាទីមានកម្រិតរបស់អ្នកស្រីក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះមិនបានអនុញ្ញាតឱ្យអ្នកស្រី ឬ ទាមទារឱ្យអ្នកស្រីកាន់កាប់លើ "កងកម្លាំងប្រដាប់អាវុធ" ឡើយ[523] ។

១៤២. លើសពីនេះទៀត ដូចបានពិភាក្សារួចហើយ គ្មានសក្ខីកម្មរបស់សាក្សីណាម្នាក់អាចចាត់ចូលជាប្រភេទភស្តុតាងរឹងមាំ ឬជាសក្ខីកម្មផ្ទាល់ផ្អែកជាក់ស្តែង ដែលអាចរកមើលបានប្រសិនជាអ្នកស្រី អ៊ឹម ចែម ពិតជាមានការគ្រប់គ្រងធំធេងលើ "កងកម្លាំងប្រដាប់អាវុធ" មែននោះ ជាពិសេស សិទ្ធិអំណាចដែលប្រើប្រាស់ដោយស្ត្រីម្នាក់ វាជារឿងមួយពិសេសបំផុត ហើយអាចឱ្យសាក្សីមានការចងចាំមិនភ្លេចឡើយ[524] ។ ប្រសិនបើដូច្នេះមែន ម៉្លេះសមភស្តុតាងទាំងនោះនឹងមិនកម្រិតត្រឹមតែភស្តុតាងទទួលបានពីសាក្សីមួយចំនួន ដែលពួកគាត់បានផ្តល់លើសពីការទាយស្មានផ្អែកលើមុខតំណែង*ស្របច្បាប់* ឬគ្រាន់តែជាភស្តុតាងចចាមអារ៉ាមផ្អែកលើការនិយាយបែបប្រថុយប្រថានតែប៉ុណ្ណោះ ។ ភស្តុតាងបែបនេះមិនបានបង្ហាញកម្រិតនៃការគ្រប់គ្រងនោះទេ កុំថាឡើយថា អ្នកស្រីបានប្រើប្រាស់សិទ្ធិគ្រប់គ្រងនេះដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះ ។

១៤៣. ដូចនឹងយកមកពិភាក្សាខាងក្រោម[525] ភស្តុតាងក៏ពុំបានបង្ហាញថា អ្នកស្រីមានសិទ្ធិអំណាចលើមន្ទីរសន្តិសុខភ្នំទ្រយោង ឬការដ្ឋានស្ពានស្រែង ដូចការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះដែរ[526] ។

---

[523] សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤០, ១៥៦។

[524] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៧៥-៨០។

[525] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៤-២២៦។

[526] *សូមមើល* សេចក្តីសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦ [មន្ទីរសន្តិសុខភ្នំទ្រយោង] ២៦២ [ការដ្ឋានស្ពានស្រែង]។

០០៤/១/០៧-កញ្ញា-២០០៩/អ.វ.ត.ក/ក.ស.ច.ស

## ឃ. អ្នកស្រី អ៊ឹម ចែម មិនបានដើរតួនាទីទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងឡើយ

១៤៤. ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង គឺសំអាងលើមុខតំណែង *ស្របច្បាប់* និង *ជាក់ស្តែង* របស់អ្នកស្រីដែលត្រូវបានចោទប្រកាន់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា ជាលទ្ធផលកើតចេញពីការមានមុខតំណែងរបស់អ្នកស្រីនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង អ្នកស្រី អ៊ឹម ចែម "បានដើរតួនាទីដ៏សំខាន់" ទាក់ទងនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានកើតឡើងជាប្រព័ន្ធក្នុងអំឡុងពេលដែលអ្នកស្រីស្ថិតក្នុងភូមិភាគពាយព្យ[527] ហើយត្រូវបានរងការចោទប្រកាន់ថាបាននាំឱ្យមានមនុស្សស្លាប់រាប់ពាន់នាក់ និងបានធ្វើឱ្យប៉ះពាល់ដល់ជីវិតមនុស្សជាច្រើនផ្សេងទៀត[528] ។

១៤៥. ក្រុមការពារក្តីសូមលើកឡើងថា អំណះអំណាងទាំងនេះ ពុំផ្អែកលើការបកស្រាយបែបសត្យានុម័ត ឬមានសំអាងហេតុលើភស្តុតាងដែលមានឡើយ ។ ដូចដែលយើងខ្ញុំនឹងពិភាក្សាខាងក្រោម មានភស្តុតាងបន្តិចបន្តួចដែលអាចជឿជាក់បានសម្រាប់ការបង្ហាញថា ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ បានកើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងនៅការដ្ឋានស្ពានស្រែង ។ លើសពីនេះ ភស្តុតាងក្នុងសំណុំរឿង០០៤/១ បង្ហាញយ៉ាងច្បាស់ថា មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ស្ថិតក្រោមសិទ្ធិអំណាចជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់កម្មាភិបាលថ្នាក់តំបន់[529] ។ ទោះក្នុងករណីណាក៏ដោយ គ្មានភស្តុតាងដែលអាចជឿជាក់បានដើម្បីបង្ហាញអំពីការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម ក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តនៅទីតាំងណាមួយក្នុងចំណោមទីតាំងទាំងពីរនេះឡើយ ។ ជាសរុប ក្រុមការពារក្តីសូម

---

[527] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០-៣២។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២-៥។

[528] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥, ៥៣០, ៥៣៦។

[529] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤ និង ១៩៣-២០៧។

អះអាងថា ការពិនិត្យភស្តុតាងទាក់ទងនឹងលក្ខខណ្ឌត្រួតគ្នាទាំងពីរនេះ (ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ដែលត្រូវបានចោទ និងកម្រិតនៃការទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មទាំងនោះរបស់អ្នកស្រី អៀង ធីរិទ្ធ ដែលត្រូវបានចោទប្រកាន់) បង្ហាញថា អ្នកស្រី អៀង ធីរិទ្ធ ពុំអាចត្រូវបានចាត់ទុកជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងនោះឡើយ ។ ចំណុចទាំងនេះនឹងត្រូវបានលើកឡើងបន្ថែមខាងក្រោម ។

### ១. អ្នកស្រី អៀង ធីរិទ្ធ មិនបានដើរតួនាទីសំខាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ

១៤៦. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា i) អ្នកស្រី អៀង ធីរិទ្ធ ជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិសុខភ្នំទ្រយោង និងបានអនុវត្ត "សិទ្ធិអំណាចទូលំទូលាយ" លើមន្ទីរសន្តិសុខនេះ[530] ហើយថាអ្នកស្រីក៏ជាប្រធានមន្ទីរសន្តិសុខនេះផងដែរ[531] និងថា ii) អ្នកស្រីបានជាប់ពាក់ព័ន្ធយ៉ាងសកម្មទាក់ទងនឹងការឃុំឃាំងអ្នកទោសចំនួនរាប់ពាន់នាក់[532] ដែលក្នុងចំណោមអ្នកទោសទាំងនោះ មានរាប់ពាន់នាក់ត្រូវបានស្លាប់ដោយសារភាពអត់ឃ្លាន ការមានជំងឺ ធ្វើការហួសកម្រិត[533] និងការសម្លាប់[534] ។

១៤៧. ដូចដែលយើងខ្ញុំនឹងពិភាក្សាខាងក្រោម ភស្តុតាងបង្ហាញថា អំណះអំណាងទាំងពីរនេះពុំត្រឹមត្រូវ ។ ទីមួយ ភស្តុតាងដ៏ច្រើនលើសលប់បានបង្ហាញថា មន្ទីរសន្តិសុខភ្នំទ្រយោង និងជនប្រព្រឹត្តមួយចំនួនដែលត្រូវបានចោទប្រកាន់ ត្រូវបានស្ថិតក្រោមការទទួលខុសត្រូវរបស់ថ្នាក់តំបន់[535] ។

---

530 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦។

531 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៧-៩៨។

532 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៧ និង ២០០។

533 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០៥។

534 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២។

535 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤។

អ្នកស្រី អ៊ឹម ចែម គ្មានសិទ្ធិអំណាចដល់កម្រិតនេះឡើយ[536] ។ ទីពីរ ភស្តុតាងពុំបង្ហាញថា អ្នកស្រី អ៊ឹម ចែម បានជាប់ពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មណាមួយទេ ។ លើសពីនេះ អំណះអំណាងមិនពិតរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទនៅទីតាំងនេះក្នុងអំឡុងពេលពាក់ព័ន្ធ គឺសំអាងលើការវិភាគនូវភស្តុតាងដែលខ្វះភាពសត្យានុម័ត[537] ។ ជាសង្ខេប ក្រុមការពារក្តីសូមអះអាងថា តាមការវាយតម្លៃដ៏សមហេតុផលអំពីលក្ខខណ្ឌត្រួតគ្នាទាំងពីរនេះ (ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានលើកឡើង) ដើម្បីឈានទៅរកការសន្និដ្ឋានដ៏រឹងមាំថា ភស្តុតាងសំអាងទាំងអម្បាលម៉ានមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គិតតួច ឬក៏គ្មានតម្លៃភស្តុតាងជាដុំកំភួនណាមួយដែលអាចបង្ហាញពីការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំទ្រយោង មានតម្លៃស្មើទៅនឹងការទទួលខុសត្រូវដ៏ធំ ឬ ប្រហាក់ប្រហែល ដើម្បីភ្ជាប់អ្នកស្រីទៅនឹងការទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរឡើយ ។ តាមលក្ខណៈជាតួអង្គនៃភស្តុតាង វាផ្តល់ការគាំទ្របន្តិចបន្តួច ឬមិនផ្តល់ការគាំទ្រទាល់តែសោះចំពោះអំណះអំណាងដែលថា អ្នកស្រីស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅ អ.វ.ត.ក ។

### *i. មន្ទីរសន្តិសុខភ្នំទ្រយោងស្ថិតក្រោមការគ្រប់គ្រងជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ ទុំ សឿន កម្មាភិបាលតំបន់៥*

១៤៨. ផ្ទុយពីការរៀបរាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិ[538] ភស្តុតាងក្នុងសំណុំរឿង០០៤/១ មិនបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច *ស្របច្បាប់* ឬ *ជាក់ស្តែង* ដែលចាំបាច់សម្រាប់ "ទទួលខុសត្រូវលើ" មន្ទីរសន្តិសុខភ្នំទ្រយោងឡើយ ។ ដូចដែលយើងខ្ញុំនឹងពិភាក្សាខាងក្រោម មន្ទីរសន្តិសុខភ្នំទ្រយោង គឺជាមន្ទីរសន្តិសុខតំបន់៥ ក្រោមការគ្រប់គ្រងជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ ទុំ សឿន កម្មាភិបាលថ្នាក់តំបន់ និងធ្វើប្រតិបត្តិការដោយទាហានតំបន់៥ ដែល

---

[536] *សូមមើល* ចម្លើយតប កថាខណ្ឌ ៩៧-១៤២។

[537] *សូមមើល* ចម្លើយតប កថាខណ្ឌ ១៥៥-៨៦។

[538] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦។

អ្នកទោសត្រូវបានបញ្ជូនទៅទីនោះ តាមបញ្ជារបស់ថ្នាក់តំបន់ ។

១៤៩. មន្ទីរសន្តិសុខភ្នំទ្រយោង ជាមន្ទីរសន្តិសុខតំបន់៥ ដោយមានអ្នកទោសមកពីស្រុកផ្សេងៗក្នុងតំបន់នេះ[539] ។ ទុំ សឿន ដែលជាទាហានជើងចាស់[540] ត្រូវបានតែងតាំងជាប្រធានកងចល័តតំបន់៥ ដោយ *តា* ជាល[541] និងត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សី ជុំ កាន់ ថាជា "អ្នកគ្រប់គ្រងមន្ទីរសន្តិសុខជាអ្នកដើរចាប់មនុស្ស" ក្នុងស្រុកនេះ[542] ។ អតីតអ្នកទោស និងឆ្មាំ[543] ព្រមទាំង ទុំ

539 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភូន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:28 ["គុកភ្នំទ្រយោងជាគុកតំបន់៥"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:57 [ដែលនិយាយថា មន្ទីរសន្តិសុខភ្នំទ្រយោង "ជារបស់តំបន់៥ ព្រោះមានមនុស្សមកពីច្រើនស្រុក]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:22 [ដែលនិយាយថាភ្នំទ្រយោងជាមន្ទីរសន្តិសុខស្រុកព្រះនេត្រព្រះ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់៥]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:89 ["តាមខ្ញុំដឹង មន្ទីរសន្តិសុខភ្នំទ្រយោងជាមន្ទីរសន្តិសុខថ្នាក់តំបន់"]។ *សូមមើល*ផងដែរ *សំណុំរឿង នួន ជា និង អ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះសាលាដំបូង (សក្ខីកម្មរបស់សាក្សី ឈិត យឿក) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ E1/330.1, EN ERNs 01131283-84 [ដែលនិយាយថាគាត់បែងចែកស្រូវទៅ មន្ទីរសន្តិសុខភ្នំទ្រយោង ក្រោមការគ្រប់គ្រងរបស់ តា រិន លេខាតំបន់៥]។

540 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/110 ឆ:17 ["ខ្ញុំស្គាល់ សឿន ច្បាស់ណាស់ ដោយសារយើងទាំងពីរនាក់ធ្លាប់ធ្វើជាទ័ពជាមួយគ្នាពីមុនមក"]។

541 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ **D119/65** ឆ:85 ឆ87។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102** ឆ:28។

542 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:17។

543 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** ឆ:35។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/19** ឆ:40។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភូន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នា ២០១៣ ឯកសារ **D119/30** ឆ:27។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/95** ឆ:22។ ប្រតិចារឹកនៃការស្តាប់ចម្លើយ ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.2**, EN ERN 01136766, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:39។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហួន អោម ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:64-65។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/88** ឆ:18។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆ:91។

សឿន ដែរ[544] មិនដែលបានឃើញអ្នកស្រី អ៊ឹម ចែម ចុះមកមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ ។ លើសពីនេះ ទុំ សឿន បានរស់នៅមន្ទីរសន្តិសុខភ្នំទ្រយោង ចម្ងាយប្រមាណជាពីរឬបីម៉ែត្រពីកន្លែងឃុំឃាំងប៉ុណ្ណោះ ជាទីកន្លែងដែលត្រូវបានចោទថាជាទីឃុំឃាំង និងសម្លាប់អ្នកទោសធ្ងន់[545] ។ យោងតាមអតីតអ្នកទោសដែលគេបានចាត់តាំងឱ្យធ្វើចុងភៅបានឱ្យដឹងថា ទុំ សឿន បានស្នាក់នៅទីនោះ "ជាអចិន្ត្រៃយ៍ជាមួយប្រពន្ធ និងកូនៗរបស់គាត់"[546] និងបានសង់ផ្ទះរបស់គាត់ដោយឈើដែលមកពីថ្នាក់តំបន់[547] ។ សាក្សី ស៊ុម សល់ អតីតឆ្មាំមន្ទីរសន្តិសុខភ្នំទ្រយោង[548] បានចាត់ទុក ទុំ សឿន ថាជា "ប្រធានធំតែមួយគត់" នៅគុកនេះ[549] ដែលអង្គហេតុនេះ ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើន[550] ។ សាក្សី ភួន ស៊ុនទី ជាអតីតអ្នកទោស ដែលក្រោយមកត្រូវគេចាត់តាំង

---

544 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ **D119/65** **ឆ:**184 ["ពេលខ្ញុំនៅទីនោះ ខ្ញុំមិនដែលឃើញគាត់មកទេ។ ប៉ុន្តែគាត់អាចមក នៅពេលដែលខ្ញុំចេញទៅលេងនៅតាមឃុំនានា"]។

545 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/95** **ឆ:**9។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92** **ឆ:**45។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** **ឆ:**64-65។

546 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153** **ឆ:**22។

547 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** **ឆ:**208 ["ឃើញម្ដងខាងភូមិភាគបានដឹកឈើមកទុកនៅភ្នំត្រយ៉ូង ដើម្បីធ្វើមន្ទីរសន្តិសុខថ្មីនៅភ្នំស្រមោច ប៉ុន្តែមិនទាន់បានសាងសង់ទេ ហើយឈើនៅសល់ខ្ញុំយកទៅធ្វើផ្ទះ"]។

548 *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** **ស-ឆ:**7។

549 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** **ឆ:**20។

550 *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គឹម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ឯកសារ **D106/6** **ឆ:**18-19 [ដែលនិយាយថាគ្រប់គ្នាដឹងថា តា សឿន ជាប្រធានមន្ទីរសន្តិសុខ]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** **ឆ:**9 ["តា សឿន ប្រធានមន្ទីរសន្តិសុខ…"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ឯកសារ **D106/8** **ឆ:**16 [ដែលនិយាយថា តា សឿន ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/19** **ឆ:**32 ["តា សឿន គឺជាអតីតមេគុកភ្នំទ្រយោង"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ឯកសារ **D119/30** **ឆ:**24 ["មេគុកភ្នំទ្រយោងឈ្មោះ សឿន"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ឯកសារ **D219/149** **ឆ:**36 ["ខ្ញុំមិនដឹងថាអ្នកណាជាអ្នកចេញ

ឱ្យធ្វើជាឆ្មាំនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ោង[551] និយាយថា ទុំ សឿន "មិនសូវចំណុះ *យាយ* ចែម ទេ ព្រោះគាត់ដូចជាមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ *យាយ* ចែម"[552] ។

១៥០. សហព្រះរាជអាជ្ញាអន្តរជាតិបានយោងទៅរកសាក្សី ១៣នាក់ ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិសុខភ្នំទ្រយ៉ោង[553] ។ ដោយទទួលយកភស្តុតាងនេះមកពិនិត្យ

---

បញ្ហាទេ ប៉ុន្តែខ្ញុំដឹងថា សឿន ជាអ្នកគ្រប់គ្រងនៅទីនោះ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/88** ឆ:23 [ដែលនិយាយថាតា សឿន គ្រប់គ្រងអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ោង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/103** ឆ:28-33 [ដែលកត់សម្គាល់ថាជាអ្នកយាមនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ោង ស៊ុម សល់ បានទទួលបញ្ជាពី និងរាយការណ៍ផ្ទាល់ទៅតា សឿន]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153** ឆ:13 [ដែលបញ្ជាក់ថាកម្មាភិបាលម្នាក់ឈ្មោះ សឿន ទទួលបន្ទុកភ្នំទ្រយ៉ោង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:29 ["ឈ្មោះ សឿន មកពីនិរតី គឺជាអ្នកគ្រប់គ្រងនៅភ្នំទ្រយ៉ោង"]។ កំណត់ហេតុនៃកិច្ចសម្ភាសន៍ (សូ ឡាង) ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579**, EN ERN 01166381 [ដែលនិយាយថាគាត់មានទំនាក់ទំនងល្អជាមួយ តា សឿន មេគុកភ្នំទ្រយ៉ោង]។

551 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ិនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** **ឆ:**24។

552 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ិនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** **ឆ:**28។

553 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ១៥៦ (ជើងទំព័រ ៩៧៥) *យោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/8** ឆ:35។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/567** ឆ:131។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:89។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ពៅ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/383** ឆ:36។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:59-62។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153** ឆ:20។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:69។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី គាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/256** ឆ:25។ កិច្ចសម្ភាសន៍ SOAS/HRW ជាមួយ យ៉ែម កោង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ ឯកសារ **D1.3.11.66**។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94** ឆ:56។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **D219/174** ឆ:71។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:112-14។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **D43**, EN ERN 00727233-34។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/5**

យ៉ាងហ្មត់ចត់ មានសាក្សីតែម្នាក់គត់ដែលអះអាងដោយភាពច្បាស់លាស់ថា អ្នកស្រី អ៊ឹម ចែម "ជាអ្នកទទួលខុសត្រូវទីតាំងនេះ" គឺ ទុំ សឿន ខ្លួនឯងតែម្តង[554] បើទោះបីជាក្រោយមកទៀត ទុំ សឿន ខ្លួនឯងបានទទួលស្គាល់ថា គាត់ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង[555] ។ ដោយសារការជាប់ពាក់ព័ន្ធរបស់ ទុំ សឿន ក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង[556] និងចេតនាដ៏ច្បាស់លាស់របស់គាត់ដើម្បីប្រខិត ឬទម្លាក់កំហុសឱ្យអ្នកផ្សេងដូច្នេះ វាទាមទារឱ្យមានការប្រយ័ត្នប្រយែងមុនពេលសំអាងលើចម្លើយរបស់គាត់[557] ។ ទុំ សឿន ត្រូវតែចាត់ទុកជាជនសមគំនិត[558] ។ ចំណុចនេះតម្រូវឱ្យមានការវាយតម្លៃយ៉ាងហ្មត់ចត់អំពីលក្ខណៈនៃសក្ខីកម្ម រួមទាំងចេតនាខាងក្នុងនៃសក្ខីកម្មនោះ និងថាតើគាត់ទទួលប្រយោជន៍ពីសក្ខីកម្មរបស់គាត់តាមរយៈការគេចវេះពីការទទួលខុសត្រូវឬទេ ក្នុងវិសាលភាពដែលចំណុចខ្វះចន្លោះក្នុងសក្ខីកម្មត្រូវបានពន្យល់ និងថាតើការរៀបរាប់របស់ ទុំ សឿន ត្រូវបានបញ្ជាក់ការពិតឬយ៉ាងណា[559] ។

១៥១. ទុំ សឿន បានទទួលប្រយោជន៍ពីលិខិតធានាចំនួន *បី* ដែលថា គាត់នឹងមិនត្រូវបានចោទប្រកាន់នៅ

---

ឆ:28។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:148, ឆ:158, ឆ:171, ឆ:173, ឆ:175, ឆ:178, ឆ:183។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102** ឆ:6-7, ឆ:45។ កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERN 01072619 ។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **D119/64.1**, EN ERN 00951706-07។

554 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៨៦ (ជើងទំព័រ៨៧៥)។

555 *សូមមើល* កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072599 ["...ខ្ញុំជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង"]។

556 *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ១៥២-៥៣, ១៥៥-៨៦។

557 *សូមមើល* Augustin Bizimungu *ទល់នឹង* រដ្ឋអាជ្ញា (ICTR-00-56B-A) សាលក្រមរបស់សាលាឧទ្ធរណ៍ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៣ [ភ្ជាប់មកជា**ឯកសារយោង ២៥**]។

558 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៨៦ (ជើងទំព័រ ៨៧៥) និងនៅកថាខណ្ឌ ១៨៧ (ជើងទំព័រ ៨៨៣)។

559 *សូមមើល* Simeon Nchamihigo *ទល់នឹង*រដ្ឋអាជ្ញា (ICTR-2001-63-A) សាលក្រមរបស់សាលាឧទ្ធរណ៍ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧ [ភ្ជាប់មកជា**ឯកសារយោង ២៦**]។

អ.វ.ត.ក ឡើយ[560] ។ វាជាព័ត៌មានត្រូវយល់ដឹងមួយដែលថា គាត់គឺជាសាក្សីតែម្នាក់គត់ដែលពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម ដែលទទួលបានផលប្រយោជន៍ពីលិខិតធានាជាច្រើន ។ មិនមានអ្វីចម្លែកឡើយ ចម្លើយរបស់គាត់ពោរពេញទៅដោយចំណុចមិនស៊ីសង្វាក់សំខាន់ៗលើបញ្ហាសម្ភារៈតឹកតាងដែលមិនទាន់ត្រូវបានពន្យល់[561] ។ ពុំមានការបញ្ជាក់ការពិតដ៏មានអត្ថន័យចំពោះការរៀបរាប់ដាក់បន្ទុករបស់គាត់ឡើយ ។ ជាការពិត សាក្សីដទៃទៀតដែលត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីគាំទ្រអំណះអំណាងដែលថា អ្នកស្រី អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវចំពោះមន្ទីរសន្តិសុខភ្នំទ្រយោង[562] ទទួលស្គាល់ថា ពួកគាត់បានដឹងបន្តិចបន្តួចអំពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅមន្ទីរសន្តិសុខភ្នំទ្រយោង ឬបានផ្តល់ភស្តុតាងដោយផ្អែកលើពាក្យចចាមអារ៉ាម ឬភស្តុតាងស្នានៗទាំងស្រុង ដែលខ្វះតម្លៃជាភស្តុតាង ។ វាជាការគួរឱ្យសោកស្តាយដែលសហព្រះរាជអាជ្ញាអន្តរជាតិប៉ុនប៉ងបិតបាំងនូវចំណុចខ្វះចន្លោះទាំងនេះ តាមរយៈការដកចេញផ្នែកពាក់ព័ន្ធនៃសក្ខីកម្មរបស់ពួកគាត់ ឬយោងទៅរកសក្ខីកម្មនានាតាមរបៀបចោះៗយ៉ាងសម្រិត

---

560 លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដល់ ទុំ សឿន ចុះថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65/1**។ លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដល់ ទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102/1**។ លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដល់ ទុំ សឿន ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230/1**។

561 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072599 ["...ខ្ញុំជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង"] *ផ្ទុយនឹង* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, **D219/422.9**, EN ERN 01136968 ["នៅទាំងមូល គឺលើយាយ ចែម ហ្នឹងឯង ។ គាត់អ្នករៀបចំមក ។"]។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ជួនកាលនីរសាររបស់គាត់មកប្រាប់ឱ្យខ្ញុំបញ្ជូនមនុស្ស ១០ ឬ ២០ នាក់ ទៅធ្វើការងារ...ពីព្រោះលិខិតទាំងនោះពុំមាននិយាយអំពីបញ្ហាសំខាន់ ទើបខ្ញុំបោះចោល"]។ ផ្ទុយនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102**, ស-ឆ:63, ស-ឆ:64 ["តើមានឯកសារភ្ជាប់មកជាមួយអ្នកទោសដែលបានបញ្ជាក់អំពីទោសកំហុសរបស់ពួកគេ មកឱ្យលោកដែរឬទេ? ជាធម្មតា គឺមិនមានឯកសារអ្វីបញ្ជាក់អំពីកំហុសរបស់អ្នកទោសនោះទេ...ទេ មិនដែលមានឯកសារភ្ជាប់បញ្ជូនមកឱ្យខ្ញុំនោះទេ"]។

562 ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥)។

សម្រាំងតាមការចង់បានរបស់ខ្លួន[563] ។

---

[563] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦ (ជើងទំព័រ ៩៧៥) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/8 ឆ:**35 [ផ្នែកទីមួយនៃចម្លើយសាក្សីដែលនិយាយថាគាត់មិនច្បាស់ ពុំត្រូវបានលើកយោងឡើយ ដោយយោងទៅលើចុងប្រយោគដែលនិយាយថាគាត់បានសន្មតថាអ្នកស្រី អ៊ឹម ចែម គឺជាថ្នាក់លើរបស់ ទុំ សឿន ដោយផ្អែកលើលិខិតមួយដែលគាត់អាន ជំនួសវិញ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/567 ឆ:**131 ["យាយ ចែម ធំជាង"] ប៉ុន្តែមិនយោងទៅរក **ឆ:**129-30 [ដែលនិយាយថាសាក្សី ពុំដឹងអំពីការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ឬអំពីទំនាក់ទំនងរវាងគាត់ និង ទុំ សឿន]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ត្លុក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400 ឆ:**59-62 [ដែលនិយាយថាគាត់មិនចាំថាអ្នកណាជាប្រធានគុកឡើយ និងត្រូវបានប្រាប់ថា យាយ ចែម នៅទីនោះ [មន្ទីរសន្តិសុខភ្នំទ្រយោង]]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23 ឆ:**113 [ដែលនិយាយថាគាត់មិនដែលបានទៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ] **ឆ:**114 [ដែលនិយាយថាគាត់មិនស្គាល់អ្នកគ្រប់គ្រងកន្លែងវាយថ្មនៅមន្ទីរសន្តិសុខភ្នំទ្រយោងទេ ប៉ុន្តែដឹងថាជាកម្លាំងរបស់ យាយ ចែម]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **D43,** EN ERN 00727233-34 [ដែលនិយាយថាគាត់ពុំដឹងលម្អិតអំពីការគ្រប់គ្រងមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153 ឆ:**20 ["ខ្ញុំឮពីអ្នកយាម និងអ្នកទោសនៅភ្នំទ្រយោងនិយាយថា យាយ ចែម ជាមេរបស់តាសឿន" (សេចក្តីបញ្ជាក់បន្ថែម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144 ឆ:**69 ["ខ្ញុំធ្លាប់ឮឈ្មោះភ្នំទ្រយោង។ ភ្នំទ្រយោងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យាយ ចែម"] (សេចក្តីបញ្ជាក់បន្ថែម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/256 ឆ:**25 ["ខ្ញុំដឹងថាយាយចែមជាអ្នកគ្រប់គ្រងគុកភ្នំត្រយ៉ូងដោយផ្ទាល់ ព្រោះអ្នកបរទេះមួយចំនួនដែលដឹកស្បៀងពី ស្រុកទៅគុកភ្នំទ្រយោងជាអ្នកប្រាប់ខ្ញុំអំពីរឿងនេះ" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ពឿ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/383 ឆ:**28 [ដែលនិយាយថាគាត់មិនដឹងថាអ្នកណាគ្រប់គ្រងមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ និងបានដឹងថាគឺអ្នកស្រី អ៊ឹម ចែម]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/94 ឆ:**56 ["តាមការអង្កេតរបស់ខ្ញុំ យាយ ចែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះ" ប៉ុន្តែមិននិយាយថាគាត់ដឹងឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **D219/174 ឆ:**71 [ដែលនិយាយថា គាត់ឮឈ្មោះរបស់អ្នកស្រី អ៊ឹម ចែម ថាជាមេខ្លាំងធំបំផុតពីព្រោះគាត់ជាអ្នកដើរបើកអង្គប្រជុំនៅតាមកងចល័តនានា ប៉ុន្តែពុំភ្ជាប់គាត់ទៅនឹង មន្ទីរសន្តិសុខភ្នំទ្រយោងឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110 ឆ:**89-90 [ដែលនិយាយថាតាមគាត់ដឹង មន្ទីរសន្តិសុខភ្នំទ្រយោងស្ថិតក្រោមថ្នាក់តំបន់ និងតាមគាត់ដឹងអ្នកទោសថ្នាក់តំបន់ ត្រូវរាយការណ៍ទៅថ្នាក់តំបន់ ប្រសិនបើអ្នកទោសជារបស់ស្រុកត្រូវរាយការណ៍ទៅអ្នកស្រី អ៊ឹម ចែម ប៉ុន្តែពុំបាននិយាយថាគាត់ដឹងដោយវិធីណាឡើយ]។

១៥២. ដោយទុកមួយឡែកនូវវិធីសាស្ត្រដែលមានវិការៈជាក់ស្តែងនេះ ភស្តុតាងបឋម និងឯកសារជាប្រចង្អុលទៅរកទិសដៅតែមួយប៉ុណ្ណោះ ពោលគឺ ភស្តុតាងបានបញ្ជាក់ភិនភាគ ទុំ សឿន យ៉ាងរឹងមាំថាគឺជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិសុខភ្នំទ្រយោង ។ នៅពេលណាដែលមានកិច្ចប្រជុំនៅមន្ទីរសន្តិសុខភ្នំទ្រយោង ទុំ សឿន ជាមនុស្សតែម្នាក់គត់ដែលនិយាយទៅកាន់អ្នកចូលរួម[564] ។ អតីតឆ្មាំគុកមួយចំនួន បានផ្តល់សក្ខីកម្មថាបានទទួលការណែនាំដោយផ្ទាល់ និងរាយការណ៍ទៅឱ្យ ទុំ សឿន[565] ។ ភស្តុតាងដ៏ស៊ីសង្វាក់ និងឯកសារជាប្របង្ហាញថា ទុំ សឿន មានសិទ្ធិអំណាចទទួលយកអ្នកទោស[566] ធ្វើការកំណត់ថាពួកគេជាអ្នកទោសកម្រិតធ្ងន់ ឬស្រាល[567] ចាត់តាំងពួកគេឱ្យធ្វើជាឆ្មាំ[568] ផ្តល់ការណែនាំផ្សេងៗ[569] ធ្វើការសម្រេចថាតើអ្នកទោសគួរត្រូវបានដោះលែង[570] និងថា

---

564 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (ចាម បួរ) ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/28**, EN ERN 00894533 ["នៅឯគុកនេះ នៅពេលណាមានការប្រជុំម្តងៗ មានតែ តា សឿន ម្នាក់ប៉ុណ្ណោះជាអ្នកធ្វើ និងនិយាយ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:24 ["នៅថ្ងៃមួយនោះ តា សឿន បានមកពីប្រជុំវិញ ហើយបានកោះហៅអ្នកទោសទាំងអស់ប្រហែល៣០០នាក់ ឱ្យមកប្រជុំ"]។ កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072611 [ដែលនិយាយថា គាត់បានកោះប្រជុំនៅពេលទ័ពវៀតណាមចូល និងបានបញ្ជាឱ្យអ្នកទោសត្រឡប់ទៅភូមិរបស់ពួកគាត់វិញ]។

565 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆ:30។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** ឆ:9។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:24-25។

566 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:43 [ដែលនិយាយថា ទុំ សឿន កំពុងរង់ចាំគាត់ពេលដែលគាត់ទៅដល់]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** ឆ:9 ["ខ្ញុំត្រូវទៅរាយការណ៍ជូនតា សឿន ភ្លាម"]។

567 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072597 ["ខ្ញុំទទួលមនុស្ស... ហើយខ្ញុំវាយតម្លៃថាតើអ្នកនោះចូលកម្រិតណា ។...ខ្ញុំវាយតម្លៃថាអ្នកនោះ ក្បត់ ឬមិនមែន"], 01072613 ["ពេលខ្លះ ខ្ញុំជាអ្នកសម្រេចប្តូរចំណាត់ថ្នាក់ដោយខ្លួនខ្ញុំ "]។

568 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERN 01072594 ["អ្នកខ្លះ [អ្នកយាម] គឺជាអ្នកទោសស្រាល ដែលខ្ញុំបានជ្រើសរើសយកឱ្យធ្វើជាអ្នកយាម"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:24

តើអ្នកទោសទាំងនោះ គួរត្រូវយកទៅសម្លាប់ឬយ៉ាងណា[571] ។

១៥៣. ជារៀងរាល់ថ្ងៃ ទាហានតំបន់៥ ក្រោមសិទ្ធិអំណាចរបស់ ទុំ សឿន បានធ្វើប្រតិបត្តិការនៅមន្ទីរសន្តិសុខភ្នំទ្រយោង[572] ។ ទាហានទាំងនោះត្រូវបានចាត់តាំងឱ្យចាប់ខ្លួន និងយកអ្នកទោសទៅមន្ទីរ

---

["ខ្ញុំបានឆ្លើយថាខ្ញុំឈ្មោះ ភួន ទី ជាអ្នកមកពីប្រាសាទ ។ ពេលនោះគាត់បាននិយាយប្រាប់ខ្ញុំថាមិត្តឯងត្រូវធ្វើជាប្រធានអ្នកទោសទាំងអស់"]។

569 *សូមមើល* ជាឧទាហរណ៍កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** **ឆ:**51 ["ដំបូងតាសឿនបានឱ្យខ្ញុំដាំចេក និងគាស់ដំបូកដែលមានគល់ឬស្សី ដើមស្វាយ ដើម្បីរំលាយដំបូកនោះសម្រាប់ធ្វើស្រែ។ ខ្ញុំធ្វើការនៅទីនោះបាន១ខែ តាសឿន បានយកខ្ញុំមកធ្វើការនៅជិតគាត់វិញ។ គាត់ បានឱ្យខ្ញុំធ្វើជាអ្នកបែងចែកកន្ទក់ឱ្យអ្នកទោសដែលមានជំងឺហើមជាដើម"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ឯកសារ **D219/153** **ឆ:**22 ["តា សឿន ចាត់តាំងការងារឱ្យយើងជីករណ្តៅដាំចេក ជម្រះស្មៅ និងបោសសម្អាតនៅទីនោះ"], **ឆ:**26 [ដែលនិយាយថា គាត់ក្រោយមកត្រូវបានចាត់តាំងឱ្យធ្វើចុងភៅនៅ មន្ទីរសន្តិសុខភ្នំទ្រយោង]។

570 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230,** EN ERNs 01072611 ["ខ្ញុំធ្លាប់បានប្រជុំ១ដងនាពេលដែលវៀតណាមចូល ហើយបានប្រាប់ពួកគេ [អ្នកទោសនៅ មន្ទីរសន្តិសុខភ្នំទ្រយោង] ថាមកពីណា ឱ្យត្រឡប់ទៅកន្លែងនោះវិញទៅ ពីព្រោះខ្ញុំមិនអាចការពារពួកគាត់ទៀតទេ"], 01072612 ["ខ្ញុំក៏បានដោះលែង [អ្នកទោស] តាមការពិនិត្យរបស់ខ្ញុំផ្ទាល់"]។ *សូមមើល*ផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** **ឆ:**28 ["តា សឿន បានឱ្យប្រជាជនវិលត្រឡប់ទៅភូមិរបស់ពួកគេវិញ" ពេលវៀតណាមចូល]។

571 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072622 ["ការសម្លាប់អ្នកណាមួយ ត្រូវមានការជូនដំណឹងពីខ្ញុំ"]។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** **ឆ:**24 [ដែលនិយាយថា ទុំ សឿន "បាននិយាយថាបើបាត់អ្នកទោសតែម្នាក់ គេនឹងវាយមិត្តឯងចោល"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** **ឆ:**62 ["តា សឿន ជាអ្នកបញ្ជាឱ្យសម្លាប់"]។

572 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/127** **ឆ:**40 ["ខ្ញុំមិនអាចធ្វើការប៉ាន់ស្មានចំនួនមនុស្សស្លាប់នៅទីនោះបានទេ ពីព្រោះនៅពេលនោះ គឺមានតែក្រុមយោធាដែលស្ថិតនៅក្រោមបញ្ជារបស់ តា សឿន ប៉ុណ្ណោះដែលបានធ្វើរឿងនោះ"] **ឆ:**49 ["យោធាមួយចំនួនដេកនៅក្បែរតាសឿន គឺនៅខាងជើងកន្លែងគាត់ស្នាក់នៅ"]។ កំណត់ហេតុនៃកិច្ចស៊ើបសួរ (សូ ឡាង) ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579** EN ERN 01166391 [ដែលនិយាយថា តា សឿន ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង ដែល "យាមដោយទាហានមកពីតំបន់៥"]។

សន្តិសុខ[573] ទទួលអ្នកទោស[574] យាមកាមអ្នកទោស[575] ពិនិត្យមើលដោយផ្ទាល់នូវការងារអ្នកទោស[576] ធ្វើការសួរចម្លើយ[577] ដាក់ខ្នោះ និងដោះខ្នោះពួកគាត់[578] សម្លាប់[579] និងបញ្ជាអ្នកទោស

---

573 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នូ ខាំ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ **D219/583** ឆ:35-36 [មានអ្នកយាមតែម្នាក់ ដែលយកអ្នកទោសទៅកន្លែង តា ពាល់ ប៉ុន្តែមានទាហាន៥នាក់និងមានកាំភ្លើងអ៊ឹមសែង ៥ ដើមដើម្បីយកពួកគាត់ទៅ មន្ទីរសន្តិសុខភ្នំទ្រយោង]។ កំណត់ហេតុនៃកិច្ចសម្ភាសន៍ (ទេព ស្រឿយ) ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/25**, EN ERN 00894525 ["ការចាប់ខ្លួនត្រូវបានអនុវត្តដោយពួកយោធា មិនមែនដោយកងឈ្លបតាមមូលដ្ឋាននោះទេ"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/8** ឆ:14 ["នៅពេលមេគុកមកនាំខ្ញុំទៅ គាត់មកជាមួយយោធាពីរនាក់"]។ ស-ឆ:15 ["ស៖ នៅពេលមេគុក និងយោធាពីរនាក់នោះមកនាំខ្លួនលោក តើលោកនៅភ្នំលៀប ឬនៅមន្ទីរសន្តិសុខនោះ? ឆ:15៖គឺខ្ញុំនៅក្នុងមន្ទីរសន្តិសុខនោះ"]។

574 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នូ ខាំ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ **D219/583** ឆ:50 ["ពេលយើងទៅដល់គុកភ្នំត្រយ៉ូងគឺមានទ័ពខ្មែរក្រហមមកច្រើនកាន់កាំភ្លើងជ្រោងច្រាង"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92** ឆ:19-20 [ដែលនិយាយថាគាត់បានឃើញយោធាប្រដាប់អាវុធប្រហែល ១០ នាក់ស្លៀកពាក់ពាក់នៅត្រង់ជើងភ្នំទ្រយោងនៅពេលគាត់បានមកដល់ក្នុងឆ្នាំ ១៩៧៨]។

575 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/127** ឆ:53 ["នៅពេលព្រឹក... ខ្ញុំឃើញយោធាប្រដាប់អាវុធចំនួន៤ទៅ៥នាក់ យាមពួកគេ [អ្នកទោស៣០នាក់]"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី (សូ ឡាង) ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/579**, EN ERN 01166381 ["គុកនេះយាមដោយទាហានពីតំបន់ ៥ និងទាហានជាច្រើនក្នុងចំណោមពួកគេត្រូវបានពង្រាយនៅភ្នំទ្រយោង"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:86-87 [ដែលនិយាយថាមានទាហានប្រដាប់អាវុធចំនួនប្រហែល២០នាក់យាមនៅមន្ទីរសន្តិសុខភ្នំទ្រយោង]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/19** ឆ:27 ["នៅពេលថ្ងៃគេបញ្ចេញខ្ញុំឱ្យទៅបែនស្រូវដោយមានយោធាយាម"]។

576 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤៣ ឯកសារ **D119/30** ឆ:25 ["កងនីមួយៗមិនមានប្រធានកងទេ តែយោធាជាអ្នកគ្រប់គ្រងផ្ទាល់...ពេលព្រឹក ក្រោយប្រជុំរួចយោធាបាននាំពួកគេចេញទៅធ្វើការ"]។

577 *សូមមើលជាឧទាហរណ៍* ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តោ ពិនថង, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1075**, EN ERN 01144959។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:123-126 [ដែលនិយាយថាគាត់ត្រូវបានគេសួរចម្លើយចំនួន៥ ឬ ៦ ដោយទាហាននៅពេលគាត់នៅមន្ទីរសន្តិសុខភ្នំទ្រយោង]។

ដទៃឱ្យជីករណ្តៅកប់សាកសព[580] ។

១៥៤. សរុបសេចក្តីមក គ្មានអ្វីត្រូវសង្ស័យទេដែលថា មន្ទីរសន្តិសុខភ្នំទ្រយោងស្ថិតក្រោមសិទ្ធិអំណាចជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ ទុំ សឿន កម្មាភិបាលថ្នាក់តំបន់ ។ ក្នុងកាលៈទេសៈទាំងនេះ ដំណើររឿងរបស់ ទុំ សឿន ទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ទៅលើមន្ទីរសន្តិសុខនេះ ត្រូវតែបដិសេធចោល ដោយសារវាជាការបម្រើឱ្យផលប្រយោជន៍ផ្ទាល់ខ្លួនទាំងស្រុង និងត្រូវបានជំរុញដោយចេតនាមិនល្អយ៉ាងប្រាកដ ។ ក្នុងការសំអាងលើដំណើររឿងនេះ ដោយមិនអើពើពីឋានៈរបស់ ទុំ សឿន ជាជនសមគំនិត និងដោយការមិនស្វែងរកការពិត ដែលអាចឱ្យជឿជាក់បានពីផ្នែកសេសសល់ដទៃទៀតនៃភស្តុតាង សហព្រះរាជអាជ្ញាអន្តរជាតិមិនបានប្រុងប្រយ័ត្នជាចាំបាច់ក្នុងការស្វែងរកឱ្យឃើញការពិតឡើយ ។ វាមានភាពច្បាស់លាស់ដែលថាភស្តុតាងពុំបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច *ជាក់ស្តែង* ឬ *ស្របច្បាប់* ដូចត្រូវបានចោទប្រកាន់ ឬក៏មានភស្តុតាងណាមួយដែលអនុញ្ញាតឱ្យគេចាត់ទុកថា អ្នកស្រី អ៊ឹម ចែម ជា "អ្នកទទួលខុសត្រូវចំពោះ" មន្ទីរសន្តិសុខភ្នំទ្រយោង ឬ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅទីតាំង

---

578 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92** ឆ:31 ["យោធា ៣នាក់ បានមកដោះខ្នោះឱ្យពួកយើង"]។

579 *សូមមើលជាឧទាហរណ៍* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D5/1075**, EN ERN 01144959 [ដែលនិយាយថាទាហានយកអ្នកទោសទៅសម្លាប់នៅភ្នំទ្រយោងជារៀងរាល់យប់], កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:62 [ដែលរៀបរាប់អំពីការសម្លាប់អ្នកទោសនៅ មន្ទីរសន្តិសុខភ្នំទ្រយោង ភ្លាមៗបន្ទាប់ពីវៀតណាមចូលមកដល់៖ "តា សឿន ជាអ្នកបញ្ជាឱ្យសម្លាប់ ហើយមានយោធា ៣០ នាក់ជាអ្នកវ៉ៃសម្លាប់អ្នកទោសទាំងនោះ"]។

580 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92** ឆ:31 ["យោធា ៣ នាក់ បានមកដោះខ្នោះឱ្យពួកយើង។ ខ្ញុំ និងសាមុន ត្រូវបានយោធាទាំង៣នាក់នោះ ប្រើទៅជីកអន្លង់ធំដើម្បីកប់សាកសពមនុស្ស ៧ នាក់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:60 [នៅពេលនោះគឺវៀតណាមជិតចូលមកដល់ ដូច្នេះហើយត្រូវបញ្ចេញអ្នកទោសទាំងអស់ចេញ។ គេបានបញ្ជាឱ្យមនុស្សប្រាំនាក់ ក្នុងនោះមានខ្ញុំដែរ ទៅជីករណ្តៅនៅម៉ោង១២យប់"] ឆ:62 [ដែលរៀបរាប់អំពីការសម្លាប់អ្នកទោសនៅ មន្ទីរសន្តិសុខភ្នំទ្រយោង ភ្លាមៗបន្ទាប់ពីវៀតណាមចូលមកដល់៖ "តា សឿន ជាអ្នកបញ្ជាឱ្យសម្លាប់ ហើយមានយោធា៣០នាក់ជាអ្នកវាយសម្លាប់អ្នកទោសទាំងនោះ"]។

នោះឡើយ ។

### ii. អ្នកស្រី អ៊ីម ចែម មិនបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលមានសភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដែលត្រូវបានចោទថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោងទេ

១៥៥. ក្នុងកថាខណ្ឌនានាខាងក្រោម[581] ក្រុមការពារក្តីសូមលើកឡើងអំពីឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទមកលើអ្នកស្រី អ៊ីម ចែម ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំទ្រយោង និងដែលសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញក្នុងដីកាសន្និដ្ឋានស្ថាពរ ។ អំណះអំណាងប៉ាតណាប៉ាតណឺមួយចំនួនទាក់ទងនឹងការធ្វើទារុណកម្ម និងការបំពានផ្លូវភេទនៅមន្ទីរសន្តិសុខភ្នំទ្រយោង[582] ពុំស្ថិតនៅក្នុងវិសាលភាពនៃបទចោទមកលើអ្នកស្រី អ៊ីម ចែម ទេ ហេតុដូច្នេះ យើងខ្ញុំនឹងមិនលើកឡើងក្នុងចម្លើយតបនេះឡើយ ។ ក្នុងការឆ្លើយតប ក្រុមការពារក្តីប្រកាន់យកវិធីសាស្ត្រប្រយ័ត្នប្រយែងរបស់ចៅក្រម Bohlander ដើម្បីធ្វើការវាយតម្លៃលើភស្តុតាង[583] ។

១៥៦. ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិមកលើអ្នកស្រី អ៊ីម ចែម ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំទ្រយោង ចាក់ឬសគល់ក្នុងអំណះអំណាងដែលថា អ្នកស្រីបានទទួលខុសត្រូវលើមន្ទីរសន្តិសុខនេះ[584] ដោយ "បានពង្រីកជាបន្តបន្ទាប់ ដើម្បីដាក់អ្នកទោស *រាប់ពាន់*នាក់ ក្នុងអំឡុងពេលធ្វើប្រតិបត្តិការ"[585] និងដែលក្រុមគ្រួសាររបស់កម្មាភិបាលភូមិភាគពាយព្យ *ជាច្រើន* ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ត្រូវបានចាប់ខ្លួន និងចាប់ដាក់ឃុំ[586] ។ ចាប់ពីចំណុចនោះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា មានអ្នកទោស*រាប់ពាន់*នាក់ "បានស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺ

---

581 ចម្លើយតប នៅកថាខណ្ឌ ១៥៧-៨៦។

582 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០៨-១១។

583 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣១។

584 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦។

585 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០០ (សេចក្តីបញ្ជាក់បន្ថែម)។

586 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៧។

និងធ្វើការធ្ងន់"[587] និងថាមានមនុស្ស*រាប់ពាន់*នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង[588] ។ អំណះអំណាងដែលគ្មានភស្តុតាងសំអាងទាំងនេះ នឹងត្រូវលើកឡើងទៅតាមលំដាប់លំដោយដូចខាងក្រោម ។

<u>ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងការឃុំឃាំងអ្នកទោសរាប់ពាន់នាក់ នៅមន្ទីរសន្តិសុខភ្នំទ្រយោង</u>

១៥៧. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានចេតនាដកហូតសេរីភាពបុគ្គល[589] និងបានបញ្ជាឱ្យចាប់ខ្លួន និងឃុំឃាំងអ្នកទោស*រាប់ពាន់នាក់* នៅមន្ទីរសន្តិសុខភ្នំទ្រយោង[590] រួមទាំងសមាជិកគ្រួសារនៃកម្មាភិបាលភូមិភាគពាយព្យ*មួយចំនួនធំ*ដែលពួកគេក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរស-២១[591] ។ ទីមួយ វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការវាយតម្លៃនូវចំនួនអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង គឺខុសពីវិធីសាស្ត្របែបសត្យានុម័តនានាក្នុងការវាយតម្លៃលើភស្តុតាង និងខុសពីវិធីសាស្ត្រលើកឡើងដោយចៅក្រម Bohlander[592] ។ ទីពីរ ដូចដែលភស្តុតាងបង្ហាញយ៉ាងជាក់ស្តែង ក្នុងមុខតំណែងអ្នកស្រីជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម ពុំមានសិទ្ធិអំណាច*ស្របច្បាប់* ឬ *ជាក់ស្តែង* ដើម្បីបញ្ជាឱ្យឃុំឃាំងអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ[593] ។

---

587 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០៥។

588 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២។

589 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៦៧។

590 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦, ១៩៩-២០០។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៦៤-៦៦។

591 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៧។

592 *សូមមើល សំណុំរឿង អោ អាន និងអ្នកដទៃ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ ២៤-២៦។

593 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៦២-៦៨។

១៥៨. វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះការពិពណ៌នាលើដំណើររឿងចំនួន ២០ ដែលនិយាយអំពីចំនួនអ្នកទោស គឺជាការជ្រើសដោយអន្លើៗតាមតែចិត្តខ្លួនចង់បាន ពោលគឺ ការសំអាងលើដំណើររឿងចំនួន ៥ ដែលមានលក្ខណៈបំផ្លើសបំផុត (ក្នុងចំណោម ២០) ដើម្បីគាំទ្រអំណះអំណាងដែលថាមានមនុស្ស *រាប់ពាន់នាក់* ត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង[594] ។ មានដំណើររឿងចំនួន ១៤ ក្នុងចំណោមដំណើររឿងនៅសេសសល់ គឺជាដំណើររឿងដែលគប្បីត្រូវជ្រើសរើស គឺ៖ ដំណើររឿងដែលបង្ហាញ ថាមានអ្នកទោសចន្លោះពី ១០០ ទៅជាចំនួនអតិបរមា គឺ ១.០០០ នាក់[595] ។

---

594 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៧) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជិម ជុំ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **D219/149** ឆ:37។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/318** ឆ:55។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/153** ឆ:21។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D219/567** ឆ:79។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/51** ឆ:26។

595 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៧) *ដែលយោងទៅលើ* ចម្លើយរបស់ យក់ នាម ដោយ ក.ស.ព ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ **D1.3.11.69**, EN ERN 00210575 ["ខ្ញុំគិតមានរហូតដល់១ពាន់នាក់ ។ *មិនលើស១ពាន់នាក់ទេ*" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:31 [ខ្ញុំឃើញមានអ្នកទោសច្រើនណាស់ *ប្រហែលជា១ពាន់នាក់*] (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ **D219/583** ឆ:52 ["មួយគុកមានប្រហែល៣៥០ទៅ៤០០នាក់។ អ្នកទោសទាំងអស់ប្រហែលពី៥០០ ទៅ១០០០នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ *សំណុំរឿង នួន ជា និងអ្នកដទៃ* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី (សក្ខីកម្មសាក្សី ឈិត យឿក) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/494.1.7**, EN ERNs 01131284-85 ["ចាប់ពីដែលខ្ញុំបើកឱ្យ ... រហូតទល់នឹងវៀតណាមចូល តែមនុស្សដែលតាមទូទាត់ក្នុងអង្គរហ្នឹង ក៏មិនលើសពី *៦០០* នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ ប្រតិចារឹកនៃបទសម្ភាសន៍ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.9**, EN ERN 01136964 ["អ្នកដែលរស់នៅហ្នឹងបែបខ្ទង់បីបួនរយនាក់ ទាំងកងចល័តខ្ញុំ ទាំងកម្លាំងប្រជាជនដែលទើបបញ្ជូនទៅហ្នឹង" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERN 01072599 ["អ្នកទោសធ្ងន់នៅទីនោះ មានប្រហែល ៥ ទៅ៦ នាក់ ។ អ្នកទោសស្រាលគឺមកទាំងគ្រួសារ ហើយមានប្រហែល ៥០០នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ

១៥៩. ជំនួសឱ្យការសំអាងលើដំណើររឿងទាំង១៤នេះ ឬធ្វើការពន្យល់ពីមូលហេតុអ្វីដែលដំណើររឿងដែលស្ថិតក្នុងភាពស៊ីសង្វាក់ជាងទាំងនេះត្រូវបានច្រានចោល សហព្រះរាជអាជ្ញាអន្តរជាតិបែរជាប៉ុនប៉ងស្វែងរកផលប្រយោជន៍ពីដំណើររឿងទាំង៥ ដែលធាតុពិតមិនមែនជាភស្តុតាងដែលអាចផ្តល់ការគាំទ្រសូម្បីតែបន្តិច ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើសាក្សីម្នាក់ដែលផ្តល់ភស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្មមួយ ដែលទីតាំងនោះមិនស្ថិតក្នុងវិសាលភាពនៃបទចោទប្រកាន់[596] និងភស្តុតាងពីសាក្សីម្នាក់ដែលបានបង្ហាញយ៉ាងច្បាស់ថា តាមពិតគាត់មិនបានជាប់ឃុំ

---

D119/159 ឆ:49 ["អ្នកទោសនៅភ្នំទ្រយោងមានប្រហែល ៥០០ នាក់ ហើយ អ្នកយាមមានចំនួនប្រហែល ២០ នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន យ៉េង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/129 ឆ:16 ["មានអ្នកទោសរាប់រយនាក់ ប៉ុន្តែខ្ញុំមិនដឹងពីចំនួនពិតប្រាកដទេ" (សេចក្តីបញ្ជាក់បន្ថែម)]; កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ឯកសារ D119/30 ឆ:33 [យោងទៅរកចំនួនមនុស្សធ្វើការនៅទីនោះ "រាប់រយនាក់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D106/6 ឆ:31 ["ខ្ញុំពិបាកនឹងប៉ាន់ស្មានចំនួនអ្នកទោសពិតប្រាកដណាស់ តែជាទូទៅនៅពេលណាមួយនោះ គឺមានចំនួនអ្នកទោសពី ២០០ ទៅ ៣០០ នាក់" (សេចក្តីបញ្ជាក់បន្ថែម)] ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ឯកសារ D119/88 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ:20 ["ពេលខ្ញុំស្នាក់នៅទីនោះ មានអ្នកទោសមិនដល់១០០នាក់ទេ។ ក្រោយពេលខ្ញុំចេញ មានឡានដឹកអ្នកទោសចូលច្រើន ហើយគេសង់ផ្ទះឱ្យអ្នកទោសស្នាក់នៅ។ តាមខ្ញុំស្មានអ្នកទោសពេលនោះមានចំនួនពីជាង១០០ ទៅ២០០នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ កិច្ចសម្ភាសន៍ SOAS/HRW ជាមួយ គៀម នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ ឯកសារ D1.3.11.20, EN ERN 00211886 ["អ្នកទោសមាន២ប្រភេទ៖ ស្រាល និង ធ្ងន់។ យើងត្រូវគេដាក់ឱ្យនៅដាច់ពីអ្នកទោសធ្ងន់។ មានអ្នកទោសស្រាលជាង១០០នាក់ ខ្លះគ្រួសារទាំងមូល...ខ្ញុំមិនប្រាកដថាមានអ្នកទោសប៉ុន្មានទេ ពីព្រោះយើងនៅដាច់ពីគ្នា" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400 ឆ:94-95 ["រោងហ្នឹងសម្រាប់អ្នកទោសធ្ងន់ មាន៧០នាក់ ហើយអ្នកទោសស្រាលមានច្រើន។ ...ប្រហែលជា៨០នាក់។ ខ្ញុំស្មានមិនបានទេអ្នកទោសស្រាលនៅឆ្ងាយពីអ្នកទោសធ្ងន់។ គេខ្លាចច្រឡំ"។ (សេចក្តីបញ្ជាក់ បន្ថែម)]។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/127 ឆ:32 ["ខ្ញុំមិនអាចស្មានបាន"] ឆ:52 ["ខ្ញុំឃើញមានអ្នកទោសស្រាលធ្វើការតាមក្រុមផ្សេងៗ ហើយមានចំនួនរាប់រយនាក់ តែមិនដល់ពាន់នាក់ទេ"]។

596 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៧) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/174 ឆ:58 [សាក្សីធ្វើការនៅកងចល័តភូមិនៅព្រះនេត្រព្រះ និងត្រូវបានគេដាក់ឃុំនៅចម្ការខ្នុរ៖ "ខ្ញុំមិនដឹងចំនួនច្បាស់ទេ ប៉ុន្តែនៅពេលខ្ញុំទៅដល់ទីនោះ គឺមានអ្នកទោសប្រហែល ៤០០ ទៅ ៥០០ នាក់"]។

នៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ[597] ។ សហព្រះរាជអាជ្ញាអន្តរជាតិអនុវត្តវិធីសាស្ត្រស្រដៀងនេះក្នុងការអះអាងថា *ក្រុមគ្រួសាររបស់*កម្មាភិបាលភូមិភាគពាយព្យ *មួយចំនួនធំ* ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង[598] ។ ជំនួសឱ្យការសំអាងលើភស្តុតាងពាក់ព័ន្ធ ឬភស្តុតាងផ្ទាល់ពីសមាជិកគ្រួសារដែលត្រូវបានឃុំឃាំង សហព្រះរាជអាជ្ញាពឹងផ្អែកលើសាក្សីពីររូបផ្សេងទៀត ដែលពុំត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ[599] ។

១៦០. លើសពីនេះ ប្រសិនបើអំណះអំណាងក្រោយមកនេះអាចជឿជាក់បានវិញ ភស្តុតាងអាចត្រូវបានរំពឹងថាអាចនឹងបញ្ជាក់បាន ឧទាហរណ៍ករណីអ្នកស្រី ជៀម គិន ដែលជាអតីតប្រពន្ធរបស់ *តា* វ៉ាល់ (ប្រធានកងចល័តតំបន់៥ រហូតដល់ពេលគាត់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧)[600] គឺស្ថិតក្នុងចំណោមសមាជិកគ្រួសារកម្មាភិបាលភូមិភាគពាយព្យ ដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ។ ប៉ុន្តែភស្តុតាងមិនបានបង្ហាញថា អ្នកស្រី ជៀម

---

[597] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០០ (ជើងទំព័រ ៩៩៧) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:33។ *ប៉ុន្តែសូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/30** ឆ:26-27 [ដែលនិយាយថាគាត់ពុំត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ឡើយ និងបានត្រឹមតែស្នាក់នៅក្បែរភ្នំនេះប៉ុណ្ណោះ]។

[598] *ជាឧទាហរណ៍* ក្រុមការពារក្តីកត់សម្គាល់ឃើញថា ហង់ ហោន បាននិយាយអំពីឈ្មោះ "ឈាម" ប្រពន្ធរបស់កម្មាភិបាលភូមិភាគពាយព្យ ដែលត្រូវបានបញ្ជូនទៅ មន្ទីរសន្តិសុខភ្នំទ្រយោង។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **D219/175** ឆ:32។ ក្រុមការពារក្តីពុំអាចរកឃើញការស្តាប់ចម្លើយរបស់គាត់ក្នុងសំណុំរឿង ០០៤/១ ឡើយ ហើយសហព្រះរាជអាជ្ញាអន្តរជាតិក៏ពុំដែលបានស្នើសុំបំពេញកិច្ចស៊ើបសួរត្រង់ប្រការនោះដែរ។

[599] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៧៧ (ជើងទំព័រ៨៩៧) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **D219/175** ឆ:31 [ដែលមិននិយាយអំពីថាតើគាត់ដឹងដោយវិធីណាថាសមាជិកគ្រួសារកម្មាភិបាលភូមិភាគពាយព្យត្រូវបានបញ្ជូនទៅ មន្ទីរសន្តិសុខភ្នំទ្រយោង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **D119/144** ឆ:37 [ដែលមិនផ្តល់ភស្តុតាងពាក់ព័ន្ធនឹង មន្ទីរសន្តិសុខភ្នំទ្រយោង]។

[600] *សូមមើល* បញ្ជីកាត់ទោសនៅមន្ទីរ ស-២១, ការសម្លាប់ដែលមិនត្រូវបានចុះបញ្ជីនូវអ្នកទោសចំនួន ៣៩ នាក់ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ **D6.1.1128**, EN ERN 00193556។

គិន ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ[601] ។ លើសពីនេះ អ្នកស្រីមិនទាំងដែលបានឮឈ្មោះអ្នកស្រី អ៊ឹម ចែម រហូតដល់*ក្រោយ* ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[602] ។

១៦១. ការវិភាគដ៏ប្រយ័ត្នប្រយែងនូវភស្តុតាងរបស់សាក្សីផ្ទាល់ភ្នែកបង្ហាញឱ្យឃើញថា ចំនួនសរុបនៃអ្នកជាប់ឃុំឃាំង មានចំនួនមិនដល់១០០នាក់ ឬមិនលើសពី ៥០០នាក់ឡើយ[603] ។ ទុំ សឿន បានចង្អុលបង្ហាញថា "ប្រជាជនដែលរស់នៅហ្នឹងបែបខ្ទង់បីបួនរយនាក់ ទាំងកងចល័ត [របស់គាត់] ទាំងកម្លាំងប្រជាជនដែលទើបបញ្ជូនទៅហ្នឹង"[604] ។ ស្រដៀងនេះដែរ សាក្សី គិម យ៉េត ដែលមានពេលមួយត្រូវបានចាត់តាំងឱ្យរាប់ចំនួនអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងជាអ្នកដែលបានស្នាក់នៅទីនោះចំនួនមួយឆ្នាំរហូតទំពវៀតណាមចូលដល់[605] បាននិយាយថា "ជាទូទៅ ក្នុងពេល

601 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/100** ឆ:8 ឆ:23-24 ឆ:33 [ដែលនិយាយថា បន្ទាប់ពីពេលគេចាប់ប្តីរបស់គាត់ រូបគាត់ត្រូវបានគេចាប់និងឃុំក្នុងគុកមួយនៅស្វាយ] ឆ:35-36 [ដែលនិយាយថាគាត់មិនដែលបានទៅភ្នំល្មៀប និងពុំដឹងអំពីមន្ទីរសន្តិសុខភ្នំទ្រយោង]។

602 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/100** ឆ:38 ["ខ្ញុំមិនដែលស្គាល់ និងឮឈ្មោះ យាយ ចែម ទេ កាលជំនាន់ខ្មែរក្រហម"]។

603 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/88** ឆ:20 [កៅ ផាន ដឹកថ្មទៅភ្នំនោះ និងបានស្នាក់នៅ មន្ទីរសន្តិសុខភ្នំទ្រយោង: "ពេលខ្ញុំស្នាក់នៅទីនោះ មានអ្នកទោសមិនដល់ ១០០ នាក់ទេ។ ក្រោយពេលខ្ញុំចេញ...តាមខ្ញុំស្មានអ្នកទោសពេលនោះមានចំនួនពីជាង១០០ទៅ២០០នាក់" (សេចក្តីបញ្ជាក់បន្ថែម)]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆ:76-77 ឆ:94-95 [ប៊ូ តួក ជាអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងបាននិយាយថាមានអ្នកទោសធ្ងន់ចំនួន៧០នាក់ អ្នកទោសស្រាលចំនួន ៨០ នាក់]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:24 [ភួន ស៊ុនទី ជាអ្នកទោស និងក្រោយមកត្រូវបានតែងតាំងជាអ្នកយាម៖ "តា សឿន បានកោះហៅអ្នកទោសទាំងអស់ប្រហែល ៣០០ នាក់ ឱ្យមកប្រជុំ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/159** ឆ:49 [ឡេង វ៉ុង ជាអ្នកទោសចំនួន ១ ខែ៖ "នៅភ្នំទ្រយោងមានប្រហែល ៥រយនាក់ ហើយអ្នកយាមមានចំនួនប្រហែល ២០ នាក់"]។

604 ប្រតិចារឹកនៃបទសម្ភាសន៍ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.9**, EN ERN 01136964។

605 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆ:31។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆ:44-49។

មួយ មានអ្នកទោសប្រហែលពី ២០០ ទៅ ៣០០ នាក់"[606] ។

១៦២. ផ្ទុយនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[607] ភស្តុតាងនេះពុំចាប់ផ្ដើមបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច *ស្របច្បាប់* ឬ*ជាក់ស្ដែង* ពេញលេញ ដើម្បីបញ្ជាឱ្យចាប់ដាក់ឃុំ ឬគ្រប់គ្រងអ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ ។ សាក្សី មូល អេង អតីតលេខាស្រុកបរិលក្នុងតំបន់៣ នៃភូមិភាគពាយព្យ[608] បានពន្យល់ថា ទាក់ទងនឹងការចាប់ខ្លួន គឺមានវិធានការដូចគ្នាត្រូវបានអនុវត្តនៅទូទាំងប្រទេស[609] ពោលគឺ លេខាស្រុកគ្មានអំណាចចាប់អ្នកណាក្នុងស្រុករបស់ពួកគាត់ឡើយ និងត្រូវរាយការណ៍ទៅកម្មាភិបាលតំបន់ជាមុនសិន[610] ។ យោងតាមសាក្សីរូបនេះបានឱ្យដឹងថា ពួកគាត់ "គ្មានសិទ្ធិសម្រេចលើបញ្ហាបែបនេះឡើយ"[611] ។

១៦៣. សូម្បីតែ ទុំ សឿន ក៏បានសារភាពថា គាត់ពុំបានដឹងថា អ្នកស្រី អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកត្រូវបានអនុញ្ញាតឱ្យចេញបញ្ជាចាប់ខ្លួន ឬបញ្ជូនទណាម្នាក់ទៅមន្ទីរសន្តិសុខភ្នំទ្រយោងដែរឬយ៉ាងណាទេ[612] ។ អង្គហេតុដែលមានសាក្សីជាច្រើនបាននិយាយថា ពួកគាត់មិនដែលបានឃើញអ្នកស្រី អ៊ឹម ចែម ជាអ្នកបញ្ជាឱ្យចាប់មនុស្ស ឬការមិនបានដឹងថាតើអ្នកស្រីមានសិទ្ធិអំណាចនេះឬយ៉ាងណានោះ គឺវាបានបញ្ជាក់នូវការពិតមួយក្នុងកម្រិតខ្ពស់ចំពោះភាពត្រឹមត្រូវនៃការពិពណ៌នាដោះ

---

606 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆ:31 ["ខ្ញុំនៅមន្ទីរនោះរហូតដល់វៀតណាមចូលមកគឺនៅប្រហែលជាមួយឆ្នាំ។ ខ្ញុំពិបាកនឹងប៉ាន់ស្មានចំនួនអ្នកទោសពិតប្រាកដណាស់ តែជាទូទៅ នៅពេលណាមួយនោះ គឺមានចំនួនអ្នកទោសពី ២០០ ទៅ ៣០០ នាក់"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆ:76 [បញ្ជាក់អះអាងចម្លើយមុន]។

607 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៤១, ១៤៤, ១៧៧, ២០០។

608 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294 ឆ36។

609 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:196។

610 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:194-96។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ១៣៩-៤២។

611 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/294** ឆ:198។

612 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:202។

បន្ទុកទាំងនេះ[613] ។

១៦៤. ជាងនេះទៀត បើទោះបីជាភស្តុតាងបានបញ្ជាក់ ឬបង្ហាញយ៉ាងគួរឱ្យជឿជាក់បានថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិបញ្ជាឱ្យមានការចាប់ខ្លួនក៏ដោយ ក៏រចនាសម្ព័ន្ធឋានានុក្រមដ៏តឹងរ៉ឹងនៃកម្ពុជាប្រជាធិបតេយ្យ រារាំងមិនឱ្យអ្នកស្រីចេញបញ្ជាឱ្យចាប់ខ្លួនកម្មាភិបាលដែលធ្វើប្រតិបត្តិការនៅថ្នាក់លើគាត់បានដែរ[614] ។ ក្នុងឋានៈជាលេខាស្រុកម្នាក់ អ្នកស្រី អ៊ឹម ចែម អាចនឹងមានសិទ្ធិត្រឹមតែ

613 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/103** ឆ:68 [ស៊ុម សល់ អ្នកយាមនៅមន្ទីរសន្តិសុខភ្នំទ្រយោង បាននិយាយថាគាត់មិនដែលឮថាអ្នកស្រី អ៊ឹម ចែម ជាអ្នកបញ្ជាឱ្យយកអ្នកទោសទៅ មន្ទីរសន្តិសុខភ្នំទ្រយោងឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:28 [ឈិត យឿក ដែលជាអ្នកគ្រប់គ្រងការងារសេដ្ឋកិច្ចនៃតំបន់ ៥ និងជាសាក្សីដែលដឹងច្រើនអំពីរចនាសម្ព័ន្ធរដ្ឋបាលបាននិយាយថា គាត់មិនដឹងថាតើអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចបញ្ជាឱ្យចាប់ខ្លួនមនុស្ស ឬយ៉ាងណាឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D101/1.2**, EN ERN 00751069 [តោ ពិនថង ដែលត្រូវបានចាប់ខ្លួនប្រហែលក្នុងឆ្នាំ១៩៧៨ និងត្រូវគេបញ្ជូនទៅ មន្ទីរសន្តិសុខភ្នំទ្រយោង ចំនួន៦ខែ មិនដែលឃើញអ្នកស្រី អ៊ឹម ចែម នៅ មន្ទីរសន្តិសុខភ្នំទ្រយោងឡើយ និងមិនដែលឮអំពីករណីដែលអ្នកស្រី អ៊ឹម ចែម បានបញ្ជាឱ្យមានការចាប់ខ្លួន ឬការសម្លាប់ឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:36 [អោម ហួន ដែលស្នាក់នៅជិតភ្នំទ្រយោង ពុំដឹងថានរណាបញ្ជាឱ្យចាប់ និងបញ្ជូនមនុស្សទៅ មន្ទីរសន្តិសុខភ្នំទ្រយោងឡើយ], ឆ:65 [និងមិនដែលឮអំពីអ្នកស្រី អ៊ឹម ចែម នៅពេលគាត់នៅភ្នំទ្រយោងឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣-១៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/455** ឆ:84 [សួរ ចាន់សារ៉េត ដែលបានចាប់មនុស្ស និងយកទៅភ្នំល្វៀបបានបញ្ជាក់គាត់ពុំដឹងបញ្ជាចេញពីណាមកទេ]។

614 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/33** ឆ:13 ["ការចាប់ខ្លួនត្រូវធ្វើឡើងពីថ្នាក់លើចុះមកថ្នាក់ក្រោម គឺពីភូមិភាគមកតំបន់ និងមកស្រុក។ ថ្នាក់ឃុំក៏អាចមានការចាប់ខ្លួនដែរ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:84 ["តាមខ្ញុំយល់ រចនាសម្ព័ន្ធបញ្ជាឱ្យចាប់មនុស្ស ឬធ្វើការងារអ្វីមួយគឺមានសំបុត្រចេញពីថ្នាក់ភូមិភាគ។ ភូមិភាគបញ្ជូនមកតំបន់ តំបន់បញ្ជូនមកស្រុក ស្រុកបញ្ជូនមកឃុំ ឃុំបញ្ជូនមកភូមិ ឬសហករណ៍ ដោយស្នើសុំឱ្យអ្នកគ្រប់គ្រងភូមិ ឬសហករណ៍នោះរកមនុស្សដែលគេចង់ចាប់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:39 ["ខ្ញុំឮតែពីថ្នាក់លើពេលគេចុះមកចាប់ខ្លួន តែខ្ញុំមិនដឹងថាថ្នាក់លើនោះត្រឹមកម្រិតណាទេ"]។ *សូមមើល* ជាទូទៅជាងនេះ សំណុំរឿង ០០២/០១, សាលក្រមជំនុំជម្រះ ឯកសារ **E313** នៅកថាខណ្ឌ ២៧០។

ការចេញបញ្ជាឱ្យចាប់ខ្លួនកម្មាភិបាលដែលឋិតក្នុងលំដាប់ថ្នាក់ប្រហាក់ប្រហែលនឹងអ្នកស្រី ឬអ្នកដែលមានឋានៈទាបជាងថ្នាក់ស្រុកតែប៉ុណ្ណោះ ។ ជាថ្មីម្តងទៀត ជាការបដិសេធសមហេតុផលមួយតបនឹងអំណះអំណាងជាទូទៅរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសិទ្ធិអំណាច ឬការប្រព្រឹត្តបទឧក្រិដ្ឋដូចត្រូវបានរងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ភស្តុតាងទាំងនោះ មិនបានកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់ ដែលបានធ្វើការនៅកម្រិតប្រហាក់ប្រហែលនឹងអ្នកស្រី ឬនៅថ្នាក់ក្រោមជាងអ្នកស្រីណាម្នាក់ដែលមានការប្រឈមនឹងការចាប់ខ្លួនឡើយ ។ ជាឧទាហរណ៍ ក្នុងអំឡុងពេលពេញរបបកម្ពុជាប្រជាធិបតេយ្យ គ្មានកម្មាភិបាលណាម្នាក់ក្នុងចំណោមកម្មាភិបាលខាងក្រោម ដែលមានមុខតំណែងប្រហាក់ប្រហែលនឹងអ្នកស្រី ឬក៏ថាមានកម្មាភិបាលថ្នាក់ក្រោមអ្នកស្រី អ៊ឹម ចែម ណាម្នាក់ត្រូវបានចាប់ខ្លួនឡើយ តួយ៉ាងរួមមានដូចជា៖ តឹក សួង ប្រធានឈ្លបឃុំភ្នំលៀប[615] សុខ គណៈប្រធានភូមិភ្នំលៀប[616] ឈឹម ផន សមាជិកគណៈឃុំព្រះនេត្រព្រះ[617] ពុំ ខូ សមាជិកគណៈស្រុកព្រះនេត្រព្រះ[618] ។

១៦៥. ភស្តុតាងតែមួយគត់ដែលភ្ជាប់អ្នកស្រី អ៊ឹម ចែម ទៅនឹងការបញ្ជាឱ្យចាប់ខ្លួន គឺផ្តល់ដោយសាក្សី

---

615 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **D219/575** ឆ:3 [ដែលនិយាយថា នៅពេលកម្មាភិបាលភូមិភាគនិរតីចូលមកដល់ គាត់ត្រូវបានដកចេញពីតំណែង និងធ្វើការតាមវាលស្រែជំនួសវិញ]។

616 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:77-80 [សាក្សីជាសមាជិកនៃគណៈឃុំព្រះនេត្រព្រះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបង្ហាញអត្តសញ្ញាណ សុខ កម្មាភិបាលពីភូមិភាគពាយព្យដែលជាប្រធានភូមិភ្នំលៀប ដែលមិនត្រូវបានចាប់ខ្លួន]។

617 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:27 [សាក្សីជាសមាជិកនៃគណៈឃុំព្រះនេត្រព្រះ និងនិយាយថាទាំងគាត់ និង ពុំ ខូ "នៅរស់ក្រោយពេលក្រុមភូមិភាគនិរតីចូលមកដល់"]។

618 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:33 ឆ:45 ឆ:56 [ដែលនិយាយថា គាត់ជាជំនួយការគណៈស្រុកព្រះនេត្រព្រះពីឆ្នាំ១៩៧៥ និងបន្ទាប់ពីកម្មាភិបាលនិរតីបានមកដល់ គាត់ត្រូវបានចាត់តាំងឱ្យមើលខុសត្រូវពលករនៅក្នុងស្រុកនេះ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D119/32** ឆ:27 [សាក្សីជាសមាជិកនៃគណៈឃុំព្រះនេត្រព្រះ និងនិយាយថាទាំងគាត់ និងពុំ ខូ "នៅរស់ក្រោយពេលក្រុមភូមិភាគនិរតីចូលមកដល់"]។

ធិប សំផាត់ ដែលអះអាងថាបានឃើញសំបុត្រមួយច្បាប់មានត្រាពណ៌ក្រហម និងត្រូវបានចោទថាមានហត្ថលេខារបស់អ្នកស្រី អ៊ឹម ចែម ត្រូវបាន ទុំ សឿន បង្ហាញឱ្យគាត់មើលនៅពេលសាក្សីរូបនេះទៅដល់មន្ទីរសន្តិសុខភ្នំទ្រយោង[619] ។ គ្មានលិខិតស្នាមប្រភេទនេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០៤/១ ឡើយ ។ សាក្សី គិម យ៉េត ដែលត្រូវបានចាប់ខ្លួនជាមួយនឹងសាក្សី ធិប សំផាត់ នាពេលនោះដែរ ពុំបានចងចាំអំពីហេតុការណ៍ដែលទាក់ទងនឹងលិខិតនេះទេ[620] ។ ខុសពីភស្តុតាងរបស់សាក្សី ធិប សំផាត់ ទុំ សឿន ខ្លួនឯងបាននិយាយថា អ្នកទោសដែលមកដល់មន្ទីរសន្តិសុខភ្នំទ្រយោង មិនមានឡើយលិខិតចាប់ខ្លួនពីអ្នកស្រី អ៊ឹម ចែម[621] ។ ទុំ សឿន បានបន្តទៀតថា៖ លិខិតនានាដែលចេញមកពីអ្នកស្រី អ៊ឹម ចែម ពុំមានហត្ថលេខារបស់អ្នកស្រីឡើយ[622] ហើយលិខិតទាំងនោះទៀតសោត និយាយតែពីសំណើសុំសម្ភារៈផ្គត់ផ្គង់ផ្សេងៗ[623] ។

១៦៦. ទោះបីជាដំណើររឿងគ្មានការបញ្ជាក់ការពិតរបស់សាក្សី ធិប សំផាត់ អាចផ្តល់ជាភស្តុតាងប្រាកដប្រជាបានមួយកម្រិតក៏ដោយ ក៏គ្មានអ្វីគាំទ្រដល់សាច់រឿងនេះដែរ ។ ជាការពិត ការយោងរបស់គាត់ស្តីពីត្រាពណ៌ក្រហមនៅលើសំបុត្រនោះ គឺជាភស្តុតាងអាចនឹងអន្ទងចិត្តឱ្យមានការជឿជាក់បានចំពោះករណីដែលថា បទបញ្ជាក្នុងលិខិតនេះ ជារបស់កម្មាភិបាលតំបន់៥ មិនមែនជាបញ្ជារបស់អ្នកស្រី អ៊ឹម ចែម ទេ ។ សាក្សី អ៊ុល ហឿន ដែលបានធ្វើការនៅស្រុកត្រាំកក់ ក្នុងភូមិភាគនិរតី[624] បាននិយាយថា លិខិតបញ្ជាឱ្យចាប់ខ្លួនដែលមានចំណារពណ៌ក្រហម គឺចេញមកពីថ្នាក់

---

619 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49 ឆ:**44។

620 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94 ឆ:**15។

621 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65 ឆ:**187។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/51,** ស-ឆ:118 [“នៅពេលដែលគេចាប់ខ្លួនម្តាយរបស់លោក និងលោក តើគេមានចេញលិខិតចាប់ខ្លួនដែរឬទេ? ឆ:18៖ អត់មានទេ”]។

622 កំណត់ហេតុនៃការតទល់មុខគ្នា(ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230,** EN ERN 01072598។

623 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230,** EN ERN 01072598-99។

624 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/34 ឆ:**5។

តំបន់[625] ដោយថ្នាក់ស្រុកគ្រាន់តែដើរតួនាទីបញ្ជូនបន្ត តែមិនមានសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចណាមួយឡើយ ។

> ជាឧទាហរណ៍ ខេត្តបញ្ជូនរបាយការណ៍ដែលមានចំណារទឹកប៊ិចពណ៌ក្រហមឱ្យចាប់នរណាម្នាក់ទៅស្រុក នោះស្រុកនឹងត្រូវបញ្ជូនរបាយការណ៍នោះបន្តទៅឃុំទៀត។ បន្ទាប់មក ឃុំបានចាប់ខ្លួនមនុស្សទាំងនោះទៅតាមចំណារទឹកប៊ិចពណ៌ក្រហមនោះ[626]។

១៦៧. សាក្សី ជុំ កាន់ អតីតលេខាឃុំភ្នំលៀប[627] បានបញ្ជាក់អះអាងថា ទោះបីជាគាត់បានទទួលលិខិតបញ្ជាឱ្យចាប់ខ្លួនតាមរយៈអ្នកស្រី អ៊ឹម ចែម ក៏ដោយ ក៏លិខិតទាំងនោះគ្មានហត្ថលេខារបស់អ្នកស្រី អ៊ឹម ចែម នោះទេ ប៉ុន្តែមានហត្ថលេខារបស់កម្មាភិបាលថ្នាក់តំបន់មួយរូបក្នុងចំណោមកម្មាភិបាលថ្នាក់តំបន់មួយចំនួនទៀត[628] ។

១៦៨. ជាចុងក្រោយ ប្រសិនបើក្រោយការពិនិត្យភស្តុតាងនេះទាំងមូលហើយនៅតែមានមន្ទិលណាមួយអំពីភាពមិនអាចជឿជាក់បានរបស់សាក្សី ធិប សំផាត់ ដែលនៅសេសសល់នោះ យើងចាំបាច់ត្រូវតែសម្គាល់ទុកថា៖ វាជាភស្តុតាងតែមួយគត់ដែលថា មានម្ដងនោះ អ្នកស្រី អ៊ឹម ចែម បានបញ្ជូនអ្នកទោសម្នាក់ទៅមន្ទីរសន្តិសុខភ្នំទ្រយោង ។ ត្រង់នេះមិនចាប់ផ្ដើមបង្ហាញអំពីលំនាំ ឬបង្ហាញអំពីសិទ្ធិអំណាចពិតប្រាកដ ឬទង្វើដែលពាក់ព័ន្ធនឹងការសម្រេចអំពី "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ ។ ភស្តុតាងរបៀបនេះ មិនអាចជាភស្តុតាងដែលបញ្ជាក់អំពីទង្វើជាប្រព័ន្ធនោះទេ ។ វាមិនអាចយកមកប្រើជំនួសឱ្យភស្តុតាងពាក់ព័ន្ធ ឬភស្តុតាងដែលមានតម្លៃបញ្ជាក់អំពីការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនោះទេ ហើយក៏មិនអាចចង្អុលបង្ហាញបានថា អ្នកស្រី អ៊ឹម ចែម បានគ្រប់គ្រង ឬឋិតនៅ

---

[625] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុល ហឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/34** ឆ:24 ឆ:26។

[626] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុល ហឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/34** ឆ:24។

[627] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:25, ឆ:29, និង ឆ:42។

[628] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:76។

ក្បែរនឹងប្រព័ន្ធមួយ ពោលគឺប្រព័ន្ធដែលបានប្រើក្នុងការបញ្ជូនអ្នកទោសទៅកាន់មន្ទីរសន្តិសុខភ្នំទ្រយោងទៅកើតដែរ ។

<u>ការទម្លាក់កំហុសលើអ្នកស្រី អ៊ឹម ចែម ពីការជាប់ពាក់ព័ន្ធនឹងការស្លាប់របស់អ្នកទោសចំនួនរាប់ពាន់នាក់ ដោយសារភាពអត់ឃ្លាន ជំងឺ និងធ្វើការហួសកម្រិតនៅមន្ទីរសន្តិសុខភ្នំទ្រយោង</u>

១៦៩. ដោយផ្អែកលើអំណះអំណាងមិនត្រឹមត្រូវ ដែលថាមន្ទីរសន្តិសុខភ្នំទ្រយោង មានអ្នកជាប់ឃុំឃាំងចំនួន*រាប់ពាន់នាក់*[629] សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា មានអ្នកទោស*រាប់ពាន់នាក់* "បានស្លាប់ដោយសារការអត់ឃ្លាន ជំងឺ និងធ្វើការហួសកម្រិត"[630] និងព្យាយាមដាក់ការទទួលខុសត្រូវមកលើអ្នកស្រី អ៊ឹម ចែម ចំពោះការស្លាប់ទាំងនេះ[631] ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិពុំបានដកស្រង់ភស្តុតាងដ៏គួរឱ្យជឿជាក់បានណាមួយ ដើម្បីគាំទ្រអំណះអំណាងទាំងនេះ[632] ។ ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិពុំបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានតួនាទីណាមួយទាក់ទងនឹងអ្នកទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាបានស្លាប់នោះ[633] ។

១៧០. តាមការពិនិត្យក្នុងកម្រិតខ្ពស់បំផុតបានបង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងលើដំណើររសាច់រឿងត្រឹមតែមួយក្តាប់តូច ដែលសាច់រឿងទាំងនោះ មានការបញ្ជាក់អំពីចំនួនអ្នកទោសដែលត្រូវបានចោទថាបានស្លាប់ ។ សំខាន់បំផុត សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើសាក្សីមួយចំនួនដែលមិនបានផ្តល់តួលេខជាក់លាក់ពាក់ព័ន្ធនឹងចំនួនមនុស្សស្លាប់ដែលត្រូវបានចោទ[634] ឬ

---

629 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦ និង ១៩៩-២០០។ *ប្រៀបធៀបនឹង* ចម្លើយតប នៅកថាខណ្ឌ ១៥៧-៦១។

630 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០៥។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥៣, ៤៦៥-៦៦, ៤៨៤, ៤៩៥។

631 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ១៩៦, ១៩៨, ២០៥។

632 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧០-៧២។

633 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧៣។

634 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២០៥ (ជើងទំព័រ ១០៤៣) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/7** ឆ:26 ["អ្វីដែលខ្ញុំចាំបាន គឺមានតែអ្នកទោសស្លាប់ដោយ

ផ្ទុយទៅវិញ ធ្វើការបង្ហាញភស្តុតាងដែលខ្វះការយល់ដឹងពាក់ព័ន្ធនឹងបញ្ហាចោទ[635] ។

១៧១. សាក្សីទាំងឡាយដែលបញ្ជាក់អំពីចំនួនអ្នកស្លាប់ រួមមានសាក្សី ធិប សំផាត់, ឡេង រ៉ុង និង ភួង ផៃ[636] ។ សាក្សីពីររូប គឺ ធិប សំផាត់ និង ឡេង រ៉ុង បានគូសបញ្ជាក់ថា ជាមធ្យម មានអ្នកទោសចំនួន២នាក់បានស្លាប់ដោយសារភាពអត់ឃ្លានក្នុងមួយថ្ងៃ[637] ចំណែក ភួង ផៃ បានកត់សម្គាល់ថា

---

សារបាក់កម្លាំង និងអត់អាហារ"]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ុម សល់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D123/1/1.67**, EN ERN 00945539 ["សៈ តើលោកបានឃើញមនុស្សស្លាប់នៅភ្នំទ្រយោងឬទេ? ឆៈ បានឃើញ។ ខ្លះស្លាប់ដោយជំងឺ និងអត់អាហារ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/103** ឆ:44-46។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដន គំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/318** ឆ:64។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/130** ឆ:47។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ម៉ក់ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1202**, EN ERN 01143628។

635 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២០៥ (ជើងទំព័រ១០៤៣) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/103** ឆ:44-46 [ត្រង់ ឆ:46 សាក្សីនិយាយថា "ខ្ញុំមិនដឹងចំនួនអ្នកទោសដែលស្លាប់ឡើយ"]។

636 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២០៥, (ជើងទំព័រ ១០៤៣) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:57។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង រ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/230** ឆ:21-22។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភួង ផៃ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D5/998**, EN ERN 01190851។ *ប្រៀបធៀបនឹង សំណុំរឿង អោ អាន និងអ្នកដទៃ,* 004/07-09-2009-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ២៦ ["ដោយគិតអានុភាពនៃគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ខ្ញុំនឹងប្រើប្រាស់តែចំនួនទាបបំផុតដែលបានគណនាតាមភស្តុតាង ហើយមិនប្រើប្រាស់ចំនួនមធ្យមភាគរវាងចំនួនទាបបំផុត ជាមួយនឹងចំនួនខ្ពស់បំផុតឡើយ នៅពេលដែលកំណត់ចំនួនជនរងគ្រោះសម្រាប់គោលបំណង និងបរិបទនៃដីកាដំណោះស្រាយ"]។

637 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ: 57 ["បើយើងគិតជាមធ្យមអ្នកទោសដែលស្លាប់ដោយអត់បាយយ៉ាងហោចណាស់២នាក់ក្នុង១ថ្ងៃ១យប់ ហើយចំពោះអ្នកដែលគេយកទៅសម្លាប់ខ្ញុំមិនដឹងនោះទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង រ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/230** ឆ:21 ["ខ្ញុំបានឃើញគេយកអ្នកទោសដែលស្លាប់នៅក្នុងរោងនោះចេញទៅក្រៅតែ

មានអ្នកទោសចំនួន ៣ ទៅ ៥ នាក់បានស្លាប់ក្នុងមួយថ្ងៃ ដោយមិនបានបញ្ជាក់អំពីមូលហេតុនៃការស្លាប់កើតឡើងដូចម្តេចឡើយ[638] ។ ការគណនាត្រង់ៗ បង្ហាញថា ដំណើរសាច់រឿងរបស់ពួកគាត់ ពុំគាំទ្រការចោទប្រកាន់ផ្តេសផ្តាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ ។ ការប៉ានស្មានរបស់សាក្សី ធិប សំផាត់ គឺបានមកពីការស្នាក់នៅប្រមាណ៤ ខែរបស់គាត់នៅមន្ទីរសន្តិសុខភ្នំទ្រយោង[639] ហើយការស្មានពីចំនួនអ្នកស្លាប់ជាអតិបរមា គឺមានចំនួន ២៤០ នាក់ ។ ជាងនេះទៀត សាក្សី ឡេង វ៉ុង បានចំណាយពេលតិចជាងមួយខែនៅមន្ទីរសន្តិសុខភ្នំទ្រយោង[640] បានធ្វើការប៉ាន់ស្មាននូវចំនួនអ្នកស្លាប់ថាមានតិចជាង ៦០ នាក់[641] ។ និយាយម្យ៉ាងទៀត ភាពសមហេតុផលនៃដំណើរសាច់រឿងរបស់ពួកគាត់ ប្រសិនត្រូវបានទទួលយកទៅពិចារណា អាចនឹងបង្ហាញថាចំនួនអ្នកទោសបានស្លាប់ក្នុងរយៈពេលពាក់ព័ន្ធជាអតិបរមា គឺមានចំនួនមួយពាន់នាក់ ។

---

ប៉ុណ្ណោះ។ អ្នកទោសនៅក្នុងរោងនោះគឺស្លាប់ជារៀងរាល់ថ្ងៃគឺអ្នកទោសស្លាប់ពី២ទៅ៣នាក់ក្នុងមួយថ្ងៃ"]។ ស-ឆ:22 ["ស៖ តើអ្នកទោសដែលស្លាប់នោះគឺស្លាប់ដោយសារតែការធ្វើទារុណកម្ម ការបង្អត់អាហារ ឬក៏ការធ្វើការហួសកម្លាំង? ស:22៖ អ្នកទោសភាគច្រើនគឺស្លាប់ដោយសារការអត់អាហារ"]។

638 *សូមមើល* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភួង ផៃ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D5/998**, EN ERN 01190851 ["រៀងរាល់ថ្ងៃ ខ្ញុំឃើញមនុស្សស្លាប់ចន្លោះពី៣ទៅ៥នាក់"]។

639 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/8, ស-ឆ:**22 ["ស៖ តើលោកនៅចាំថាពេលណាដែលលោកត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខនោះ? ឆ:22៖ ខ្ញុំចាំមិនច្បាស់ទេ។ តែគ្រាន់តែនៅចាំបានថាខ្ញុំនៅទីនោះប្រហែល៤ខែ មុនពេលវៀតណាមចូលមកដល់"]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49 ឆ:**33 ["ខ្ញុំត្រូវបានគេបញ្ជូនខ្ញុំទៅដាក់គុកប្រហែលជាដើមខែ ៨ ឆ្នាំ ១៩៧៨ រហូតដល់វៀតណាមចូលមកដល់"]។

640 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/159, ស-ឆ:**46 [" ស៖តើលោកជាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោងអស់រយៈពេលប៉ុន្មានដែរ? ឆ:46៖ ខ្ញុំជាប់នៅភ្នំទ្រយោងជិត១ខែ ខ្វះបីថ្ងៃ... ក្រោយពីគេដោះលែងពីភ្នំទ្រយោងបានមួយសប្តាហ៍របបខ្មែរក្រហមបានបែក"]។

641 *ប្រៀបធៀបនឹង សំណុំរឿង អោ អាន និងអ្នកដទៃ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤ របស់ អោ អាន ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D244/1** នៅកថាខណ្ឌ២៦ ["ដោយគិតអានុភាពនៃគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ខ្ញុំនឹងប្រើប្រាស់តែចំនួនទាបបំផុតដែលបានគណនាតាមភស្តុតាង ហើយមិនប្រើប្រាស់ចំនួនមធ្យមភាគរវាងចំនួនទាបបំផុត ជាមួយនឹងចំនួនខ្ពស់បំផុតឡើយនៅពេលដែលកំណត់ចំនួនជនរងគ្រោះសម្រាប់គោលបំណង និងបរិបទនៃដីកាដំណោះស្រាយ"]។

១៧២. ស្រដៀងគ្នានេះ ការស្ទង់មើលរបស់ ភួង ផៃ អំពីចំនួនមនុស្សស្លាប់ ៣ នាក់ក្នុងមួយថ្ងៃ គឺវាស្មើនឹងមានមនុស្សស្លាប់មួយពាន់នាក់ នៅក្នុងអំឡុងដើមឆ្នាំ១៩៧៨ រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។ ទោះបីជាចំនួនទាំងនេះនៅតែជាសោកនាដកម្មផ្ទាល់ខ្លួនមួយ តំណាងឱ្យសោកនាដកម្មជាច្រើនក្តី ក៏ចំនួននេះ បង្ហាញអំពីការបកស្រាយដ៏ខ្វះខ្លាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីភស្តុតាងនេះ ហើយការអះអាងដ៏ស្វាហាប់ទាំងខ្វះភស្តុតាងគាំទ្រទាំងនេះ បច្ចុប្បន្នគឺកំពុងតែត្រូវបានប្រើប្រាស់ប្រឆាំងអ្នកស្រី អ៊ឹម ចែម ។

១៧៣. ទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទលើការស្លាប់ទាំងនេះ ឬការចោទទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានកើតឡើង ភស្តុតាងបង្ហាញឱ្យឃើញថា ទំនាក់ទំនងតែមួយគត់ដែលអ្នកស្រី អ៊ឹម ចែម មានជាមួយមន្ទីរសន្តិសុខតំបន់៥ ឬប្រធានមន្ទីរសន្តិសុខនេះ គឺនៅពេលដែលអ្នកស្រីត្រូវបានបង្គាប់ឱ្យធ្វើការផ្តល់ស្បៀង*តាមសំណើ*របស់ ទុំ សឿន[642] ។ សាក្សី មី តាល់ អ្នកដឹកជញ្ជូនស្រូវ និងបន្លែបង្ការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[643] បានបញ្ជាក់អះអាងថា ថ្នាក់ស្រុកបានបញ្ជូនស្បៀងទៅមន្ទីរសន្តិសុខភ្នំទ្រយោង[644] ។

១៧៤. សរុបសេចក្តីមក ភស្តុតាងបង្ហាញច្បាស់ណាស់ថាអ្នកស្រី អ៊ឹម ចែម ជាប់ទាក់ទងតែនឹងការផលិត

---

642 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERNs 01072598-99 [" សំបុត្ររបស់គាត់បានណែនាំខ្ញុំឱ្យរាយការណ៍អំពីចំនួនកម្លាំង និងស្នើសុំសម្ភារៈ និងម្ហូបអាហារ...គាត់ក៏បានណែនាំពួកខ្ញុំកុំឱ្យហូបលើសពីប្រជាជន ក៏ដូចជាកុំឱ្យផ្តល់របបហូបលើសពី កន្លែងផ្សេង...ខ្ញុំបានស្នើសុំស្បៀងពី *យាយ* ចែម"], 01072622 [" ខ្ញុំបាននិយាយជាមួយ *យាយ* ចែម ថាខ្ញុំត្រូវការឱ្យពួកគេហូបដើម្បីមានកម្លាំងធ្វើការ ហើយគាត់បានឯកភាព"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/102** ឆ:47 ["ក្រោយពេលខ្ញុំធ្វើបញ្ជីឈ្មោះមនុស្សរួច ខ្ញុំបានបញ្ជូនបញ្ជីនោះទៅយាយ ចែម ដើម្បីសុំរបបអង្ករសម្រាប់ផ្គត់ផ្គង់ពួកគេ។ តាមពិតបញ្ជីអ្នកទោសដែលខ្ញុំធ្វើនោះ គឺមិនបានដាក់ឈ្មោះមនុស្សទេ គឺដាក់តែចំនួនមនុស្សសរុបតែប៉ុណ្ណោះ"]។

643 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/256** ឆ:20។

644 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/256** ឆ:22 ["ទេ ខ្ញុំមិនដែលដឹកអង្ករ និងបន្លែទៅទីនោះទេ។ សម្រាប់ភ្នំទ្រយោង ចំពោះស្បៀងខាងស្រុកជាអ្នកបញ្ជូនទៅឱ្យដោយផ្ទាល់"]។

ស្បៀងប៉ុណ្ណោះ ។ ទុំ សឿន ក៏បានទទួលស្គាល់ការពិតនេះដែរ[645] ។ ទោះបីជាសាក្សីខ្លះបង្ហាញថា មានអ្នកទោសស្លាប់ដោយសារការអត់ឃ្លាន ជំងឺ ឬធ្វើការហួសកម្រិតនៅមន្ទីរសន្តិសុខភ្នំទ្រយោង ក៏ដោយ[646] ក៏អត្ថិភាពនៃទំនាក់ទំនងរវាងអ្នកស្រី អ៊ឹម ចែម និងការផ្គត់ផ្គង់ស្បៀងដែលត្រូវបាន បញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោងតាមសំណើរបស់ ទុំ សឿន ពុំអាចបង្ហាញអំពីហេតុនិងបច្ច័យនៃ ឧក្រិដ្ឋកម្មនានាបានឡើយសូម្បីតែមួយករណី ដើម្បីចង្អុលបង្ហាញថា អ្នកស្រី អ៊ឹម ចែម បាន ផ្តួចផ្តើម ឬបានអនុវត្ត ឬបានគ្រប់គ្រង ឬបានចូលរួមតាមមធ្យោបាយនានាក្នុងគោលនយោបាយ ដែលបានគិតទុកជាមុនក្នុងការសម្លាប់អ្នកទោស ។ ផ្ទុយទៅវិញ ការស្លាប់ទាំងនោះ ទំនងជា បណ្តាលមកពីផលលំបាកផ្នែកកសិកម្មដែលអូសបន្លាយប្រមាណជាង ២ ឆ្នាំ ក្នុងស្រុកនេះ[647] ។

<u>ការទម្លាក់កំហុសដាក់អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងការសម្លាប់អ្នកទោសចំនួនរាប់ពាន់នាក់ នៅមន្ទីរសន្តិសុខភ្នំទ្រយោង</u>

១៧៥. សហព្រះរាជអាជ្ញាអន្តរជាតិពិពណ៌នាអំពីការសម្លាប់ប្រចាំថ្ងៃ[648] និងលើកទឡ្ហីករណ៍ថា មានមនុស្ស *រាប់ពាន់នាក់*ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង តាមការបញ្ជាពីអ្នកស្រី អ៊ឹម ចែម[649] និងថា អ្នកស្រីបានរួមចំណែកយ៉ាងសំខាន់ដល់ការសម្លាប់ប្រជាជនស៊ីវិល*រាប់មិនអស់*[650] ។ ភស្តុតាងដែលសំអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ផ្តោតលើសាច់រឿងចចាមអារ៉ាមដែលមិន អាចឱ្យជឿជាក់បាន និងមានវិការៈជាក់ស្តែងបំផុត។

១៧៦. ទាក់ទងនឹងការសម្លាប់ដែលត្រូវបានចោទប្រកាន់ សាក្សី ទុំ សឿន បាននិយាយថា មិនមានការ

---

645 ប្រតិចារឹកបទសម្ភាសន៍ជាមួយ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D219/422.9**, EN ERN 01136968 ["ធ្វើការ ក៏គាត់អត់មាននិយាយពីរឿងអី ។ និយាយតែពីរឿងយើងយកចិត្តទុកដាក់ធ្វើស្រែ ការពារផលដំណាំដែលធ្វើ កើតហ្នឹង ធ្វើប្រឡាយដើម្បីដោះស្រាយទឹកយកទៅធ្វើស្រែ ជួយប្រជាជនហ្នឹង។"]។

646 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧០-៧២។

647 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២៣។

648 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២-១៣។

649 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២។

650 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥២, ៤៥៤, ៤៥៦, ៤៥៩។

សម្លាប់កើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ោងឡើយ[651] ។ ដោយស៊ីសង្វាក់ជាមួយឋានៈរបស់គាត់ជាជនសមគំនិតម្នាក់ក្នុងសាច់រឿងនេះ សក្ខីកម្មរបស់គាត់ត្រូវតែពិនិត្យឱ្យបានហ្មត់ចត់ ។ ទោះជាយ៉ាងណាក្តី ក្នុងករណីនេះ នៅពេលអានដោយយោងទៅដល់ការសន្មតជាមុនថាគ្មានទោស និងដោយយោងទៅលើភស្តុតាងដែលបញ្ជាក់ការពិតដទៃៗទៀត សក្ខីកម្មរបស់គាត់អាចនឹងទទួលយកបាន ។

១៧៧. តាមការពិនិត្យយ៉ាងល្អិតល្អន់បំផុត សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើឯកសារសំអាងចំនួន ៤ ដែលក្នុងនោះ មានឯកសារចំនួន ២ ទាក់ទងនឹងការស្តាប់ចម្លើយរបស់សាក្សីតែមួយ មានតួលេខស្តីពីការសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយ៉ោង ។ ឯកសារទាំងនេះ រួមបញ្ចូលទាំងរបាយការណ៍មួយដែលរៀបចំឡើងក្នុងឆ្នាំ ១៩៨៤ ដោយមន្ទីរឃោសនាការស្រុកព្រះនេត្រព្រះ និងព័ត៌មានដែលទទួលបានពីសាក្សី ប្រាង សល់ និង ភួន ស៊ុនទី[652] ។ ឯកសារសំអាងទាំងនេះ នឹងត្រូវបានលើកឡើងតាមលំដាប់លំដោយដូចខាងក្រោម ។

១៧៨. ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹងស្រាប់ហើយថា របាយការណ៍ពីមន្ទីរឃោសនាការស្រុកព្រះនេត្រព្រះដែលបានរៀបចំឡើងក្នុងឆ្នាំ ១៩៨៤ ដែលបានគូសបញ្ជាក់ថា "ភ្នំទ្រយ៉ោងវាយនិងសម្លាប់-២០០០០"[653] ពុំត្រូវបានបញ្ជាក់ការពិតនោះទេ និងមានភាពពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំ

---

651 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:191-93 ឆ: 217។

652 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* របាយការណ៍មន្ទីរឃោសនាការស្រុកព្រះនេត្រព្រះស្តីពីបញ្ជីប្រាសាទបុរាណ ទីសក្ការបូជា និងវិចិត្រករ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ ឯកសារ **D119/50.2**, EN ERN 00938421។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/127** ឆ:54។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:31។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92** ឆ:48។

653 របាយការណ៍មន្ទីរឃោសនាការស្រុកព្រះនេត្រព្រះស្តីពីបញ្ជីប្រាសាទបុរាណ ទីសក្ការបូជា និង វិចិត្រករ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D119/50.2**, EN ERNs 00938416 ["កម្មាភិបាលឃោសនាការស្រុក បានស្រាវជ្រាវដល់

ទ្រយោងដោយប្រយោលតែប៉ុណ្ណោះ ។ អ្នកធ្វើរបាយការណ៍នេះត្រូវបានចាត់តាំងឱ្យប្រមូលស្ថិតិជនរងគ្រោះ*ក្នុងស្រុកនេះ*[654] ។ ជាងនេះទៀត ពុំមានការជីកគាស់ណាមួយត្រូវបានធ្វើនៅមន្ទីរសន្តិសុខភ្នំទ្រយោង ដែលអាចផ្តល់ភាពច្បាស់លាស់ក្នុងកម្រិតណាមួយឡើយ[655] ។ ផ្ទុយនឹងយុទ្ធសាស្ត្រផ្ទាល់ខ្លួនរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មានម្នាក់ក្នុងចំណោមអ្នករួមចំណែកចងក្រងរបាយការណ៍នេះ មានឆន្ទៈពិនិត្យខ្លឹមសារនៃរបាយការណ៍នេះដោយការប្រុងប្រយ័ត្នក្នុងកម្រិតមួយ ពោលគឺដោយបានទទួលស្គាល់ថា ដោយសារមធ្យោបាយក្នុងការទទួលបានតួលេខចំនួនទាំងនេះ "អាចមិនមែនជាការពិត"[656] និងថា "ជនរងគ្រោះជាច្រើននាក់ត្រូវបានកប់ក្នុងភូមិរបស់ពួកគាត់ និងពុំស្ថិតនៅតាមទីតាំងឧក្រិដ្ឋកម្មណាមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្ម នានា"[657] ដូចដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងរបាយការណ៍នោះឡើយ ។

១៧៩. កង្វះការប្រុងប្រយ័ត្នរបស់សហព្រះរាជអាជ្ញាអន្តរជាតិក៏បង្ហាញយ៉ាងច្បាស់ផងដែរ ទាក់ទងនឹងព័ត៌មានរបស់ ប្រាង សល់ ដែលជាអ្នកឃាមនៅមន្ទីរសន្តិសុខភ្នំទ្រយោង ។ សហព្រះរាជអាជ្ញា

---

ទីកន្លែង និងបានពិនិត្យតាមឃុំនីមួយៗដើម្បីបង្កើតស្ថិតិជាក់ស្តែងនៃប្រាសាទបុរាណ ទីសក្ការបូជា និងវិចិត្រករ និងតួលេខដែលបានផ្តល់"], 00938421។

[654] របាយការណ៍នៃសកម្មភាពស៊ើបអង្កេត (ឆាយ ថួម) ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/155**, EN ERN 01058773 ["ប្រធានក្រុមប្រឹក្សាស្រុកព្រះនេត្រព្រះបច្ចុប្បន្ន...បានពន្យល់ថា គាត់គឺជាអតីតសមាជិកម្នាក់នៃក្រុមយុវជនស្រុកដែលត្រូវបានគេចាត់តាំងឱ្យប្រមូលស្ថិតិនៃជនរងគ្រោះទាំងអស់សម្រាប់ស្រុកព្រះនេត្រព្រះ ដែលជាស្ថិតិដែលយើងអាចអានបានក្នុងរបាយការណ៍ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ នេះ"]។

[655] របាយការណ៍នៃសកម្មភាពស៊ើបអង្កេត (ឆាយ ថួម) ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/155**, EN ERN 01058773 "[ការប្រមូលចំនួនជនរងគ្រោះ បានចាប់ផ្តើមធ្វើឡើងក្នុងឆ្នាំ១៩៨០ ដោយធ្វើដំណើរចេញពីភូមិទៅភូមិមួយនៅក្នុងឃុំនីមួយៗនៅក្នុងស្រុកនេះ។ ការធ្វើដូច្នេះគឺសមាជិកក្រុមបានជួបជាមួយគ្រួសារនីមួយៗ ដែលរស់នៅក្នុងភូមិទាំងអស់នោះ។ ស្ថិតិស្តីពីចំនួនជនរងគ្រោះទាំងអស់នោះ ត្រូវបានគេទទួលបានដោយធ្វើការសាកសួរអ្នកភូមិនានារកអ្នកដែលបានបាត់ខ្លួនរបស់ពួកគាត់តែប៉ុណ្ណោះ និងមិនមែនដោយធ្វើការជីកគាស់សាកសពចេញពីក្នុងដីនៅឯទីកន្លែងនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍នោះ ទេ"]។

[656] របាយការណ៍នៃសកម្មភាពស៊ើបអង្កេត (ឆាយ ថួម) ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/155**, EN ERN 01058773។

[657] របាយការណ៍នៃសកម្មភាពស៊ើបអង្កេត (ឆាយ ថួម) ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/155**, EN ERN 01058773។

អន្តរជាតិសំអាងលើការស្មានរបស់សាក្សីនេះ នៅពេលដែលគាត់បាននិយាយថា មានអ្នកទោសចំនួន ៥.០០០ ដល់ ១០.០០០ នាក់បានស្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង[658] ។ ភស្តុតាងនេះ គឺមិនអាចទទួលយកបានជាដាច់ខាត ។ វាប្រាកដណាស់ដែលថា សាក្សីនេះពុំមានភស្តុតាងពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ដែលអាចជឿជាក់បានឡើយ ។ ទីមួយ សាក្សីនេះមិនបានឃើញការសម្លាប់ណាមួយកើតឡើង[659] ។ ក្រោយមក គាត់បានសារភាពថា គាត់មិនអាចប៉ាន់ស្មានអំពីចំនួនមនុស្សស្លាប់ឡើយ ពីព្រោះ "មានតែទាហានក្រោមបញ្ជារបស់ *តា* សឿន ប៉ុណ្ណោះដែលអាចដឹងចំនួននោះបាន"[660] ។ ទីពីរ សាក្សីនេះបង្ហាញថា ភាគច្រើននៃអ្នកទោសទាំងនោះ បានស្លាប់ដោយសារជំងឺ និងគ្មានអាហារបរិភោគគ្រប់គ្រាន់ ឬ "*ប្រហែល* ពួកគាត់អាចត្រូវបានសម្លាប់ដោយទាហាន ប៉ុន្តែ [គាត់] *ពុំបានដឹង* អំពីចំនួនមនុស្សដែលត្រូវបានសម្លាប់ដោយទាហានទាំងនោះឡើយ"[661] ។ វាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយ ប្រការដែលសហព្រះរាជអាជ្ញាអន្តរជាតិពុំអាចបំបែកភស្តុតាងនេះឱ្យដាច់ដោយឡែកពីគ្នា ។ ប៉ុន្តែវាជាការគួរឱ្យភ្ញាក់ផ្អើលដែលមិនថាភស្តុតាងនោះជាភស្តុតាងអ្វីនោះទេ ក៏វាត្រូវបានលើកមកសំអាងក្នុងដីកាសន្និដ្ឋានស្ថាពរដែរ ។

១៨០. យុទ្ធសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានលាតត្រដាងបន្ថែមទៀតទាក់ទងនឹងភស្តុតាងរបស់ ភួន ស៊ុនទី ជាអ្នកទោសម្នាក់ដែលត្រូវបានដំឡើងតួនាទីជាប្រធាននៅមន្ទីរសន្តិសុខភ្នំទ្រយោង ដោយ ទុំ សឿន[662] ។ គាត់ត្រូវបានលើកមកសំអាងចំពោះអំណះអំណាងរបស់គាត់ដែល

[658] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/127** ឆ:54។

[659] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, **D219/127** ឆ:39 ["ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំដឹងថាគុកភ្នំទ្រយោងគឺជាកន្លែងកសាងខ្លួន ហើយនៅពេលមានអ្នកទោសណាមួយដែលត្រូវបានគេលត់ដំម្តងឬពីរដង ហើយនៅតែមិនព្រមកែប្រែខ្លួន នោះគេនឹងយកអ្នកទោសនោះទៅសម្លាប់ចោល។ ទាំងនេះគ្រាន់តែជាការប៉ាន់ស្មានរបស់ខ្ញុំផ្ទាល់តែប៉ុណ្ណោះ ពីព្រោះខ្ញុំមិនដែលបានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់មនុស្សនៅភ្នំទ្រយោងនោះទេ"]។

[660] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, **D219/127** ឆ:40។

[661] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, **D219/127** ឆ:54 (សេចក្តីបញ្ជាក់បន្ថែម)។

[662] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ:24។

ថាមានអ្នកទោសចំនួន ៣០ ដល់ ៥០ នាក់ត្រូវបានសម្លាប់ជារៀងរាល់ថ្ងៃនៅមន្ទីរសន្តិសុខនេះ ។ ហេតុដូច្នេះហើយ មានមនុស្ស "រាប់ម៉ឺននាក់" ត្រូវបានសម្លាប់នៅទីនោះ[663] ។ ជាការគួរឱ្យភ្ញាក់ផ្អើល ដោយសារតែការរាប់នូវចំនួនដ៏សម្បើម និងដោយភាពមិនប៉ិនប្រសប់នេះ ភួន ស៊ុនទី សារភាពថា គាត់បានឃើញតែការសម្លាប់មួយ ដែលមានអ្នកទោសចំនួន ៧ នាក់ប៉ុណ្ណោះ[664] ។ ទោះជាយ៉ាងនេះក្តី ចំណុចនេះ (មួយផ្នែក) អាចនឹងត្រូវបានពន្យល់ចំពោះករណីដែលថា ភួន ស៊ុនទី តាមពិតទៅមិនបាននិយាយថា មានអ្នកទោសពី ៣០ ទៅ ៥០ នាក់ត្រូវបានសម្លាប់ទេ ។ ប៉ុន្តែគាត់បាននិយាយថា *ចំនួនខ្លះនៃចំនួនសរុបនោះ* ត្រូវបានសម្លាប់[665] ។ កង្វះខាតនូវភស្តុតាងដែលមានលក្ខណៈខ្លាំងក្លា ឬភស្តុតាងស៊ីសង្វាក់គ្នា អាចនឹងត្រូវបានពន្យល់ដោយប្រភពរបស់វាខ្លួនឯង ពោលគឺ ការសន្និដ្ឋានរបស់គាត់ គឺផ្អែកលើព័ត៌មានដែលគាត់ទទួលបានពី ប្រាង សល់[666] ដែលវាជាឧទាហរណ៍ជាក់ស្តែងមួយ នៃភាពមិនអាចជឿជាក់បាននៃភស្តុតាងជាចចាមអារ៉ាម ដែលផ្អែកលើ ពាក្យចចាមអារ៉ាម ។

១៨១. ការពិពណ៌នាផ្សេងទៀត ដែលត្រូវបានលើកឡើងដើម្បីគាំទ្រជាទូទៅដោយសហព្រះរាជអាជ្ញាអន្តរជាតិ មួយភាគធំមិនបានផ្តល់ការគាំទ្រលើអំណះអំណាងដែលថា មានមនុស្ស*រាប់ពាន់នាក់* ត្រូវបាន

663 *សូមមើល* ដីកាសន្និដ្ឋានស្តាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30** ឆ31។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92 ឆ:**48។

664 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30 ឆ:**20-21 [ដែលនិយាយថាគាត់បានឃើញការសម្លាប់មនុស្សចំនួន ៧ នាក់]។

665 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92 ឆ:**50 ["តាមកត់សម្គាល់របស់ខ្ញុំ មនុស្សទាំងអស់នោះខ្លះស្លាប់ដោយសារជំងឺ អត់អាហារ ការធ្វើការងារធ្ងន់ធ្ងរ និងការកាប់សម្លាប់។ ខ្ញុំនៅចាំថានៅពេលគេនៅទីនោះ ខ្ញុំបានកប់មនុស្ស២នាក់ស្លាប់ដោយជំងឺ"]។

666 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/30 ឆ:**31។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/92 ឆ:**48។ កំណត់ហេតុនៃការ តទល់មុខគ្នា (ភួន ស៊ុនទី) ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D231**, EN ERN 01056932 [ដែលនិយាយថា ស៊ុម សល់ ដែលគាត់បានតទល់ជាមួយ ពុំមែនជាអ្នកយាមដែលបានប្រាប់គាត់អំពីព័ត៌មាននេះ ប៉ុន្តែគឺឈ្មោះ សល់ ម្នាក់ទៀត ដែលជាអ្នកយាមនៅមន្ទីរសន្តិសុខភ្នំទ្រយោងដែរ ដែលមានកម្ពស់ទាប]។

សម្លាប់នោះទេ ហើយជំនួសមកវិញ វាបានត្រឹមតែបង្ហាញយ៉ាងច្បាស់ពីកង្វះនូវការដឹងឮ[667] ដែលបង្ហាញថា ការសម្លាប់មិនបានកើតឡើងជាប្រចាំ តែជាហេតុការណ៍ដ៏កម្រ[668] ។ ដោយយោងទៅលើការសន្និដ្ឋានដែលនាំឱ្យមានបញ្ហាជាក់ស្តែងទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិផ្តោតផ្តល់ជាថ្មីម្តងទៀតទៅលើភស្តុតាងដែលជ្រើសយកតាមចិត្តខ្លួនចង់បាន ។ សាក្សី គឹម យ៉េត បាននិយាយថា គាត់បានឃើញផ្ទាល់ភ្នែកថាមាន "មនុស្សជាច្រើនត្រូវបានយកទៅសម្លាប់"[669] និងបាននិយាយពីដំបូងថា ការសម្លាប់បានកើតឡើងជារៀងរាល់សប្តាហ៍[670] ។ ប៉ុន្តែក្រោយមកទៀត គាត់បានពន្យល់ថា មានការសម្លាប់កើតឡើងតែម្តងប៉ុណ្ណោះ[671] និងបានទទួលស្គាល់ថា គាត់មិនបានឃើញថាមានការសម្លាប់ដោយផ្ទាល់ភ្នែកឡើយ[672] ។ សាក្សី ប៊ូ តួក បាននិយាយថា "គេសម្លាប់ឡើងស្រឡះអស់ ។ ពេលស្រឡះហើយ គេដាក់មនុស្សថ្មីមកពេញទៀត"[673] ។ ប៉ុន្តែគាត់បានបញ្ជាក់បំភ្លឺក្នុងការស្តាប់ចម្លើយដដែលនេះថា គាត់បានត្រឹមតែឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់មនុស្សចំនួន ២ នាក់[674] ។ ទោះបីជា ប៊ូ តួក បានអះអាងថាបានឃើញមានអ្នកទោសនានាពីតំបន់នេះបាន

---

667 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆ60។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆ16។

668 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆៈ69។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆៈ31។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆៈ58-59។

669 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆៈ16។

670 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **D106/6** ឆៈ31។

671 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆៈ70។

672 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/94** ឆៈ60។

673 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *យោង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400** ឆៈ69។

674 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400**, ឆៈ98។

បាត់ខ្លួនជារៀងរាល់ថ្ងៃក៏ដោយ[675] ក៏គាត់បានទទួលស្គាល់ថា គាត់មិនបានដឹងថាតើមានអ្វីកើតឡើងចំពោះអ្នកទាំងនោះឡើយ និងបានបញ្ជាក់អះអាងថា អំណះអំណាងរបស់គាត់ដែលថា មានទាហានសម្លាប់អ្នកទោសទាំងនោះ គឺគ្រាន់តែជាការស្មានប៉ុណ្ណោះ[676] ។

១៨២. បន្ថែមពីនេះទៀត សាក្សី ដែង លៀប បានអះអាងថា ពេលខ្លះអ្នកទោសត្រូវបានចង និងយកទៅសម្លាប់នៅពេលយប់ (បើទោះបីជាគាត់បានសារភាពថាមិនដឹងអំពីចំនួនប៉ុន្មានក៏ដោយ)[677] ។ ទោះជាយ៉ាងណាក្តី សាក្សីរូបនេះ ពិតជាបាននិយាយថា គាត់បានឃើញ "មួយ ឬពីរករណីដែលអ្នកជាប់ឃុំឃាំងខ្សោយៗ ដែលមិនអាចបន្តការងាររបស់ពួកគាត់ ត្រូវបានសម្លាប់"[678] ។ សាក្សីដដែលនេះបាននិយាយថា ក្នុងចំណោមអ្នកជាប់ឃុំឃាំងចំនួន ៣០ នាក់ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោងជាមួយគាត់ បានរួចពីការស្លាប់ទាំងអស់[679] ។ ស្រដៀងគ្នានេះដែរ ធិប សំផាត់ ជាសាក្សីដែលត្រូវបានលើកមកសំអាងត្រង់ចំណុចដែលគាត់អះអាងថា ការសម្លាប់បានកើតមានជារៀងរាល់យប់ និងបាននិយាយថា គាត់មិនបានដឹងថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានសម្លាប់ឡើយ[680] និងត្រឹមតែធ្លាប់បានឃើញហេតុការណ៍បែបនេះតែម្តងគត់[681] ។

---

675 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400**, ឆ:108-20។

676 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/400**, ឆ:108-20។

677 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *យោង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:31។

678 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:31 ["...ពួកខ្ញុំគេឱ្យដាំស្ពៃ និងជីឡឹក។ គេឱ្យបបរមួយវែកៗម្នាក់។ អ្នកខ្លះខ្សោយពេក អស់កម្លាំង មិនអាចធ្វើការបាន ត្រូវបានពួកឈ្លបសម្លាប់ ដោយវាយនឹងដំបង ឬស្វាយកាំភ្លើង។ ខ្ញុំបានឃើញផ្ទាល់ភ្នែករាប់មិនអស់។ ខ្ញុំមិនបានឃើញហេតុការណ៍ទាំងនេះ កើតឡើងជារៀងរាល់ថ្ងៃទេ ប៉ុន្តែជាធម្មតាខ្ញុំឃើញវាកើតឡើងនៅពេលល្ងាច។ ខ្ញុំឃើញគេសម្លាប់ ១ ឬ ២ នាក់ នៅនឹងកន្លែងនៅពេលដែលអ្នកខ្សោយពេកមិនអាចធ្វើការទៅរួចទៀត"]។

679 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **D219/252** ឆ:44-45។

680 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧០) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:58-59។

១៨៣. សរុបសេចក្តីមក ជំនួសឱ្យការផ្អែកលើភស្តុតាងពាក់ព័ន្ធ និងភស្តុតាងបញ្ជាក់ពីការពិត ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ផ្អែកលើការប្រើប្រាស់ដោយសម្រាំងយកនូវសក្ខីកម្មមិនគ្រប់ជ្រុងជ្រោយ និងជាពាក្យចចាមអារ៉ាមដែលភស្តុតាងទាំងនេះ មិនអាចគាំទ្រដល់ការចោទប្រកាន់ធ្ងន់ធ្ងរនៃបទឧក្រិដ្ឋឡើយ ។ ការវិភាគដ៏ប្រុងប្រយ័ត្នលើភស្តុតាងផ្ទាល់បង្ហាញឱ្យឃើញថា ការសម្លាប់មនុស្សមានភាពកម្រ និងបានកើតឡើងក្នុងរយៈពេលដ៏ខ្លីមុនពេលវៀតណាមចូលមកដល់ ។ បើទោះបីជាមានចំណុចខ្វះចន្លោះសំខាន់ៗនៃការចងចាំរបស់សាក្សីក៏ដោយ ក៏តួលេខខ្ពស់បំផុតដែលត្រូវបានផ្តល់ឱ្យទាក់ទងការសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង មានម្តងនោះ គឺចំនួន ៩០ នាក់ ដែលត្រូវបានសម្លាប់ដោយកងទ័ព នៅពេលដែលទាហានវៀតណាមបានកំពុងជិតចូលមកដល់[682] ដែលព្រឹត្តិការណ៍នេះ គឺត្រូវបានទទួលស្គាល់ដោយសហព្រះរាជអាជ្ញាអន្តរជាតិដែរថាវាបានកើតឡើងតាមការបញ្ជារបស់ ទុំ សឿន[683] ។ តាមពិត ទោះបីជាការសម្លាប់មនុស្សចំនួន ៩០ នាក់ គឺជាឧក្រិដ្ឋកម្មដ៏គួរឱ្យរន្ធត់ក្តី តែនៅពេលបានពិនិត្យមើលដោយពិចារណាលើការមានចេតនានៃជនទាំងឡាយ ដែលបានកំណត់លក្ខណៈវិនិច្ឆ័យនៃនិយមន័យពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" បង្ហាញថា ការសម្លាប់នោះ មិនអាចត្រូវបានចាត់ទុកថាវាមានតម្លៃជាភស្តុតាងបន្ទាល់ខ្លាំងក្លា ឬមានតម្លៃអាចបញ្ជាក់អំពីអ្វីមួយបានឡើយ ។

១៨៤. វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានរៀបចំឡើងដើម្បីបិទបាំងភាពផុយស្រួយនៃភស្តុតាងដាក់បន្ទុកដែលភ្ជាប់អ្នកស្រី អ៊ឹម ចែម ដោយផ្ទាល់ទៅនឹងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ថ្វីបើមានអំណះអំណាងទូទៅរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម បានបញ្ជា

---

[681] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:60, ស-ឆ:63-64 [ដែលពិពណ៌នាអំពីការសម្លាប់មនុស្ស៩០នាក់ដោយទាហាន]។

[682] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/49 ឆ:60, ស-ឆ: 63-64។

[683] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១៥។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/49** ឆ:62។

ឱ្យមានការសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោងក៏ដោយ[684] ក៏តម្លៃខ្ពស់បំផុតនៃភស្តុតាងនេះ គឺគ្រាន់តែអាចនឹងភ្ជាប់អ្នកស្រី អ៊ឹម ចែម ទៅនឹងការសម្លាប់ដែលត្រូវបានចោទនូវអ្នកទោសចំនួន *បួន* នាក់ប៉ុណ្ណោះ[685] ។ ខណៈដែលចំណុចនេះមិនត្រូវបានចាត់ទុកជាការពិតក៏ដោយ ក៏វាមានប្រយោជន៍ដល់ការណែនាំក្នុងការពិនិត្យពិច័យលើដំណើររឿងតែមួយនេះ និងសន្ទុះទឹកចិត្តដែលត្រូវបានពិពណ៌នា ។ សូម្បីតែនៅពេលពិពណ៌នាអំពីហេតុការណ៍នេះ ទុំ សឿន បានពន្យល់ថា អ្នកស្រី អ៊ឹម ចែម បានបញ្ជាឱ្យគាត់សម្លាប់អ្នកទោស ពីព្រោះអ្នកទោសទាំងនោះបានទទួលរងទារុណកម្មធ្ងន់ធ្ងរពេកមុនពេលចូលទៅមន្ទីរសន្តិសុខភ្នំទ្រយោង[686] ដែលធ្វើឱ្យស្ថានភាពរបស់ពួកគាត់មិនអាចព្យាបាលបាន[687] ។

១៨៥. សរុបសេចក្តីមក ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំទ្រយោង ភស្តុតាងនេះពុំផ្តល់ការគាំទ្រណាមួយដល់ការសន្មតដែលថាអ្នកស្រី អ៊ឹម ចែម អាចជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងអម្បាលម៉ាននៅក្នុងទីតាំងនោះ ឬក៏ថាភស្តុតាងនេះ គឺជាភស្តុតាងមានទម្ងន់ធ្ងន់ធ្ងរ ឬភស្តុតាងបញ្ជាក់ការពិតដើម្បីគាំទ្រអំណះអំណាងដែលថា អ្នកស្រីស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" បានឡើយ ។ ជំនួសឱ្យការពិចារណាអំពីលក្ខខណ្ឌត្រួតគ្នាទាំងពីរនេះទាក់ទងនឹងភស្តុតាងទាំងមូល ក្នុងបំណងបញ្ជាក់ការពិត សហព្រះរាជអាជ្ញាអន្តរជាតិបែរជាធ្វើការវិភាគបែបជ្រើស

684 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២។

685 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ [ជាឧទាហរណ៍ អ៊ឹម ចែម បញ្ជាឱ្យ ទុំ សឿន សម្លាប់អ្នកទោសបួននាក់ ដែលត្រូវបានទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរ"]។

686 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២១២ (ជើងទំព័រ ១០៧៣) *យោង* កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230**, EN ERN 01072613 ["ខ្ញុំចាំថាអ្នកទោសធ្ងន់បួននាក់ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ ...ស្ថានភាពរបស់ពួកគាត់ធ្ងន់ធ្ងរ និងមិនអាចព្យាបាលបាន។ *យាយ* ចែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទោសទាំងបួន នោះទៅ។ ខ្ញុំបានបញ្ជាបន្តឱ្យអ្នកការពារសម្លាប់ពួកគាត់ទៅ"]។

687 កំណត់ហេតុនៃការតទល់មុខគ្នា (ទុំ សឿន) ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D230,** EN ERN 01072613 ["ខ្ញុំចាំថាអ្នកទោសបួនធ្ងន់នាក់ត្រូវបានគេវាយធ្វើបាប មុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ ...ស្ថានភាពរបស់ពួកគាត់ធ្ងន់ធ្ងរ និងមិនអាចព្យាបាលបាន។ *យាយ* ចែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទោសទាំងបួននាក់នោះទៅ។ ខ្ញុំបានបញ្ជាបន្តឱ្យអ្នកការពារសម្លាប់ពួកគាត់ទៅ"]។

ចោះៗ និងបែបអត្តនោម័ត គឺជាយុទ្ធសាស្ត្រមួយដែលជាញឹកញាប់ គ្មានអ្វីក្រៅពីសម្រាំងយកតែភស្តុតាងដាក់បន្ទុកដែលមានលក្ខណៈបំផ្លើសបំផុត និងទម្លាក់ទៅលើអ្នកស្រី អ៊ឹម ចែម តាមរយៈប្រើប្រាស់ភស្តុតាងដែលជាពាក្យចចាមអារ៉ាម និងការសន្មត ។

១៨៦. ការវិភាគដ៏សមហេតុផលលើភស្តុតាងនេះបង្ហាញថា អ្នកស្រី អ៊ឹម ចែម ជាកម្មាភិបាលថ្នាក់ស្រុកមួយរូបដែលពុំមានសិទ្ធិអំណាច *ស្របច្បាប់* ឬ *ជាក់ស្តែង* ទៅលើឋានៈជាប្រធានរបស់ ទុំ សឿន ឬទៅលើប្រតិបត្តិការណាមួយរបស់មន្ទីរសន្តិសុខភ្នំទ្រយោង ដែលត្រូវបានគ្រប់គ្រងដោយ ទុំ សឿន ឬថ្នាក់លើឡើយ ។ ភស្តុតាងពាក់ព័ន្ធ និងគួរឱ្យជឿជាក់បានបង្ហាញថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលត្រូវបានចោទថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង មានកម្រិតទាប ហើយទោះជាក្នុងករណីណាក៏ដោយ គឺវាតិចជាងអ្វីដែលចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ។ ភស្តុតាងបង្ហាញឱ្យឃើញថា អ្នកស្រី អ៊ឹម ចែម ជាប់ទាក់ទងនឹងការផលិតស្បៀងតែប៉ុណ្ណោះ និងថាតួនាទីតែមួយមុខរបស់អ្នកស្រីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំទ្រយោង គឺការផ្គត់ផ្គង់ស្បៀងតាមសំណើរបស់ប្រធាន ទុំ សឿន ដោយផ្អែកតាមបញ្ជីស្នាមនានាដែល ទុំ សឿន បានរៀបចំ ។ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម ជាអ្នកផ្គត់ផ្គង់ស្បៀង ពុំពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោងឡើយ ។ តួនាទីនេះពុំអាចជាភស្តុតាងខ្លាំងក្លាដែលអាចបញ្ជាក់អំពីការពិត ឬមានជាភស្តុតាងនៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ឬជាប្រភេទភស្តុតាងប្រើដើម្បីធ្វើការកំណត់ប្រដូចអ្នកស្រីជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" បានឡើយ ។

### ២. អ្នកស្រី អ៊ឹម ចែម មិនបានដើរតួនាទីណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងនោះទេ

១៨៧. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា i) អ្នកស្រី អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវលើការដ្ឋានទាំងអស់ដែលត្រូវបានគ្រប់គ្រងពីមុនដោយអតីតប្រធានកងចល័តតំបន់៥[688] (រួមទាំងការដ្ឋានស្ពាន

[688] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២។

ស្រែង[689]) ព្រមទាំងគ្រប់គ្រងប្រធានថ្មីនៃកងចល័តតំបន់៥[690] និងថា ii) អ្នកស្រីបានចូលរួមយ៉ាងសកម្មក្នុងការបង្ខំពលកររាប់ពាន់នាក់ឱ្យធ្វើការងារជាទម្ងន់[691] ដែលពួកគេជាច្រើនបានស្លាប់ដោយសារភាពអត់ឃ្លាន និងជំងឺ[692] ហើយបានបាត់ខ្លួន[693] ជាទៀងទាត់[694] ។

១៨៨. ដូចនឹងការពិភាក្សាខាងក្រោម ភស្តុតាងបង្ហាញថា អំណះអំណាងទាំងពីរពុំបានផ្អែកតាមការវាយតម្លៃបែបសត្យានុម័តនៃភស្តុតាងឡើយ ។ ទីមួយ ភស្តុតាងនេះបង្ហាញយ៉ាងច្បាស់ថា ការដ្ឋានស្ពានស្រែង ស្ថិតក្រោមការគ្រប់គ្រងជាផ្លូវការរបស់គណៈតំបន់៥ និងក្រោមការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ប្រធានកងចល័តតំបន់៥ តា ពាល់ ដែល មានឋានានុក្រមមុខតំណែងខ្ពស់ជាងអ្នកស្រី អ៊ឹម ចែម[695] ។ ទីពីរ ភស្តុតាងនេះពុំគាំទ្រអំណះអំណាងនានា ពាក់ព័ន្ធនឹងស្ថានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឬការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម ក្នុងឧក្រិដ្ឋកម្មទាំងនោះឡើយ[696] ។

១៨៩. ជាសង្ខេប ក្រុមការពារក្តីសូមអះអាងថា ការវាយតម្លៃដ៏សមហេតុផលអំពីលក្ខណៈវិនិច្ឆ័យត្រួតគ្នាទាំងពីរនេះ (ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលត្រូវបានចោទប្រកាន់នៅការដ្ឋានស្ពានស្រែង និងកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានលើកឡើងទាំងនេះ) នាំឱ្យមានការសន្និដ្ឋានដ៏ច្បាស់លាស់ថា មានកម្រិតតិចតួចណាស់ ដែលភស្តុតាងទាំងនោះមានភាពមធ្យ័ត ឬក៏ថាវាអាចបញ្ជាក់ការពិតបាន ឬបើមិនដូច្នោះទេ វាគឺជាភស្តុតាងដែលមានតម្លៃតិចតួចដើម្បីបង្ហាញពីការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ក្នុង ការដ្ឋានស្ពានស្រែង អាចជាការទទួលខុសត្រូវដ៏

689 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២-៦៣ និង ៥៣២។
690 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣០)។
691 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤។
692 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៧។
693 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧០។
694 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤-៧១។
695 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៩៦-២០៧។
696 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២០៨-២៦។

ធំផេង ឬស្ទើរតែអាចបង្ហាញពីការនៅកៀកនឹងការទទួលខុសត្រូវផ្ទាល់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានានោះ ។ យោងតាមលក្ខណៈជាអង្គនៃភស្តុតាង ភស្តុតាងដូច្នេះគាំទ្រក្នុងកម្រិតតិចតួច ឬមិនគាំទ្រសោះចំពោះការអះអាងដែលថាអ្នកស្រីស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅ អ.វ.ត.ក ។

### *i. ភាពជាក់លាក់ទាក់ទងនឹងវិសាលភាពភូមិសាស្ត្រនៃការដ្ឋានស្ពានស្រែង*

១៩០. មុនពេលលើកឡើងអំពីខ្លឹមសារនៃទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្រុមការពារក្តីសូមលើកឡើងពីភាពមានមន្ទិលថាតើករណីការដ្ឋានអូរលៀប ត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃការចោទប្រកាន់មកលើអ្នកស្រី អ៊ឹម ចែម ឬទេ ។ ក្នុងចម្លើយតបនេះ ការជូនដំណឹងអំពីបទចោទប្រកាន់ និងការយោងទៅរក "ការដ្ឋានស្ពានស្រែង" មានភាពស្រពិចស្រពិល និងខ្វះភាពជាក់លាក់ដែលជាលក្ខខណ្ឌតម្រូវ[697] ។ ការដ្ឋានអូរលៀប ពុំត្រូវបានដាក់បញ្ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ឬសេចក្តីថ្លែងការណ៍នានាដែលភ្ជាប់ទៅនឹងដីកានេះឡើយ[698] ។

១៩១. សាក្សីមួយចំនួនក៏មានការភ័ន្តច្រឡំជាខ្លាំង នៅពេលត្រូវបានស្នើសុំឱ្យពិពណ៌នាអំពីទីតាំងទំនប់ស្ពានស្រែង និងទំនប់អូរលៀប[699] ។ ជាឧទាហរណ៍ នៅ ចាត់ ដែលបានធ្វើការនៅទីតាំងទាំងពីរ

---

697 *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ឯកសារ **D239.1** នៅកថាខណ្ឌ ៦ និង៨។

698 *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ឯកសារ **D1** នៅកថាខណ្ឌ ៧៩ (ជើងទំព័រ ៣២៤-៣០)។

699 *សូមមើល ជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:197 [នៅពេលត្រូវបានសួរថាតើស្ពានស្រែង និងអូរលៀប ជាប្រឡាយតែមួយឬយ៉ាងណា នៅ ចាត់ បានឆ្លើយថា "ប្រឡាយស្ពានស្រែង និងភូមិចា ជួបគ្នាជាមួយនឹងប្រឡាយអូរលៀប"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/133**, ស-ឆ:11 ["សៈ តើការដ្ឋានទំនប់អូរលៀបដែលលោកធ្វើការ គេហៅថាទំនប់ស្ពានស្រែងឬ? ឆ:11៖ មិនមែនទេ កន្លែងខ្ញុំធ្វើការគឺនៅក្នុងឃុំភ្នំលាប ហើយទំនប់ស្ពានស្រែងមានទីតាំងនៅក្នុងឃុំទឹកជោរ"] ឆ:13 ["[អូរលៀប] ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦"] ឆ:121 ["បច្ចុប្បន្នគេហៅថាប្រឡាយអូរលៀប ហើយមានប្រភពទឹកចេញពីស្ពានស្រែង"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:27 [ក្នុងអំឡុងពេលគាត់ធ្វើការនៅទំនប់ស្ពានស្រែង "ពេលនោះខ្ញុំធ្វើការនៅខាងលិចស្ទឹងស្ពានស្រែងដែលមានទីតាំងនៅក្នុងឃុំ ស្ពានស្រែង ឬក្នុងឃុំពង្រ ស្រុកភ្នំស្រុក ក្នុងតំបន់ ៥"] ឆ:28 ["ទំនប់ស្ពានស្រែងចាប់ផ្តើមពីខាងកើតស្រុកភ្នំស្រុក ទល់ទៅនឹង

និយាយថាមានទំនប់ស្ពានស្រែងចំនួនពីរ ព្រមទាំងមានទំនប់ពីរផ្សេងទៀត មួយឈ្មោះទំនប់អូរលៀប និងមួយទៀតឈ្មោះទំនប់អូរ តា ផល[700] ។ ការភ័ន្តច្រឡំនេះ មិនដែលត្រូវបានលើកឡើង ឬបញ្ជាក់បំភ្លឺដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ដែលបានបំពេញកិច្ចស៊ើបសួរលើកចុងក្រោយរបស់ពួកគាត់ដើម្បីកំណត់ទីតាំងទំនប់ និងប្រឡាយស្ពានស្រែងប្រាំពីរខែមុនពេលយកចម្លើយរបស់ អៅ ចាត់[701] ។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា ទោះបីជាអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានចុះទៅដល់ទីកន្លែងចំនួនបីទាក់ទងនឹងការដ្ឋានស្ពានស្រែក៏ដោយ[702] ក៏ការសន្និដ្ឋានដ៏ជាក់លាក់មិនដែលត្រូវបានធ្វើឡើយទាក់ទងនឹងវិសាលភាពភូមិសាស្ត្រនៃការដ្ឋាននេះ ។

១៩២. ក្រោមកាលៈទេសៈទាំងនេះ និងដោយអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ភាពស្រពិចស្រពិលនានាអំពីវិសាលភាពភូមិសាស្ត្រនៃការដ្ឋានស្ពានស្រែង និងព្រៃនាមគប្បីដោះស្រាយឱ្យបានជាប្រយោជន៍ដល់អ្នកស្រី អ៊ឹម ចែម ។ ហេតុដូច្នេះ ក្រុមការពារក្តីសូមស្នើថា សហចៅក្រមស៊ើបអង្កេតគួរកំហិតការពិចារណាលើទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នេះ ត្រឹមទីតាំងទាំងឡាយណាដែលត្រូវបានកំណត់អត្តសញ្ញាណជាក់លាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងសូមស្នើសុំឱ្យច្រានចោលនូវរាល់ភស្តុតាងទាំងឡាយណា ដែលគ្មានការយោងជាក់លាក់ទៅរកហេតុការណ៍នានាដែលបានកើតឡើងទាំងនៅស្ពានស្រែង

---

ស្ពានស្រែងដែលស្ថិតនៅភូមិរោគ ឃុំស្ពានស្រែងដែលជាស្ពានបុរាណបាក់បែក ហើយក៏បន្តទៅខាងកើតទៀត"] ឆ:29 ["កងចល័តឃុំរបស់ខ្ញុំបានបញ្ចប់ការលើកទំនប់ស្ពានស្រែង ហើយត្រូវផ្លាស់ទៅការដ្ឋានធ្វើអាងអូរលៀប"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/397** ឆ:5 ["ប្រឡាយ [អូរលៀប] ចេញពីអូរលៀបឆ្ពោះទៅទិសខាងជើងដល់ស្ពានស្រែង"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/92** ឆ:21 ["ប្រឡាយអូរលៀបមានចម្ងាយប្រហែល ១គីឡូម៉ែត្រនៅខាងកើតភ្នំលៀប"]។

700 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:195-96។

701 *សូមមើល* កំណត់ហេតុនៃកិច្ចស៊ើបសួរ (កោ ឡិន) ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/129**។

702 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង (ការដ្ឋានស្ពានស្រែង) ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/19**។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/95**។ កំណត់ហេតុនៃកិច្ចស៊ើបសួរ (កោ ឡិន) ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/129**។

ក្ដី និងទំនប់ព្រៃនាមក្ដី ។ ក្នុងចម្លើយតបនេះ និងលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ការយោងទាំងអស់ទៅ "ការដ្ឋានស្ពានស្រែង" គួរត្រូវយល់ថាវារួមបញ្ចូលតែចំពោះទំនប់ស្ពានស្រែង និង/ឬ ព្រៃនាមប៉ុណ្ណោះ ។

### *ii. ការដ្ឋានស្ពានស្រែងស្ថិតក្រោមអំណាចផ្លូវការ និងដែលមានប្រសិទ្ធភាពរបស់គណៈតំបន់៥ និង តា ពាល់ ដែលជាប្រធានកងចល័តតំបន់៥*

១៩៣. ផ្ទុយស្រឡះពីការពិពណ៌នារបស់សហព្រះរាជអាជ្ញាអន្តរជាតិ[703] ភស្តុតាងក្នុងសំណុំរឿង ០០៤/១ មិនបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានអំណាច*ស្របច្បាប់* ឬ*ជាក់ស្ដែង* ដែលចាំបាច់ក្នុងការទទួលខុសត្រូវលើការដ្ឋានស្ពានស្រែងឡើយ ។ ដូចនឹងត្រូវពិភាក្សាខាងក្រោម ការដ្ឋានស្ពានស្រែងស្ថិតក្រោមសិទ្ធិអំណាចផ្លូវការរបស់គណៈតំបន់៥ និងក្រោមការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ តា វ៉ាល់ ដែលជាប្រធានកងចល័តតំបន់៥ (រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៧) និង តា ពាល់ (ចាប់ពីពាក់កណ្ដាលឆ្នាំ ១៩៧៧) ដែលអ្នកស្រី អ៊ឹម ចែម មិនមានសិទ្ធិអំណាចលើ ។

១៩៤. ការដ្ឋានស្ពានស្រែង ដែលត្រូវបានគ្របដណ្ដប់លើស្រុកចំនួនពីរ (ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ)[704] ស្ថិតក្រោមសិទ្ធិអំណាចផ្លូវការរបស់គណៈតំបន់៥ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[705] ។ ការសាងសង់បានចាប់ផ្ដើមនៅដើមខែ វិច្ឆិកា ឆ្នាំ ១៩៧៥[706] ដោយមានភស្តុតាងស៊ី

---

703 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២។

704 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៥៧-៦០។

705 *សូមមើល រឿងក្ដី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី (សក្ខីកម្មរបស់សាក្សី ប៉ាន ឈួង) ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ **E1/359.1**, KH 01175867 ["ដែលណែនាំឱ្យខ្ញុំធ្វើនេះគឺតាហ៊ីង្ស គាត់បញ្ជាមក តាវ៉ាល់, តាវ៉ាល់បញ្ជាឱ្យខ្ញុំធ្វើប៉ុណ្ណោះឯង ខ្ញុំធ្វើតាមបទបញ្ជានេះឯង។"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130**, ស-ឆ:164 ["ស ៖ លោកនិយាយពីតាពាល់ដែលឡើងជំនួសតាវ៉ាល់។ តើតាពាល់ពេលនោះ គាត់រាយការណ៍ទៅឱ្យអ្នកណា? ឆ:164៖ គាត់រាយការណ៍ទៅឱ្យថ្នាក់តំបន់ ព្រោះគាត់ទទួលខុសត្រូវតំបន់ចល័ត"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣-១៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/455** ឆ:90 ("តាវិនជាប្រធានតាពាល់")។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:97 [ដែលនិយាយថា ប្រឡាយស្ពានស្រែង

សង្វាក់គ្នាដែលបង្ហាញថា ផ្នែកសំខាន់នៃការដ្ឋានស្ពានស្រែង ត្រូវបានបញ្ចប់ការសាងសង់នៅមុនពេលការមកដល់របស់កម្មាភិបាលភូមិភាគនិរតី និងការមកដល់របស់អ្នកស្រី អ៊ឹម ចែម ក្នុងភូមិភាគពាយព្យ[707] ។ នៅអំឡុងខែ ឧសភា ឆ្នាំ ១៩៧៧ ពោលគឺមុនពេល អ្នកស្រី អ៊ឹម ចែម មកដល់

---

និងប្រឡាយអូរលៀបត្រូវបានលើកដោយកងចល័តតំបន់] ឆ:99 [ដែលនិយាយថា ការដ្ឋានប្រឡាយអូរលៀបគ្រប់គ្រងដោយថ្នាក់តំបន់]។

706 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/133** ឆ:4-5 [ដែលនិយាយថា គាត់ធ្វើការនៅទំនប់អូរលៀប ឃុំភ្នំលៀប នៅអំឡុងខែវិច្ឆិកា ឆ្នាំ ១៩៧៥ រយៈពេល ៣ ឬ ៤ ខែ មុនពេលគាត់ត្រូវបានគេបញ្ជូនឱ្យទៅលើកទំនប់នៅឃុំប្រាសាទ] ឆ:11, ឆ:13 [ដែលនិយាយថា ទំនប់អូរលៀបស្ថិតនៅភាគខាងជើងផ្លូវជាតិលេខ ៦] ឆ:121 [ដែលនិយាយថា ប្រឡាយស្ពានស្រែង មានឈ្មោះថា ប្រឡាយអូរលៀបនៅពេលបច្ចុប្បន្ន] ឆ:123 [ដែលនិយាយថា ដំបូង ការលើកប្រឡាយអូរលៀបស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយព្យ ហើយគាត់បានឮថា ឈ្មោះតាវ៉ាល់ជាអ្នកគ្រប់គ្រងប្រឡាយនោះ] ឆ:127 [ដែលនិយាយថា គាត់មិនធ្លាប់ឮថាអ្នកស្រី អ៊ឹម ចែម ជាអ្នកគ្រប់គ្រងការងារលើកប្រឡាយអូរលៀបឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:230 [ដែលនិយាយថា គាត់ធ្វើការនៅប្រឡាយស្ពានស្រែងដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលភូមិភាគនិរតី និងភូមិភាគពាយព្យ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:62 [ដែលនិយាយថា ការងារនៅប្រឡាយស្ពានស្រែងដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលភូមិភាគពាយព្យ គឺធ្វើឡើងដូចជាតាវ៉ាល់ពីមុនដែរ]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រុច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:68-74 [ដែលនិយាយថា គាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើស្រែប្រាំងនៅជិតការដ្ឋានស្ពានស្រែង ដែលកងចល័តផ្សេងទៀតកំពុងលើកប្រឡាយស្ពានស្រែង ហើយការដ្ឋាននេះស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលភូមិភាគពាយព្យ]។ សេចក្តីរាយការណ៍ប្រចាំសប្តាហ៍របស់គណៈតំបន់ ៥ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, KH 00275596 [ដែលកត់សម្គាល់ថា នៅខែ ឧសភា ឆ្នាំ ១៩៧៧ ប្រឡាយមួយដែលជីកចេញពីស្ទឹងស្ពានស្រែងមករកអាងមួយនៅក្បែរវត្តចារ កំពុងត្រូវបានសាងសង់បញ្ចប់ដោយពលករមកពីឃុំប្រាសាទ]។ សេចក្តីរាយការណ៍អំពីសភាពការណ៍ខ្លាំង ដោយ ម-៥៦០ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.27.3**, KH 00008501 (ព័ត៌មានដូចគ្នា)។

707 ប្រតិចារឹកបទសម្ភាសន៍របស់ តក់ ប៊ុយ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D219/422.8**, KH 01121355-01121356 (ប្រឡាយស្ពានស្រែង "គឺវាចប់ហើយ បានគេមកគ្រប់គ្រង។ ហើយគេនឹងជួសជុល ពួកយាយ ចែម ហ្នឹងគេនឹងជួសជុលបន្តទៅទៀតអីម៉េចៗខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅឯណោះផុតណា"។ KH 01121355 (ភាសាអង់គ្លេស) ["តាមពិត ការជីកប្រឡាយនេះត្រូវបានបញ្ចប់មុនពេលដែលពួកភូមិភាគនីរតី និងយាយចែមមកដល់។ ប៉ុន្តែនៅពេលដែលយាយ ចែម និងពួកភូមិភាគនិរតីមកដល់ ប្រហែលជាពួកគេបានធ្វើការនៅប្រឡាយនេះរួចទៅហើយ។ ខ្ញុំមិនដឹងច្បាស់ទេ ព្រោះនៅពេលនោះ ខ្ញុំត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅទីតាំងមួយផ្សេងទៀត"]។ របាយការណ៍ស្តីពីការ

ភូមិភាគពាយព្យ[708] គណៈតំបន់៥ បានពិពណ៌នាលម្អិតពីការខ្វះខាតស្បៀងអាហារធ្ងន់ធ្ងរនៅគ្រប់ស្រុកទាំងអស់ដោយសារកង្វះទឹកភ្លៀង និងប្រព័ន្ធធារាសាស្ត្រសម្រាប់ផ្គត់ផ្គង់ទឹកដល់វាលស្រែ[709] និងបានរៀបចំផែនការដូចតទៅពាក់ព័ន្ធនឹងការដ្ឋាននានា ពោលគឺ ធ្វើការវាយសម្រុកសាងសង់ប្រព័ន្ធភ្លឺប្រឡាយ បង្កើយការជីកប្រឡាយមួយចំនួនដែលចែកតាមស្រុកនីមួយៗ បង្កើយអាងទឹកតូចៗនៅតាមមូលដ្ឋានស្រុក និងតាមបណ្ដាឃុំ បន្តបញ្ចប់ការងារសាងសង់ទ្វារទឹកសំខាន់ៗ និងបន្តពង្រីកទំនប់ចាស់ៗដែលមានស្រាប់[710] ។ វាប្រាកដណាស់ គណៈតំបន់៥ ទទួលខុសត្រូវលើការបង្កើតគម្រោងផែនការប្រព័ន្ធធារាសាស្ត្រសម្រាប់តំបន់ទាំងមូល ។

១៩៥. ជារៀងរាល់ថ្ងៃ ពលករទាំងអស់នៅការដ្ឋានស្ពានស្រែង ត្រូវបានស្ថិតក្រោមការគ្រប់គ្រងដោយប្រសិទ្ធភាពរបស់ប្រធានកងចល័តតំបន់៥ ពោលគឺ រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៧ ។ ពលករ

---

កំណត់អត្តសញ្ញាណទីកន្លែង (ការដ្ឋានស្ពានស្រែង) ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/19**, KH 00919501 [“តាមព័ត៌មានទទួលបានពីការសម្ភាសន៍សាក្សី តក់ ប៊ុយ ព្រែកជីកនេះត្រូវបានជីកមុនពេល អ៊ឹម ចែម មកទទួលខុសត្រូវក្នុងស្រុកព្រះនេត្រព្រះ”]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆាយ ផាន ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/40** ឆ:15 [“ការដ្ឋានទំនប់ស្ពានស្រែងធ្វើចប់សព្វគ្រប់មុនពេលពួកនិរតីមកដល់”]។ កំណត់ហេតុនៃកិច្ចស៊ើបសួរ (កោ ឡិន) ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/129**, KH 01001321 [“ផ្នែកខាងជើងនៃប្រឡាយនោះ បានសាងសង់រួចមុនពេល អ៊ឹម ចែម និងកម្មាភិបាលនិរតីបានមកដល់”]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រឹម សឺត ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D106/10 ឆ:**4-5, **ឆ:**9, **ឆ:**14 [សាក្សីបានធ្វើការនៅការដ្ឋានព្រៃរនាមមុនពេលចូលឆ្នាំខ្មែរនៅឆ្នាំ ១៩៧៧ និងនិយាយថា ប្រឡាយស្ពានស្រែងត្រូវបានសង់រួចមុនពេលគាត់ចាប់ផ្ដើមធ្វើការនៅការដ្ឋានព្រៃរនាម]។

708 *ប្រៀបធៀបនឹង* ចម្លើយតប នៅកថាខណ្ឌ ១០២។

709 *សូមមើលជាឧទាហរណ៍* របាយការណ៍ប្រចាំសប្ដាហ៍របស់គណៈតំបន់ ៥ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, KH 00275594 [“មូលហេតុជាសត្យានុម័តគឺមកពីមានការខ្វះខាតទឹក ដោយយើងមិនទាន់ម្ចាស់ការលើទឹក ហើយរហូតមកទល់ថ្ងៃនេះមិនទាន់មានភ្លៀងគ្រប់គ្រាន់ដើម្បីអនុគ្រោះឱ្យស្រូវបាននៅឡើយ”], KH 00275595 [“រហូតចាប់ពីខែ ១ ខែ ២ មកទល់ថ្ងៃនេះ (ខែ ឧសភា ឆ្នាំ ១៩៧៧) មានភ្លៀងធ្លាក់មកតែម្ដងប៉ុណ្ណោះ។ កត្តានេះធំគឺកត្តាមិនម្ចាស់ការលើទឹក ពឹងផ្អែកលើមេឃ”], KH 00275596 [ក្នុងស្រុកភ្នំស្រុក “ភ្លៀងម្ដងក៏ដាំ (ពោត និងសណ្ដែក) ដាំហើយរាំងក៏ខ្លោចងាប់អស់។ លុះភ្លៀងទៀត ដាំទៀត ត្រូវរាំងទៀត ងាប់ទៀត”]។

710 *សូមមើល* របាយការណ៍ប្រចាំសប្ដាហ៍របស់គណៈតំបន់ ៥ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **D1.3.10.1**, KH 00275596។

ទាំងឡាយត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ តា វ៉ាល់[711] ដែលត្រូវបានចាប់ខ្លួននៅអំឡុងខែ មិថុនា ឆ្នាំ ១៩៧៧[712] ។

១៩៦. ដើម្បីជំរុញឱ្យមានការចោទប្រកាន់ទៅបាន ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម មាន "សិទ្ធិអំណាចគ្រប់គ្រងលើការដ្ឋានទាំងអស់នេះ ដែលពីមុនក្តោបក្តាប់ដោយ តា

---

[711] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាយ ផាន ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/40,** ស-**ឆ:**12 ["សៈ នៅការដ្ឋានស្ពានស្រែង នរណាជាអ្នកគ្រប់គ្រងរួមនៅទីនោះ? ឆ12៖ តាវ៉ាល់គឺជាអ្នកគ្រប់គ្រងនៅទីនោះ"] **ឆ:**15 ["តាវ៉ាល់អ្នកមកពីពាយព្យ ជាអ្នកគ្រប់គ្រង (ទំនប់ស្ពានស្រែង) ផ្ទាល់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ផិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149 ឆ:**9 [ដែលគូសបញ្ជាក់ថា តាវ៉ាល់ បានគ្រប់គ្រងកម្លាំងនៅការដ្ឋានទំនប់ស្ពានស្រែង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89 ឆ:**35 [នៅឆ្នាំ ១៩៧៧ "តា វ៉ាល់ ជាអ្នកគ្រប់គ្រងការដ្ឋានស្ពានស្រែង និងការដ្ឋានអាងត្រពាំងថ្ម"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/139 ឆ:**60 ["នៅពេលដែលខ្ញុំធ្វើការនៅការដ្ឋានប្រឡាយស្ពានស្រែង តា សន និងតាវ៉ាល់ គឺជាអ្នកគ្រប់គ្រងផ្ទាល់នៅការដ្ឋានប្រឡាយស្ពានស្រែងនោះ"]។ ប្រតិចារឹកបទសម្ភាសន៍របស់ តក់ ប៊ុយ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D219/422.8,** KH 01121340, 01121341 ["ដូច្នេះក្នុងសម័យនោះ ខ្ញុំជាកងចល័ត។ លើកទំនប់ លើកប្រឡាយ ជីកប្រឡាយលើកទំនប់ ហើយក្នុងនោះគឺអ្នកដែលគ្រប់គ្រង គឺមាន តា វ៉ាល់...។ ធ្វើអាងហ្នឹងរួច បានដកកងខ្ញុំទៅកន្លែងដែលយើងទៅព្រឹកមិញ ជីកអានោះទៀត បង្ហូរ។ អាងត្រពាំងថ្ម....ស្ពានស្រែង"]។ កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី សម សក្ក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/120 ឆ:**61, **ឆ:**62 [ដែលនិយាយថា តាវ៉ាល់ជាអ្នកគ្រប់គ្រងកងចល័តទាំងអស់នៅការដ្ឋានស្ពានស្រែង] **ឆ:**70 ["ខ្ញុំមិនដឹងទេ (ថាតើនរណាជាអ្នកគ្រប់គ្រងការដ្ឋានស្ពានស្រែង) ប៉ុន្តែបញ្ជាចេញពី តាវ៉ាល់"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/52 ឆ:**11 ["គឺសមមិត្ត វ៉ាល់ គាត់ជាអ្នកទទួលបន្ទុកខាងផ្នែកសាងសង់ទំនប់ និងប្រឡាយ..."]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23 ឆ:**97 [ដែលសួរថាតើគាត់ធ្លាប់ឮឈ្មោះប្រឡាយស្ពានស្រែង ឬប្រឡាយអូរលៀប ឬទេ, ពុំ ខូ បានឆ្លើយថា ៖ "បាទ ខ្ញុំធ្លាប់លឺ។ ប្រឡាយនេះត្រូវបានលើកដោយកងចល័តតំបន់"]។ *សំណុំរឿងនួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី (សក្ខីកម្មរបស់សាក្សី ឡុត សួយ) ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/329.1**, KH 01130087-01130088 ["តាវ៉ាល់ គាត់ក្តាប់រួមទាំងអស់ក្នុងតំបន់ ៥ នេះ គឺកន្លែងទំនប់ត្រង់ណាក៏គាត់ក្តាប់រួមដែរ...ដូចជា ទំនប់ស្ពាន ស្រែង"]។

[712] បញ្ជីកាត់ទោស នៅមន្ទីរ ស-២១, ឈ្មោះអ្នកទោសកំទេច ៣៩ នាក់ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ **D6.1.1128,** KH 01128615 [ដែលកត់ត្រាពីការចាប់ខ្លួនតាវ៉ាល់ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៧]។

វ៉ាល់ ក្រោយពេលបានក្លាយជាលេខាស្រុក"[713] ។ ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម ជាអ្នកគ្រប់គ្រងលើប្រធានថ្មីនៃកងចល័តតំបន់៥ ឈ្មោះ តា ពាល់[714] ។ ការអះអាងទាំងនេះនឹងត្រូវលើកឡើងតាមលំដាប់លំដោយក្នុងផ្នែកខាងក្រោម ។

១៩៧. ពាក់ព័ន្ធនឹងការអះអាងទីមួយដែលថា អ្នកស្រី អ៊ឹម ចែម ជាអ្នកគ្រប់គ្រងការដ្ឋានទាំងអស់បន្តពី តា វ៉ាល់ សហព្រះរាជអាជ្ញាអន្តរជាតិផ្អែកលើឯកសារសំអាងចំនួន៤ឯកសារ[715] ។ ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិបានពិនិត្យភស្តុតាងដោយសមហេតុផល ឬដោយមិនលម្អៀង នោះសេចក្តីសន្និដ្ឋាននៃឯកសារសំអាងចំនួន២នៃឯកសារសំអាងទាំងនេះ ពោលគឺសក្ខីកម្មរបស់ មុន មុត និង សែន សុផុន ពិតណាស់ថាវាគ្មានមូលដ្ឋានអ្វីទាល់តែសោះ ក្រៅតែពីពាក្យចចាមអារ៉ាម ។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានជ្រើសរើសយកដោយអន្លើ និងមិនពិចារណាលើភស្តុតាងទាំងឡាយណាដែលមិនបម្រើឱ្យការចង់បានរបស់ខ្លួន សូម្បីតែនៅពេលដែលភស្តុតាងនេះទទួលបានពីសាក្សីតែមួយក្តី ។ សាក្សី មុន មុត ពិតជាបានថ្លែងក្នុងបទសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ថា អ្នកស្រី អ៊ឹម ចែម បានគ្រប់គ្រងបន្តពី តា វ៉ាល់[716] ប៉ុន្តែនៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សីរូបនេះបានបញ្ជាក់

---

713 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២។

714 *សូមមើល* ដីកាសិន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២។

715 ដីកាសិន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៦) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:65។ ប្រតិចារឹកបទសម្ភាសន៍ អ៊ឹម ចែម ដោយអង្គការយុវសន្តិភាព គ្មានកាលបរិច្ឆេទ ឯកសារ **D219/264.1**, KH 01107032។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មុន មុត ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.10**, KH 00728890។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី (សក្ខីកម្មរបស់សាក្សី សែន សុផុន) ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/494.1.1**, KH 01122556។

716 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៦), *ដែលយោងទៅលើ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មុន មុត ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.10**, KH 00728891។

បំភ្លឺថា មាន*កម្មាភិបាលម្នាក់ ឈ្មោះ* តា ញ៉ារ *បានឡើងជំនួស* តា វ៉ាល់[717] ។ គាត់បានបន្តគូស បញ្ជាក់ទៀតថា អ្នកស្រី អ៊ឹម ចែម គឺនៅជាគណៈស្រុកព្រះនេត្រព្រះរហូតដល់បែករបបខ្មែរក្រហម[718] ហើយថា គាត់មិនបានដឹងពីរបៀប "ការគ្រប់គ្រង និងដែនអំណាច" របស់អ្នកស្រីនៅក្នុងស្រុកព្រះនេត្រព្រះឡើយ[719] ។ វាជាការរំលោភបំពានលើកាតព្វកិច្ចនៃការជួយរកឱ្យឃើញការពិត ករណីដែលសហព្រះរាជអាជ្ញាអន្តរជាតិមិនបានលើកឡើងពីអង្គហេតុសំខាន់ៗទាំងនេះ ។

១៩៨. ស្រដៀងគ្នានេះដែរ យោងតាមចម្លើយរបស់សាក្សី សែន សុផុន ដែលលើកឡើងថា ក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីត្រូវបានផ្ទេរទៅភូមិភាគពាយព្យ គាត់លែងបានឮឈ្មោះ តា វ៉ាល់ ទៀតហើយ ប៉ុន្តែគាត់បានឮឈ្មោះ អ្នកស្រី អ៊ឹម ចែម វិញ[720] ។ ពិតណាស់ ដែលការលើកឡើងនេះមិនមានតម្លៃជាភស្តុតាង មិនត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ហើយចុងក្រោយទៅ បានត្រឹមតែធ្វើឱ្យមានឮសន្ធកម្មតែប៉ុណ្ណោះ ។ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិ ពឹងផ្អែកលើភស្តុតាងនេះក្តី ក៏វាមិនអាចផ្តល់តម្លៃជាភស្តុតាងពិតប្រាកដណាមួយពាក់ព័ន្ធនឹងសំណួរថាតើអ្នកស្រី អ៊ឹម ចែម បានគ្រប់គ្រងការដ្ឋានមួយចំនួនដូចម្តេច ខណៈដែលពីមុនមកគ្រប់គ្រងដោយ តា វ៉ាល់ ។ ទោះក្នុងករណីណាក៏ដោយ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹង ប៉ុន្តែធ្វើជាមិនដឹងថា សែន សុផុន

717 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/139** ឆ:33 ["តាវ៉ាល់ជាអ្នកគ្រប់គ្រងកងចល័តតំបន់ ៥"] ឆ:34 ["តាវ៉ាល់ត្រូវបានចាប់ខ្លួន ហើយជំនួសដោយកម្មាភិបាលនិរតីឈ្មោះ ញ៉ារ វិញ"], ស-ឆ:40 ["ស៖ ក្រោយពេល តាវ៉ាល់ និងតាហ៊ឹង បានបាត់ខ្លួន តើលោកធ្វើការនៅក្នុងកងចល័តនៅក្រោមការគ្រប់គ្រងរបស់នរណា? ឆ:40 ៖ ខ្ញុំធ្វើការនៅក្រោមការគ្រប់គ្រងរបស់ តាញ៉ារ។ ខ្ញុំបានធ្វើការនៅកងចល័តរហូតដល់បែករបបខ្មែរក្រហម"]។

718 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/139** ឆ:38។

719 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/139** ឆ:59។

720 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៦) *ដែលយោងដល់* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី (សក្ខីកម្មរបស់សាក្សី សែន សុផុន) ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/494.1.1**, KH 01122556។

បានគូសបញ្ជាក់បន្ថែមទៀតថា គាត់ "មិនដែលបានឃើញ តា វ៉ាល់ ឬយាយ ចែម ផង" [721] ហើយគាត់ក៏ "មិនបានដឹងរឿងច្រើន" ពីអ្នកស្រី អ៊ឹម ចែម ដែរ[722] ។

១៩៩. ឯកសារសំអាងនៅសល់ពីរទៀតដែលសហព្រះរាជអាជ្ញាអន្តរជាតិពឹងផ្អែក រឹតតែគ្មានតម្លៃជាភស្តុតាង ។ ឯកសារសំអាងទាំងនេះ គឺមិនពាក់ព័ន្ធទាល់តែសោះទៅនឹងបញ្ហាដែលចោទឡើង និងគ្រាន់តែប្រើដើម្បីបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះប៉ុណ្ណោះ[723] ។

២០០. ការវាយតម្លៃដោយយុត្តិធម៌លើភស្តុតាងក្នុងសំណុំរឿង004/1 បង្ហាញយ៉ាងច្បាស់ថា ក្រោយការចាប់ខ្លួនរបស់ តា វ៉ាល់ នៅអំឡុងខែ មិថុនា ឆ្នាំ ១៩៧៧ តា ពាល់ ត្រូវបានជំនួស ក្នុងនាមជាប្រធានកងចល័តតំបន់៥[724] ។ សាក្សី ឈុំ សេង ដែលធ្វើការនៅស្ថានីយ៍បូមទឹកនៅការដ្ឋានស្ពានស្រែង ទទួលបានដំណឹងក្នុងពេលប្រជុំថា "ពីពេលនេះទៅ តា ពាល់ ជាអ្នកគ្រប់គ្រងជំនួស តាវ៉ាល់

---

[721] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ 002/19-09-2007-អវតក/អជសដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី (សក្ខីកម្មរបស់សាក្សី សែន សុផុន) ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **D219/494.1.1**, KH 01122556។

[722] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/506** ឆ36។

[723] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៦) *ដែលយោងទៅលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **D119/65** ឆ:65 [ដែលនិយាយថាអ្នកស្រី អ៊ឹម ចែមត្រូវបានតែងតាំងជាគណៈស្រុកព្រះនេត្រព្រះ]។ បទសម្ភាសន៍របស់អង្គការយុវសន្តិភាព ជាមួយ អ៊ឹម ចែម គ្មានកាលបរិច្ឆេទ ឯកសារ **D219/264.1**, KH 01107032 [ដែលនិយាយថា អ្នកស្រីបានក្លាយជាលេខាស្រុកព្រះនេត្រព្រះ]។

[724] កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:103 ["គឺតាពាល់ដែលជាអ្នកមកពីនិរតី (ឡើងជំនួស តា វ៉ាល់)"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ឆ:23 ["គឺឈ្មោះតាពាល់ជាអ្នកជំនួស តា វ៉ាល់"] ឆ:33 ["នៅព្រឹកមួយនោះ គេបានកោះប្រជុំ ហើយតារិន បានប្រកាសថា ពីពេលនេះទៅ តាពាល់ជាអ្នកគ្រប់គ្រងជំនួស តា វ៉ាល់"]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម គឹមរស់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D123/1/2.44**, KH 00927071, 00927072 [ដែលនិយាយថា តា ពាល់ឡើងជំនួស តា វ៉ាល់ និងមានឋានៈដូចគាត់ដែរ និងនិយាយថា តា ពាល់ បានចុះទៅការដ្ឋាន]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈិត យឿក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.9**, KH 00728819, 00728820 [ដែលនិយាយថា តា ពាល់ ឡើងជំនួស តា វ៉ាល់]។

ពីព្រោះ តា វ៉ាល់ ត្រូវបានអង្គការហៅទៅរៀនសូត្រ"[725] ។ នៅ ចាត់ ដែលធ្វើការនៅការដ្ឋានស្ពានស្រែងក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី និងពាយព្យ[726] បានគូសបញ្ជាក់ថា តា ពាល់ គឺជាអ្នកគ្រប់គ្រងមកពីភូមិភាគនិរតីតែមួយគត់នៅក្នុងការដ្ឋាន[727] ។ ដូច តា វ៉ាល់ ដែរ តា ពាល់ ជាអ្នកគ្រប់គ្រងទាំងស្រុងលើការដ្ឋាននេះ[728] និងត្រូវរាយការណ៍ជាផ្លូវការទៅលេខាតំបន់[729] ។

---

725 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ឆ:33, ឆ:35។

726 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:230។

727 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:232។

728 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:228 ["ប្រឡាយនេះ គឺតាពាល់ជាអ្នកគ្រប់គ្រងបន្តពេលពួកនិរតីមកដល់"] ឆ:230 [ដែលនិយាយថា គាត់បន្តធ្វើការនៅប្រឡាយស្ពានស្រែង ហើយ តា ពាល់ ជាអ្នកគ្រប់គ្រង] ឆ:232 [ដែលនិយាយថា តាពាល់គឺជាអ្នកគ្រប់គ្រងភូមិភាគនិរតីតែមួយគត់នៅប្រឡាយស្ពានស្រែង]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ឆ:23 ឆ:33 ឆ:35 [ដែលនិយាយថា តា វ៉ាល់ ដែលគ្រប់គ្រងការដ្ឋានស្ពានស្រែងនៅឆ្នាំ ១៩៧៧ ត្រូវបានឡើងជំនួសដោយតាពាល់]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:26, ឆ:31 [ដែលនិយាយថា ខុន គឺជាប្រធានកងចល័តក្នុងស្រុកព្រះនេត្រព្រះ ហើយ "ជួនកាល តា រិន និងតា ពាល់ (អ្នកនិរតី) បានពិនិត្យមើលការដ្ឋានស្ពានស្រែង និងអូរលៀបផ្ទាល់" នៅដើមឆ្នាំ ១៩៧៨]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:97 [ដែលនិយាយថា ប្រឡាយស្ពានស្រែង និងប្រឡាយអូរលៀប ត្រូវបានលើកដោយកងចល័តតំបន់] ឆ:99 [ដែលនិយាយថា ការដ្ឋានប្រឡាយអូរលៀបស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់តំបន់]។

729 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130**, ស-ឆ:164 ["ស៖ លោកនិយាយពីតាពាល់ដែលឡើងជំនួស តា វ៉ាល់។ តើតាពាល់ពេលនោះ គាត់រាយការណ៍ទៅឱ្យអ្នកណា? ឆ៖ គាត់រាយការណ៍ទៅឱ្យថ្នាក់តំបន់ ព្រោះគាត់ទទួលខុសត្រូវតំបន់ចល័ត"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣-១៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/455** ឆ:54 ["ខ្ញុំនៅការដ្ឋានបោកស្រូវ (នៅការដ្ឋានស្ពានស្រែង) ជាមួយពាល់ ដែលជាប្រធានកងចល័តតំបន់ ៥ ដែលមកជំនួស តា វ៉ាល់។ នៅពេលនោះ រិន ដែលជាប្រធានតំបន់ ៥ តែងមកមើលការដ្ឋាន។"] ឆ:90 ["តា រិន ជាប្រធាន តា ពាល់"]។ *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី (សក្ខីកម្មរបស់សាក្សី ប៉ាន

២០១. ការអះអាងបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រី អ៊ឹម ចែម គឺជាប្រធានរបស់ តា ពាល់[730] គឺផ្អែកលើការជ្រើសសម្រាំងយកចម្លើយដោយអន្លើៗតាមចិត្តខ្លួនឯង ។ អំណះអំណាងដែលថា ឆៅ ចាត់, កោ ឡិន, យ៉ែម គឹមរស់, និង ឈិត យឿក[731] គាំទ្រករណីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាប្រការខុសឆ្គងទាំងស្រុង[732] ។ ពួកគាត់បានបញ្ជាក់ថា ការដ្ឋានទាំងនេះ ដែលពីមុនស្ថិតក្រោមការគ្រប់គ្រងរបស់ តា វ៉ាល់ ត្រូវបានឡើងជំនួសដោយ តា ពាល់ មិនមែនអ្នកស្រី អ៊ឹម ចែម នោះទេ ។

២០២. ក្នុងការបញ្ជាក់បន្ថែមទៀត ពីវិធីសាស្ត្រចម្លែករបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបញ្ហាជាក់ស្តែងនៃការពន្យល់នូវហេតុសេចក្តីរបស់គាត់ គេគប្បីពិនិត្យពិច័យមើលលើភស្តុតាងដែលផ្តល់ដោយសាក្សី សួរ ចាន់សារ៉េត និងចរិតលក្ខណៈនៃការផ្អែកលើភស្តុតាងនេះ ។ ទីមួយ ចម្លើយរបស់សាក្សី សួរ ចាន់សារ៉េត ត្រូវបានពឹងផ្អែកត្រង់ចំណុចដែល គាត់និយាយថា គាត់ទទួលបានលិខិតណែនាំពី តា ពាល់ ឱ្យជួបជាមួយអ្នកស្រី អ៊ឹម ចែម[733] ។ តាមធម្មតា ចំណុចនេះមិនអាចបញ្ជាក់បានថា អ្នកស្រី អ៊ឹម ចែម មានមុខតំណែងគ្រប់គ្រងលើ តា ពាល់ ឡើយ ប៉ុន្តែវាគ្រាន់តែជាការបង្ហាញថា សាក្សី សួរ ចាន់សារ៉េត មិនអាចធ្វើដំណើរទៅទីណាមួយ ដោយគ្មានលិខិតអនុញ្ញាតបានទេ ពោលគឺវាដូចគ្នាស្ថានភាពប្រជាជនផ្សេងទៀតដែរ ដែលរស់ក្រោមរបបកម្ពុជា

---

ឈូង) ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ **E1/359.1**, KH 01175867 ["ដែលណែនាំឱ្យខ្ញុំធ្វើនេះគឺ តា ហ៊ង្ស គាត់បញ្ជាមក តា វ៉ាល់, តា វ៉ាល់ បញ្ជាឱ្យខ្ញុំធ្វើប៉ុណ្ណោះឯង ខ្ញុំធ្វើតាមបទបញ្ជានេះឯង"]។

730 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២។

731 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៩), *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:103 ឆ228។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:26, ឆ:31។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម គឹមរស់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D123/1/2.44**, KH 00927071, 00927072។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈិត យឿក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.9**, KH 00728819, 00728820។

732 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២។

733 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៩) *ដែលយោងដល់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣-១៤ ខែ សីហាឆ្នាំ ២០១៥ ឯកសារ **D219/455** ឆ:68, ឆ:91។

ប្រជាធិបតេយ្យ[734] ។

២០៣. ដោយអបអរនឹងបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិបានព្យាយាមដោះស្រាយភាពខ្វះចន្លោះដែលបានកើតឡើង ។ ចម្លើយរបស់សាក្សី សូរ ចាន់សារ៉េត ត្រូវបានដកស្រង់ក្នុងដីកាសន្និដ្ឋានស្ថាពរដូចខាងក្រោម ៖

> ឯកសារ **D219/455** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូរ ចាន់សារ៉េត នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥, ឆ:91, KH 01129820 មានខ្លឹមសារដូចតទៅ៖ ["បើគិតតាមឋានានុក្រម តាពាល់ ជាប្រធានចល័តតំបន់ ចំណែកយាយថែមជាគណៈស្រុក ដូច្នេះឋានៈតាពាល់គួរណាតែខ្ពស់ជាងយាយថែម តែតាមការសង្កេតឃើញថា តាពាល់ដូចជាគោរពកោតខ្លាចយាយថែមខ្លាំងណាស់ [...]។ បានន័យថា យាយថែមប្រាកដជាមានឋានៈអ្វីមួយខ្ពស់ជាងតាពាល់។ ខ្ញុំសង្កេតឃើញផងដែរថា ក្នុងចំណោមគណៈស្រុកទាំងអស់ យាយថែមមានអំណាចលើសគេ[...]។ ខ្ញុំឃើញ តាពាល់ដូចជាគោរពគាត់ណាស់"][735]។

---

734 *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហូ ហឿន ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **D219/285** ឆ:2 ["ពីមុន យើងដើរហើរសេរី តែដល់ពេលខ្មែរក្រហមឡើងកាន់កាប់អំណាច ពេលយើងធ្វើដំណើរទៅណាមក ណា យើងទាល់តែមានលិខិតអនុញ្ញាតត្រឹមត្រូវ បានអាចធ្វើដំណើរទៅណាមកណាបាន"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គាន ឡី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **D117/57** ឆ:16 ["មុនពេលចេញដំណើរ ខាងសង្កាត់គេចេញលិខិតឧទ្ទេសនាមឱ្យធ្វើដំណើរមួយ ហើយពេលទៅដល់កន្លែងណាមួយ ខ្ញុំក៏បង្ហាញលិខិតនោះទៅឱ្យអាជ្ញាធរភូមិគេដឹងឮ និងឱ្យគេជួយផ្គត់ផ្គង់តាមសំណូមពរ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ួង សារ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D118/199** ឆ43 ["នៅសម័យនោះក្នុងការដើរទៅកន្លែងផ្សេង បើពុំមានលិខិតដើរផ្លូវដែលស៊ីញ៉េដោយមេក្រុមនោះទេ គឺពុំអាចដើរទៅណាបានទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ថ្ងៃទី ៣-៥ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/442** ឆ:135 ["ជាធម្មតា ប្រធានមន្ទីរជាអ្នកចេញលិខិតធ្វើដំណើរ។ ប្រធានមន្ទីរជាអ្នកទទួលខុសត្រូវលើការធ្វើដំណើររបស់បុគ្គលិកដែលធ្វើតាមគាត់។ សម្រាប់កម្មាភិបាលជាន់ខ្ពស់ ដូចជា លេខាស្រុកជាដើម ពួកគេត្រូវប្រាប់តាអានឱ្យបានដឹង ខ្ញុំមិនដឹងថា អាំ ឬក៏អួន រាយការណ៍ទៅតាអាន យ៉ាងណានោះឡើយ"]។

735 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៩) (សេចក្តីបញ្ជាក់បន្ថែម)។

២០៤. ទោះជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាអន្តរជាតិបានលុបចេញនូវការសំអាងលើចម្លើយពីមុនរបស់សាក្សី សួរ ចាន់សារ៉េត ដែលមានក្នុងសេចក្តីថ្លែងការណ៍តែមួយ ។ នៅក្នុងចម្លើយពីមុនរបស់គាត់ សាក្សី សួរ ចាន់សារ៉េត បានបញ្ជាក់យ៉ាងច្បាស់ថា "តា រិន [ប្រធានតំបន់ ៥] ជាប្រធានរបស់ តា ពាល់ ។ តា រិន មកកន្លែងខ្ញុំធ្វើការជាញឹកញាប់ ។ ខ្ញុំធ្លាប់ហូបបាយជាមួយ តា រិន ម្តងដែរ ។ គាត់សាមញ្ញណាស់"[736] ។

២០៥. លើសពីនេះ ចំណុចបន្តបន្ទាប់ទៀត គឺត្រូវតែយកមកធ្វើការពិចារណា ។ ទីមួយ សាក្សី សួរ ចាន់សារ៉េត បានចាប់ផ្តើមចម្លើយរបស់គាត់ដោយនិយាយថា "ខ្ញុំមិនច្បាស់ទេ [ពីការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ក្នុងតំបន់នោះឡើយ]" និងបានបញ្ជាក់ក្នុងចម្លើយជាបន្តបន្ទាប់ថា គាត់មិនដែលបានចូលរួមក្នុងកិច្ចប្រជុំជាមួយអ្នកស្រី អ៊ឹម ចែម ទេ ។ ទីពីរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត តាមការពិតមានកំហុសឆ្គងក្នុងការបកប្រែ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីក្នុងឯកសារដើមជាភាសាខ្មែរបញ្ជាក់ថា "តា ពាល់ ដូចជាគោរពកោតខ្លាចយាយចែមខ្លាំងណាស់" ដែលចំណុចនេះ ត្រូវបានបកប្រែខុសជាភាសាអង់គ្លេសក្នុងន័យជាភាសាខ្មែរថា "តាពាល់ខ្លាចយាយចែមខ្លាំងណាស់"[737] ។

២០៦. ជាធម្មតា យោងតាមអំណាចរបស់គាត់ក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម ធ្វើការនៅថ្នាក់ក្រោម តា ពាល់[738] ។ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ្នកស្រីគ្រប់គ្រង តា ពាល់ មិនមានភស្តុតាងបញ្ជាក់ពេញលេញឡើយ ពោលគឺ បន្ទាប់ពីអ្នកស្រីត្រូវបានតែងតាំងឱ្យក្លាយជាលេខាស្រុកព្រះនេត្រព្រះ អ្នកស្រី អ៊ឹម ចែម បានទទួលផែនការការងារសម្រាប់ស្រុកព្រះនេត្រព្រះ ដូចជា ការងារពាក់ព័ន្ធនឹងការលើកទំនប់ និងជីកប្រឡាយ ក្នុងអំឡុងកិច្ចប្រជុំជាមួយ

---

[736] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣-១៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **D219/455** ធ:90។

[737] *ប្រៀបធៀបនឹង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់ សារ៉េត ថ្ងៃទី ១៣-១៤ ខែសីហា ឆ្នាំ ២០១៥ ឯកសារ **D219/455** (KH 01129820, EN ERN 01151199)។

[738] *ប្រៀបធៀបនឹង* ចម្លើយតប នៅកថាខណ្ឌ ៩៩-១០០។

ថ្នាក់លើ[739] ។ បន្ទាប់មក អ្នកស្រីជួបជាមួយសមាជិកគណៈភូមិ និងគណៈឃុំពាក់ព័ន្ធដើម្បីអនុវត្តផែនការទាំងនេះ[740] ។ ដូច្នេះ ការលើកឡើងដែលថា អ្នកស្រី អ៊ឹម ចែម ជួបជាមួយ តា ពាល់ ដើម្បីពិភាក្សាពីតួនាទីរបស់អ្នកស្រីក្នុងន័យនេះ គឺជារឿងធម្មតា និងមិនអាចបញ្ជាក់បានថា អ្នកស្រីមានសិទ្ធិអំណាចលើ តា ពាល់ ឡើយ[741] ។ អង្គហេតុដែលថាមានកិច្ចប្រជុំមួយចំនួនត្រូវបានរៀបចំឡើងដោយថ្នាក់តំបន់ គឺធ្វើឡើងដើម្បីសុំកម្លាំងពលកម្មពីថ្នាក់ក្រោមឱ្យទៅធ្វើការនៅការដ្ឋានស្ពានស្រែង[742] ។

---

739 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, KH 00929732 ["[ផែនការការងារ] ដាក់ពីភូមិភាគចុះមកខេត្ត ចុះមក។ ភូមិភាគមានតាញឹម ហើយដល់ខេត្តមានឈ្មោះតាឡៃ នៅស្វាយស៊ីសុផុន។ ដើរគាត់ដាក់មកបន្តចឹងមក ដូចថា ឥឡូវយើងពីខេត្តមកស្រុក ពីស្រុកមកឃុំចឹងទៅណា...។ ទទួលគេហៅយើងប្រជុំ ហៅទៅប្រជុំទៅទទួលផែនការ ដូចថា ខែនេះត្រូវធ្វើទំនប់ធ្វើប្រឡាយ ធ្វើស្រែប្រាំងអីហ្នឹងហែចឹងណា។ ចឹងយើងរៀបចំកម្លាំងសម្រាប់មកខាងក្រោយដើម្បីដាំដុះកម្លាំងនៅខាងមុខ ។ ខ្ញុំចែកជាពីរកម្លាំងនៅខាងមុខនៅការដ្ឋានហ្នឹង ហ្នឹងមួយផ្នែកដាច់ចឹងទៅ កម្លាំងនៅខាងក្រោយដាំដុះធ្វើស្រែប្រាំង ស្រែវស្សាហ្នឹងដាច់ទៅ"]។

740 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **D119/52** ឆ:18 [ដែលរំឭកថាគាត់ធ្លាប់ជួបអ្នកស្រី អ៊ឹម ចែម ដើម្បីពិភាក្សាពីការងារលើកទំនប់ និងប្រឡាយពីត្រពាំងថ្ម ទៅភ្នំលៀប]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ម៉ន ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/96** ឆ:74-77 [ដែលកត់សម្គាល់ថាអ្នកស្រី អ៊ឹម ចែម និយាយតែអំពី "ការប្រមូលផលស្រូវ ការលើកទំនប់ជីកប្រឡាយ ដូចជា នៅស្ពានតាប៉ុន។ល។" ក្នុងអង្គប្រជុំដែលធ្វើឡើងរៀងរាល់ពីរទៅបីខែម្តងក្នុងស្រុក]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **D119/20** ឆ:9 ["កាលនោះ គាត់បានលើកឡើងអំពីការខិតខំធ្វើស្រែ និងលើកទំនប់ជីកប្រឡាយ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០១៥ ឯកសារ **D219/397** ឆ:2 [ដែលកត់សម្គាល់ថា នៅពេលអ្នកស្រី អ៊ឹម ចែម បានមកដល់ភ្នំលៀប គាត់បានណែនាំប្រជាជនឱ្យស្តារ និងរៀបចំសេដ្ឋកិច្ច និងរៀបចំធ្វើស្រែចម្ការ។ ក្រោយពីនោះមក គាត់បានដឹកនាំយើងខាងលើកជីកទំនប់ប្រឡាយ]។

741 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦២ (ជើងទំព័រ ១៣៣៩), *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៤ ឯកសារ **D119/98** ឆ:39។

742 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែមីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:49 ["តួនាទីរបស់ខ្ញុំគ្រាន់តែជ្រើសរើសមនុស្ស ដើម្បីបញ្ជូនឱ្យទៅធ្វើការនៅតាមការដ្ឋាននានាពីខាងតំបន់មកទៅតាមសំណើរបស់គេតែប៉ុណ្ណោះ"] ឆ:51 ["ខ្ញុំត្រូវរាយការណ៍ឱ្យទៅថ្នាក់តំបន់ដែលគេបានធ្វើការនៅតាមការដ្ឋាននោះ"]។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:27 ["តំបន់ជាអ្នកគ្រប់គ្រងលើការដ្ឋានទាំងនោះ ហើយស្រុកគ្រាន់តែជាអ្នកផ្តល់កម្លាំងពលកម្មតែប៉ុណ្ណោះ នៅពេលដែលតំបន់ស្នើសុំ"]។

២០៧. ជារួម គ្មានការលើកឡើងខាងលើណាមួយដែលបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម ប្រើប្រាស់សិទ្ធិអំណាច*ស្របច្បាប់* ឬ*ជាក់ស្តែង* លើការដ្ឋានស្ពានស្រែង ទៅតាមអ្វីដែលជាការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ ។ ព្រោះតែភាពបរាជ័យក្នុងការបង្ហាញច្បាស់ពីការបរាជ័យរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការព្យាយាមបង្ហាញផ្ទុយពីនេះ ពោលគឺ ភស្តុតាងបែរជាបង្ហាញថា ប្រធានកងចល័តតំបន់៥ ស្ថិតក្រោមការបញ្ជារបស់គណៈតំបន់៥ ។ អ្នកស្រី អ៊ឹម ចែម មិនមានអំណាចបញ្ជាលើជនប្រព្រឹត្តឧក្រិដ្ឋពាក់ព័ន្ធណាម្នាក់ទេ និងមិនបានចូលរួមក្នុងបទឧក្រិដ្ឋបង្កដោយពួកគេ ហើយក៏គ្មានការទទួលខុសត្រូវលើបទឧក្រិដ្ឋទាំងនោះឡើយ ។

### *iii. អ្នកស្រីអ៊ឹម ចែម មិនបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់គ្រប់គ្រាន់ដូចបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងឡើយ*

២០៨. ក្នុងកថាខណ្ឌខាងក្រោមនេះ ក្រុមការពារក្តីគ្រាន់តែលើកឡើងពីអំពើឧក្រិដ្ឋកម្មដែលអ្នកស្រី អ៊ឹម ចែម រងការចោទប្រកាន់ពាក់ព័ន្ធនឹងការដ្ឋានស្ពានស្រែង និងដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងក្នុងដីកាសន្និដ្ឋានស្ថាពរប៉ុណ្ណោះ ។ សម្រាប់មូលហេតុនេះ ការចោទប្រកាន់ពីបទអាពាហ៍ពិពាហ៍ដោយបង្ខំនៅការដ្ឋានស្ពានស្រែង[743] ដែលស្ថិតនៅក្រៅវិសាលភាពនៃបទចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម មិនត្រូវបានលើកឡើងក្នុងចម្លើយតបនេះទេ ។

២០៩. ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិលើអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងការដ្ឋានស្ពានស្រែងកើតចេញពីការអះអាងដែលថា អ្នកស្រីមានសិទ្ធិអំណាចលើការដ្ឋាននេះ[744] ដែលទីនោះមាន "ប្រជាជន*រាប់ពាន់នាក់*ត្រូវបានបង្ខំឱ្យធ្វើការ[745]" និងដែលប្រជាជនបានស្លាប់ដោយសារដាច់អាហារ និងដោយសារជំងឺ[746] និងការបាត់ខ្លួន[747] កើតមាន*យ៉ាងសាយញ្ញទៅហើយ*[748] ។ បទចោទ

[743] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរនៅកថាខណ្ឌ ២៦៩ និង ៤៧៦-៧៧។

[744] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរនៅកថាខណ្ឌ ២៦២-៦៣, ៥៣២។

[745] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤ (សេចក្តីបញ្ជាក់បន្ថែម)។

[746] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៧។

[747] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧០។

ប្រកាន់ទាំងនេះ នឹងត្រូវបានលើកឡើងក្នុងផ្នែកខាងក្រោម ។ ដូចការលើកឡើងខាងលើ[749] ក្រុមការពារក្តីបានអនុវត្តវិធីសាស្រ្តយ៉ាងប្រុងប្រយ័ត្នរបស់ចៅក្រម Bohlander ក្នុងការវាយតម្លៃលើភស្តុតាង[750] ។ ការលើកឡើងខាងក្រោមនេះ គឺជាវិធីសាស្រ្តដែលសហព្រះរាជអាជ្ញាអន្តរជាតិមិនបានយកមកអនុវត្តនោះទេ ។

<u>ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ក្នុងការងារដោយបង្ខំលើពលករ រាប់ពាន់នាក់នៅការដ្ឋានស្ពានស្រែង</u>

២១០. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ្នកស្រី អ៊ឹម ចែម មានបំណងបង្កព្យសនកម្មធ្ងន់ធ្ងរខាងផ្លូវកាយ និង/ឬផ្លូវចិត្ត[751] លើពលករទាំងឡាយ តាមរយៈដាក់ការងារឱ្យធ្វើដោយបង្ខំ *រាប់ពាន់នាក់* នៅការដ្ឋានស្ពានស្រែង[752] ។ វិធីសាស្រ្តរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការវាយតម្លៃចំនួនពលករនៅការដ្ឋានស្ពានស្រែងមានលក្ខណៈសម្រាំងបំផុត ដោយជ្រើសយកតែផ្នែកណាដែលខ្លួនចង់បាន ។ លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនយកចិត្តទុកដាក់លើសំណួរសំខាន់ពាក់ព័ន្ធនឹងចំនួនពលករដែលធ្វើការនៅការដ្ឋានស្ពានស្រែង នៅពេលដែលអ្នកស្រី អ៊ឹម ចែម *មានវត្តមាន* ក្នុងភូមិភាគពាយព្យឡើយ[753] ។ ម្យ៉ាងវិញទៀត យោងតាមទម្រង់វិធីសាស្រ្តសត្យានុម័តចំពោះភស្តុតាងបង្ហាញឱ្យឃើញថា ក្នុងមុខតំណែងរបស់ខ្លួនក្នុងនាមជាលេខាស្រុក អ្នកស្រី អ៊ឹម ចែម គ្មានសិទ្ធិអំណាច *ស្របច្បាប់* ឬ *ជាក់ស្តែង* ដើម្បីគ្រប់គ្រងពលករនៅការដ្ឋានស្ពានស្រែងឡើយ[754] ។

២១១. សហព្រះរាជអាជ្ញាអន្តរជាតិផ្អែកលើការពិពណ៌នាចំនួន ៧ ដើម្បីបញ្ជាក់ថា មានប្រជាជន *រាប់ពាន់*

---

748 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤-៧១។

749 *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ១៥៥។

750 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣១។

751 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៤-៨៥។

752 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៣-៦៤។

753 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២១១-១៣។

754 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២១៤-១៥។

*នាក់*ត្រូវបានបង្ខំឱ្យធ្វើការនៅការដ្ឋានស្ពានស្រែង[755] ។ តាមពិត មានសាក្សីតែ៤នាក់គត់ ដែលត្រូវបានយកមកសំអាងក្នុងដីកាសន្និដ្ឋានស្ថាពរ ដែលបានផ្ដល់នូវតួលេខទាំងនេះ ។ សាក្សីទាំងនោះរួមមាន ជុំ កាន់, ឆោ ចាត់, កោ ឡឹន, និងអ្នកស្រី អ៊ឹម ចែម ផ្ទាល់ ។ សាក្សី ជុំ កាន់ ត្រូវបានសំអាងតាមការអះអាងរបស់គាត់ដែលថា មានពលករ "រាប់ម៉ឺននាក់" ត្រូវបានបញ្ជូនមកពីខេត្តបាត់ដំបងទាំងមូលទៅកាន់ការដ្ឋានទាំងនោះ[756] ហើយថា ភារកិច្ចរបស់គាត់ក្នុងនាមជាគណៈឃុំភ្នំលៀប និងយោងតាមសំណើរបស់ថ្នាក់តំបន់ គឺត្រូវជ្រើសរើសមនុស្សពី ៣០ ទៅ ៤០ នាក់ក្នុងមួយភូមិក្នុងឃុំរបស់ខ្លួនដើម្បីធ្វើការនៅការដ្ឋាននានាក្នុងតំបន់នេះ[757] ។ សេចក្ដីថ្លែងការណ៍របស់ ជុំ កាន់ មានភាពពាក់ព័ន្ធតែត្រឹមអ្វីដែលគាត់បានដឹង ឬជឿជាក់ចំពោះអ្វីដែលគាត់បានស្ដាប់ឮប៉ុណ្ណោះ ។ គាត់ទទួលស្គាល់ថា គាត់មិនដែលបានចុះទៅការដ្ឋានស្ពានស្រែងនោះទេ[758] ហេតុដូច្នេះហើយ គាត់ក៏មិនទំនងជាបានដឹងពីចំនួនមនុស្សដែលធ្វើការនៅទីនោះដែរ ។ លើសពីនេះ ដោយសារតែ ជុំ កាន់ មិនបានផ្ដល់តួលេខពាក់ព័ន្ធនឹងចំនួនពលករដែលគាត់បានជ្រើសរើសឱ្យទៅធ្វើការនៅ*ការដ្ឋានស្ពានស្រែងជាពិសេសនោះ* ដូច្នេះការលើកឡើងរបស់គាត់ មិនបានជួយដល់ការចោទ

---

755 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣), *ដែលយោងដល់* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:46, ឆ:48-49។ ប្រតិចារឹកបទសម្ភាសន៍ អ៊ឹម ចែម ដោយអង្គការយុវសន្តិភាព គ្មានកាលបរិច្ឆេទ ឯកសារ **D219/264.1**, KH 01107031។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, KH 00929735, KH 00929741-42។ បទសម្ភាសន៍របស់ Youth For Peace ជាមួយ អ៊ឹម ចែម, ឆ្នាំ ២០១១ ឯកសារ **D215/1.1.1**, EN ERN 01030495។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/42** ឆ:5។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡឹន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:26។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤-៥ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:68- 69។ កំណត់ ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:54, ឆ:59, ឆ:65។ កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឆោ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:236- 37។

756 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣) *ដែលយោងលើ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:48-49។

757 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:47-49។

758 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:47។

ប្រកាន់ជាក់លាក់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ឡើយ ។

២១២. មានបុគ្គលដែលបានលើកយកមកសំអាងតែ៣នាក់ប៉ុណ្ណោះ គឺ នៅ ចាត់, កោ ឡិន និង អ្នកស្រី អ៊ឹម ចែម ផ្ទាល់ បានផ្តល់ខ្លឹមសារពេញលេញពាក់ព័ន្ធនឹងចំនួនពលករដែលបានធ្វើការនៅការដ្ឋានស្ពានស្រែង ។ នៅ ចាត់ បានបញ្ជាក់ថា មានពលករប្រហែល ៥០០ នាក់បានជីកប្រឡាយទាំងមូលដែលចេញពីស្ពានស្រែងឆ្លងកាត់ភូមិពង្រ ហើយចាក់ទៅដល់ផ្លូវជាតិលេខ៦[759] ។ ទោះបីជា នៅ ចាត់ មិនបានផ្តល់ពេលវេលាជាក់លាក់ណាមួយដែលខ្លួនបានទទួលតួលេខក្តី ក៏អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានធ្វើការនៅការដ្ឋានស្ពានស្រែងក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី និងភូមិភាគពាយព្យ[760] ហេតុដូច្នេះ ការផ្តល់តួលេខនេះ បង្ហាញពីភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន ។ ទោះជាយ៉ាងណាក្តី ចម្លើយរបស់គាត់មិនបានជួយដល់ការបញ្ជាក់ពីកម្រិតអំណាចរបស់អ្នកស្រី អ៊ឹម ចែម បានឡើយ ពោលគឺចម្លើយរបស់គាត់ មិនបានវាស់ស្ទង់នូវចំនួនពលករនៅការដ្ឋានស្ពានស្រែង*ក្រោយពេល*ដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានបញ្ជូនមកកាន់ភូមិភាគពាយព្យទេ[761] ។ សាក្សី កោ ឡិន និង អ្នកស្រី អ៊ឹម ចែម បានផ្តល់ព័ត៌មានលម្អិតទាំងនេះ ។ កោ ឡិន ដែលជាប្រធានកងចល័តនៃគណៈឃុំព្រះនេត្រព្រះនៅការដ្ឋានស្ពានស្រែង បានគូស

---

[759] *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣), *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130**, ស.-ឆ:236 [ស៖ "តើលោកអាចស្មានថាតើអ្នកធ្វើការទាំងអស់ដែលធ្វើការនៅប្រឡាយនោះ នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតីមានប៉ុន្មាននាក់ដែរ? ឆ:236៖ មិនច្រើនទេ នៅតែបីកងទេ។ ប្រហែល ១០០ នាក់ (សម្រាប់ស្រុកភ្នំស្រុក)"], ស-ឆ:237 [ស៖ ១០០ នាក់ហ្នឹងគឺជីកប្រឡាយ ឬក៏ធ្វើស្ពាន? ឆ:237៖ មានអ្នកធ្វើស្ពានផ្សេង។ ប្រហែល ៥០០ នាក់ដែលជីកប្រឡាយទាំងមូលដែលចេញពីស្ពានស្រែងឆ្លងកាត់ភូមិពង្រ ហើយទៅដល់ផ្លូវជាតិលេខ៦"]។

[760] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:230។

[761] ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦៣-៦៤។

បញ្ជាក់ថា កងចល័តរបស់គាត់មានពលករ "ប្រហែល ២០០ នាក់[762]" ។ ចម្លើយនេះ ស៊ីសង្វាក់គ្នានឹងការដឹងឮរបស់អ្នកស្រី អ៊ឹម ចែម ដែរ ដែលអ្នកស្រីបានថ្លែងដូច្នេះថា មានពលកររហូតដល់ ៨០០ នាក់ដែលត្រូវបានបញ្ជូនមកពីស្រុកព្រះនេត្រព្រះ ពោលគឺ មានពលករចំនួន ២០០ នាក់ក្នុងមួយឃុំ ត្រូវបានចាត់ឱ្យទៅធ្វើការនៅការដ្ឋានស្ពានស្រែងក្នុងអំឡុងពេលដែលអ្នកស្រីធ្វើជាលេខាស្រុក[763] ។ ដោយពិចារណាក្នុងកម្រិតខ្ពស់បំផុត តួលេខនេះ គឺស្មើនឹងចំនួនពលករតិចជាង ១.០០០ នាក់នៅការដ្ឋានស្ពានស្រែងក្នុងអំឡុងពេលពាក់ព័ន្ធ មិនមែនដូចការចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលថាមានពលករ*រាប់ពាន់នាក់* ធ្វើការនៅការដ្ឋានស្ពានស្រែងនោះឡើយ ។

២១៣. មានភស្តុតាងតិចតួចដែលបង្ហាញថា ការពិពណ៌នាទាំងបីនេះមិនបង្ហាញពីការប៉ុនប៉ងដោយទៀងត្រង់នោះទេក្នុងការផ្តល់ការរៀបរាប់ពីចំនួនទាំងនេះ ។ ជំនួសឱ្យការប្រឈមជាមួយភស្តុតាងទាំងនេះដោយយុត្តិធម៌ និងសត្យានុម័តភាព សហព្រះរាជអាជ្ញាអន្តរជាតិបានគេចវេសពីលក្ខខណ្ឌតម្រូវទាំងនេះទៅវិញ ដោយសម្រេចគាំទ្រការអះអាងដែលថាមានពលករ*រាប់ពាន់នាក់* តាមរយៈការផ្អែកលើភស្តុតាងផ្សេងទៀតដែលមិនមានភាពពាក់ព័ន្ធ និងខ្វះតម្លៃជាភស្តុតាង ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិបានផ្អែកលើសាក្សី ក្រូច ទឹម[764] ដែលបានធ្វើការនៅការដ្ឋានស្ពានស្រែង *មុនពេលដែល*អ្នកស្រី អ៊ឹម ចែម ត្រូវបានបញ្ជូនទៅភូមិភាគពាយព្យ[765] សាក្សី ហ៊ាក

---

[762] *សូមមើលជាឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:26។

[763] *សូមមើលជាឧទាហរណ៍* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ **D123/1/5.1a**, KH 00929741-42 [ដែលនិយាយថា មានពលករ ៨០០ នាក់៖ មួយឃុំ ២០០ នាក់ដើម្បីលើកប្រឡាយមួយពីទំនប់ស្ពានស្រែង ទៅទំនប់ព្រៃរនាម]។

[764] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣), *ដែលយោងទៅលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:68-69។

[765] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:73-74 [ដែលនិយាយថា គាត់បានធ្វើការនៅការដ្ឋានស្ពានស្រែង "ប្រហែលជានៅដើមឆ្នាំ ១៩៧៧" ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលភូមិភាគពាយព្យ]។

ស[766] ដែលបានធ្វើការនៅទីតាំងមួយចំនួននៃការដ្ឋាននេះដែលស្ថិតក្នុងស្រុកភ្នំស្រុក[767] និងសាក្សី ក្រិត រិត[768] ដែលមិនបានផ្តល់តួលេខពាក់ព័ន្ធនឹងចំនួនពលករនៅការដ្ឋានស្ពានស្រែង[769] ។ ប្រាកដណាស់ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថាអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងការបង្ខំពលករ*រាប់ពាន់នាក់*ឱ្យធ្វើការនៅការដ្ឋានស្ពានស្រែង មិនបានផ្អែកលើភស្តុតាងជាក់លាក់ ឬស៊ីសង្វាក់គ្នាឡើយ ។

២១៤. លើសពីនេះទៀត ទោះបីជាការអះអាងនេះមានការពាក់ព័ន្ធនឹងភស្តុតាងនេះក៏ដោយ ក៏ភស្តុតាងផ្សេងទៀតបង្ហាញថា អ្នកស្រីអ៊ឹម ចែម មិនមានសិទ្ធិអំណាច*ស្របច្បាប់* ឬ*ជាក់ស្តែង*ក្នុងការគ្រប់គ្រងពលករទាំងអស់នៅការដ្ឋានស្ពានស្រែងនោះទេ[770] ។ ផ្អែកលើការវាយតម្លៃសមហេតុផល និងយុត្តិធម៌មួយ បង្ហាញថាតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងការដ្ឋានស្ពានស្រែង ត្រូវបានកម្រិតត្រឹមតែការផ្តល់កម្លាំងតាមសំណើរបស់កម្មាភិបាលថ្នាក់តំបន់តែប៉ុណ្ណោះ ។ ជុំ កាន់ អតីតលេខាឃុំភ្នំលៀប បានរម្លឹកឡើងវិញនូវកិច្ចប្រជុំមួយដែលបានធ្វើឡើងនៅមន្ទីរស្រុកព្រះនេត្រព្រះ ដែលក្នុងអំឡុងពេលនោះកម្មាភិបាលតំបន់៥ បានស្នើសុំមនុស្សពីមូលដ្ឋានឱ្យទៅធ្វើការនៅការដ្ឋាន

---

766 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣), *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:54, ឆ:59, ឆ:65។

767 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **D219/357** ឆ:54, ឆ:49, ឆ:65 [ដែលនិយាយថា មានសមាជិក ១៥០ នាក់ក្នុងកងចល័តរបស់ស្រុកភ្នំស្រុក ហើយគាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានស្ពានស្រែងដែលស្ថិតក្នុងស្រុកភ្នំស្រុក]។

768 *សូមមើល* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦៤ (ជើងទំព័រ ១៣៤៣) *ដែលយោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/42** ឆ5 ["ក្នុងកងចល័តមានមនុស្សរាប់ពាន់នាក់ហើយត្រូវមានឧបករណ៍ជាប់នឹងខ្លួន ដូចជា បង្គី ចប ប៉ែល ហើយនិងត្រូវផ្លាស់ទីពីការដ្ឋានមួយទៅការដ្ឋានមួយ"]។

769 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/42** ឆ:5។

770 *ប្រៀបធៀប* ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦២។

នានា[771] ។ ទោះបីមានវត្តមាននៅក្នុងកិច្ចប្រជុំនោះក្តី ក៏អ្នកស្រី អ៊ឹម ចែម មិនបាននិយាយអ្វីឡើយ[772] ។ សាក្សី ជុំ កាន់ បានពន្យល់បន្ថែមទៀតថា ភារកិច្ចរបស់គាត់គឺត្រូវផ្តល់ពលករតាមសំណើរបស់ថ្នាក់តំបន់[773] ។ ពុំ ខូ ដែលបានធ្វើការនៅក្នុងគណៈស្រុកព្រះនេត្រព្រះ បានថ្លែងថា កម្មាភិបាលថ្នាក់ស្រុកមានភារកិច្ចដូចគ្នាក្នុងការផ្តល់នូវកម្លាំងឱ្យទៅធ្វើការតាមការដ្ឋានផ្សេងៗ នៅថ្នាក់តំបន់[774] ។

២១៥. និយាយម្យ៉ាងទៀត សិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម នៅការដ្ឋានស្ពានស្រែង បើទោះជាមានក៏ដោយ ក៏វាអាចត្រូវបានកម្រិតត្រឹមការជ្រើសរើសពលករពីស្រុករបស់អ្នកស្រីតែប៉ុណ្ណឹង។ វាគ្មានអ្វីដែលមិនប្រក្រតីនោះទេដែលអ្នកស្រី អ៊ឹម ចែម យូរៗម្តងបានចុះទៅពិនិត្យមើលការដ្ឋានស្ពានស្រែងនោះ[775] ។ ការណ៍ដែលគាត់កម្រចុះទៅមើលការដ្ឋាននោះ ត្រូវបានបញ្ជាក់ដោយការពិត

---

[771] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:57-59 [ដែលរំលឹកឡើងវិញនូវកិច្ចប្រជុំមួយនៅមន្ទីរស្រុកថា មនុស្សមកពីឃុំនីមួយៗ បានចូលរួមការប្រជុំ ដែលអំឡុងពេលនោះ កម្មាភិបាលថ្នាក់តំបន់បានស្នើកម្លាំងពីមូលដ្ឋាន]។

[772] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:63។

[773] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:49, ["តួនាទីរបស់ខ្ញុំគ្រាន់តែជ្រើសរើសមនុស្ស ដើម្បីបញ្ជូនឱ្យទៅធ្វើការនៅតាមការដ្ឋាននានាពីខាងតំបន់មកទៅតាមសំណើរបស់គេតែប៉ុណ្ណោះ"] ឆ:51 ["ខ្ញុំត្រូវរាយការណ៍ឱ្យទៅថ្នាក់តំបន់ដែលគេបានធ្វើការនៅតាមការដ្ឋាននោះ"]។

[774] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ,ថ្ងៃទី ៦-៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **D219/23** ឆ:27 ["តំបន់ជាអ្នកគ្រប់គ្រងលើការដ្ឋានទាំងនោះ ហើយស្រុកគ្រាន់តែជាអ្នកផ្តល់កម្លាំងពលកម្មតែប៉ុណ្ណោះ នៅពេលដែលតំបន់ស្នើសុំ"]។

[775] *សូមមើល*ដីកាសន្និដ្ឋានស្ពាពរ នៅកថាខណ្ឌ ២៦៣។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/139** ឆ:60 ["នៅពេលដែលខ្ញុំធ្វើការនៅការដ្ឋានប្រឡាយស្ពានស្រែង តា សន និងតា វ៉ាល់ គឺជាអ្នកគ្រប់គ្រងផ្ទាល់នៅការដ្ឋានប្រឡាយស្ពានស្រែងនោះ ប៉ុន្តែពេលមួយនោះ ខ្ញុំធ្លាប់បានឃើញយាយ ចែម និងកម្មាភិបាលពីរបីនាក់ផ្សេងទៀត បានចុះទៅមើលការដ្ឋាននោះដែរ"]។ កំណត់ហេតុនៃកិច្ចស៊ើបសួរ (កោ ឡិន) ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/129**, KH 01001320, [ដែលនិយាយថា គាត់បានឃើញអ្នកស្រី អ៊ឹម ចែម ចុះទៅពិនិត្យមើលប្រឡាយមួយដែលតភ្ជាប់ទៅការដ្ឋានស្ពានស្រែង និងថា ពេលខ្លះអ្នកស្រីអ៊ឹម ចែម បានរែកដីដោយខ្លួនគាត់]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:32 [ដែលនិយាយថា អ្នកស្រីអ៊ឹម ចែម បានចុះពិនិត្យមើលការដ្ឋានអូរលៀប និងបានជួយពលករនៅទីនោះ]។

ដែលថា ភាគច្រើននៃអតីតពលករនៅការដ្ឋានស្ពានស្រែងដែលបានអះអាងដូច្នេះ គឺដោយសារថា ពួកគេមិនបានស្គាល់អ្នកស្រី អ៊ឹម ចែម[776] ឬមិនដែលបានឃើញអ្នកស្រីទៅមើលការដ្ឋាននោះ[777] ។ តាមពិត ទោះបីជាមានភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម អាចមានសិទ្ធិអំណាចលើអ្នកដែលមកពីស្រុកកំណើតរបស់អ្នកស្រីក៏ដោយ[778] ក៏ទាំងសាក្សី ជុំ កាន់ (ជាអ្នកដែលបានជ្រើសរើសពលករពីបណ្តាភូមិនានា) និង កោ ឡឺន (ជាអ្នកដែលបានដឹកនាំកងចល័តឃុំ) បាននិយាយថា ពួក

---

[776] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ មុត ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D219/1** ឆ:77 ["ខ្ញុំមិនដែលឮ" ពីអ្នកស្រីអ៊ឹម ចែម ទេ] ឆ:83 ["ខ្ញុំមិន"ចាំថា នរណាបានគ្រប់គ្រងការដ្ឋានស្ពានស្រែងនោះទេ]។

[777] ប្រតិចារឹកនៃបទសម្ភាសន៍សាក្សី តក់ ប៊ុយ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **D219/422.8**, KH 01121353 ["សះ ប៉ុន្តែសំណួរខ្ញុំចង់សួរថា តើពេលដែលលោកពូធ្វើការជីកប្រឡាយនៅឯស្ពានស្រែងហ្នឹង លោកពូមានដែលជួបយាយ ចែម ដែរអត់ទេ? ឆះ មិនដែលទេ។ ខ្ញុំមិនដែលឃើញមុខយាយចែមយ៉ាងណា។ ទើបនឹងឃើញដែលមជ្ឈមណ្ឌលកម្ពុជានេះ គេយកមកឱ្យខ្ញុំឃើញ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/43** ឆ:20 ["ខ្ញុំមិនដែលបានស្គាល់មុខគាត់ទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ ម៉ុត ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ឯកសារ **D53**, KH 00727206 ["ខ្ញុំមិនដែលឃើញគាត់នៅតាមការដ្ឋានទាំងនោះទេ"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/92** ឆ:20-21, ឆ:24 [សាក្សីត្រូវបានគេប្រាប់ថា អ្នកស្រី អ៊ឹម ចែម បានចុះទៅមើលប្រឡាយអូរលៀប ប៉ុន្តែមិនដែលបានឃើញអ្នកស្រីដោយផ្ទាល់ទេ]។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:261-62, ឆ:265 [ដែលនិយាយថា គាត់មិនដែលបានឃើញអ្នកស្រីអ៊ឹម ចែម នៅការដ្ឋានស្ពានស្រែង ហើយក៏មិនបានដឹងថាតើអ្នកស្រីមានតួនាទីអ្វីដែរនៅទីនោះ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/152** ឆ:27-28 [សាក្សីមិនដែលបានឃើញអ្នកស្រីអ៊ឹម ចែម នៅទំនប់អូរលៀបនោះឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម វុយ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **D219/317** ឆ26-27 [សាក្សីមិនដែលបានឃើញអ្នកស្រីអ៊ឹម ចែម ចុះទៅពិនិត្យមើលការដ្ឋានណាមួយឡើយ]។

[778] *សូមមើល* កំណត់ហេតុនៃកិច្ចស៊ើបសួរ (កោ ឡឺន) ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **D119/129**, KH 00988077, ["តា ពាល់ កម្មាភិបាលក្នុងគណៈកម្មាធិការតំបន់ ៥ បានមើលការខុសត្រូវគម្រោងទាំងអស់ក្នុងតំបន់។ ចំណែក អ៊ឹម ចែម គ្រប់គ្រងកងចល័តស្រុក"]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **D119/89** ឆ:36 ["កងចល័តនៅស្ពានស្រែងមានពីរក្រុម។ កងចល័តតំបន់មានតាវ៉ាល់ ជាអ្នកគ្រប់គ្រង ហើយកងចល័តសហករណ៍មានយាយចែម ជាអ្នកគ្រប់គ្រង"]។

គាត់បានរាយការណ៍ដោយផ្ទាល់ទៅថ្នាក់តំបន់[779] ពោលគឺមិនមែនរាយការណ៍ទៅអ្នកស្រី អ៊ឹម ចែម ទេ ។

២១៦. សរុបសេចក្ដីមក ទោះបីជាមានការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក៏ដោយ ក៏ភស្តុតាងចង្អុលបង្ហាញឆ្ពោះទៅរកការសន្និដ្ឋានបានថា តួនាទីតែមួយគត់របស់អ្នកស្រី អ៊ឹម ចែម នៅការដ្ឋានស្ពានស្រែង គឺត្រូវផ្ដល់កម្លាំងពលកម្មតាមសំណើរបស់ថ្នាក់តំបន់[780] ។ អត្ថិភាពនៃទំនាក់ទំនងរវាងអ្នកស្រី អ៊ឹម ចែម និងលក្ខខណ្ឌតម្រូវឱ្យផ្ដល់ពលករទៅធ្វើការនៅការដ្ឋានស្ពានស្រែងតាមមធ្យោបាយនេះ មិនបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម បានបង្កើត ឬអនុវត្តគោលនយោបាយដែលបានគិតទុកជាមុននៃពលកម្មដោយបង្ខំ ឬថា អ្នកស្រី អ៊ឹម ចែម មានតួនាទីណាមួយដែលគ្រប់គ្រងលើពលករ នៅពេលពួកគេធ្វើការនៅការដ្ឋានស្ពានស្រែង ឬបានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មណាមួយដែលកើតមានឡើងនៅទីតាំងនោះឡើយ ។

## ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងការស្លាប់ដោយសារការបង្អត់អាហារ និងជំងឺ នៅការដ្ឋានស្ពានស្រែង

២១៧. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា អ្នកស្រី អ៊ឹម ចែម មានចេតនាបង្កឱ្យមានព្យសនកម្មផ្លូវកាយ និង/ឬ ផ្លូវចិត្តធ្ងន់ធ្ងរ និង/ឬ ការប្រព្រឹត្តិអំពើឃោរឃៅអមនុស្សធម៌ និងបន្ថោកបន្ទាប

---

[779] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:31 ["[ជាកងចល័តឃុំ] ខ្ញុំមិនបានរាយការណ៍ទៅអ្នកណាទេ គឺប្រធានតំបន់ចុះផ្ទាល់តាមការដ្ឋាន។ បងរិន (អ្នកបូព៌ា) គណៈតំបន់ជាអ្នកគ្រប់គ្រងផ្ទាល់។ មេគ្រប់គ្រងផ្ទាល់របស់ខ្ញុំឈ្មោះ បង ខុន (ប្រុស) ស្លាប់។ ខុនជាប្រធានគ្រប់គ្រងកងចល័តស្រុកព្រះនេត្រព្រះទាំងមូល។ ខ្ញុំទទួលបញ្ជាផ្ទាល់ពី ខុន ជួនកាល តា រិន និង តា ពាល់ (អ្នកនិរតី) បានពិនិត្យមើលការដ្ឋានផ្ទាល់"]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:51 ["ខ្ញុំត្រូវរាយការណ៍ឱ្យទៅថ្នាក់តំបន់ដែលគេបានធ្វើការនៅតាមការដ្ឋាននោះ...ប្រសិនបើគេតម្រូវឱ្យយើងរកមនុស្សមកជំនួស យើងត្រូវទៅទាក់ទងនឹងប្រធានភូមិរបស់មនុស្សដែលឈឺនោះ ដើម្បីឱ្យគេរកមនុស្សថ្មីមកជំនួស"]។

[780] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:57-59 [ដែលរំលឹកឡើងវិញនូវកិច្ចប្រជុំមួយនៅមន្ទីរស្រុកថា មនុស្សមកពីឃុំនីមួយៗ បានចូលរួមការប្រជុំ ដែលអំឡុងពេលនោះ កម្មាភិបាលថ្នាក់តំបន់បានស្នើកម្លាំងពីមូលដ្ឋាន]។

រួមទាំងការអត់ឃ្លានរបស់ពលករនៅការដ្ឋានស្ពានស្រែង[781] ដូច្នេះមានន័យថា អ្នកស្រីបានរួមចំណែកធ្វើឱ្យលក្ខខណ្ឌនានានៅថ្នាក់តំបន់ដែលគួរឱ្យស្អប់ខ្ពើមរួចទៅហើយនោះ កាន់តែអាក្រក់ឡើងថែមទៀត[782] ។ នៅក្នុងបរិបទនេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់ដោយសារការអត់ឃ្លាន និងជំងឺដែលបានកើតឡើង "យ៉ាងសាមញ្ញ"[783] ។ ភស្តុតាងនេះមិនគាំទ្រដល់ការចោទប្រកាន់ទាំងនេះទេ ពីព្រោះសហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញពីការស្លាប់ជាញឹកញាប់ ឬថាមានទំនាក់ទំនងដ៏គួរឱ្យកត់សម្គាល់រវាងអ្នកស្រី អ៊ឹម ចែម និងអ្នកទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាបានស្លាប់នោះឡើយ ។

២១៨. មានការគាំទ្រតិចតួចចំពោះអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងភាពញឹកញាប់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនេះ ។ ការអះអាងដែលថា "ការស្លាប់ដោយសារការអត់ឃ្លាន និងដោយសារជំងឺឃើញកើតមានយ៉ាងសាមញ្ញទៅហើយ"[784] គឺជាការបំផ្លើសនៃចម្លើយធម្មតាដែលគ្មានការបញ្ជាក់របស់សាក្សី សម ស័ក្ត ដែលបានធ្វើការនៅផ្នែកមួយនៃការដ្ឋាននៅស្រុកភ្នំស្រុកក្នុងរយៈពេលពីរសប្តាហ៍[785] ។ ទោះបីសាក្សីបានថ្លែងថា ការស្លាប់ពិតជាបានកើតមានឡើងនៅការដ្ឋានស្ពានស្រែងក្តី ប៉ុន្តែគាត់មិនបានបញ្ជាក់ថា ការស្លាប់ទាំងនោះ "ជារឿងសាមញ្ញ" នោះឡើយ[786] ។ គាត់បានសារភាពថា គាត់មិនបានដឹងពីចំនួនមនុស្សដែលបានស្លាប់នៅ

---

781 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៥២-៥៨, ៤៨៤-៨៥។

782 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៤៨៥។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៤៥។

783 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៧។

784 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៦៧ (ជើងទំព័រ ១៣៥៥)។

785 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/120** ឆ:23-24, [ដែលនិយាយថា គាត់ស្ថិតនៅក្នុងស្រុកភ្នំស្រុក] ឆ:77 [ដែលនិយាយថា គាត់បានធ្វើការនៅទំនប់ស្ពានស្រែងរយៈពេលពីរ សប្តាហ៍មុនពេលត្រឡប់ទៅទំនប់ត្រពាំងថ្មវិញ] ឆ:80-81 [ដែលនិយាយថា គាត់មិនដឹងពីការដ្ឋានជីកប្រឡាយនៅជិតទន្លេស្ពានស្រែង និងមិនដឹងអំពីអាងស្តុកទឹកព្រៃរនាម ហើយគាត់បានធ្វើការនៅតែទំនប់ស្ពានស្រែងប៉ុណ្ណោះ]។

786 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/120** ឆ:96។

ការដ្ឋានស្ពានស្រែងទេ[787] ។ ភស្តុតាងនេះគ្មានលក្ខណៈគ្រាប់គ្រាន់ដែលអាចគាំទ្រដល់ការអះអាងដែលថា ការស្លាប់បានកើតឡើងដោយសារគោលនយោបាយដែលបានគិតទុកជាមុនឡើយ ។ ផ្ទុយទៅវិញ ដូចបានផ្តល់ទឡ្ហីករណ៍នៅផ្នែកខាងលើការស្លាប់ទាំងនេះ គឺទំនងជាដោយសារបញ្ហាលំបាកក្នុងវិស័យកសិកម្មដែលកើតមានឡើងប្រមាណជាពីរឆ្នាំនៅក្នុងស្រុកនេះ[788] ។

២១៩. ភស្តុតាងនេះមិនបានបង្ហាញពីទំនាក់ទំនងរវាងអ្នកស្រី អ៊ឹម ចែម និងការស្លាប់ដោយការអត់ឃ្លាន និងជំងឺនៅឯការដ្ឋានស្ពានស្រែងនោះទេ ។ ដូចបានផ្តល់ទឡ្ហីករណ៍នៅផ្នែកខាងលើភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម មិនមានសិទ្ធិអំណាច*ស្របច្បាប់* ឬ*ជាក់ស្តែង*ណាមួយ ដែលអនុញ្ញាតឱ្យអ្នកស្រីអនុវត្តគោលនយោបាយដែលត្រូវកំណត់ជាមុននូវប្រភេទណាមួយ ដើម្បីបង្កឱ្យមានការស្លាប់ដោយសារការអត់ឃ្លាន ឬជំងឺឡើយ ។ ការអះអាងបែបនេះ គឺដើម្បីបំភ្លេចចោលនូវភស្តុតាងដែលបង្ហាញថាការដ្ឋានស្ពានស្រែង គឺស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលថ្នាក់តំបន់ឈ្មោះតា ពាល់ ហើយធាតុពិតដែល អ្នកស្រី អ៊ឹម ចែម ពុំមានសិទ្ធិអំណាចអាចធ្វើអ្វីមួយនៅកម្រិតនេះទេ[789] ។ គេក៏ត្រូវទាញយកហេតុផលពីគោលនយោបាយដោយគ្មានភស្តុតាងគ្រប់គ្រាន់នៃការប្រព្រឹត្តដែលពាក់ព័ន្ធ ឬគំរូនៃបង្ហាញពីការស្លាប់របស់មនុស្សមកពិចារណាផងដែរ[790] ។

## ការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ក្នុងការចាប់ខ្លួន ការឃុំឃាំង ការសម្លាប់ និងការបាត់ខ្លួននៅការដ្ឋានស្ពានស្រែង

២២០. ពាក់ព័ន្ធទៅនឹងការដ្ឋានស្ពានស្រែង សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា អ្នកស្រី អ៊ឹម ចែម មាន "អំណាចបញ្ជាឱ្យចាប់ខ្លួននៅប្រឡាយស្ពានស្រែង និងអាងស្តុកទឹកព្រៃរនាម ហើយដាក់ទណ្ឌកម្ម រួមមានការឃុំឃាំង និងការសម្លាប់" និងថា "ការបាត់ខ្លួនពីការដ្ឋានឃើញមានជា

---

[787] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/120** ឆ:97។

[788] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២៣។

[789] *ប្រៀបធៀប* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៩៧-១២៩។

[790] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២១៨-១៩។

ធម្មតា"[791] ។ ភស្តុតាងនេះមិនគាំទ្រដល់ការលើកឡើងទាំងនេះឡើយ ។ ជំនួសមកវិញ សហព្រះរាជអាជ្ញាអន្តរជាតិប៉ុនប៉ងគាំទ្រដល់ការអះអាងនានា តាមរយៈការផ្អែកលើភស្តុតាងដែលបង្ហាញយ៉ាងច្បាស់ថាគ្មានការពាក់ព័ន្ធនឹងបញ្ហា ព្រមទាំងផ្អែកលើវិធីសាស្ត្រមួយដែលគ្មានសត្យានុម័តភាពពេញលេញ យកទៅអនុវត្តចំពោះភស្តុតាងដែលនៅសេសសល់ផ្សេងៗទៀត ។ វិធីសាស្ត្រទាំងនេះនឹងត្រូវលើកយកមកពិភាក្សាខាងក្រោម ។

២២១. ឯកសារសំអាងយ៉ាងច្រើនលើសលប់ដែលត្រូវបានយកមកពឹងផ្អែក មិនអាចបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចចេញបញ្ជាឱ្យចាប់ខ្លួនពលករនៅការដ្ឋានស្ពានស្រែងនោះឡើយ[792] ។ ដូចដែលបានលើកឡើងនាពេលកន្លងមកនៅកថាខណ្ឌ **១៣៩** ដល់ **១៤២** និងកថាខណ្ឌ **១៦២** នៃចម្លើយតបនេះ ភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម មិនមានសិទ្ធិអំណាចនេះទេ ។ យ៉ាងច្រើន

[791] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧០។

[792] *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧០ (ជើងទំព័រ ១៣៦៥) *ដែលយោងដល់* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D123/1/2.66**, KH00927402-00927403 [ដែលនិយាយអំពីព្រឹត្តិការណ៍មួយដែលបានកើតឡើងនៅក្នុងឃុំភ្នំលៀប]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/133** ឆ:82-83 [ដែលនិយាយអំពីព្រឹត្តិការណ៍មួយដែលគេបានប្រាប់គាត់ ដែលបានកើតឡើងនៅក្នុងឃុំភ្នំលៀប]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/110** ឆ:76 [ដែលនិយាយអំពីលិខិតចាប់ខ្លួនដែលមានហត្ថលេខារបស់ថ្នាក់តំបន់ នៅពេលគាត់គឺជាប្រធានឃុំភ្នំលៀប]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **D119/154** ឆ:32, ឆ:36 [ដែលនិយាយថា គាត់បានឮគេនិយាយថា អ្នកដែលបានប្រព្រឹត្តកំហុស នឹងត្រូវបានបញ្ជូនទៅជួបអ្នកស្រី អ៊ឹម ចែម ហើយបន្ទាប់មកត្រូវបានចាប់ដាក់គុក ឬសម្លាប់ ដោយមិនបានលើកឡើងថាព្រឹត្តិការណ៍បែបនេះមានជាប់ពាក់ព័ន្ធទៅនឹងការដ្ឋានស្ពានស្រែងនោះឡើយ]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សរ ឡោម ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/138** ឆ:38-39 [ដែលនិយាយថា គាត់បានឮថា អ្នកស្រី អ៊ឹម ចែម ទទួលខុសត្រូវនៅភ្នំលៀប]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត វិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **D119/42** ឆ:16 [ដែលនិយាយថា អ្នកស្រី អ៊ឹម ចែម បានបញ្ជាឱ្យធ្វើការឱ្យបានល្អ និងលើកទំនប់ឱ្យបានត្រង់]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/99** ឆ:32 [ដែលនិយាយអំពីព្រឹត្តិការណ៍មួយដែលបានកើតឡើងនៅទំនប់វាលជង្កៀបក្តាម]។ *ក៏សូមមើលផងដែរ* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ២៧០ (ជើងទំព័រ ១៣៦៨), *ដែលយោងដល់* កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130** ឆ:147-48 [ដែលជជែកអំពីព្រឹត្តិការណ៍មួយដែលគាត់មិនបានឃើញ ដោយមិនបានលើកឡើងអំពីទីតាំងណាមួយ]។

បំផុត មានសាក្សី៥នាក់ អះអាងអំពីការដឹងឮពីការបាត់ខ្លួននៅការដ្ឋាននេះ ។ ទោះជាយ៉ាងណាក្តី គ្មាននរណាម្នាក់បង្ហាញពីការលើកឡើងណាមួយដែលថា តើការបាត់ខ្លួនទាំងនេះ ឃើញកើតមានឡើងជាធម្មតាឡើយ[793] ឬមិនទាំងបានលើកឡើងពីលទ្ធផលកើតចេញពីសកម្មភាពរបស់អ្នកស្រី អ៊ឹម ចែម ដូចម្តេចនោះដែរ[794] ។ ឆៅ ចាត់ ជាសាក្សីមួយរូបដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពឹងផ្អែកលើនោះ បានទទួលស្គាល់ថា នៅក្នុងអំឡុងពេលធ្វើការនៅការដ្ឋានស្ពានស្រែង អ្នកស្រី អ៊ឹម ចែម មិនមានវត្តមាននោះទេ[795] ។ សាក្សីមិនបានដឹងអំពីការលើកឡើងដែលថា អ្នកស្រី អ៊ឹម

---

793 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **D119/69** ឆ:71 [“ខ្ញុំមិនបានឃើញទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានការបាត់ខ្លួន។ ខ្ញុំមិនដឹងថាអ្នកនោះត្រូវបានបញ្ជូនទៅការដ្ឋានកន្លែងផ្សេង ឬយ៉ាងណាទេ”]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **D219/506** ឆ:42 [“ខ្ញុំមិនបានឃើញមនុស្សត្រូវបានគេចាប់ខ្លួនទេ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានមនុស្សបាត់ខ្លួន ដោយមិនដឹងមូលហេតុ ដូចជាអ្នកធ្វើការនៅក្នុងក្រុមរបស់ខ្ញុំជាដើម។ ខ្ញុំមិនដឹងថា មានមនុស្សប៉ុន្មាននាក់បាត់ខ្លួនទេ ប៉ុន្តែនៅក្នុងក្រុមខ្ញុំ មានមនុស្សបាត់ខ្លួន ដូច្នេះនៅក្នុងក្រុមផ្សេងក៏អាចមានមនុស្សបាត់ខ្លួនដែរ”]។

794 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **D119/133**, ស-ឆ46 [“ស៖ នៅពេលដែលយាយ ចែម និយាយថាកុំឱ្យចាញ់ល្បិចខ្មាំង ឬរួមគំនិតជាមួយខ្មាំង តើមានន័យថាម៉េច? ឆ46៖ ខ្ញុំពិបាកសន្និដ្ឋានចំពោះពាក្យនេះណាស់ ពីព្រោះខ្ញុំមិនយល់អំពីការដឹកនាំរបស់គាត់ទេ”។], ស-ឆ47 [“ស៖ គាត់មានបានបញ្ជាក់បន្ថែមទៀតទេថា ប្រសិនបើអ្នកណាម្នាក់ត្រូវបានចាត់ទុកថាជាខ្មាំងរបស់អង្គការ តើមានរឿងអ្វីកើតឡើងចំពោះពួកគេទាំងនោះ? ឆ:47៖ គាត់មិនបានបញ្ជាក់បន្ថែមអំពីបញ្ហានេះទេ”។]។ ស-ឆ49 [“ស៖ តើលោកដឹងថា អ្នកណាជាអ្នកចេញបញ្ជាឱ្យយកមនុស្សទៅរៀនសូត្រដែរ ឬទេ? ឆ:49៖ ខ្ញុំមិនដឹងអំពីរឿងនេះទេ។ តាមពិតយើងគ្រប់ៗគ្នាខិតខំតែធ្វើការដើម្បីឱ្យយើងបានរស់តែប៉ុណ្ណោះ”]។ ស-ឆ:84 [“ស៖ តើលោកដឹងថាមានអ្នកណាម្នាក់ត្រូវបានយាយ ចែម បញ្ជាឱ្យចាប់ខ្លួនដែរ ឬទេ? ឆ:84៖ ទេ ខ្ញុំមិនដឹងទេ”]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149**។ ស-ឆ:41 [ឯកសារយោងតែមួយគត់ដែលសាក្សីបានផ្តល់ចំពោះ អ៊ឹម ចែម មានដូចខាងក្រោម៖ “ស៖ តើលោកដែលធ្លាប់ឮឈ្មោះ យាម ចែម ដែរឬទេ? ឆ:41៖ ខ្ញុំធ្លាប់ឮឈ្មោះនេះ ប៉ុន្តែពុំដែលឃើញផ្ទាល់និងស្គាល់ទេ”]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98**, ស-ឆ:40 [“ស៖ ក្នុងនាម យាម ចែម ជាគណៈស្រុកព្រះនេត្រព្រះ តើលោកដឹងថា គាត់មានតួនាទីគ្រប់គ្រងផ្ទាល់ទៅលើការដ្ឋាននានា ឃោធា ឈ្លប ឬមន្ទីរសន្តិសុខនានាដែរឬទេ? ឆ40៖ ខ្ញុំក្តាប់មិនបានទេ ព្រោះខ្ញុំធ្វើការនៅក្នុងកងចល័ត”]។

795 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ **D219/130**, ស-ឆ:261 [“ស៖ ចុះពេលនោះ យាយចែមមានដែលទៅមើលទេ [ពេលដែលសាក្សីធ្វើការនៅប្រឡាយស្ពានស្រែង]? ឆ:261៖ ទេ”]។

ចែម មានតួនាទីនៅទីតាំងនោះឡើយ[796] ។

២២២. សាក្សីនៅសេសសល់ផ្សេងទៀតដែលសហព្រះរាជអាជ្ញាអន្តរជាតិបានយកជាសំអាង មិនបានជួយអ្វីបន្ថែមនោះទេ ។ ពួកគាត់បានត្រឹមដឹងឮតែពាក្យចចាមអារ៉ាមដែលមានន័យថា ជាការសន្និដ្ឋាន និងជាការនិយាយតៗគ្នា[797] ឬមិនមានទំនាក់ទំនងអ្វីសោះទៅនឹងការដ្ឋានស្ពានស្រែង[798] ។ ការផ្អែកទៅលើសាក្សី ជុំ ជិម ឧទាហរណ៍ស្រាប់៖ គាត់ "បានឮ" គេថាមានមនុស្សបានបាត់ខ្លួន[799] ។ ទោះជាយ៉ាងណាក្តី ក្នុងអំឡុងពេលដែលគាត់ធ្វើការនៅក្នុងកងរបស់គាត់ សាក្សីរូបនេះ "មិនដែលសង្កេតឃើញមានអ្នកណាម្នាក់បាត់ខ្លួនទេ"[800] ហើយគាត់ក៏មិនដែលឃើញការចាប់ខ្លួនណាមួយ ឬការយកមនុស្សទៅសម្លាប់នោះដែរ ក្នុងអំឡុងធ្វើការនៅការដ្ឋានស្ពានស្រែង[801] ។ ពិតណាស់ បើទោះជាគាត់បានឃើញ "គេយកមនុស្សទៅសម្លាប់" ក្តី ក៏ការណ៍នេះនឹងមិនមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ។ យ៉ាងហោចណាស់សាក្សីម្នាក់បានពន្យល់ថា មនុស្សមួយចំនួន "បានបាត់ខ្លួន"

---

[796] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130**, ស-ឆ:262 ["ស៖ តើលោកឮថា យាយ ចែម មានតួនាទីអ្វីនៅប្រឡាយ [ស្ពានស្រែង] នោះដែរឬទេ? ឆ262៖ ទេ ខ្ញុំមិនដឹងទេ"]។

[797] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149 ឆ:**16 ["ខ្ញុំគ្រាន់តែឮពីក្រុមគ្នាឯងនិយាយគ្នាអំពីរឿងបាត់ខ្លួនមនុស្ស"]។

[798] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D123/1/2.66**, KH00927407-00927408 [ដោយសំដៅលើគ្រួសារនានាដែលត្រូវបានបញ្ជូនទៅដាក់គុកនៅមន្ទីសន្តិសុខភ្នំទ្រយោង ប៉ុន្តែមិនបានបញ្ជាក់ច្បាស់លាស់ថាតើពួកគេមកពីកន្លែងណានោះទេ] ។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨-១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **D219/130**, ស-ឆ:134, ឆ:147-48 [បន្ទាប់ពីសួរសំណួរជាច្រើនពាក់ព័ន្ធនឹងការងារនៅអាងត្រពាំងថ្ម]។

[799] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149 ឆ:**16។

[800] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149 ឆ:**13។

[801] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **D219/149 ឆ:**16 ["តាមពិត ខ្ញុំពុំដែលបានឃើញគេចាប់ និងយកមនុស្សទៅសម្លាប់ទេ គឺគ្រាន់តែឮពីក្រុមគ្នាឯងនិយាយគ្នាអំពីរឿងបាត់ខ្លួនមនុស្ស ដូច្នេះ ហើយខ្ញុំខ្លួនឯងក៏ខ្លាច ហើយសម្រេចរត់តែម្តង"]។

ហើយការពិត មនុស្សមួយចំនួនត្រូវបានបញ្ជូនត្រលប់ទៅសហករណ៍ផ្សេងៗវិញ[802] ។ ក្រោយមក សាក្សីរូបនោះមានឱកាសជួបមនុស្សមួយចំនួនក្នុងចំណោមអ្នកដែលបាន "បាត់ខ្លួន" ។ ពួកគេនៅរស់ ហើយសុខសប្បាយជាធម្មតា[803] ។

២២៣. សរុបសេចក្តីមក ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំទ្រយោង ការវិភាគដ៏យុត្តិធម៌ និងសមហេតុផលលើភស្តុតាង គឺមិនបានផ្តល់ការគាំទ្រណាមួយដល់សេចក្តីសំអាងដែលថា អ្នកស្រី អ៊ឹម ចែម អាចទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋម្មនានានៅទីតាំងនោះឡើយ ។ ជាជាងពិចារណាទៅលើភស្តុតាងទាំងមូល ក្នុងគោលបំណងលើកឡើងអំពីការពិតនោះ វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិមានការជ្រើសសម្រាំងយកព័ត៌មានដែលខ្លួនចង់បានយ៉ាងប្រយ័ត្នប្រយែង ។ ទោះជាយ៉ាងណាការណ៍នេះមិនអាចលាក់បាំងនូវកង្វះខាតនៃភស្តុតាង ដើម្បីគាំទ្រដល់សំណុំរឿងដែលចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម នោះទេ ។

២២៤. ការវិភាគដ៏សមហេតុផលមួយទៅលើភស្តុតាងបង្ហាញថា អ្នកស្រី អ៊ឹម ចែម គឺជាកម្មាភិបាលថ្នាក់ស្រុកម្នាក់រហូតទាល់តែបញ្ចប់របបនេះ ដោយគ្មានសិទ្ធិអំណាច*ស្របច្បាប់* ឬ*ជាក់ស្តែង*នៅការដ្ឋានស្ពានស្រែងនៅពេលណាមួយនោះឡើយ ។ ការដ្ឋានស្ពានស្រែង ដែលការសាងសង់បានចាប់ផ្តើមមុនពេលអ្នកស្រី អ៊ឹម ចែម មកដល់ភូមិភាពពាយព្យនោះ ស្ថិតក្រោមសិទ្ធិអំណាចផ្លូវការរបស់ថ្នាក់តំបន់ និងស្ថិតក្រោមសិទ្ធិអំណាចដ៏មានឥទ្ធិពលរបស់ តា វ៉ាល់ (រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៧) ហើយចុងក្រោយស្ថិតក្រោម តា ពាល់ (ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ទៅ)។

802 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **D119/98** ឆ:42 ["ជួនកាលពួកគេបាត់ខ្លួន តែខ្ញុំមិនដឹងថា ពួកគេត្រូវបញ្ជូនទៅសហករណ៍វិញឬក៏ទៅទីណាទេ។ ខ្ញុំមិនដឹងអំពីការបាត់ខ្លួន និងមនុស្សឈឺស្លាប់នៅក្នុងកងផ្សេងៗទេ"]។

803 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **D119/121** ឆ:33 ["តាមខ្ញុំចាំមនុស្សដែលបានបាត់ខ្លួនពីកងរបស់ខ្ញុំ គឺប្រហែលជាពាក់កណ្តាលមនុស្សសរុបនៅក្នុងកងរបស់ខ្ញុំទាំងមូល ប៉ុន្តែខ្ញុំមិនដឹងថាពួកគេទៅទីណាទេ ប្រហែលជាទៅសហករណ៍ហើយក៏មិនដឹង។ ក្រោយមក ខ្ញុំបានជួបពួកគេខ្លះ ប៉ុន្តែមិនទាំងអស់នោះទេ។ នៅពេល នោះ កូនក្រុមរបស់ខ្ញុំមានប្រហែល ២០០នាក់"]។

២២៥. លើសពីនេះទៀត ដូចដែលបានលើកឡើងខាងលើ ភស្តុតាងនេះមិនគាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ ពាក់ព័ន្ធនឹងទំហំនៃការកើតឡើងញឹកញាប់ ឬស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ។ ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម មានការពាក់ព័ន្ធនឹងការបង្ខំមនុស្ស "រាប់ពាន់នាក់" ឱ្យធ្វើការនៅការដ្ឋានស្ពានស្រែង ព្រមទាំងការគ្រប់គ្រង និងរដ្ឋបាលនៃប្រព័ន្ធដាក់ទោស (ឧទាហរណ៍ រួមមានដូចជាការឃុំឃាំង និងការសម្លាប់មនុស្ស) ការស្លាប់ដោយការអត់ឃ្លាន ជំងឺ និងការបាត់ខ្លួននោះ មិនត្រូវបានគាំទ្រដោយភស្តុតាងដ៏គួរឱ្យទុកចិត្តបាននោះទេ ។ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅការដ្ឋានស្ពានស្រែង ប្រសិនបើមានមែន គឺត្រឹមតែផ្តល់កម្លាំងពលកម្មឱ្យទៅធ្វើការនៅការដ្ឋាននេះ និងនៅពេលដែលថ្នាក់តំបន់បានស្នើសុំមនុស្សទៅធ្វើការ ។ អាស្រ័យហេតុនេះ បើទោះជាភស្តុតាងបានបង្ហាញថា ឧក្រិដ្ឋកម្មមានស្ថានភាពធ្ងន់ធ្ងរជាពិសេសក្តី ក៏វាមិនបង្ហាញថា អ្នកស្រី អ៊ឹម ចែម មានតួនាទីប្រហាក់ប្រហែលណាមួយនៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរ ពោលគឺ តួនាទីរបស់អ្នកស្រីនៅឆ្ងាយដាច់ពីឧក្រិដ្ឋកម្មណាក៏ដោយ ដែលត្រូវបានប្រព្រឹត្តទៅនៅការដ្ឋានស្ពានស្រែង ។

២២៦. សរុបសេចក្តីមក ភស្តុតាងទាំងមូលសម្រាប់គាំទ្រដល់ការអះអាងដែលថា អ្នកស្រី អ៊ឹម ចែម មានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅការដ្ឋានស្ពានស្រែងនោះ នៅខ្វះភាពខ្លាំងក្លា ភាពស៊ីសង្វាក់គ្នា និងការបញ្ជាក់ការពិត ។ វាមិនអាចប្រែក្លាយទៅជាភស្តុតាងមានលក្ខណៈគ្រប់គ្រាន់ធ្វើឱ្យអ្នកស្រីធ្លាក់ចូលទៅក្នុងប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" របស់ អ.វ.ត.ក នោះឡើយ ។

## ខ. សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការបុគ្គល

២២៧. សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[804] ដោយសំអាងថា អ្នកស្រីគឺជា "មន្ត្រីបក្សកុម្មុយនីស្តកម្ពុជាក្នុងឋានានុក្រមដ៏សំខាន់នៅថ្នាក់ស្រុក និងថ្នាក់តំបន់ [ដែល] មានតួនាទីយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលបាន

[804] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥២៩-៣៨។

ប៉ះពាល់ដល់មនុស្សរាប់សិបពាន់នាក់ និងបានបណ្តាលឱ្យមានមនុស្សស្លាប់រាប់ពាន់អ្នក"[805] ។ ដូច ការពិភាក្សាខាងលើ ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលផ្អែកលើការអះអាង ដូចតទៅ៖ i) អ្នកស្រី អ៊ឹម ចែម បានឡើងឋានៈពីប្រធានសហករណ៍ក្នុងភូមិភាគនិរតីមុនអំឡុងឆ្នាំ ១៩៧៥ រហូតក្លាយជាអនុលេខាតំបន់៥ ក្នុងភូមិភាគពាយព្យនៅអំឡុងឆ្នាំ ១៩៧៨[806] ii) រាល់តួនាទី របស់អ្នកស្រីត្រូវបានចាត់តាំងដោយ *តា ម៉ុក*[807] និង iii) អ្នកស្រីមានតួនាទីសំខាន់ក្នុងការប្រព្រឹត្ត ឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងក្នុងភូមិភាគនិរតី និងភូមិភាគពាយព្យនៅអំឡុងពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩[808] ។

២២៨. ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម "ប្រហែលជាស្មើទៅនឹងការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច"[809] ។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា អ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចខ្ពស់ជាង ឌុច ដោយអ្នកស្រីបានគ្រប់គ្រងលើជីវិតរបស់ជនរងគ្រោះជាជនស៊ីវិលក្នុងកម្រិតច្រើនជាង ជាច្រើន ដង ហើយមន្ទីរសន្តិសុខភ្នំទ្រយោងមានចំនួនជនរងគ្រោះស្មើ ឬច្រើនជាងចំនួនជនរងគ្រោះនៅមន្ទីរ ស-២១ ក្នុងរយៈពេលដំណើរការដ៏ខ្លី[810] ។

២២៩. ដូចការលើកទឡ្ហីករណ៍ជាហូរហែក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាអន្តរជាតិមានការភ័ន្តច្រលំ លើផ្នែកអង្គច្បាប់ និងអង្គហេតុក្នុងការទាញសេចក្តីសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងប្រភេទ "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិភ័ន្តច្រលំលើផ្នែក អង្គហេតុតាមរយៈការសំអាងលើភស្តុតាងទាំងអស់ដែលមានក្នុងសំណុំរឿង០០៤/១ ដោយមិន

805 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០។

806 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣១។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣០-៣២។

807 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣១។

808 *សូមមើល* ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣២។

809 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៤។

810 ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៤។

ពិចារណាពីការជូនដំណឹងអំពីបទចោទប្រកាន់ និងព្រំដែនកំណត់នៃការជូនដំណឹងនេះលើវិសាលភាពនៃការចោទប្រកាន់ណាមួយ[811] ។ ទីពីរ ការវាយតម្លៃរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើភស្តុតាង គឺធ្វើឡើងដោយគ្មានអ្នកវិនិច្ឆ័យសមហេតុផល ដែលនាំឱ្យការសំអាងណាមួយនោះអាចនឹងទទួលយកមកអនុវត្តបានឡើយ ។ ការវាយតម្លៃនេះ ខ្វះនូវភាពសត្យានុម័តដូចបានតម្រូវដើម្បីជួយដល់ការបញ្ជាក់ពីការពិត ហើយវាបង្ហាញពីភាពពាក់ព័ន្ធតិចតួចណាស់ បើពិចារណាទៅដល់ភារកិច្ចរបស់ព្រះរាជអាជ្ញាក្នុងការបំពេញតួនាទីជាមន្ត្រីយុត្តិធម៌មួយរូប[812] ។

២៣០. ផ្អែកលើភស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះសិទ្ធិអំណាចផ្លូវការ និងដែលមានប្រសិទ្ធភាពរបស់អ្នកស្រី អ៊ឹម ចែម នៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង និងការចោទប្រកាន់ចំពោះការចូលរួមរបស់អ្នកស្រីក្នុងបទឧក្រិដ្ឋដែលមានស្ថានទម្ងន់គ្រប់គ្រាន់ វាប្រាកដណាស់ដែលអ្នកស្រីមិនគួរត្រូវបានចោទប្រកាន់ ។ ភស្តុតាងនេះគឺ "មិនមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់" និងមិនអាចឈានដល់កម្រិតចាំបាច់នៃតម្លៃជាភស្តុតាង ដើម្បីអះអាងថា អ្នកស្រី អ៊ឹម ចែម ទំនងជាស្ថិតក្នុងចំណោមបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឡើយ[813] ។ ប្រសិនបើមានប្រភេទភស្តុតាងដូចការចង្អុលបង្ហាញដូច្នេះ នោះសហព្រះរាជអាជ្ញាអន្តរជាតិ គប្បីនឹងពេញចិត្តក្នុងការផ្អែកលើសំណុំរឿងរបស់ខ្លួននេះ ត្រឹមបទចោទប្រកាន់ដែលមានក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ និងប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈកាន់តែសត្យានុម័តលើភស្តុតាង និងអាចបញ្ជាក់ការពិត ។ ផ្ទុយទៅវិញនៅក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានប្រើប្រាស់វិធីសាស្ត្រដោយប្រុងប្រយ័ត្នរបស់ចៅក្រម Bohlander ចំពោះភស្តុតាងដើម្បីគាំទ្រការចោទប្រកាន់ដែលមានរៀបរាប់ក្នុងការជូនដំណឹងអំពីបទចោទប្រកាន់នោះទេ (ដូចជា គោលការណ៍ *វិមតិសង្ស័យ*) ។ ជំនួសឱ្យការអះអាងដែលថា អ.វ.ត.ក មានយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម

---

811 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៥៤-៦០។ *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២០-២៩។

812 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៣០-៣៦។ *ប្រៀបធៀបនឹង* សំណុំរឿង ០០១, សេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋាន ឯកសារ **E72.3** នៅកថាខណ្ឌ ២០-២១, ២៤, ៣៤។

813 ដីកាដំណោះស្រាយសំណុំរឿង ០០២ ឯកសារ **D427** នៅកថាខណ្ឌ ១៣២៣។

វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអង្គច្បាប់ និងអង្គហេតុ គ្រាន់តែជាការបង្ហាញបែបបញ្ចុះបញ្ចូលដែលមិនសូវមានភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាង ដើម្បីគាំទ្រការអះអាងដែលថាអ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងប្រភេទ "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ។

២៣១. អ្នកស្រី អ៊ឹម ចែម គឺជាលេខាស្រុកព្រះនេត្រព្រះ *ស្របច្បាប់* និង*ជាក់ស្តែង* ចាប់តាំងពីចុងឆ្នាំ ១៩៧៧ រហូតដល់របបខ្មែរក្រហមដួលរលំ[814] ។ ទីតាំងឧក្រិដ្ឋកម្មទាំងពីរដែលអ្នកស្រី អ៊ឹម ចែម រងការចោទប្រកាន់ (មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង) ស្ថិតក្រោមសិទ្ធិអំណាច *ស្របច្បាប់* និង*ជាក់ស្តែង*របស់កម្មាភិបាលថ្នាក់តំបន់ គឺ ទុំ សឿន[815] និងគណៈតំបន់ និង តា ពាល់[816] ។ ដូចការបង្ហាញច្បាស់ក្នុងភស្តុតាង យោងតាមសមត្ថកិច្ចរបស់អ្នកស្រីក្នុងនាមជាលេខាស្រុក*ស្របច្បាប់* និង*ជាក់ស្តែង* អ្នកស្រី អ៊ឹម ចែម បានចូលរួមក្នុងការងារកសិកម្ម និងការផលិតស្បៀងអាហារ[817] និងការជីកប្រឡាយ និងលើកទំនប់[818] ។ អ្នកស្រី អ៊ឹម ចែម ទទួលការណែនាំពី និងរាយការណ៍ទៅថ្នាក់លើរបស់អ្នកស្រី ពោលគឺថ្នាក់តំបន់[819] ។ យោងតាមតួនាទីយេនឌ័រជាប្រពៃណី និងមុខតំណែងរបស់អ្នកស្រី ក្នុងនាមជាកម្មាភិបាលថ្នាក់ស្រុក អ្នកស្រី អ៊ឹម ចែម មិនត្រូវបានបង្គាប់ឱ្យពាក់ព័ន្ធក្នុងបញ្ហាសន្តិសុខឡើយ[820] និងគ្មានអំណាចគ្រប់គ្រងលើកងទ័ព[821] កងឈ្លប[822] ឬលើមន្ទីរសន្តិសុខ ដូចជៀមន្ទីរសន្តិសុខភ្នំទ្រយោងនោះទេ[823] ។ អ្នកស្រីគ្មានអំណាចបញ្ជា

814 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២, ១០៨-០៩។
815 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤។
816 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៩៣-២០៧។
817 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២២-២៩, ១៧៣-៧៤។
818 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១២២-២៩, ២១៤-១៦។
819 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១១៣, ១១៧, ១២៧-២៩, ១៧៣,២១៤។
820 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៧៥-៧៩។
821 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៣៣-៣៦។
822 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៣៧-៣៨។
823 *សូមមើលជារួម* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤។

ឱ្យចាប់ខ្លួន និងឃុំឃាំង ឬមានការគ្រប់គ្រងលើឧក្រិដ្ឋកម្មឡើយ[824] ។

២៣២. ភស្តុតាងទាំងនេះមិនបង្ហាញថា មន្ទីរសន្តិសុខភ្នំទ្រយោង ស្ថិតក្រោមគោលនយោបាយដោយចេតនា និងជាប្រព័ន្ធចំពោះការបង្អត់អាហារ ការធ្វើការបាក់កម្លាំង ឬអំពើអមនុស្សធម៌លើអ្នកទោស ឬមិនបង្ហាញថា អ្នកស្រី អ៊ឹម ចែម បានចូលរួមក្នុងផែនការនេះឡើយ[825] ។ ភស្តុតាងទាំងនេះមិនបញ្ជាក់ថា អ្នកស្រីធ្លាប់ចុះទៅមន្ទីរសន្តិសុខនេះទេ[826] ។ ផ្ទុយទៅវិញ ភស្តុតាងទាំងនេះបង្ហាញថា មន្ទីរសន្តិសុខភ្នំទ្រយោង គឺជាមន្ទីរសន្តិសុខថ្នាក់តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ទុំ សឿន និងដំណើរការដោយកងទ័ពថ្នាក់តំបន់[827] ។ យោងតាមតួនាទីរបស់អ្នកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទំនាក់ទំនងតែមួយគត់របស់អ្នកស្រី អ៊ឹម ចែម ទៅនឹងមន្ទីរសន្តិសុខភ្នំទ្រយោង ត្រូវបានកម្រិតត្រឹមការផ្គត់ផ្គង់ស្បៀងទៅតាមសំណើរបស់ ទុំ សឿន[828] ។ ក្នុងនាមជាអ្នកផ្គត់ផ្គង់ស្បៀងអាហារ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង គឺវាឆ្ងាយហួសក្នុងការចាត់ទុកថាអ្នកស្រីស្ថិតក្នុងចំណោមបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" សូម្បីតែចំពោះឧក្រិដ្ឋកម្មនៅទីតាំងនេះ ។

២៣៣. ស្រដៀងគ្នានេះដែរ ភស្តុតាងទាំងនេះមិនបានបង្ហាញថា ការដ្ឋានស្ពានស្រែងស្ថិតក្រោមគោលនយោបាយនៃការប្រព្រឹត្តអំពើអមនុស្សធម៌ដែលបង្កជាការស្លាប់ និងរបួសស្នាម ឬក៏មិនបានបញ្ជាក់ថា រាល់ឧក្រិដ្ឋកម្មទាំងនេះកើតចេញពីបទបញ្ជា ឬសកម្មភាពរបស់អ្នកស្រី អ៊ឹម ចែម ដែរ[829] ។ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម ត្រូវបានកម្រិតត្រឹមការផ្តល់ពលករទៅតាមសំណើរបស់ថ្នាក់តំបន់[830] ។ ដោយស៊ីសង្វាក់គ្នានឹងអង្គហេតុដែលថា ការដ្ឋានស្ពានស្រែង គឺជាការដ្ឋានថ្នាក់

---

[824] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៣៩-៤២, ១៦២-៦៤, ១៧៣, ២១៤-១៥, ២១៩-២២១។

[825] *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ១៥៧-៨០។

[826] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៩។

[827] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៤៨-៥៤។

[828] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧៣-៧៤។ *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ៧៦, ១២៤-២៩។។

[829] *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ១៥៧-៨០។

[830] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២១៤។

តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈតំបន់៥ និងធ្វើប្រតិបត្តិការដោយកងចល័តថ្នាក់តំបន់ ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ តា ពាល់[831] ពលករទាំងឡាយត្រូវរាយការណ៍ផ្ទាល់ទៅប្រធានគ្រប់គ្រងថ្នាក់តំបន់របស់ខ្លួន[832] ។ យោងតាមភារកិច្ចរបស់អ្នកស្រីក្នុងការផ្តល់ពលករ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយចំនួនដែលបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែង គឺវាឆ្ងាយពេកក្នុងការកំណត់ថា អ្នកស្រីស្ថិតក្នុងចំណោមបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" សូម្បីតែចំពោះឧក្រិដ្ឋកម្មនៅទីតាំងនេះ ។

២៣៤. ក្រុមការពារក្តីយល់ស្របថា សំណុំរឿង ឌុច បានផ្តល់ការប្រៀបធៀបដ៏មានសារប្រយោជន៍មួយ។ ប៉ុន្តែ ដូចការពិភាក្សាដោយសង្ខេបខាងក្រោម ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបង្ហាញចំណុចសមមូលគ្នារវាងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម និងការទទួលខុសត្រូវរបស់ ឌុច ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការពង្រីកដែនកំណត់នូវដំណើររឿងមួយដែលស្ទើរតែមិនគួរឱ្យជឿ ហើយការធ្វើដូច្នេះ ត្រូវតែបរាជ័យ ។ ការពិនិត្យដោយប្រុងប្រយ័ត្នលើអង្គហេតុពាក់ព័ន្ធ បានបង្ហាញពីភាពមិនសមទំនងនៃការបញ្ជាក់ដែលថា ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម "ប្រហែលជាស្មើទៅនឹងការទទួលខុសត្រូវរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច"[833] ។ គ្មានភស្តុតាងជាក់លាក់ ឬស៊ីសង្វាក់គ្នាដើម្បីបញ្ជាក់ពីវោហាសាស្ត្រនេះឡើយ ហើយការអះអាងនេះគ្មានមូលដ្ឋានក្នុងសំណុំរឿងនេះនោះទេ ។ រាល់ការប្រៀបធៀបដោយយុត្តិធម៌ គឺសុទ្ធតែបានគូសបញ្ជាក់ពីកង្វះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើរូបអ្នកស្រី អ៊ឹម ចែម ។

២៣៥. ឌុច ត្រូវបានជំនុំជម្រះទោស និងចោទប្រកាន់ដោយផ្អែកលើមូលដ្ឋានដែលថា គាត់ធ្លាប់ធ្វើជាអនុប្រធានមន្ទីរស-២១[834] លេខាគណៈកម្មាធិការមន្ទីរស-២១[835] និងប្រធានមន្ទីរស-២១[836] ជាមន្ទីរ

---

[831] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៩៣-២០៧។

[832] *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ២១៥។

[833] ដីកាសន្និដ្ឋានស្ថាពរ នៅកថាខណ្ឌ ៥៣៤។

[834] សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១១១។

សន្តិសុខដែលធ្វើប្រតិបត្តិការទទួលយកអ្នកទោសពីទូទាំងប្រទេស នៅចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩[837] មានប្រជាជនយ៉ាងតិច ១២.២៧៣ នាក់ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង[838] ទទួលទារុណកម្ម[839] និងសម្លាប់ជាប្រព័ន្ធ[840] ។ ក្នុងសមត្ថកិច្ចរបស់គាត់ដែលជាប្រធានមន្ទីរស-២១ និងជាលេខាគណៈមន្ទីរស-២១[841] ឌុច មានតួនាទីយ៉ាងសកម្មក្នុងការចេញបញ្ជាឱ្យចាប់ខ្លួនអ្នកទោស[842] និងសម្លាប់ពួកគេ[843] ព្រមទាំងគ្រប់គ្រងលើអង្គភាពសួរចម្លើយដោយមានបុគ្គលិកក្រោមបង្គាប់ ២០ នាក់[844] ដែលប្រើប្រាស់របបធ្វើទារុណកម្មជាប្រព័ន្ធ[845] ។ ឌុច ត្រូវបានចាត់តាំងដោយផ្ទាល់ឱ្យកាន់តួនាទីទាំងនេះដោយគណៈមជ្ឈិម[846] និងរាយការណ៍ផ្ទាល់ទៅ សុន សេន និង នួន ជា[847] ដែលជាសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។ ឌុច មានសិទ្ធិអំណាចពេញលេញលើបុគ្គលិកមន្ទីរស-២១[848] និងទទួលខុសត្រូវលើអង្គភាពផ្សេងៗទៀត រួមមានដូចជា អង្គភាពចុះឈ្មោះ និងរក្សាកំណត់ហេតុរបស់បុគ្គលិក និងអ្នកជាប់ឃុំ[849] និងអង្គភាពដែលត្រូវទាញយក

---

835 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៣២។

836 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១១១។

837 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១១១។

838 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៤១, ២៣៤-៣៩។

839 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២៤០-៥៦។

840 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២០៥-២៤។

841 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188**នៅកថាខណ្ឌ ១៣២។

842 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៦៩-៧២។

843 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៨១-៨៣។

844 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១២៥-២៦។

845 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១២៧, ១៥៣។

846 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ១១៩-២០ ដែលយោងដល់ដីកាដំណោះស្រាយសំណុំរឿង ០០១ឯកសារ D99 នៅកថាខណ្ឌ ២០-២១។

847 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៣១។

848 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៣២, ១៦២-៦៥។

849 សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ១៤៥។

ចម្លើយសារភាពជាលាយលក្ខណ៍អក្សរ ដូចជាតាមរយៈការធ្វើទារុណកម្ម[850] ។ ក្នុងអំឡុងពេលនៃការជំនុំជម្រះទោស ឌុច បានបញ្ជាក់ថា គាត់បានដឹងយ៉ាងច្បាស់នូវកិច្ចការប្រតិបត្តិការប្រចាំថ្ងៃនូវអ្វីដែលបានកើតឡើងនៅមន្ទីរស-២១[851] ដោយសារតែប្រព័ន្ធនៃការរាយការណ៍គ្រប់ជាន់ថ្នាក់ដែលគាត់បានបង្កើតឡើងដើម្បីធានាថា រាល់បទបញ្ជារបស់គាត់ពិតជាត្រូវបានអនុវត្ត "ភ្លាមៗ និងដាក់លាក់"[852] ។

២៣៦. ពាក់ព័ន្ធនឹងកម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ ឌុច ពិនិត្យមើលប្រតិបត្តិការទាំងមូលរបស់មន្ទីរស-២១ ដោយរួមបញ្ចូលទាំងការរៀបចំផែនការធំទូលាយលើប្រតិបត្តិការរបស់មន្ទីរនេះ រហូតដល់ការចេញបញ្ជាឱ្យសម្លាប់[853] ។ អ្នកស្រី អ៊ឹម ចែម ជាអ្នកបញ្ជូនពលករទៅការដ្ឋានស្ពានស្រែង[854] និងផ្គត់ផ្គង់ស្បៀងអាហារដល់មន្ទីរសន្តិសុខភ្នំទ្រយោង[855] ។ ពាក់ព័ន្ធនឹងតួនាទីតាមឋានានុក្រមរបស់គាត់ ឌុច "រាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់របស់បក្សកុម្មុយនីស្តកម្ពុជា[856]" ខណៈដែលអ្នកស្រី អ៊ឹម ចែម ប្រាស្រ័យទាក់ទងដោយផ្ទាល់តែជាមួយថ្នាក់តំបន់ប៉ុណ្ណោះ[857] ។ ពាក់ព័ន្ធនឹងភាពអចិន្ត្រៃយ៍នៃមុខតំណែងរបស់ពួកគាត់ទាំងពីរវិញ គឺថា ឌុច ពាក់ព័ន្ធនឹងមន្ទីរស-២១ ក្នុងនាមជាអនុប្រធាន ឬប្រធានមន្ទីរក្នុងអំឡុងពេលជាង ៤ ឆ្នាំនៃប្រតិបត្តិការទាំងអស់របស់មន្ទីរនេះ[858] ។ ផ្ទុយទៅវិញ អ្នកស្រី អ៊ឹម ចែម បានកាន់តួនាទីជាលេខាស្រុកព្រះនេត្រព្រះក្នុងរយៈពេលតែជាង ១ ឆ្នាំប៉ុណ្ណោះ[859] ។

---

[850] សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** នៅកថាខណ្ឌ ១៥0-៥២។

[851] សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** នៅកថាខណ្ឌ ១៣៣។

[852] សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** នៅកថាខណ្ឌ ១៤៤។

[853] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** នៅកថាខណ្ឌ ២៣។

[854] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ២១៤។

[855] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១៧៣-៧៤។ *ប្រៀបធៀប* ចម្លើយតបនៅកថាខណ្ឌ ៧៦, ១២៤-២៩។

[856] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** កថាខណ្ឌ ២៣។

[857] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១១៣, ១១៧, ១២៧-២៩, ១៧៣, ២១៤។

[858] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង 00១ឯកសារ **E188** នៅកថាខណ្ឌ ១២១, ១២៥, ១២៨, ២0៣។

[859] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១0២ និង ១0៨-0៩។

២៣៧. ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ និងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង គឺមិនអាចប្រៀបធៀបគ្នាបានឡើយ ។ មានអ្នកជាប់ឃុំជាង ១២.២៧៣ នាក់នៅមន្ទីរស-២១[860] ។ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ គឺ "មានលក្ខណៈសាហាវយង់ឃ្នង និងគួរឱ្យព្រឺខ្លាច[861]" ហើយវាទីកន្លែងដែលមានការធ្វើមនុស្សឃាត[862] និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់[863] ជាង ១២.២៧៣ ករណីដែលជនរងគ្រោះ "យ៉ាងច្រើនលើសលប់" ត្រូវទទួលរងទារុណកម្មផងដែរ[864] ។ ផ្ទុយទៅវិញ សូម្បីតែនៅពេលដែលគេប្រើប្រាស់វិធីសាស្ត្របែបសប្បុរសយ៉ាងណាក្តី ក្នុងការកំណត់តួលេខលើករណីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក៏មានមនុស្សត្រឹមតែ១.000 នាក់ប៉ុណ្ណោះ ដែលទទួលរងផលប៉ះពាល់នៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង[865] និងនៅក្នុងកាលៈទេសៈដែលមិនអាចត្រូវបានចាត់ទុកដោយសមហេតុផលថាវាដូចគ្នា ឬសមមូលគ្នាកើតនោះទេ ។ វិសាលភាពភូមិសាស្ត្រនៃសកម្មភាពរបស់មន្ទីរស-២១ "ធ្វើប្រតិបត្តិការពាសពេញផ្ទៃប្រទេស[866]" ចំណែកការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម គ្របដណ្តប់តែលើស្រុកមួយប៉ុណ្ណោះ[867] ។ មន្ទីរស-២១ បំពេញមុខងារស្ទើរតែពេញមួយអំឡុងពេលទាំងស្រុង នៃការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម[868] ប៉ុន្តែអ្នកស្រី អ៊ឹម ចែម មិនត្រូវបានចាត់តាំងឱ្យកាន់តួនាទីណាមួយក្នុងស្រុកព្រះនេត្រព្រះនោះទេ

---

[860] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២៣ (ជើងទំព័រ ៣១)និងកថាខណ្ឌ ១៤១។

[861] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ៥៩៧។

[862] សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២០៨។

[863] សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២៣៥។

[864] *សូមមើល* សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២៤០។

[865] *ប្រៀបធៀប* ចម្លើយតបនៅកថាខណ្ឌ ១៥៥-៨៦ និង ២០៨-២៦។

[866] សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ឯកសារ **E188** នៅកថាខណ្ឌ ២៣។

[867] *ប្រៀបធៀប* ចម្លើយតបនៅកថាខណ្ឌ ៩៧-១៤២។

[868] សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ ឯកសារ **E188** នៅកថាខណ្ឌ ២៣ ("មន្ទីរស-២១ បានធ្វើប្រតិបត្តិការចាប់ពីខែ តុលា ឆ្នាំ ១៩៧៥ រហូតដល់ដើមខែ មករា ឆ្នាំ ១៩៧៩ ដូច្នេះ វាគ្របដណ្តប់ស្ទើរតែទាំងមូលនៃអត្ថិភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ")។

រហូតដល់រយៈពេលប្រហែលជាងមួយឆ្នាំមុនពេលដែលរបបខ្មែរក្រហមដួលរលំ[869] ។ ដូចការពិភាក្សាខាងលើ ភស្តុតាងទាំងនេះមិនគាំទ្រការអះអាងជាក់លាក់ ឬគួរឱ្យជឿជាក់ថា អ្នកស្រី អ៊ឹម ចែម បានចេញបញ្ជា គ្រប់គ្រង ឬចូលរួមអនុវត្តប្រព័ន្ធនៃការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការដាក់មនុស្សក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ឬក៏ថាអ្នកស្រីបានប្រព្រឹត្តបទឧក្រិដ្ឋសាហាវយង់ឃ្នងស្រដៀងគ្នាផ្សេងទៀតឡើយ ។ តាមពិត ភស្តុតាងទាំងនេះមិនបានគាំទ្រការអះអាងដែលថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង[870] និងការដ្ឋានស្ពានស្រែង[871] ក្នុងអំឡុងពេលពាក់ព័ន្ធមានលក្ខណៈធ្ងន់ធ្ងរ ទូលំទូលាយ ឬជាប្រព័ន្ធនោះទេ ។

២៣៨. ជារួម នៅពេលវាយតម្លៃពីចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងវិសាលភាពពេលវេលា និងលក្ខណៈនៃឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ថាបានប្រព្រឹត្ត និងចំនួនហេតុការណ៍ដាច់ដោយឡែក វាបង្ហាញថា *ស្ថានទម្ងន់នៃបទឧក្រិដ្ឋ* ដែលកើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងក្នុងអំឡុងពេលពាក់ព័ន្ធ ហាក់មានលក្ខណៈស្រាល និងកាន់តែស្រាលជាងសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក ដូចជា សំណុំរឿងរបស់ ឌុច ។ ផ្ទុយស្រឡះពីអង្គហេតុដែលគូសបញ្ជាក់ពីការទទួលខុសត្រូវរបស់ ឌុច ការវាយតម្លៃលើ*កម្រិតនៃការទទួលខុសត្រូវ*របស់អ្នកស្រី អ៊ឹម ចែម ចំពោះបទឧក្រិដ្ឋទាំងនោះពាក់ព័ន្ធនឹងកម្រិតនៃការចូលរួម តួនាទីតាមឋានានុក្រម និងអំណាច*ស្របច្បាប់* និង*ជាក់ស្តែង* ដូចជា ថ្នាក់លើតាមឋានានុក្រមរបស់អ្នកស្រី បង្ហាញថា អ្នកស្រីមិនបានចូលរួមដោយផ្ទាល់ ឬធ្វើសកម្មភាពជំរុញការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មពាក់ព័ន្ធណាមួយឡើយ ។ ផ្ទុយពី*លទ្ធភាព*នៃការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ភស្តុតាងទាំងនេះបង្ហាញថា សកម្មភាពនិងការគ្រប់គ្រងរបស់អ្នកស្រីនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងមិនអាចចាត់ទុកជាកំហុសព្រហ្មទណ្ឌបានទេ។

២៣៩. លើសពីនេះ ទោះបីជាអ្នកស្រី អ៊ឹម ចែម អាចត្រូវបានចាត់ទុកថាជាបុគ្គលដែលទទួលខុសត្រូវខ្ពស់

---

[869] *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ១០២ និង ១០៨-០៩។

[870] *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ១៥៧-៨៦។

[871] *ប្រៀបធៀប* ចម្លើយតប នៅកថាខណ្ឌ ២១០-២៦។

បំផុតក្តី ក៏ភស្តុតាងដែលត្រូវបានពិភាក្សាក្នុងចម្លើយតបនេះបង្កើតបានជាមូលដ្ឋានថា អ្នកស្រីគ្មានកំហុសព្រហ្មទណ្ឌ គឺជាភស្តុតាងបញ្ជាក់ពីការចូលរួមចំណែកតិចតួចរបស់អ្នកស្រី និង*ធាតុផ្សំអត្តនោម័ត*សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចនឹងបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង[872] ។ ដូចការកត់សម្គាល់ ភស្តុតាងទាំងនេះមិនបានគាំទ្រការសន្និដ្ឋានដោយសមហេតុផលដែលថា អ្នកស្រី អ៊ឹម ចែម បានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មតាមលក្ខណៈសំខាន់ ឬប្រហាក់ប្រហែលគ្នានោះទេ ។ អ្នកស្រី អ៊ឹម ចែម i) មិនមានទំនាក់ទំនងជាក់លាក់ណាមួយជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ដូចជា *តា ម៉ុក*[873] ii) មិនមានតួនាទីសំខាន់ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ iii) មិនមានមុខនាទីសំខាន់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[874] និង iv) មិនមានសិទ្ធិអំណាច*ស្របច្បាប់* ឬ*ជាក់ស្តែង*លើជនប្រព្រឹត្តផ្ទាល់នៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែងឡើយ[875] ។ ក្នុងការវិភាគចុងក្រោយ ភស្តុតាងទាំងនេះមិនបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម បានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម ឬធ្វើសកម្មភាពក្នុងចេតនាជំរុញការអនុវត្តគោលនយោបាយដែលពាក់ព័ន្ធនឹងការវាយប្រហារមានលក្ខណៈជាប្រព័ន្ធ និងទូលំទូលាយលើជនស៊ីវិលនោះទេ ។

២៤០. នៅពេលត្រឡប់ទៅពិនិត្យសារសំខាន់នៃចម្លើយតបនេះ គេអាចមានមន្ទិលសង្ស័យតិចតួចដែលបង្ហាញថា ភស្តុតាងទាំងមូលនេះបញ្ជាក់ថា ការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គឺមានតែលក្ខណៈនិមិត្តរូប មិនស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក និងរាល់ការយល់ឃើញដោយមិនសមហេតុផលលើបុគ្គលដែលទទួលខុសត្រូវ

---

872 *ប្រៀបធៀប* សាលក្រមការជំនុំជម្រះទោសសំណុំរឿង ០០១ ឯកសារ **E188** កថាខណ្ឌ ៤៥។ *សូមមើលផងដែរ* មតិយោបល់រួមលេខ ៣២ លើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), ក្រុមប្រឹក្សាសិទ្ធិមនុស្ស (HRC), CCPR/C/GC/32 (២០០៧) នៅកថាខណ្ឌ ៣០ ("សច្ចធារណ៍នៃនិរទោសដែលជាមូលដ្ឋាននៃការការពារសិទ្ធិមនុស្ស អនុវត្តលើការផ្តន្ទាទោសជនជាប់ចោទ") (ភ្ជាប់ជា**ឯកសារយោង ២៧**)។

873 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៦៨-៧៣។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ១១៨-២១។

874 *សូមមើល* ចម្លើយតប នៅកថាខណ្ឌ ៨៣-១៤២។

875 *ប្រៀបធៀបនឹង* ចម្លើយតប នៅកថាខណ្ឌ ១១៤-២២៦។

ខ្ពស់បំផុតលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

## VI. **សំណើដែលស្នើសុំ**

២៤១. ផ្អែកតាមទឡ្ហីករណ៍ដែលបានលើកឡើងខាងលើ ក្រុមការពារក្តីស្នើសុំដោយក្តីគោរព ដោយយោងតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងបម្រើឱ្យផលប្រយោជន៍យុត្តិធម៌ សូមឱ្យសហចៅក្រមស៊ើបអង្កេត៖

ក) សម្រេចថា អ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងប្រភេទ "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការជាកម្មវត្ថុរបស់ អ.វ.ត.ក ។

ខ) ច្រានចោលការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិលើអ្នកស្រី អ៊ឹម ចែម ។

សូមមេត្តាទទួលយកដោយគោរព ៕

ចុះហត្ថលេខា នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

សហមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម

________________ ________________

ប៊ិត ស៊ាងលឹម Wayne JORDASH, QC